ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# របាយការណ៍
# ស្តីពី
# ស្ថានភាពកុមារកម្ពុជា ឆ្នាំ២០២៥



ខែឧសភា ឆ្នាំ២០២៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# របាយការណ៍
# ស្តីពី
# ស្ថានភាពកុមារកម្ពុជា ឆ្នាំ២០២៥

ខែឧសភា ឆ្នាំ២០២៦

# អារម្ភកថា

ការរក្សាបាននូវសន្តិភាព និងការពង្រឹងស្ថិរភាពសង្គម នយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាបានរួមចំណែកយ៉ាងធំធេងក្នុងការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវកំណើនសេដ្ឋកិច្ចរបស់កម្ពុជាគួរឱ្យកត់សម្គាល់។ តាមរយៈការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០២៤-២០២៨ ប្រកបដោយចក្ខុវិស័យច្បាស់លាស់ កម្ពុជាបានឈានដល់ឋានៈជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងមានគោលដៅសម្រេចឱ្យបានជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ គ្រប់ដំណាក់កាលទាំងអស់ នៃការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលបានកំណត់យក "មនុស្ស" ជាវិស័យអាទិភាពចម្បងបំផុត ហេតុនេះ ការយកចិត្តទុកដាក់ចំពោះសុខុមាលភាព សុវត្ថិភាព និងការអភិវឌ្ឍកុមារ គឺជាគ្រឹះដ៏សំខាន់ក្នុងការកសាងមូលធនមនុស្ស ប្រកបដោយសក្តានុពលសម្រាប់ការអភិវឌ្ឍកម្ពុជានាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តយ៉ាងពេញលេញ និងមានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ដោយធ្វើយ៉ាងណាឱ្យកុមារ ក្រុមគ្រួសារ និងសហគមន៍ទទួលបាននូវគុណភាព និងគុណតម្លៃនៃការរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាពស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដោយមានការចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងការអភិវឌ្ឍគ្រប់វិស័យ និងគ្រប់កម្រិត។

របាយការណ៍នេះ បង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានាថា សិទ្ធិជាមូលដ្ឋានរបស់កុមារត្រូវបានអនុវត្តឱ្យបានពេញលេញ និងគាំទ្រចំពោះឧត្តមប្រយោជន៍របស់ពួកគេ។ របាយការណ៍នេះ គឺជាការបង្ហាញពីវឌ្ឍនភាពនៃការងារវិស័យកុមារ និងជាឯកសារសម្រាប់ចង្អុលបង្ហាញពីការទទួលខុសត្រូវ ការតស៊ូមតិ និងជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយ និងផែនការផងដែរ។ របាយការណ៍នេះ មិនត្រឹមតែបង្ហាញពីការអនុវត្តរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ តែក៏ជាកញ្ចក់ឆ្លុះបញ្ចាំង និងវាយតម្លៃលើការអនុវត្តរបស់អង្គការសង្គមស៊ីវិល និងផ្នែកពាក់ព័ន្ធនានាផងដែរ ដោយបង្ហាញពីការធានានូវការអនុវត្តពេញលេញចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ។ លទ្ធផលនៃរបាយការណ៍នេះ នឹងក្លាយជាមូលដ្ឋាននៃការពិចារណាក្នុងការសម្រេចចិត្តរៀបចំយុទ្ធសាស្ត្រ កម្មវិធីសកម្មភាព និងការបែងចែកធនធានសម្រាប់ធ្វើអន្តរាគមន៍ចំគោលដៅ ជាពិសេស គឺជាកាតាលីករសម្រាប់ការផ្លាស់ប្តូរវិជ្ជមាន តាមរយៈការផ្តល់តឹកតាងសម្រាប់ការពិនិត្យតាមដានលើការរីកចម្រើន ឬតម្រូវការបន្ទាន់ណាមួយរបស់កុមារ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមកោតសរសើរដោយស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិល ឪពុកម្តាយ អាណាព្យាបាល និងក្មួយៗកុមារទាំងអស់ ដែលបានរួមសហការប្រកបដោយការទទួលខុសត្រូវ និងការប្តេជ្ញាខ្ពស់ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីផ្តល់កិច្ចការពារកុមារពីអំពើហិង្សា ការកេងប្រវ័ញ្ច និងរំលោភបំពានគ្រប់ទម្រង់។

ថ្ងៃ[illegible] ១០កើត ខែ[illegible] ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៦

**ជ. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**

**ជា_សុមេធី**

# មាតិកា


អារម្ភកថា ..... i

១. សេចក្តីផ្តើម ..... ២

២. ក្របខ័ណ្ឌច្បាប់ និងយុទ្ធសាស្ត្រ ..... ៣

២.១. ក្របខ័ណ្ឌច្បាប់ ..... ៣

២.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាព ..... ៤

៣. ការរស់រានមានជីវិត ..... ៩

៣.១. សុខភាព និងសុខុមាលភាពមូលដ្ឋាន ..... ៩

ក. ដំណើរឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសាកល ..... ៩

ខ. ភាពប្រសើរឡើងនៃស្ថានភាពសុខភាព ..... ១០

គ. សុខភាពបន្តពូជ ..... ១១

ឃ. សុខភាពមាតា និងទារក ..... ១២

ង. សុខភាពកុមារ ..... ១៣

ច. ការកែលម្អកង្វះអាហារូបត្ថម្ភ ..... ១៥

៣.២. ការចុះអត្រានុកូលដ្ឋាន ..... ១៦

ក. ការចុះបញ្ជីកំណើត ..... ១៦

៣.៣. បរិយាកាសគ្រួសារ ..... ១៧

ក.ការថែទាំជំនួស ..... ១៧

ខ.ការសុំកូន ..... ១៨

គ.កូនតាមម្តាយក្នុងពន្ធនាគារ ..... ១៩

៣.៤. បទដ្ឋាននៃការរស់នៅ ..... ១៩

ក. ទឹកស្អាត និងអនាម័យ ..... ១៩

ខ. បង្គន់អនាម័យ ..... ២០

គ. វឌ្ឍនភាពការតភ្ជាប់បណ្តាញអគ្គិសនីតាមភូមិ និងការតភ្ជាប់ចរន្តអគ្គិសនីតាមខ្នងផ្ទះ ..... ២១

៤. ការអភិវឌ្ឍកុមារ ..... ២៣

៤.១. ការអប់រំ ..... ២៣

ក. ធនធានមនុស្សផ្នែកអប់រំ ..... ២៣

ខ. ការអប់រំកុមារតូច ..... ២៤

គ. ការអប់រំបឋមសិក្សា ..... ២៦

ឃ. ការអប់រំមធ្យមសិក្សា ..... ២៧

៤.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ ..... ៣០

៥. ការការពារកុមារ ..... ៣២

៥.១.ការបង្ការ ទប់ស្កាត់ ..... ៣២

៥.២. ការអន្តរាគមន៍ និងឆ្លើយតប ..... ៤១

៥.៣. ការផ្តល់ជំនួយ និងសេវាគាំទ្រ ..... ៤៣
៦. ការចូលរួមរបស់កុមារ ..... ៥៣
៦.១. ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងកាយរឹទ្ធិជាតិកម្ពុជា ..... ៥៣
៦.២. បណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ ..... ៥៣
៧.១. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ..... ៥៤
៧. កិច្ចសហប្រតិបត្តិការលើវិស័យកុមារ ..... ៥៥
៧.១. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ..... ៥៥
ក. អង្គការភ្លែនអន្តរជាតិកម្ពុជា ..... ៥៥
ខ. អង្គការឆោលហ្វាន កម្ពុជា ..... ៥៦
គ. អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា ..... ៥៨
ឃ. អង្គការសកម្មភាពដើម្បីកុមារ (APLE) ..... ៥៩
ង. អង្គការសេរីភាពកម្ពុជាអូស្ត្រាលី (AusCam Freedom Project) ..... ៦២
ច. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) ..... ៦៣
ឆ. អង្គការមូលនិធិហាការអន្តរជាតិ (Hagar International Foundation) ..... ៦៣
ជ. អង្គការសម្ព័ន្ធចាប់ដៃ ..... ៦៤
ឈ. អង្គការសង្គ្រោះកុមារ (Save the Children) ..... ៦៦
ញ. អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (១២៨០) ..... ៦៨
ដ. អង្គការសម្ពន្ធដើម្បីសិទ្ធិកុមារកម្ពុជា - ស.ស.ក. (CRC Cambodia) ..... ៧៣
ឋ. អង្គការម្លប់ឫស្សី ..... ៧៥
ឌ. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (ច.ក.យ.ក.ស.ក./CCYMCR) ..... ៧៦
ឍ. អង្គការទស្សនៈពិភពលោក ..... ៧៦
ណ. អង្គភាពការពារកុមារ (CPU) ..... ៧៨
៨. បញ្ហាប្រឈម ..... ៨១
៩. ទិសដៅអនុវត្តបន្ត ..... ៨៨
១០. សេចក្តីសន្និដ្ឋាន ..... ៩៤

# ១.សេចក្តីផ្តើម



រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកកុមារជាអ្នកបន្តវេនរបស់ប្រទេសជាតិ ដូចពាក្យស្លោកថា "កុមារជាទំពាំងស្នងឫស្សី" និង "កុមារជាសសរទ្រូងសម្រាប់ប្រទេសជាតិ"

# ១. សេចក្តីផ្តើម

១. នៅឆ្នាំ២០២៥ តាមរយៈកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ កុមារកម្ពុជាទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន ប៉ុន្តែទន្ទឹមនេះក៏បានប្រឈមមុខនឹងការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរផងដែរ។ ជម្លោះព្រំដែន (ចុងខែឧសភា ដល់ថ្ងៃទី២៨ ខែកក្កដា) បានធ្វើឱ្យមនុស្សប្រហែល ១៣៤ ៧០០នាក់ ផ្លាស់ទីលំនៅ បិទសាលារៀនចំនួន ៦០០ (ប៉ះពាល់ដល់សិស្សជាង ១៥០ ០០០នាក់) និងធ្វើឱ្យមានផលប៉ះពាល់ដល់សេវាសុខភាព និងការផ្តល់អាហារូបត្ថម្ភ។ តាមរយៈរបាយការណ៍របស់វិទ្យាជាតិស្ថិតិ ជំងឺក្រិនបានប៉ះពាល់ដល់កុមារអាយុក្រោម ៥ឆ្នាំចំនួន ២២% (ធ្លាក់ចុះពី ៣២% ក្នុងឆ្នាំ២០១៤) ភាពស្គមស្គាំងមានប្រហែល ១០% ខណៈពេលដែលធាត់លើសទម្ងន់បានកើនឡើងដល់ ៥,៧%។ ការចុះឈ្មោះចូលរៀនបឋមសិក្សាលើសពី ៩០% អត្រាបោះបង់ចោលការសិក្សាធ្លាក់ចុះមកត្រឹម ៤,៤% នៅបឋមសិក្សា។ ពលកម្មកុមារបានធ្លាក់ចុះមកនៅត្រឹម ១១,៩% (និន្នាការឆ្នាំ២០២៣) ប៉ុន្តែការជួញដូរ ការបោកប្រាស់ និងការកេងប្រវ័ញ្ចទាក់ទងនឹងការធ្វើចំណាកស្រុកនៅតែបន្ត។ អំពើហិង្សាលើកុមារនៅតែកើតមាន អាកប្បកិរិយាអំពើហិង្សាក្នុងគ្រួសារបានធ្លាក់ចុះ ប៉ុន្តែអត្រារីករាលដាលនៅតែខ្ពស់។

២. សមិទ្ធផលសំខាន់ៗឆ្នាំ២០២៥ ពាក់ព័ន្ធនឹងវិស័យកុមារ មានដូចជា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ឆ្នាំ២០២៥-២០៣០ ការពង្រីកការផ្តល់អាហារដល់សាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ១ ១១៤សាលា (សាលារៀនចំនួន ៦៨៦ បានទទួលមូលនិធិពីរាជរដ្ឋាភិបាល) និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ នៃព្រះជាណាចក្រកម្ពុជា។ បញ្ហាប្រឈមរួមមាន ភាពងាយរងគ្រោះដោយសារអាកាសធាតុ ហានិភ័យឌីជីថល និងគម្លាតគុណភាពសេវាកម្ម។ អនុសាសន៍ផ្តោតលើការពង្រឹកយន្តការបង្ការទប់ស្កាត់ ការដាក់បញ្ចូលភាពធន់នឹងអាកាសធាតុ និងការពន្លឿនច្បាប់កិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា។ ទោះជាមានវិបត្តិមនុស្សធម៌ និងការប្រឈមចំពោះវិសមភាពយ៉ាងណាក៏ដោយ ក៏ការអនុវត្តសិទ្ធិកុមារនៅតែមានវឌ្ឍនភាព។

៣. នៅឆ្នាំ២០២៥ ចំនួនប្រជាជនកម្ពុជាបានឈានដល់ប្រហែល ១៧,៩លាននាក់ ដែលក្នុងនោះកុមារអាយុពី ០-១៧ឆ្នាំ មានចំនួនជិត ៥,៤លាននាក់ (ការធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានជំរឿនឆ្នាំ២០១៩)។ តំបន់ជនបទមានកុមារប្រហែល ៨០% ការធ្វើចំណាកស្រុកក្នុងទីក្រុងបានកើនឡើង។ ជនជាតិភាគតិច ( ដូចជាក្រុមជនជាតិដើមភាគតិចនៅភាគឦសាន) និងកុមារពិការ (ប្រមាណ ១,២% ឬ ១៦៩,២២៥នាក់ដែលមានអាយុពី ៥-១៤ឆ្នាំ) ប្រឈមមុខនឹងភាពងាយរងគ្រោះ។ ដោយមានជំនួយពីឧបករណ៍ឌីជីថល ការចុះបញ្ជីកំណើតបានខិតជិតគោលដៅជាសកល (ជាង ៩៥% ដែលត្រូវបានព្យាករណ៍)។ កម្រិតសមភាពយេនឌ័រមានភាពល្អប្រសើរ ប៉ុន្តែក្មេងស្រីវ័យជំទង់នៅតែប្រឈមមុខនឹងហានិភ័យខ្ពស់ នៃអាពាហ៍ពិពាហ៍មុនអាយុ (១៩% នៃស្ត្រីរៀបការមុនអាយុ ១៨ឆ្នាំ) កំណើនប្រជាជនថយចុះ ការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក (ក្នុងប្រទេស/ឆ្លងដែន) របស់ឪពុកម្តាយបានទុកចោលកុមាររាប់ពាន់នាក់នៅជាមួយសាច់ញាតិ ឬជីដូន ជីតា ដែលចាស់ជរា។

៤. ដើម្បីលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារ និងដោះស្រាយនូវបញ្ហានានានៃវិស័យកុមារ រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ និងលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ច្បាប់ជាតិ និងច្បាប់អន្តរ

ជាតិពាក់ព័ន្ធ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ ដោយប្ដេជ្ញាចិត្តក្នុងការគោរព ការពារ បំពេញសិទ្ធិនានាចំពោះប្រជាពលរដ្ឋ ជាពិសេសចំពោះកុមារ ដើម្បីរស់នៅក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដើម្បីធានាឲ្យបាននូវសុខុមាលភាព និងការគាំពារសង្គមចំពោះកុមារកម្ពុជា។ រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំ និងពង្រឹងក្របខ័ណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងយន្តការជាច្រើនពាក់ព័ន្ធកិច្ចការកុមារ។ ប្រព័ន្ធនៃការអប់រំត្រូវបានកែទម្រង់ និងបង្កើនប្រសិទ្ធភាពពីមួយថ្ងៃទៅមួយថ្ងៃ។ ការលើកកម្ពស់សុខភាព តាមរយៈការលុបបំបាត់ការកង្វះអាហារូបត្ថម្ភលើកុមារ ការកាត់បន្ថយមរណភាពមាតា ទារកនិងកុមារ ការទទួលបានទឹកស្អាត និងអនាម័យព្រមទាំងការពង្រីកកម្មវិធីគាំពារសង្គមឱ្យកាន់តែទូលំទូលាយ។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើបរិយាបន្នៃការការពារ ការដោះស្រាយអំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់លើកុមារ ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាព និងការពារឧត្តមប្រយោជន៍របស់កុមារ។

៥. រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ និងដាក់ចេញគោលដៅអាទិភាពក្នុងការពង្រឹងប្រសិទ្ធភាពអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០២៤-២០២៨ សំដៅធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពទីផ្សារការងារ ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ លក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ សុខុដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ និងរបបសន្តិសុខសង្គម។ កន្លងមក ផែនការសកម្មភាពជាតិស្ដីពី ការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ គឺជាត្រីវិស័យតម្រង់ទិស ដើម្បីលើកកម្ពស់ ការយល់ដឹងឱ្យកាន់តែប្រសើរឡើងចំពោះបញ្ហាពលកម្មកុមារ និងផ្ដល់ជាកម្លាំងចលករ ជំរុញដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការការពារឧត្តមប្រយោជន៍សម្រាប់កុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

៦. របាយការណ៍ស្ដីពីស្ថានភាពកុមារត្រូវបានចងក្រង និងដកស្រង់ចេញពីឯកសាររបស់ក្រសួង ស្ថាប័ននានាដែលកំពុងអនុវត្តការងារពាក់ព័ន្ធនឹងវិស័យកុមារ។ ចំពោះទិន្នន័យនៃរបាយការណ៍នេះ គឺជាការប្រើប្រាស់ទិន្នន័យដែលមានលក្ខណៈគុណភាព និងបរិមាណ ព្រមជាមួយការសិក្សាលើឯកសារពាក់ព័ន្ធ ដែលផ្ដោតលើវិស័យសំខាន់ៗ រួមមាន សុខភាព ការអប់រំ ការការពារកុមារ និងស្ថានភាពសង្គម សេដ្ឋកិច្ច។ ការបង្ហាញពីបច្ចុប្បន្នភាពនៃទិន្នន័យ គឺជាចំណុចសំខាន់ នៃរបាយការណ៍ក្នុងការបង្ហាញពីស្ថានភាពជឿទុកចិត្តបានច្បាស់លាស់ ពិតប្រាកដរបស់កុមារនៅក្នុងសង្គម និងជួយបង្កើតយុទ្ធសាស្ត្រឆ្លើយតបឲ្យមានប្រសិទ្ធភាព។

# ២. ក្របខ័ណ្ឌច្បាប់ និងយុទ្ធសាស្ត្រ



២.១. ក្របខ័ណ្ឌច្បាប់
២.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាព

## ២. ក្របខ័ណ្ឌច្បាប់ និងយុទ្ធសាស្ត្រ

៧. ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការគោរព ការពារ បំពេញសិទ្ធិនានាចំពោះប្រជាពលរដ្ឋ ជាពិសេសចំពោះកុមារ ដើម្បីរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដើម្បីធានាឲ្យបាននូវសុខុមាលភាព និងការគាំពារសង្គមចំពោះកុមារកម្ពុជា។ រាជរដ្ឋាភិបាលបាននិងកំពុងពង្រឹងការអនុវត្ត និងរៀបចំក្របខ័ណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងយន្តការជាច្រើនពាក់ព័ន្ធកិច្ចការកុមារ។

### ២.១. ក្របខ័ណ្ឌច្បាប់

៨. ចាប់ពីឆ្នាំ២០២០ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា (ស.អ.យ.) បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា ដោយរំពឹងថានឹងស្នើសុំការអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងដើម្បីការពារ លើកកម្ពស់សុខុមាលភាពកុមារ ផ្តល់អំណាចក្នុងការចូលរួម រក្សាឧត្តមប្រយោជន៍របស់កុមារ និងពង្រឹងការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។

៩. ក្រសួងមហាផ្ទៃបាននិងងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ក្នុងគោលបំណងធានាសុចរិតភាព នៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការការពារសិទ្ធិ សេរីភាពបុគ្គល ពិសេសដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

១០. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពី សន្តិសុខសាយប័រ និងកិច្ចការពារទិន្នន័យបុគ្គល ដែលសេចក្តីព្រាងច្បាប់ទាំងពីរនេះ ត្រូវបានរៀបចំឡើងស្របតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល គោលនយោបាយរដ្ឋាភិបាលឌីជីថល និងតាមនិន្នាការតំបន់ និងសកលលោក ក្នុងគោលបំណងកំណត់នូវគោលការណ៍ វិធាន យន្តការគ្រប់គ្រង និងការថែរក្សាសន្តិសុខសាយប័រ នៃហេដ្ឋារចនាសម្ពន្ធព័ត៌មានសំខាន់ៗ និងកំណត់អំពីគោលការណ៍ វិធាន និងយន្តការនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល ដើម្បីលើកកម្ពស់កិច្ចការពារសិទ្ធិប្រធានទិន្នន័យ ធានាការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដោយមានការទទួលខុសត្រូវ និងតម្លាភាព។

១១. ក្រសួងព័ត៌មានបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិទទួលព័ត៌មាន ក្នុងគោលបំណងធានាដល់សាធារណជនគ្រប់រូបនូវសិទ្ធិ សេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

១២. ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ បាននិងកំពុងបន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើរត់ពន្ធមនុស្ស និងសេចក្តីព្រាងច្បាប់ស្តីពីអំពើពពោះជំនួស។

១៣. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (ក.ប.) បានផ្តួចផ្តើម និងពិគ្រោះយោបល់លើការរៀបចំ (១).សេចក្តីព្រាងច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារក្នុងគោលបំណងលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ និងចូលរួមទប់ស្កាត់ការជួញដូរមនុស្សខុសច្បាប់ (២).សេចក្តីព្រាងច្បាប់ស្តីពីការអប់រំ

បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីពង្រឹងយន្តការក្នុងការគ្រប់គ្រងការដឹកនាំ និងសម្របសម្រួល កិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល និង (៣).សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារ មានគោលបំណងអនុលោមតាមបទដ្ឋានស្តង់ដាការងារអន្តរជាតិ ដើម្បីបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ធានាបាននូវបរិយាកាសការងារល្អប្រកបដោយផាសុកភាព លើកកម្ពស់ផលិតភាពការងារ និងចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ។

## ២.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាព

១៤. ដើម្បីបន្តជំរុញការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្ន រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិ ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ លើមូលដ្ឋាននេះ ជាមួយបាវចនាទាំង ៥ គឺ កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព។ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤-២០២៨ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា កម្មវិធីកែទម្រង់យុទ្ធសាស្ត្រតាមវិស័យ និងផែនការយុទ្ធសាស្ត្រថវិកា។

១៥. បញ្ចកោណទី១ ៖ ការអភិវឌ្ឍធនធានមនុស្ស - ការអភិវឌ្ឍមូលធនមនុស្ស គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងភាពធន់។ មូលធនមនុស្សមានគុណភាពខ្ពស់ និងសុខភាពល្អ គឺជាទ្រព្យសកម្មជាតិដ៏រឹងមាំសម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និងជវភាពការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាព ៥ ៖ (១).ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (២).ការបណ្តុះបណ្តាលជំនាញបច្ចេកទេស (៣).ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន (៤).ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និង (៥).ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

១៦. ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០២៤-២០៣៥ មានគោលដៅចម្បង ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព ក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ ស្របតាមការរីកចម្រើនសេដ្ឋកិច្ចជាតិ។ រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងសុខុមាលភាពពលរដ្ឋ តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ និងមានភាពធន់ដែលជាអាទិភាពមួយកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺការផ្តោតលើការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម តាមអភិក្រមហានិភ័យ នៃវដ្តជីវិត ដោយឈរលើស្មារតី "មិនបោះបង់ពលរដ្ឋណាម្នាក់" ជាមួយនឹងទស្សនវិស័យ និងគោលដៅដ៏ច្បាស់លាស់គឺ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ និងបរិយាបន្ន។

១៧. អនុវត្តតាមផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ ដែលជាត្រីវិស័យតម្រង់ទិសដើម្បីលើកកម្ពស់ការយល់ដឹងឱ្យកាន់តែ

ប្រសើរចំពោះបញ្ហាពលកម្មកុមារនៅប្រទេសកម្ពុជា និងផ្តល់ជាកម្លាំងចលករជំរុញដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីសម្រេចឱ្យបានគោលដៅអភិវឌ្ឍសកលប្រកបដោយចីរភាព ២០១៥-២០៣០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញ (១).គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ ក្នុងគោលដៅ ៣.៦ ស្តីពីការគ្រប់គ្រង និងការពារពលករទេសន្តប្រវេសន៍ ក្នុងការទទួលបានការងារសមរម្យ និងការទទួលស្គាល់ជំនាញ (២).គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ដែលលើកកម្ពស់ការបណ្តុះបណ្តាលយុវជន ស្របគ្នានឹងក្រោមជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីភ្នាក់ងារអភិវឌ្ឍប្រទេសស្វីសដែលក្នុងនោះ ការផ្សព្វផ្សាយស្តីពីពលកម្មកុមារ ប្រកបដោយបរិយាបន្ន នៅកន្លែងការងារសម្រាប់សហគ្រាសធុនតូច និងមធ្យម គឺជាវិធានការចាំបាច់ក្នុងការពង្រឹងការយល់ដឹងរបស់កម្មកនិយោជិត និយោជក និងសហគមន៍ ដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ (៣).ផែនការមេលើកទី៣ ស្តីពីសុវត្ថិភាពនិងសុខភាពការងារឆ្នាំ២០២៣-២០២៧ ដែលមានបញ្ចូលយុទ្ធសាស្ត្រ ការលុបបំបាត់ពលកម្មកុមារ និងការងារដោយបង្ខំ សហប្រតិបត្តិការក្នុងការបង្ការមេរោគអេដស៍ ជំងឺអេសដ៍ ការប្រើប្រាស់គ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការ។ លើសពីនេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីទេសន្តរប្រវេសន៍ការងារ ឆ្នាំ២០២៥-២០៣៤ និងកែសម្រួលសេចក្តីព្រាងប្រកាសលេខ ០៤៦ ស្តីពីដំណើរការជ្រើសរើស និងរៀបចំសេចក្តីព្រាងសេចក្តីណែនាំ ស្តីពីដំណើរការជ្រើសរើស និងការណែនាំតម្រង់ទិសពលករមុនចេញដំណើរ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តប្រកាសលេខ ០៤៦/១៣ កប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីដំណើរការជ្រើសរើស និងការណែនាំតម្រង់ទិសពលករមុនចេញដំណើរ។

១៨. នៅខែឧសភា ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩។ គោលនយោបាយជាតិនេះ បានកំណត់នូវសរសរស្តម្ភជាយុទ្ធសាស្ត្រចំនួន៣ ដោយផ្តោតលើការបង្ការទប់ស្កាត់ ការអន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតប។ ដើម្បីឆ្លើយតបចំពោះការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារឱ្យទទួលបានជោគជ័យ ក.ជ.ក. បានរៀបចំផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ដោយបានកំណត់នូវសកម្មភាពជាក់លាក់សម្រាប់ក្រសួង ស្ថាប័ន ដែលត្រូវបំពេញការងារក្នុងការលើកកម្ពស់សិទ្ធិកុមារ។ ផែនការនេះត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១។

១៩. ទន្ទឹមនេះ ដើម្បីរៀបចំប្រព័ន្ធកិច្ចការពារកុមារមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីបង្ការទប់ស្កាត់ អន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតបនៅគ្រប់កម្រិត ប្រកបដោយប្រសិទ្ធភាព ក្នុងការការពារកុមារគ្រប់ទម្រង់នៃការរំលោភបំពាន និងការអនុវត្តប្រកបដោយគ្រោះថ្នាក់ នៅខែវិច្ឆិកា ឆ្នាំ២០២២ ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦។

២០. ដើម្បីលើកកម្ពស់វិស័យអប់រំ ជាពិសេសការកសាងគ្រឹះ នៃមូលធនមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក.) បានអនុម័ត និងផ្សព្វផ្សាយឱ្យអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ និងរៀបចំផែនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ ឆ្នាំ២០២៤-២០២៨។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ

យុវជន និងកីឡាក៏បានដាក់ឱ្យអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយ ស្តីពីកិច្ចការពារកុមារនៅសាលារៀន ឆ្នាំ២០២៤-២០២៨ ផងដែរ។

២១. ក្រសួងសុខាភិបាលបានដាក់ចេញផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០២៥-២០៣៤ ដែលជាបំណងប្រាថ្នាធម្មានុរូបរបស់ប្រជាជនកម្ពុជាគ្រប់រូប និងជាប្លង់គោលសម្រាប់ធ្វើអាទិភាវូបនីយកម្មគោលដៅយុទ្ធសាស្ត្រក្នុងការធ្វើឱ្យប្រជាជនគ្រប់រូបរស់នៅប្រកបដោយសុខភាព និងសុខុមាលភាពល្អប្រសើរ រួមចំណែកក្នុងការអភិវឌ្ឍមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈការបន្តពង្រឹងវឌ្ឍនភាព និងអន្តរាគមន៍ជាអាទិភាពផ្សេងៗ ដែលក្នុងនោះរួមមាន ការកែលម្អសុខភាពបន្តពូជ កង្វះអាហារូបត្ថម្ភលើកុមារ ព្រមទាំងការកាត់បន្ថយមរណភាពមាតា ទារក និងកុមារ។

២២. ក្រសួងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០២៣-២០២៧ ព្រមទាំងបានដាក់ឱ្យអនុវត្តប្រកាសលេខ២៣៣ ស.អ.យ. ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ និងបានបញ្ចប់ការពិនិត្យ និងកែសម្រួលសេចក្តីព្រាងបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ និងសៀវភៅបណ្តុះបណ្តាល ព្រមទាំងសេចក្តីព្រាងប្រកាសស្តីពីការបង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងគុណវុឌ្ឍនៃអង្គការសុវត្ថិភាព។

២៣. អនុវត្តតាមផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (២០២១-២០២៥) ក.ជ.ក. បានបញ្ជ្រាបគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញទៅដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទន្ទឹមនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក៏បានធ្វើការផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជាផងដែរ។

២៤. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បាននិងកំពុងរៀបចំសេចក្តីព្រាងស្តីពី យុទ្ធសាស្ត្រជាតិបញ្ញាសិប្បនិម្មិត ក្នុងចក្ខុវិស័យលើកស្ទួយការចាប់យក និងការអភិវឌ្ឍបញ្ញាសិប្បនិម្មិតដើម្បីបង្កើនផលិតភាពនិងបង្កើតតម្លៃបន្ថែម សំដៅលើកកំពស់គុណភាពជីវិតប្រជាពលរដ្ឋ និងជំរុញការការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព និងបរិយាបន្ន។

២៥. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានផ្សព្វផ្សាយជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ ដល់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលក្នុងស្រុក និងក្រុមហ៊ុនអន្តរជាតិ ដើម្បីស្វែងរកលទ្ធភាពបច្ចេកទេសក្នុងការទប់ស្កាត់ និងដកហូតរូបភាពមិនសមរម្យពីប្រព័ន្ធអនឡាញ។ ក្រសួងបានរៀបចំ នីតិវិធីផ្ទៃក្នុងរបស់ក្រុមហ៊ុន (Code of Conduct) ស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ ដើម្បីគាំទ្រដល់ក្រុមហ៊ុនឌីជីថលក្នុងការអនុវត្តតាមគោលការណ៍ណែនាំ។ ក្រៅពីនេះ ក្រសួងបានរៀបចំបន្ថែមនូវយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពីគ្រោះថ្នាក់និងហានិភ័យលើប្រព័ន្ធអនឡាញ។ ក្រសួងបានលើកទឹកចិត្តឱ្យដាក់តំណភ្ជាប់ប្រព័ន្ធរាយការណ៍ និងលេខទូរស័ព្ទជំនួយបន្ទាន់ក្នុងគេហទំព័រ និងថ្នាលកម្មវិធីឌីជីថលរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ព្រមទាំងបានធ្វើការផ្សព្វផ្សាយសារនានាតាមទូរស័ព្ទដៃជាប្រចាំ។

២៦. ផ្អែកលើផែនការយុទ្ធសាស្ត្រ ដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ២០២១-២០២៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងរៀបចំយន្តការកសាងសមត្ថភាពកម្លាំងសេវាសង្គម ឱ្យមានកម្រិត

ចំណេះដឹង និងកម្រិតជំនាញពិតប្រាកដ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីផ្តល់សេវាសង្គមកិច្ចជូនអតិថិជន ដែលជាជនរងគ្រោះ និងងាយរងគ្រោះធានាបានប្រសិទ្ធភាពខ្ពស់។

២៧. សមិទ្ធផលថ្មីដ៏សំខាន់សម្រាប់កុមារកម្ពុជាគឺ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥។ ផែនការសកម្មភាពជាតិនេះ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ផែនការនេះរំពឹងថា នឹងផ្តល់អត្ថប្រយោជន៍ដល់កុមារប្រមាណ ៦,៣លាននាក់ (រួមទាំងកុមារី ៣,១លាននាក់) តាមរយៈការពង្រឹងការទប់ស្កាត់ ការគាំទ្រ និងទទួលបានសេវាកម្មប្រកបដោយគុណភាព។

# ៣. ការរស់រានមានជីវិត



៣.១. សុខភាព និងសុខុមាលភាពមូលដ្ឋាន
៣.២. ការចុះអន្រ្តាគុកូលដ្ឋាន
៣.៣. បរិយាកាសគ្រួសារ
៣.៤. បទដ្ឋាននៃការរស់នៅ

# ៣. ការរស់រានមានជីវិត[1]

## ៣.១. សុខភាព និងសុខុមាលភាពមូលដ្ឋាន[2]

### ក. ដំណើរឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសាកល

២៨. ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្នុងនោះអាទិភាពគន្លឹះមួយ នៃការអភិវឌ្ឍមូលធនមនុស្សគឺ ការកែលម្អសុខភាព និងសុខុមាលភាពប្រជាជន តាមរយៈការបន្តកាត់បន្ថយការឈឺ និងស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ និងការលើកកម្ពស់សុខភាពបន្តពូជមាតា ទារក និងកុមារ។ ខណៈដែលកម្មវិធីគោលនយោបាយអាទិភាពទី១ ក្នុងចំណោមកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ របស់រាជរដ្ឋាភិបាល គឺ "ការពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកល" ដែលបានកំណត់គោលដៅច្បាស់លាស់ឆ្នាំ២០៣៥៖ គ្របដណ្តប់ប្រជាជនយ៉ាងតិច ៨០% ដោយប្រព័ន្ធគាំពារសុខភាពសង្គមគ្របដណ្តប់សេវាសុខភាពសារវន្តយ៉ាងតិច ៨០% និងកាត់បន្ថយចំណាយប្រាក់ពីហោប៉ៅលើការថែទាំសុខភាពក្រោម ៣៥% នៃការចំណាយសរុបលើសុខភាព។

២៩. ប្រជាជនគ្របដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាល និងបេឡាជាតិសន្តិសុខសង្គមផ្នែកថែទាំសុខភាព (ប.ស.ស-ថ) មានចំនួន ៧ ៦២៦ ៤១៦នាក់ ឬស្មើ ៤៣,៣៩% នៃប្រជាជនសរុប។ ក្នុងនោះប្រជាជនដែលគ្រប់ដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាលចំនួន ៤ ៦៦៥ ៨៨៨នាក់ និងសមាជិក ប.ស.ស-ថ ដែលបានចុះបញ្ជី និងបង់ភាគទានចំនួន ២ ៩៦០ ៥២៨នាក់ បានកើនឡើងប្រមាណ ៤,៩៩% ។

**ស្ថិតិប្រជាជនគ្របដណ្តប់ដោយប្រព័ន្ធគាំពារសង្គម ឆ្នាំ២០២៥**

| សូចនាករ | លទ្ធផល | | ចំណុចដៅ |
|---|---|---|---|
| | ២០២៤ | ២០២៥ | ២០២៥ |
| ១. ប្រជាជនដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម (%) | 43.73 | 43.39 | 50 |
| - មូលនិធិសមធម៌ (ម.ស.ស.) | 27.44 | 26.54 | |
| - របបសន្តិសុខសង្គម (ប.ស.ស.) | 16.26 | 16.84 | |
| ២. សន្ទស្សន៍គ្របដណ្តប់សេវាសុខភាពនៃការគ្របដណ្តប់សុខភាពជាសកល (រង្វាស់ពី ០-១០០). | 60.10 | 63.6 | 64 |
| ៣. កម្រិតចំណាយប្រាក់ពីហោប៉ៅលើការថែទាំសុខភាព (%) | 60 | 61 | 57 |

ប្រភពទិន្នន័យ៖ របាយការណ៍សមិទ្ធផលវិស័យសុខាភិបាល ឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត ។

៣០. សន្ទស្សន៍នៃការគ្របដណ្តប់សេវាសុខភាពកម្ពុជាបានកើនឡើងពី ៦០,១ នៅឆ្នាំ២០២៤ ដល់ ៦៣,៦ នៅឆ្នាំ២០២៥។ និន្នាការនេះ បញ្ជាក់ពីវឌ្ឍនភាពក្នុងដំណើរឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា។ គួរសម្គាល់ថា ក្នុងសន្ទស្សន៍នេះ មានសូចនាករចំនួន១៧ ចែកចេញជា ៤ក្រុម ដែលក្រុមនីមួយៗមានអត្រាដូចតទៅ៖ (១).សុខភាពបន្តពូជ មាតា ទារក និងកុមារ មានអត្រានៅទ្រឹងដដែល ៦៦,៦% (២).សេវាជំងឺឆ្លងបានកើនពី ៨៧,១ ទៅ ៩១,៩% (៣).សេវាជំងឺមិនឆ្លងកើនពី ៥១,៤ ទៅ ៥៩% (៤).សមត្ថភាពផ្តល់សេវា និងការទទួលបានសេវាបានកើនឡើងពី ៤៣,៨ ទៅ ៤៥,២%។

1 កុមារត្រូវមានជីវិតរស់នៅ មានសុវត្ថិភាព និងមានអ្វីៗចាំបាច់សម្រាប់រស់នៅ ដូចជាចំណីអាហារមានជីវជាតិ មានឈ្មោះ មានសញ្ជាតិ ការព្យាបាលសុខភាព សម្លៀកបំពាក់ ជម្រកស្នាក់នៅ និងជីវភាពសមរម្យ ព្រមទាំងទទួលបានការថ្នាក់ថ្នមពីឪពុកម្តាយ អាណាព្យាបាល និងសង្គម

2 របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០២៤ ទិសដៅការងារឆ្នាំ២០២៥ និងឆ្នាំបន្ត របស់ក្រសួងសុខាភិបាល

៣១. រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ការប្រើប្រាស់សេវាសុខភាពក្រោមប្រព័ន្ធគាំពារសុខភាពសង្គមបានកើនឡើង ៣,៥៨%។ ករណីប្រើប្រាស់សេវាក្រោមកម្មវិធីមូលនិធិសមធម៌កើនឡើង ៤,៤៨% ឬពី ៤ ៨៦១ ៨២៩ ករណី ដល់ ៥ ០៧៩ ៧៥០ករណី និងក្រោមគម្រោង ប.ស.ស បានកើនឡើង ៤.២៤% ឬពី ៧ ៧៧៣ ៧៩៩ដង ទៅ ៨ ១០៣ ៥៨៥ដង។

៣២. ការចំណាយដោយមូលនិធិសមធម៌ក្នុងឆ្នាំ២០២៥ បានកើនឡើង ៥៨,៦៦% ធៀបនឹងការចំណាយក្នុងឆ្នាំ ២០២៤ និងដោយឡែកការចំណាយដោយ ប.ស.ស ផ្នែកថែទាំសុខភាពបានកើនឡើង ២៣,២០%។ ជារួម កំណើននៃការចំណាយខាងលើនេះ គឺមានសង្គតិភាពជាមួយការកើនឡើងនៃការប្រើប្រាស់សេវាសុខាភិបាល និងការពង្រីកវិសាលភាពគ្របដណ្តប់ប្រជាជននៃកម្មវិធីទាំងពីរ។

៣៣. នៅក្នុងឆ្នាំ២០២៣ កម្រិតចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាពស្មើនឹង ៦១% នៃការចំនាយចរន្ត សរុបលើសុខភាព។ តាមការធ្វើចំណោលប៉ានស្មាននៅឆ្នាំ២០៣០ ចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាពអាចនៅចន្លោះពី ៥០% ទៅ ៥៥% នៅក្នុងបរិការណ៍ដែលការចំណាយមូលនិធិសាធារណៈក្នុងប្រទេស បន្តកើនឡើង និងបន្តវិសាលភាពគ្របដណ្តប់ប្រជាជនដោយប្រព័ន្ធគាំពារសង្គម (មូលនិធិ ប.ស.ស. និង មូលនិធិជំនួយសង្គម)។

## ខ. ភាពប្រសើរឡើងនៃស្ថានភាពសុខភាព

៣៤. កម្ពុជាសម្រេចបានសមិទ្ធផលធំធេងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសុខភាព នៅក្នុងបណ្តាទសវត្សចុងក្រោយនេះ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធប្រកបដោយការប្រុងប្រយ័ត្ន បានដើរតួចម្បងក្នុងការរក្សាកំណើនសេដ្ឋកិច្ចរឹងមាំ និងមានសង្គតិភាព ការធ្លាក់ចុះយ៉ាងលឿននៃភាពក្រីក្រ ភាពរឹងមាំនៃប្រព័ន្ធសុខាភិបាល ការពង្រីកប្រព័ន្ធគាំពារសង្គម ភាពប្រសើរឡើងនៃកត្តាសង្គមដែលមានបច្ច័យលើសុខភាព។ល។ វឌ្ឍនភាពទាំងអស់នេះបានធ្វើឱ្យអត្រារស់រានមានជីវិតរបស់កុមារកើនឡើង។




ប្រភព៖ ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០០៨ និង២០១៩

## គ. សុខភាពបន្តពូជ

៣៥. **ផែនការគ្រួសារ និងការពន្យារកំណើត៖** រវាងឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជអាយុពី ១៥-៤៩ឆ្នាំ មាននិន្នាការធ្លាក់ចុះ ៣ឆ្នាំជាប់គ្នា។ ចំនួនស្ត្រីក្នុងវ័យបន្តពូជអាយុពី ១៥-៤៩ឆ្នាំ ដែលបានរៀបការហើយកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយបានថយចុះពី ៥៥៦ ៥៥៧នាក់ នៅឆ្នាំ២០២៤ មកត្រឹម ៥៣០ ៣២២នាក់ (ប្រើប្រាស់នៅសេវាសាធារណៈចំនួន ៥១២ ៤២៩នាក់ និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ១៧ ៨៩៣នាក់) នៅឆ្នាំ២០២៥ ឬថយចុះ ១,០១% ធៀបនឹងឆ្នាំ២០២៤។ អត្រានេះប្រែប្រួលពីខេត្តដែលមានអត្រាទាបជាងគេ ១,២៦% ទៅខេត្តដែលអត្រាខ្ពស់ជាងគេ ២១,៣២%។ មធ្យោបាយពន្យារកំណើតទំនើបដែលកំពុងប្រើប្រាស់នៅមូលដ្ឋានសុខាភិបាលសាធារណៈភាគច្រើនគឺថ្នាំគ្រាប់ ៥០,១៥% នៃចំនួនស្ត្រីប្រើប្រាស់សរុប ថ្នាំចាក់ ៣០,៣៦% បន្ទាប់មកដាក់កងក្រោមស្បែក ៩,១០% កងដាក់ក្នុងស្បូន ៦,៩៤% និងស្រោមអនាម័យ ៣,៤៥%។ នៅឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលសាធារណៈកំពុងផ្តល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទសម្រាប់យុវវ័យ តាមពិធីសារដែលបានធ្វើបច្ចុប្បន្នភាពមានចំនួន ១៥៥កន្លែង។

៣៦. **ការរំលូត/រលូត៖** រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ករណីរលូត និងរំលូត បានកើនឡើង ៤,៦២% ឬពី ១៧ ៤១៧ករណី នៅឆ្នាំ២០២៤ ទៅ ១៨ ២២០ករណី នៅឆ្នាំ២០២៥ ក្នុងនោះករណីរលូតមានចំនួន ១១ ៩៣៦ករណី ឬកើនឡើងប្រមាណ ៤,៦៤% (ឆ្នាំ២០២៤ មានចំនួន ១១ ៤០៧ករណី) និងករណីរំលូតមានចំនួន ៦ ២៨៤ករណី ឬកើនឡើង ៩,៤៨% (ឆ្នាំ២០២៤ មានចំនួន ៥ ៧៤០ករណី)។ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលមានផ្តល់សេវារំលូត/រលូតប្រកបដោយសុវត្ថិភាព និងសេវាថែទាំក្រោយរំលូត/រលូតមានចំនួន ៩៣០កន្លែង។ ចំនួនករណីរំលូត និងករណីរលូតមានកម្រិតផ្សេងៗគ្នាពីខេត្តមួយទៅខេត្តមួយទៀត។



### ឃ. សុខភាពមាតា និងទារក

៣៧. អត្រាមរណភាពមាតា មរណភាពទារក និងកុមារអាយុក្រោម ៥ឆ្នាំ បានបន្តធ្លាក់ចុះថែមទៀតរវាងឆ្នាំ២០១៤ និងឆ្នាំ២០២១/២២។ គួរកត់សម្គាល់ថា មរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ មុនកាលកំណត់ ៨ឆ្នាំ។ ដោយឡែកការធ្លាក់ចុះនៃមរណភាពមាតាមានល្បឿនយឺតក្នុងអំឡុងពេលពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២១ ធៀបនឹងល្បឿននៃការធ្លាក់ចុះក្នុងសម័យកាលគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ឆ្នាំ២០០០-២០១៥។

៣៨. **ការថែទាំគភ៌មុនសម្រាល៖** នៅឆ្នាំ២០២៥ ករណីពិនិត្យថែទាំគភ៌មុនសម្រាលលើកទី២ បានកើនឡើង ៣,៦៤% ធៀបនឹងឆ្នាំ២០២៤។ ស្ត្រីមានគភ៌ ៣៣៧ ៤៨២នាក់ បានមកពិនិត្យថែទាំគភ៌លើកទី២ (ពិនិត្យនៅសេវាសាធារណៈចំនួន ៣០៥ ២៩១នាក់ និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ៣២ ១៩១នាក់) ឬស្មើនឹង ៩៥,០៥% នៃស្ត្រីមានគភ៌រំពឹងទុក។ អត្រាពិនិត្យលើកទី២ ប្រែប្រួលពីកម្រិតទាបបំផុត ៥៩,៦៥% ទៅកម្រិតខ្ពស់បំផុត ១០០,៥៥%។ ការពិនិត្យថែទាំគភ៌មុនសម្រាលលើកទី៤ បានកើនឡើង ១,០២% ធៀបនឹងឆ្នាំ២០២៤។ ការពិនិត្យថែទាំគភ៌មុនសម្រាលបានស្រាវជ្រាវរកឃើញស្ត្រីចំនួន ៣៧ ៤០៦នាក់បម្រុងមានគ្រោះថ្នាក់ ក្នុងនោះមានបញ្ហាធ្លាក់ឈាម ៨៦៩នាក់ ស្លេកស្លាំង ១២ ៩៤៨នាក់ និងបញ្ហាផ្សេងៗទៀត ២៣ ៥៨៩នាក់។ ស្ត្រីប្រឈមគ្រោះថ្នាក់ទាំងនោះ បានទទួលការប្រឹក្សាយោបល់ និងការណែនាំ ព្រមទាំងការពិនិត្យតាមដាន និងការថែទាំយ៉ាងយកចិត្តទុកដាក់នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

៣៩. **ការសម្រាលទូទៅ៖** នៅឆ្នាំ២០២៥ ស្ត្រីមានគភ៌បានសម្រាលដោយបុគ្គលិកសុខាភិបាល មានចំនួន ២៥៣ ២០៥នាក់ ទាបជាងឆ្នាំ២០២៤ ដែលមានចំនួន ២៨៣ ៩៥១នាក់។ បើគិតជាភាគរយនៃស្ត្រីមានគភ៌រំពឹងទុក អត្រានេះបានធ្លាក់ចុះពី ៧៧,៦៣% នៅឆ្នាំ២០២៤ មកនៅ ៧១,៣១% នៅឆ្នាំ២០២៥។ រីឯចំនួនស្ត្រីសម្រាលនៅមូលដ្ឋានសុខាភិបាលមានចំនួនសរុប ២៥១ ៧១៨នាក់ ក្នុងនោះ សម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ២៣៦ ៣០១នាក់ និងនៅសេវាសុខាភិបាលឯកជនដែលបានរាយការណ៍ ១៥ ៤១៦នាក់។ បើគិតជាអត្រាសម្រាលនៅមូលដ្ឋានសុខាភិបាលបានធ្លាក់ចុះពី ៧៥,៨២% នៅឆ្នាំ២០២៤ មកនៅ ៧០,៨៩% នៃស្ត្រីមានគភ៌រំពឹងទុក នៅឆ្នាំ២០២៥។

៤០. **មរណភាពមាតា និងទារក៖** យោងតាមរបាយការណ៍នៃប្រព័ន្ធតាមដានមរណភាពមាតា និងការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបកើត នៅឆ្នាំ២០២៥ ករណីសង្ស័យមរណភាពមាតាដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួនសរុប ៤៣នាក់ ទាបជាងឆ្នាំ២០២៤ ដែលមានចំនួន ៧៩នាក់។ រីឯទារកកើតរស់មានចំនួន ២៣៧ ៧៥៧នាក់ ទារកកើតស្លាប់ ៤៩៦នាក់ (កើតស្លាប់មុន២៤ ម៉ោង ២០៩នាក់) និងស្លាប់កើត ១ ៤០១នាក់ (ស្លាប់កើតភ្លាមៗ និងស្លាប់កើតយូរ)។ ក្រៅពីស្ថានភាពទាំងនេះ ទារកកើតទម្ងន់តិចជាង ២.៥ គ.ក្រ មានចំនួន ១៥ ៦៥៥នាក់ ទារកទម្ងន់លើសពី ២.៥ គ.ក្រ ចំនួន ២២១ ៩៤១នាក់ ទារកកើតមិនបានថ្លឹងទម្ងន់ចំនួន ១៦១នាក់ និងម្តាយផ្តល់កំណើតកូនភ្លោះពីរ ១ ៣៨២ នាក់ និងកូនភ្លោះបីចំនួន ១១នាក់។

### ស្ថានភាពទារកកើត ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឆ្នាំ២០២០-២០២៥

| ស្ថានភាពទារកកើត | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|
| ទារកកើតរស់ | 309 637 | 285 173 | 259 954 | 280 972 | 267 500 | 237,757 |
| ទារកកើតស្លាប់ | 2 416 | 2 540 | 2 042 | 2 087 | 1 055 | 496 |
| - ទារកកើតស្លាប់មុន២៤ម៉ោង | 304 | 280 | 240 | 492 | 198 | 209 |
| ទារកស្លាប់កើត (កើតភ្លាមៗ/កើតយូរ) | 2 054 | 1 157 | 1 100 | 2 025 | 1 716 | 1,406 |
| ទារកកើតមានទម្ងន់តិចជាង ២.៥ គ.ក្រ | 19 654 | 17 942 | 17 902 | 17 472 | 17 415 | 15,655 |
| ទារកកើតមានទម្ងន់លើសពី ២.៥ គ.ក្រ | 289 506 | 266 949 | 241 747 | 263 353 | 249 687 | 221,941 |
| ទារកកើតមិនបានថ្លឹងទម្ងន់ | 477 | 282 | 8 234 | 147 | 398 | **161** |
| ចំនួនម្តាយផ្តល់កំណើតកូនភ្លោះពីរ/បី | 1 982/24 | 1 673/22 | 1 442/15 | 1 769/18 | 1 597/18 | 1,382/11 |

ប្រភពទិន្នន័យ៖ របាយការណ៍សមិទ្ធផលវិស័យសុខាភិបាល ឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត ។

៤១. **ការបង្ការការចម្លងមេរោគអេដស៍/មេរោគស្វាយពីម្តាយទៅកូន៖** ស្ត្រីមានគភ៌ដែលមកទទួលការពិនិត្យថៃទាំមុនសម្រាល ហើយបានធ្វើតេស្តវិជ្ជមានមេរោគអេដស៍មានចំនួន ១ ១៤៤នាក់ ក្នុងនោះស្ត្រី ១ ១៣៧នាក់ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ ចំណែកស្ត្រីមានគភ៌ដែលបានធ្វើតេស្តវិជ្ជមានមេរោគស្វាយមានចំនួន ៧ ៧៣៥នាក់ ក្នុងនោះស្ត្រីចំនួន ៧ ៥១៦នាក់ បានទទួលការព្យាបាលជំងឺស្វាយ។ រីឯស្ត្រីមានគភ៌ដែលបានមកសម្រាល ហើយបានរកឃើញមានផ្ទុកមេរោគអេដស៍មានចំនួន ១ ១៩៤នាក់ ក្នុងនោះស្ត្រី ១ ១៨៨នាក់ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍តាមលក្ខខណ្ឌបច្ចេកទេស និងទារកប្រឈមហានិភ័យ ១ ១៧៧នាក់ បានទទួលឱសថសម្រាប់ការបង្ការការចម្លងពីម្តាយ។ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន មានចំនួនសរុប ១ ៤២៣កន្លែង នៅឆ្នាំ២០២៥ ដោយបានកើនឡើង ៧កន្លែង (នៅឆ្នាំ២០២៤ មានចំនួន ១ ៣៨៧កន្លែង)។

## ង. សុខភាពកុមារ

| | លទ្ធផល | | | ចំណុចដៅ | % បម្រែបម្រួល |
|---|---|---|---|---|---|
| សូចនាករស្នូល | ២០២៣ | ២០២៤ | ២០២៥ | ២០២៥ | |
| ១. អត្រាគ្របដណ្តប់នៃបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកថ្លើមប្រភេទបេ រលាកសួត រលាកស្រោមខួរ (DPT-HepB-Hib3) ៣ដូស (%) | 107.77 | 95.35 | **93.14** | > 95 | -1.86 |
| ២. អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូច នៅខែទី៩ (%) | 108.63 | 109.1 | **98.32** | > 95 | +3.32 |
| ៣. ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ | 1.64 | 1.63 | **1.77** | 1.69 | +4.73 |

ប្រភពទិន្នន័យ៖ របាយការណ៍សមិទ្ធផលវិស័យសុខាភិបាល ឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត ។

៤២. **ការផ្តល់ថ្នាំបង្ការជំងឺ៖** នៅឆ្នាំ២០២៥ កម្មវិធីជាតិផ្តល់ថ្នាំបង្ការបានផ្តល់វ៉ាក់សាំងកញ្ជ្រឹល-ស្អូច ដល់កុមារអាយុ ៦ខែ ឡើងវិញ ដើម្បីទប់ស្កាត់ការផ្ទុះរីករាលដាលនៃជំងឺកញ្ជ្រឹល។ កុមារអាយុក្រោមមួយឆ្នាំ ចំនួន ៣២៨ ៧០៤នាក់ បានទទួលថ្នាំបង្ការតាមប្រភេទវ៉ាក់សាំង រួមមាន៖

- វ៉ាក់សាំងបង្ការរបេង (BCG) ៨៤,៧៨% (កុមារ ២៧៨ ៦៨៤នាក់)
- វ៉ាក់សាំងបង្ការរលាកថ្លើមប្រភេទបេ <២៤ម៉ោង (Hep B) ៧៣,៦៨% (កុមារ ២៤២ ១៧៨នាក់)
- វ៉ាក់សាំងបង្ការគ្រុនស្វិតដៃជើង ៣ដូស ៩២,៧៧% (កុមារ ៣០៤ ៩៥០នាក់)
- វ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស-រលាកថ្លើមប្រភេទបេ-រលាកសួត-រលាកស្រោមខួរ (DPT-HepB-Hib3) ៣ដូស ៩៣,១៤% (កុមារ ៣០៦ ១៥៥នាក់)
- វ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល-ស្អូច (MR9) ៩៨,៣២% (កុមារ ៣២៣ ១៨១នាក់)
- វ៉ាក់សាំងបង្ការជំងឺរលាកខួរក្បាល (JE) ៩៨,៣២% (កុមារ ៣២៣ ១៨១នាក់)
- វ៉ាក់សាំងបង្ការជំងឺរលាកសួត និងស្រោមខួរក្បាល (PCV3) ៣ដូស ៩២,៨៥% (កុមារ ៣០៥ ២០២នាក់)។

ទន្ទឹមនឹងនេះ ក្រុមកុមារដែលមានអាយុលើសពី ១ឆ្នាំ ចំនួន ៣០០ ៣៣២នាក់ បានទទួលថ្នាំបង្ការជំងឺកញ្ជ្រឹល-ស្អូច (MR18) ឬស្មើនឹង ៩១,៣៧%។

៤៣. **ការពិគ្រោះជំងឺក្រៅលើកុមារ៖** ការពិនិត្យជំងឺក្រៅករណីថ្មី លើកុមារអាយុក្រោមប្រាំឆ្នាំ បានកើនពី ២ ៥៩៤ ៣៨៩ករណី នៅឆ្នាំ២០២៤ ទៅ ២ ៧៨៥ ៦៧៤ករណី នៅឆ្នាំ២០២៥ ក្នុងនោះ ពិនិត្យនៅមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ២ ៤៨៥ ០០៦ករណី និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ៣០០ ៦៦៨ករណី។ រីឯ ចំនួនលើកនៃការពិនិត្យពិគ្រោះជំងឺក្រៅករណីថ្មី នៃកុមារអាយុក្រោមប្រាំឆ្នាំម្នាក់ក្នុងមួយឆ្នាំមាននិន្នាការកើនពី ១,២៦ នៅឆ្នាំ២០២១ មកដល់ ១,៧៧ នៅឆ្នាំ២០២៥។ កម្រិតប្រើប្រាស់សេវាពិនិត្យជំងឺក្រៅករណីថ្មី និងចំនួនលើកពិនិត្យជំងឺករណីថ្មី ក្នុងកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ ប្រែប្រួលតាមរាជធានីខេត្ត ពីអត្រាទាបបំផុត ០,៥៨លើក ទៅអត្រាខ្ពស់បំផុត ២,៧៥លើក។

៤៤. **ជំងឺនាំមុខ ឬបញ្ហាសុខភាព១០៖** ដែលជាមូលហេតុចម្បងនៃការពិគ្រោះជំងឺក្រៅករណីថ្មី ឆ្នាំ២០២៥ សរុប ៨៤៣ ២៨៥ករណី ក្នុងនោះរួមមាន ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ចំនួន ៥៨២ ៨៨៣ករណី ឬស្មើនឹង ៦៩,១២%, ជំងឺរាកគ្មានខ្សោះជាតិទឹក ៦២ ០០៧ករណី ឬស្មើនឹង ៧,៣៥%, ជំងឺរលាកសួត ៤៣ ៦៤៨ករណី ឬស្មើនឹង ៥,១៨%, ជំងឺរលាកបំពង់កស្រួចស្រាល់ ៣៣ ០៥០ករណី ឬស្មើនឹង ៣,៩២%, ជំងឺរលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត ២៧ ៣៩៦ករណី ឬស្មើនឹង ៣,២៥%, ជំងឺរលាកទងសួតស្រួចស្រាល់ ២៥ ២៣៦ករណី ឬស្មើនឹង ២,៩៩%, ជំងឺរាកមួល ២៣ ៤៩១ករណី ឬស្មើនឹង ២,៧៩%, ជំងឺរមាស់ស្បែក ១៨ ១៣៥ករណី ឬស្មើនឹង ២,១៥%, ជំងឺរាកមានខ្សោះជាតិទឹកមធ្យម ១៥ ០៣៧ករណី ឬស្មើនឹង ១,៨៩% និងជំងឺក្រហមភ្នែក ១១ ៥០២ករណី ឬស្មើនឹង ១,៣៦%។ គួរកត់សម្គាល់ថា ជំងឺហឺតដែលបានលេចឡើងនៅឆ្នាំ២០២៤ មិនមានលេខរៀងនៅក្នុងបញ្ហាសុខភាពចម្បងទាំង១០ នៅឆ្នាំ២០២៥ទេ និងត្រូវបានជំនួសវិញដោយជំងឺភ្នែកក្រហមនៅលេខរៀងទី១០។

៤៥. ការពិនិត្យជំងឺក្រៅតាមពិធីសារសមាហរណកម្មគ្រប់គ្រងជំងឺកុមារអាយុក្រោមប្រាំឆ្នាំ មានចំនួនសរុប ១ ១១០ ២៦៣ករណី ក្នុងនោះករណីថ្មីចំនួន ១ ០៧០ ៤០៧ករណី។ គួរកត់សម្គាល់ថា ការពិនិត្យក្រៅករណីថ្មីតាមបែបសមាហរណកម្ម នៅឆ្នាំ២០២៥ បានថយចុះតិចតួចប្រមាណ ០.៥% ទាបជាងឆ្នាំ២០២៤។

៤៦. **ការសម្រាកព្យាបាល៖** នៅឆ្នាំ២០២៥ កុមារអាយុក្រោមប្រាំឆ្នាំសម្រាកព្យាបាលបានកើនឡើងពី ២៥៩ ១២៥នាក់ (ស្រី ១១៤ ៩៤៥នាក់) នៅឆ្នាំ២០២៤ ទៅ ២៧៦ ៤៩០នាក់ (ស្រី ១២១ ៩៤៨នាក់) នៅឆ្នាំ

២០២៥ ឬកើនឡើង ៦,៧០%។ កុមារដែលស្លាប់មានចំនួន ១ ២៥០នាក់ ទាបជាងឆ្នាំ២០២៤ ដែលមានចំនួន ១ ៣០១នាក់។ មូលហេតុនាំមុខនៃការចូលសម្រាកព្យាបាលរបស់កុមារ ៨៦ ១៣៩ករណី គឺជំងឺរលាកបំពង់កស្រួចស្រាវ ២៣ ៥០៥ករណី ឬស្មើនឹង ២៧,២៩%, ជំងឺរលាកទងសួតស្រួចស្រាវ ១៩ ៣១៩ករណី ឬស្មើនឹង ២២,៤៣%, ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាវ ១៦ ៤៥៥ករណី ឬស្មើនឹង ១៩,១០%, ជំងឺរលាកសួត ១៣ ៩៨១ករណី ឬស្មើនឹង ១៦,២៣% និងជំងឺរាកគ្មានខ្សោះជាតិទឹក ១២ ៨៧៩ករណី ឬស្មើនឹង ១៤,៩៥%។ គួរកត់សម្គាល់ថា ជំងឺរាកគ្មានខ្សោះជាតិទឹក បានធ្លាក់ពីលេខរៀងទី៣ នៅឆ្នាំ២០២៤ ទៅលេខរៀងទី៥ នៅឆ្នាំ២០២៥ ខណៈជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាវ និងជំងឺរលាកសួត បានឡើងពីលេខរៀងទី៤ និងទី៥ មកទី៣ និងទី៤ វិញ។

## ច. ការកែលម្អកង្វះអាហារូបត្ថម្ភ

| សូចនាករស្នូល | លទ្ធផល | | | ចំណុចដៅ | %បម្រែបម្រួល |
|---|---|---|---|---|---|
| | ២០២៣ | ២០២៤ | ២០២៥ | ២០២៥ | |
| % នៃទារកបានទទួលការបំបៅដោយទឹកដោះម្ដាយក្នុងអំឡុង១ម៉ោងដំបូងនៃកំណើត | 71.02 | 72.73 | **76.28** | 74 | +2.28 |
| % នៃកុមារអាយុពី ៦-៥៩ខែ បានទទួលគ្រាប់ថ្នាំជីវជាតិ-អា ក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ | 84.02 | 92.73 | **84.60** | 93 | -8.40 |
| % នៃកុមារអាយុពី ១២-៥៩ខែ បានទទួលថ្នាំម៉េបង់ដាហ្សុលក្នុងអំឡុងពេល ៦ខែចុងក្រោយនៃឆ្នាំ | 73.73 | 92.73 | **83.87** | 93 | -9.13 |
| % ស្ត្រីមានគភ៌ទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៩០គ្រាប់ | 87.29 | 79.55 | **85.87** | 90 | -4.13 |
| % ស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៤២គ្រាប់ | 76.22 | 68.39 | **67.25** | 82 | -14.75 |

៤៧. អន្តរាគមន៍ក្នុងការកែលម្អស្ថានភាពអាហារូបត្ថម្ភកុមារ រួមមាន៖ ផ្ដល់ការអប់រំម្ដាយពីអត្ថប្រយោជន៍នៃការបំបៅទារកដោយទឹកដោះម្ដាយ ការផ្ដល់អាហារបំប៉នស្របតាមដំណាក់កាលលូតលាស់របស់កុមារ ការថែទាំ និងការបង្ការទារក/កុមារពីជំងឺផ្សេងៗ ការផ្ដល់វ៉ាក់សាំងបង្ការជំងឺតាមកាលវិភាគ ការផ្ដល់មីក្រូសារជាតិ និងថ្នាំទម្លាក់ព្រូន ការតាមដានការលូតលាស់របស់កុមារ និងការពិនិត្យព្យាបាលថែទាំកុមារកង្វះអាហារូបត្ថម្ភតាមលំនាំគ្លីនិក។

៤៨. **ការបំបៅទារកដោយទឹកដោះម្ដាយ៖** នៅឆ្នាំ២០២៥ ទារកកើតរស់ដែលបានទទួលការបំបៅដោយទឹកដោះម្ដាយ នៅក្នុងម៉ោងដំបូងក្រោយកំណើតបានកើនឡើង ៣,៥៥% (ពោលគឺកើនពី ៧២,៧៣% ទៅ ៧៦,២៨% បើធៀបនឹងឆ្នាំ២០២៤)។ អត្រានេះប្រែប្រួលពីខេត្តមួយទៅខេត្តមួយ ពីអត្រាទាបបំផុត ៦៩,៥៦% ទៅអត្រាខ្ពស់បំផុត ៩៩,៣៤%។

៤៩. **ការផ្តល់គ្រាប់ថ្នាំជីវជាតិ-អា៖** តាមការប៉ាន់ស្មានដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កុមារអាយុពី ៦-៥៩ខែ នៅឆ្នាំ២០២៥ មានចំនួន ១ ៤០០ ៩៤៨នាក់ ក្នុងនោះ កុមារបានទទួលគ្រាប់ថ្នាំជីវជាតិ-អា ក្នុងអំឡុងពេល ៦ខែដើមឆ្នាំ២០២៥ (ជុំទីមួយ) មានចំនួន ១ ២៤១ ៧១៩នាក់ ស្មើនឹង ៨៨,៦៣% និងក្នុងអំឡុងពេល ៥ខែចុងឆ្នាំ (ជុំទីពីរ គិតត្រឹមខែវិច្ឆិកា) មានចំនួន ១ ១៨៥ ១៥៣នាក់ ឬស្មើនឹង ៨៤,៦០%។ អត្រានេះមានការប្រែប្រួលពីខេត្តមួយទៅខេត្តមួយទៀត ពីអត្រាទាបបំផុត ១៩,២១% ទៅកម្រិតខ្ពស់បំផុត ១៣២,៦០%។ ដោយឡែក គិតត្រឹមខែវិច្ឆិកាឆ្នាំ២០២៥ ការផ្តល់គ្រាប់ថ្នាំជីវជាតិ-អា ក្នុងការព្យាបាលកុមារមានជំងឺស្ងួតភ្នែក និងជំងឺខ្វាក់មាន់បានចំនួន ១១ ៣២២នាក់ កុមារមានជំងឺកញ្ជ្រឹល ១៣៩នាក់ និងកុមារមានជំងឺកង្វះអាហារូបត្ថម្ភ ឬរាកជាប់ ឬរាករុំរ៉ៃ ចំនួន ៣៥០នាក់។

៥០. **ការផ្តល់ថ្នាំទំលាក់ព្រូន៖** នៅឆ្នាំ២០២៥ កុមារអាយុពី ១២-៥៩ខែ ដែលបានទទួលថ្នាំមេបង់ដាហ្សុលជុំទីពីរ (៥ខែចុងឆ្នាំ គិតត្រឹមខែវិច្ឆិកា) មានចំនួន ១ ០៤០ ៨៤៤នាក់។ គិតត្រឹមខែវិច្ឆិកាឆ្នាំ២០២៥ ស្ត្រីក្នុងវ័យបន្តពូជអាយុពី ១៥-៤៩ឆ្នាំ ចំនួន ២៥១ ៣៦១នាក់ និងស្ត្រីបំបៅដោះកូន ចំនួន ១៤៥ ៤៩៩នាក់ ក៏បានទទួលថ្នាំទម្លាក់ព្រូននេះផងដែរ។

៥១. **ការផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក៖** នៅឆ្នាំ២០២៥ ស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក ៩០គ្រាប់ មានចំនួន ៣០៤ ៥៣២នាក់ ឬស្មើនឹង ៨៥,៨៧% នៃស្ត្រីមានគភ៌រំពឹងទុក (កើនឡើងធៀបនឹងឆ្នាំ២០២៤ ដែលមានត្រឹម ៧៩,៥៥%)។ រីឯស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក ៤២គ្រាប់ មានចំនួន ២៣៨ ៧៧៨នាក់ ឬស្មើនឹង ៦៧,២៥% (ថយចុះបន្តិចធៀបនឹងឆ្នាំ ២០២៤ ដែលមាន ៦៨,៣៩%)។

៥២. **ការពិនិត្យពិគ្រោះ និងព្យាបាលជំងឺកង្វះអាហារូបត្ថម្ភស្រួចស្រាវ មធ្យម និងធ្ងន់ធ្ងរ៖** នៅឆ្នាំ២០២៥ កុមារអាយុក្រោម ៥ឆ្នាំ ដែលបានមកពិនិត្យជំងឺក្រៅ និងបានរកឃើញមានបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវមានចំនួនសរុប ៨ ២៩៤ករណី ដោយថយចុះប្រមាណ ២៧% បើធៀបនឹងឆ្នាំ២០២៤ (ដែលមាន ១១ ៣១០ករណី)។ ដោយឡែកកុមារអាយុក្រោម ៥ឆ្នាំ ដែលបានធ្វើរោគវិនិច្ឆ័យថាមានជំងឺកង្វះអាហារូបត្ថម្ភស្រួចស្រាវ ហើយបានមកសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈនៅក្នុងឆ្នាំ២០២៥ មានចំនួនសរុប ៩៣០នាក់ ច្រើនជាងឆ្នាំ២០២៤ ចំនួន ១៤នាក់ (ឆ្នាំ២០២៤ មានចំនួន ៩១៦នាក់)។

## ៣.២. ការចុះអត្រានុកូលដ្ឋាន

### ក. ការចុះបញ្ជីកំណើត

៥៣. នៅកម្ពុជា មានកុមារប្រមាណ ៩៥,៧% នៃកុមារទាំងអស់ដែលមានអាយុ ០-៤ ឆ្នាំ មានសំបុត្រកំណើតនៅប្រទេសកម្ពុជា។ ភាគរយនេះ គឺមានកម្រិតខ្ពស់បំផុតនៅរាជធានីភ្នំពេញមានប្រមាណជិត ៩៧,២% នៅទីប្រជុំជនផ្សេងៗមានជិត ៩៦,៨% និងនៅតំបន់ជនបទមាន ៩៥%។[3]

៥៤. រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីសមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន។ អនុក្រឹត្យនេះ មានចំណុចសំខាន់ៗចំនួន ៤ គឺ (១).កំណត់សមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានទាំង ៥ថ្នាក់ (២).បើកផ្លូវឱ្យអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាននៅក្រៅប្រទេសតាមស្ថាន

[3] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៣ ទំព័រ៣៤

តំណាង (៣).បើកផ្លូវឱ្យមានការកែតម្រូវទិន្នន័យតាមថ្នាក់នីមួយៗ និង (៤).បើកផ្លូវឱ្យអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធព័ត៌មានវិទ្យា ។

៥៥. រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ ស្តីពីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដោយមានចំណុចសំខាន់ៗចំនួន ៤ គឺ (១).អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមានទ្រង់ទ្រាយជាសន្លឹកប្លាស្ទិក និង/ឬជាទ្រង់ទ្រាយអេឡិចត្រូនិច ដែលអាចធ្វើអន្តរកម្មជាមួយប្រព័ន្ធផ្សេងៗសម្រាប់សេវាកម្មឌីជីថល (២).ត្រូវបានផ្តល់ជូនបុគ្គលមានសញ្ជាតិខ្មែរគ្រប់រូបដែលមានអាយុចាប់ពី ១៥ឆ្នាំ ឡើងទៅ រួមទាំងព្រះសង្ឃ បព្វជិតសាសនា ជនជាប់ឃុំ ជនវិបល្លាសស្មារតី (៣).មានសុពលភាពរយៈពេល ១០ឆ្នាំ ចំពោះបុគ្គលមានអាយុចាប់ពី ១៥ឆ្នាំ ដល់ក្រោម ៦០ឆ្នាំ និងមានសុពលភាពជាអចិន្ត្រៃយ៍ចំពោះបុគ្គលមានអាយុចាប់ពី ៦០ឆ្នាំ ឡើង និង (៤).ដំណើរការផ្តល់ ប្រគេន អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានរយៈពេល ២១ថ្ងៃ នៃថ្ងៃធ្វើការ (គិតចាប់ពីថ្ងៃស្នើសុំ) ។ ផ្អែកតាមអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ ៤២២១ ប្រក ស្តីពីបែបបទ និងនីតិវិធីនៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត ។

៥៦. ក្រសួងមហាផ្ទៃបាននិងកំពុងដាក់ឱ្យប្រើប្រាស់សាកល្បងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន (CRS) តាមប្រព័ន្ធអេឡិចត្រូនិច ទាំងបញ្ជីកំណើតរស់ បញ្ជីអាពាហ៍ពិពាហ៍ និងបញ្ជីមរណភាព (គ្រោងដាក់ឱ្យអនុវត្តពេញលេញនៅរាជធានីភ្នំពេញនាចុងត្រីមាសទី១ ឆ្នាំ២០២៦) ព្រមទាំងរៀបចំកែលម្អ និងពង្រឹងការផ្តល់សេវាកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ឱ្យមានភាពងាយស្រួល និងរហ័ស។ ក្រសួងបាននិងកំពុងសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីត្រួសត្រាយផ្លូវចុះបញ្ជីអត្រានុកូលដ្ឋាននៅតាមស្ថានទូត ឬស្ថានកុងស៊ុលក្រៅប្រទេស (អាចចាប់អនុវត្តនាដើមឆ្នាំ២០២៦)។

៥៧. ក្នុងឆ្នាំ២០២៥ ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន ៧១៨ ៩៨៣បញ្ជី មនុស្ស ៩៨៣ ៣៩០នាក់ (ស្ត្រី ៤៨៣ ២២៣នាក់) បូកយោងពីឆ្នាំ២០០២ ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទសរុបបានចំនួន ២២ ១១១ ៧៥០បញ្ជី មនុស្ស ២៣ ៨០៥ ៣៧៨នាក់ (ស្ត្រី ១១ ៤១០ ៩៥០នាក់)។ ដោយឡែក គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ ការចុះបញ្ជីអត្រានុកូលដ្ឋានតាមរយៈប្រព័ន្ធជូនដំណឹងពីមូលដ្ឋានសុខាភិបាលដែលដាក់ឱ្យដំណើរការសាកល្បងក្នុងសង្កាត់ចំនួន៦ នៃខណ្ឌពោធិ៍សែនជ័យ រួមមាន ការចុះបញ្ជីកំណើត បានចំនួន ២៨៧នាក់ (ក្នុងចំណោមការជូនដំណឹងចំនួន ២.១១៨នាក់)។

## ៣.៣. បរិយាកាសគ្រួសារ[4]

### ក.ការថែទាំជំនួស

៥៨. កន្លែងថែទាំកុមារមានចំនួន ២៤០កន្លែង ដែលមានកុមារនិងយុវជនអាយុចាប់ពី ១៨ឆ្នាំឡើង សរុបចំនួន ៩ ២៥១នាក់ ស្រី ៥ ០៣៦នាក់ ក្នុងនោះ កុមារអាយុពី 0-១៧ឆ្នាំ មានចំនួន ៧ ៣៦១នាក់ ស្រី ៤ ០២៩នាក់ និងយុវជនមានអាយុចាប់ពី ១៨ឆ្នាំឡើង មានចំនួន ១ ៨៩០នាក់ ស្រី ១ ០០៧នាក់។ កុមារទទួលបានសេវាថែទាំជំនួសនៅក្នុងគ្រួសារផ្លូវការចំនួន ៨៨៦នាក់ ស្រី ៤៥៣នាក់ រួមមាន កុមារថែទាំដោយសាច់ញាតិផ្លូវការចំនួន ៥៣០នាក់ ស្រី ២៨២នាក់ និងយុវជនអាយុចាប់ពី ១៨ឆ្នាំចំនួន ៩៩នាក់ ស្រី ៥៩នាក់។ កុមារថែទាំ

[4] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួង ស.អ.យ.

ដោយគ្រួសារធម៌ចំនួន ២៥២នាក់ ស្រី ១១០នាក់ និងយុវជនចាប់ពីអាយុ ១៨ឆ្នាំចំនួន ៥នាក់។ កុមារដែលត្រូវបានធ្វើសមាហរណកម្ម ឬបង្រួបបង្រួមគ្រួសារ ឬកុមារចាកចេញពីមណ្ឌលថែទាំសរុបចំនួន ៧៦៦នាក់ ស្រី ៥៤០នាក់ និងយុវជនចាប់ពីអាយុ ១៨ឆ្នាំ សរុបចំនួន ២២០នាក់ ស្រី ១០៨នាក់។

**តារាង ៖ ចំនួនកន្លែងថែទាំ និងចំនួនកុមារ និងយុវជន ទិន្នន័យឆ្នាំ២០២៥**

| ប្រភេទកន្លែងថែទាំ | ចំនួន | ចំនួនកុមារអាយុ ០-១៧ឆ្នាំ | | ចំនួនយុវជន ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី |
| មណ្ឌលថែទាំរបស់រដ្ឋ | ២១ | ៩០៤ | ៤១៤ | ២៣៧ | ១០៩ |
| មណ្ឌលថែទាំរបស់អង្គការដៃគូ | ១៣៦ | ៤ ៤៤២ | ២ ៤៥៩ | ១ ០៩៨ | ៥២៨ |
| កន្លែងថែទាំបែបសហគមន៍ | ៨៣ | ២ ០១៥ | ១ ១៥៦ | ៥៥៥ | ៣៧០ |
| **សរុបរួម** | **២៤០** | **៧ ៣៦១** | **៤ ០២៩** | **១ ៨៩០** | **១ ០០៧** |

ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត របស់ក្រសួង ស.អ.យ.

៥៩. ក្នុងឆ្នាំ២០២៥ បានផ្ដល់វិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារចំនួន ៦៥មណ្ឌល ដែលមានសុពលភាពលើមណ្ឌលថែទាំកុមារសរុបចំនួន ១៣៦។

៦០. គោលនយោបាយថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងសហគមន៍ ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ បានបណ្ដុះបណ្ដាលឃុំ-សង្កាត់ អំពីការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ អំពើហិង្សា និងការរំលោភបំពានផ្សេងៗមកលើកុមារចំនួន ១១៦ឃុំ សង្កាត់ និងបានបណ្ដុះបណ្ដាលស្ដីពីអង្គការសុវត្ថិភាពកុមារដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន ២៥។ បានរៀបចំបណ្ដុះបណ្ដាលអំពីការអនុវត្តនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ថ្នាក់រាជធានី ខេត្ត ទាំង២៥។

៦១. បានចូលរួមកិច្ចប្រជុំជាន់ខ្ពស់លើកទី១ ស្ដីពីកិច្ចសហប្រតិបត្តិការកិច្ចការពារកុមារធ្វើទេសន្តរប្រវេសន៍ នៅទីក្រុងបាងកក ប្រទេសថៃ ដើម្បីពិភាក្សាលើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការកិច្ចការពារកុមារ ដែលរងផលប៉ះពាល់ដោយការធ្វើទេសន្តរប្រវេសន៍រវាងប្រទេសថៃ និងប្រទេសកម្ពុជា។ ជាលទ្ធផល ភាគីទាំងពីរបានឯកភាពលើសេចក្ដីព្រាងអនុស្សរណៈនេះ ដើម្បីស្នើសុំប្រមុខរដ្ឋាភិបាលចុះហត្ថលេខាក្នុងឆ្នាំ២០២៥ ប៉ុន្តែដំណើរការនៃការចុះអនុស្សរណៈនេះ ត្រូវបានផ្អាកវិញក្រោយពេលថៃឈ្លានពានកម្ពុជា។

## ខ.ការសុំកូន

៦២. ដើម្បីពង្រឹងការអនុវត្តនីតិវិធីសុំកូនក្នុងប្រទេស ក្រសួងបានផលិត និងផ្សព្វផ្សាយវីដេអូអប់រំខ្លីស្ដីពីដំណើរការអនុវត្តសុំកូនក្នុងប្រទេស រៀបចំបណ្ដុះបណ្ដាលអំពីច្បាប់ នីតិវិធី និងទម្រង់បែបបទពាក់ព័ន្ធនឹងសុំកូនដល់មន្ត្រីពាក់ព័ន្ធ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងចុះផ្ដល់បច្ចេកទេស ពិនិត្យតាមដានការអនុវត្តផែនការអចិន្ត្រៃយ៍សម្រាប់កុមារតាមរយៈសុំកូនក្នុងប្រទេស។ ជាលទ្ធផលបានទទួលដីកាសម្រេចសុំកូនក្នុងប្រទេសចំនួន ២០ករណី និងមានអ្នកដាក់ពាក្យសុំកូនសរុបចំនួន ២០គ្រួសារ។

៦៣. បានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យនូវសំណុំឯកសារចាស់ៗនៃការសុំកូនអន្តរប្រទេសចំនួន ៤៩៧ករណី។ បានទទួលរបាយការណ៍ស្តីពីស្ថានភាពកុមារដែលជាកូនសុំសរុបចំនួន ៩៤ករណី បានតាមដានត្រួតពិនិត្យ វាយតម្លៃទីភ្នាក់ងារសុំកូនអន្តរប្រទេសចំនួន ២ភ្នាក់ងារ និងបានកំណត់កុមារជាកម្មវត្ថុសុំកូនអន្តរប្រទេសចំនួន ៥នាក់។

### គ.កូនតាមម្តាយក្នុងពន្ធនាគារ

៦៤. ក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ជូនដល់ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះចំនួន ៦៥នាក់ និងកូនអាយុក្រោម ២ឆ្នាំថ្មី (កូនតាមម្តាយក្នុងពន្ធនាគារ) ចំនួន ៨៨នាក់ ដោយចំណាយថវិកាសរុប ៤១ ៦៤០ ០០០រៀល ស្មើនឹង ១០ ៤១០ដុល្លារអាម៉េរិក។ គណកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) តែងតែផ្តល់អាទិភាពខ្ពស់ចំពោះកុមារដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារ ដោយបានសម្របសម្រួលបញ្ជូនកុមារតាមម្តាយទាំងនោះយកទៅស្នាក់នៅក្នុងទីកន្លែងសមរម្យដូចជាអង្គការការអភិវឌ្ឍកុមារកម្ពុជា និងសមាគមស្នាមញញឹមថ្មីនៃក្តីសង្ឃឹមរបស់កុមារ ដើម្បីឱ្យពួកគេមានឱកាសទទួលបានសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ខ្លួនដូចកុមារដទៃទៀត ជាពិសេស សិទ្ធិទទួលបានការថែទាំសុខភាព និងការអប់រំ។ ជាងនេះទៀត គ.ស.ម.ក. ក៏តែងតែបានគិតគូរពីចំណងទំនាក់ទំនង និងក្តីស្រឡាញ់រវាងម្តាយ និងកូន ដោយបានសម្របសម្រួលយកកុមារទាំងនោះ ពីអង្គការទៅជួបជុំជាមួយម្តាយនៅក្នុងឱកាសបុណ្យប្រពៃណីជាតិខ្មែរ និងទិវាអន្តរជាតនានា។

## ៣.៤. បទដ្ឋាននៃការរស់នៅ

### ក. ទឹកស្អាត និងអនាម័យ

៦៥. ទឹកស្អាត និងអនាម័យត្រូវបានចាត់ទុកថា មានចំណងទាក់ទងយ៉ាងរឹងមាំជាមួយអាហារូបត្ថម្ភ។ បញ្ហាកង្វះអាហារូបត្ថម្ភ និងភាពគ្រិនក្រេះ បានបង្កឡើងដោយសារបញ្ហាអនាម័យនៅមានកម្រិតទាប និងការប្រើប្រាស់ទឹកមិនស្អាត។ នៅទូទាំងប្រទេសកម្ពុជា ក្នុងឆ្នាំ២០២១ មានគ្រួសារប្រមាណ ៨៧% (ទីប្រជុំជន ៩១.៦% ទីជនបទ ៨២.៧%) មានលទ្ធភាពប្រើប្រាស់ប្រភពទឹកដែលបានកែលម្អ។[5] សេចក្តីប្រកាសថ្នាក់ជាតិ ស្តីពីស្តង់ដាគុណភាពទឹកទទួលទាន និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ត្រូវបានរៀបចំឡើងដាក់ឱ្យប្រើប្រាស់ ហើយស្ថានីយប្រព្រឹត្តិកម្មទឹកស្អាតមួយចំនួនត្រូវបានកែលម្អ និងបើកឱ្យដំណើរការដើម្បីលើកកម្ពស់គុណភាពទឹកស្អាត និងពង្រីកវិសាលភាពឱ្យបានកាន់តែទូលំទូលាយ ដល់អ្នកប្រើប្រាស់នៅទូទាំងប្រទេស។

៦៦. រាជរដ្ឋាភិបាលអាណត្តិទី៧ បានគិតគូរដល់ការពង្រឹងសមត្ថភាពផលិត និងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅគ្រប់តំបន់ទីប្រជុំជន រហូតដល់ទីជនបទដទៃទៀត សម្រាប់ការប្រើប្រាស់ទូទៅដល់សាធារណជន ដោយពង្រឹង និងធានាប្រសិទ្ធភាពនៃការផលិត ការចែកចាយ និងការធ្វើអាជីវកម្មប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជនទូទាំងប្រទេសមានប្រតិបត្តិករផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ដែលទទួលបានអាជ្ញាបណ្ណសរុបចំនួន ៤៦០អាជ្ញាបណ្ណ ដែលក្នុងនោះមាន

[5] របាយការណ៍អង្កេតសេដ្ឋកិច្ចកម្ពុជា ២០២១ ទំព័រ៤៣

រដ្ឋាករទឹកសាធារណៈចំនួន ១១ (មាន ១៤អាជ្ញាបណ្ណ) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនមានចំនួនសរុប ៤៤៦អាជ្ញាបណ្ណ។[6]

៦៧. ក្នុងឆ្នាំ២០២៥ ការផលិត និងផ្គត់ផ្គង់ទឹកស្អាតសរុបចំនួនប្រមាណ ៥៥៦ លានម៉ែត្រគូប មានកំណើនប្រមាណ ២៦ លានម៉ែត្រគូប ស្មើនឹង ៤,៩% ធៀបនឹងឆ្នាំ២០២៤ ដែលមានចំនួនប្រមាណ ៥៣០ លានម៉ែត្រគូប។ រដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនបានភ្ជាប់តំណជូនអតិថិជនសរុបចំនួន ១ ៥៧១ ៩៧៦ តំណ មានកំណើនឡើង ១៣១ ០៦៣ តំណ ស្មើនឹង ៩,១% ប្រៀបធៀបនឹងឆ្នាំ២០២៤ ដែលមានចំនួន ១ ៤៤០ ៩១៣ តំណ។

៦៨. គិតត្រឹមចុងឆ្នាំ២០២៥ ភូមិដាក់បណ្តាញទឹកស្អាតសរុបមានចំនួន ៧ ៩៨៩ ភូមិ នៃចំនួនភូមិសរុបដែលមានក្នុងតំបន់សេវាកម្មចំនួន ១០ ៧៩៤ ភូមិ ក្នុងនោះរដ្ឋាករទឹកសាធារណៈបានដាក់បណ្តាញក្នុងភូមិសរុបចំនួន ១ ៥០៩ ភូមិ នៃចំនួនភូមិសរុបក្នុងតំបន់សេវាកម្មចំនួន ១ ៩៧១ ភូមិ។ ចំណែកប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនបានដាក់បណ្តាញក្នុងភូមិចំនួន ៦ ៤៨៩ ភូមិ នៃចំនួនភូមិសរុបក្នុងតំបន់សេវាកម្មចំនួន ៨ ៨២៣ ភូមិ។[7]

៦៩. គិតត្រឹមឆ្នាំ២០២៥ លទ្ធផលសម្រេចបានលើសេវាផ្គត់ផ្គង់ទឹកស្អាតកម្រិតមូលដ្ឋាន នៅតំបន់ជនបទប្រមាណ ៨៩% កើនឡើង ២% ធៀបនឹងឆ្នាំ២០២៤ និងការផ្គត់ផ្គង់ទឹកប្រកបដោយសុវត្ថិភាពនៅតំបន់ជនបទប្រមាណ ២៥% កើនឡើង ៤% ធៀបនឹងឆ្នាំ២០២៤ និងការផ្តល់សេវាអនាម័យជនបទកម្រិតមូលដ្ឋានប្រមាណ ៩៥% កើនឡើង ៣% ធៀបនឹងឆ្នាំ២០២៤ និងការគ្រប់គ្រងអនាម័យជនបទប្រកបដោយសុវត្ថិភាពប្រមាណ ៥១%។ ដោយឡែក នៅក្នុងឆ្នាំ២០២៥ នេះ កម្ពុជាសម្រេចបាននូវការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (ODF) ១០០% នៅទូទាំងប្រទេស។ ក្រសួងអភិវឌ្ឍន៍ជនបទបានប្តេជ្ញាអនុវត្តផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកឱ្យសម្រេចបានគោលដៅអត្រាគ្របដណ្តប់ចំនួន ១០០% ត្រឹមឆ្នាំ ២០៣០ លើការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ។[8]

## ខ. បង្គន់អនាម័យ

៧០. ចំពោះការលើកកម្ពស់ការរស់នៅស្អាត និងអនាម័យ ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបានគោលដៅធំ ដោយនៅក្នុងឆ្នាំ២០២៥ នេះ ប្រទេសកម្ពុជាបានសម្រេចការបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល (ODF) ១០០% នៅទូទាំងប្រទេស ដែលគ្របដណ្តប់រាជធានី-ខេត្តទាំង២៥, ស្រុក-ក្រុងចំនួន ២១០ និងឃុំ-សង្កាត់ចំនួន ១ ៦៦២។ លើសពីនេះ រាជធានីភ្នំពេញ និងខេត្តកណ្តាល បានសម្រេចការបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលកម្រិតខ្ពស់ (ODF Plus)។ ក្រសួងក៏បានជម្រុញការអប់រំប្រជាពលរដ្ឋ និងគាំទ្រដល់ការសាងសង់បង្គន់អនាម័យគ្រួសារបានចំនួនសរុប ៣ ៣០៨ ៣៨០ បង្គន់ និងបង្គន់សាធារណៈចំនួន ១០ ៥៤៣ បង្គន់។[9]

[6] របាយការណ៍លទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

[7] របាយការណ៍លទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

[8] របាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

[9] របាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

### គ. វឌ្ឍនភាពការតភ្ជាប់បណ្តាញអគ្គិសនីតាមភូមិ និងការតភ្ជាប់ចរន្តអគ្គិសនីតាមខ្នងផ្ទះ

៧១. ការអភិវឌ្ឍបណ្តាញចែកចាយថាមពលអគ្គិសនីទាំងរដ្ឋ និងឯកជន នៅក្នុងប្រទេសកម្ពុជា តាមរយៈខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនីដល់រាជធានី-ខេត្ត ទាំង២៥ ភូមិដែលមានអគ្គិសនីប្រើប្រាស់ មានការកើនឡើងពី ២៤.១៦% នៅឆ្នាំ២០០៩ ដល់ ៩៩.០៩% នៅឆ្នាំ២០២៥។ ចំពោះការតភ្ជាប់ថាមពលអគ្គិសនីតាមខ្នងផ្ទះក៏មានការកើនឡើងពី ១៨.៧៩% នៅឆ្នាំ២០០៩ ដល់ ៩៥.៨៨% នៅឆ្នាំ២០២៥។




សម្គាល់៖ ភាគរយមានការប្រែប្រួលរវាងឆ្នាំ២០២៤ និង២០២៥ ដោយចំនួនភូមិសរុបមានការកើនឡើង



# ៤. ការអភិវឌ្ឍកុមារ



៤.១. ការអប់រំ
៤.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ

## ៤. ការអភិវឌ្ឍកុមារ[10]

### ៤.១. ការអប់រំ[11]

៧២. ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ ដែលជាឆ្នាំទីពីរនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ វិស័យអប់រំ យុវជន និងកីឡា បានសម្រេចសមិទ្ធផលធំៗ គួរឱ្យកត់សម្គាល់ រួមមាន៖ កំណើននៃការចូលរៀននៅគ្រប់ភូមិសិក្សា ជាពិសេសការអប់រំមូលដ្ឋាន ៩ឆ្នាំ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងបរិយាបន្ន តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ ការបង្កើនចំនួនសិស្សទទួលបានអាហារូបករណ៍ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាប្រចាំ ការអប់រំឌីជីថល ការពង្រឹងអភិបាលកិច្ចសាលារៀន និងការចូលរួមយ៉ាងសកម្មពីសហគមន៍ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលជាកត្តាអំណោយផលល្អសម្រាប់ការសិក្សារបស់សិស្សានុសិស្ស។

៧៣. ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់សូចនាករសមិទ្ធផលគន្លឹះ សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ រួមមាន ១.លទ្ធផលនៃកម្មវិធីវង្វាយតម្លៃសិស្សជាអន្តរជាតិ (PISA) ២.អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ និង ៣.អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូម និងទុតិយភូមិ។

| ល.រ | សូចនាករ<br>យុទ្ធសាស្ត្របញ្ចកោណ | ឯកតា | ជាក់ស្តែង<br>២០២៤ | ចំណុចដៅ<br>២០២៥ | ជាក់ស្តែង<br>២០២៥ | ស្ថានភាព |
|---|---|---|---|---|---|---|
| ១ | **លទ្ធផលនៃកម្មវិធីវាយតម្លៃសិស្សអន្តរជាតិ (PISA)** | | | | | |
| ១.១ | ពិន្ទុមធ្យម នៃមុខវិជ្ជាអំណាន | ពិន្ទុ | - | ៣៣៩ | ចុងឆ្នាំ២០២៦ | - |
| ១.២ | ពិន្ទុមធ្យម នៃមុខវិជ្ជាគណិតវិទ្យា | ពិន្ទុ | - | ៣៤៦ | ចុងឆ្នាំ២០២៦ | - |
| ១.៣ | ពិន្ទុមធ្យម នៃមុខវិជ្ជាវិទ្យាសាស្ត្រ | ពិន្ទុ | - | ៣៥៧ | ចុងឆ្នាំ២០២៦ | - |
| ២ | **អត្រារួមនៃការសិក្សា** | | | | | |
| ២.១ | មធ្យមសិក្សាបឋមភូមិ | % | ៧៥,២ | ៧៦,៧ | ៧៩,០* | ⬆ |
| ២.២ | មធ្យមសិក្សាទុតិយភូមិ | % | ៤៤,៣ | ៤៥,៦ | ៤៦,៦* | ⬆ |
| ៣ | **អត្រាបោះបង់ការសិក្សា** | | | | | |
| ៣.១ | មធ្យមសិក្សាបឋមភូមិ | % | ១៥,៥ | ១៥,០ | ១៤,១** | ⬆ |
| ៣.២ | មធ្យមសិក្សាទុតិយភូមិ | % | ១៣,៧ | ១៣,២ | ១១,២** | ⬆ |

សម្គាល់៖ ⬆ សម្រេចបានតាមចំណុចដៅ ➡ អាចទទួលយកបាន ⬇ សម្រេចមិនបានតាមចំណុចដៅ

*ឆ្នាំសិក្សា ២០២៥-២០២៦ **ឆ្នាំសិក្សា ២០២៥-២០២៦

#### ក. ធនធានមនុស្សផ្នែកអប់រំ

៧៤. ក្នុងឆ្នាំ២០២៥ ក្រសួងអប់រំ យុវជន និងកីឡាមានបុគ្គលិកសរុបចំនួន ១២៥ ២០៨នាក់ ស្រី ៦០ ៣៥៦នាក់ ក្នុងនោះនៅថ្នាក់ជាតិចំនួន ៥ ២៤៨នាក់ ស្រី ១ ៨៣៩នាក់ និងថ្នាក់ក្រោមជាតិចំនួន ១១៩ ៩៦០នាក់ ស្រី ៥៨ ៥១៧នាក់។

---

[10] កុមារត្រូវទទួលបាននូវការសិក្សារៀនសូត្រគ្រប់ប្រភេទ គឺការសិក្សានៅសាលារៀន និងនៅតាមផ្ទះ ឬសហគមន៍ ដូចជាទទួលការអប់រំ និងផ្តល់ដំបូន្មានល្អៗស្តីពីការរស់នៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែបំប៉នសុខភាព។ល។

[11] សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅឆ្នាំសិក្សា២០២៤-២០២៥

៧៥. បុគ្គលិកអប់រំនៅតាមកម្រិតសិក្សាមានចំនួនដូចតទៅ៖ បុគ្គលិកមត្តេយ្យសិក្សាមានចំនួន ១៦ ៩៨៤នាក់ (ស្រី ១៥ ៨៥២នាក់) ក្នុងនោះបុគ្គលិករដ្ឋមាន ៥ ៣២៦នាក់ ឯកជន ៧ ៩៤១នាក់ និងសហគមន៍ ៣ ៧១៧ នាក់។ បុគ្គលិកអប់រំបឋមសិក្សារដ្ឋមាន ៦០ ៦៥៩នាក់ (ស្រី ៣៣ ៩៨៦នាក់) និងបុគ្គលិកឯកជន ១៤ ៣៩១នាក់ (ស្រី ៧ ០៩៣នាក់)។ ចំណែកបុគ្គលិកអប់រំមធ្យមសិក្សាមាន ៥២ ៨៣៥នាក់ (ស្រី ២១ ៦៩៣ នាក់) រីឯបុគ្គលិកបម្រើការងារនៅតាមគ្រឹះស្ថានឧត្តមសិក្សាមាន ២០ ៧១៩នាក់ (ស្រី ៤ ៨៩៨នាក់)។

៧៦. ក្រសួងបានបន្តសិក្សាលើស្ថានភាពពង្រាយគ្រូបង្រៀន និងបានប្រើប្រាស់គ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ ដើម្បីដោះស្រាយបញ្ហាកង្វះគ្រូ ជាពិសេសនៅតំបន់ជួបការលំបាក។ ជាមួយគ្នានេះ ក្រសួងនៅតែបន្តការពង្រឹង និងពង្រីកប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) ដោយបានជួយគាំទ្រសាលាគរុកោសល្យដែលមានសក្តានុពលឱ្យក្លាយជាអ្នកផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈនេះ។

៧៧. សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលបែបចម្រុះដែលមានការទទួលស្គាល់គុណភាពដោយក្រសួងអប់រំ យុវជន និងកីឡាជាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនបឋមសិក្សារួមមាន៖ (១).ការអភិវឌ្ឍនិងការរៀនសូត្ររបស់កុមារកម្រិតបឋម (២).ការប្រើប្រាស់ ICT សម្រាប់ការបង្រៀន និងរៀន (៣).គរុកោសល្យ និងវិធីសាស្រ្តក្នុងការអប់រំវិទ្យាសាស្រ្តកម្រិតបឋម (៤).កម្មវិធីសិក្សា ការវិភាគកម្មវិធីសិក្សានិងស្តង់ដាសមិទ្ធកម្មសិក្សានៅបឋមសិក្សា (៥).ប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀន (៦).ការអនុវត្តវិធីសាស្រ្តបង្រៀនដោយបញ្ចូលការអប់រំភាពជាពលរដ្ឋសាកល(GCED) ដើម្បីសិស្សមានសីលធម៌ល្អ (៧).ការវាយតម្លៃការសិក្សាកម្រិតបឋមសិក្សា (៨).អប់រំកាយ និងសុខភាពសិក្សា (៩).អន្តរកម្មវាងព័ត៌មានវិទ្យាលើការបង្រៀន និងរៀន (១០).វិធីសាស្រ្តបង្រៀនភាសាអង់គ្លេសគ្រូបឋមសិក្សា (១១).ផលប៉ះពាល់នៃបទពិសោធគ្រោតគ្រាត និងរបួសផ្លូវចិត្តពីកុមារភាពលើការលូតលាស់ខួរក្បាលកុមារ និងអាកប្បកិរិយា (១២).ប្រព័ន្ធគាំទ្រពហុកម្រិតដល់សិស្សដែលមានកម្រិតនៃការរៀនផ្សេងៗគ្នា និងរៀនយឺតក្នុងថ្នាក់ (១៣).ការអប់រំពហុភាសា (១៤).ចំណេះដឹងមូលដ្ឋានក្នុងការគាំទ្រសិស្សមានពិការភាព និង**អភិវឌ្ឍម៉ូឌុលសារមេរៀនថ្មីៗបន្ថែមចំនួន ៦ប្រធានបទ** រួមមាន៖ ១)បំណិនសតវត្សរ៍ទី២១ ២)ការប្រែប្រួលអាកាសធាតុ ៣)ការអប់រំបរិយាបន្នឆ្លើយតបយេនឌ័រនិងពិការភាព ៤)បំណិន ICT ៥)វិធីសាស្រ្តបង្រៀនបែបសកម្ម និង ៦)ការស្រាវជ្រាវប្រតិបត្តិ។ លើសពីនេះ ក្រសួងក៏**បានរៀបចំសន្និសីទគ្រូបង្រៀនថ្នាក់ជាតិឆ្នាំ២០២៥** ដោយផ្តោតលើប្រធានបទ "គ្រូបង្រៀនជាបេះដូងនៃកំណែទម្រង់វិស័យអប់រំ ការស្រាវជ្រាវ គោលនយោបាយ និងការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងបញ្ញាសិប្បនិម្មិតប្រកបដោយក្រមសីលធម៌"។

### ខ. ការអប់រំកុមារតូច

៧៨. សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមានចំនួន ៩ ២០៧ សាលា/កន្លែង កើនចំនួន ១៧១ សាលា/កន្លែង។ ក្នុងនោះសាលាមត្តេយ្យសិក្សាសាធារណៈមានចំនួន ៤ ៧៦៧ កើនចំនួន ៤២ សាលា (ក្នុងនោះថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សាមាន ៤ ៣៥៤ កើន ៩)។ សាលាឯកជនមានកម្រិតមត្តេយ្យសិក្សាចំនួន ១ ០២២ សាលា/កន្លែង កើន ៥៩ សាលា។ សាលាមត្តេយ្យសិក្សាសហគមន៍មានចំនួន ៣ ៤១៨ កន្លែង កើនចំនួន ៧០ កន្លែង និងទារកដ្ឋាននៅតាមសហគមន៍ចំនួន ១៣កន្លែង និងទារកដ្ឋានរោងចក្រ សហគ្រាសមាន ២កន្លែង[12]។

[12] ចំនួនទារកដ្ឋានផ្តល់ដោយនាយកដ្ឋានការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៧៩. ថ្នាក់រៀនមត្តេយ្យសិក្សាគ្រប់រូបភាពមានចំនួន ១៧ ០២៣ ថ្នាក់ កើន ១ ០៩៣ ថ្នាក់។ ថ្នាក់មត្តេយ្យសិក្សារដ្ឋមានចំនួន ៨ ៥៣១ ថ្នាក់ កើន ៧៤ ថ្នាក់។ ថ្នាក់មត្តេយ្យសិក្សាឯកជនមាន ៤ ១២៦ ថ្នាក់ កើន ២១០ ថ្នាក់។ ថ្នាក់មត្តេយ្យសិក្សាសហគមន៍មានចំនួន ៤ ៣៦៦ ថ្នាក់ កើន ៨០៩ ថ្នាក់ (ក្នុងនោះមត្តេយ្យសិក្សាសហគមន៍មានលក្ខណៈស្តង់ដាទទួលបានថវិកាឧបត្ថម្ភមាន ១ ៤៣៨ ថ្នាក់)។

៨០. កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាពមានចំនួន ៤៤០ ៩៩១ នាក់ កើន ១៤ ២៩៩ នាក់ ស្រីចំនួន ២១៩ ៣៣៩ នាក់ កើន ៦ ៨៤៧ នាក់។ កុមារអាយុ ៣ឆ្នាំមានចំនួន ៥៤ ៧០១ នាក់ ថយ ១ ៧៨៦ នាក់ ស្រីចំនួន ២៨ ១២០ នាក់ ថយ ៨៩២ នាក់។ កុមារអាយុ ៤ឆ្នាំមានចំនួន ១៣៧ ៩៤៣ នាក់ ថយ ៩២៥ នាក់ ស្រីចំនួន ៦៩ ៤៧១ នាក់ ថយ ២៣៩ នាក់។ កុមារអាយុ ៥ឆ្នាំមានចំនួន ២៤៨ ៣៤៧ នាក់ កើនចំនួន ១៨ ២៣៣ នាក់ ស្រីចំនួន ១២១ ៧៤៨ នាក់ កើនចំនួន ៨ ៥៥៧ នាក់។

៨១. ការពង្រឹងអភិបាលកិច្ចសាលាមត្តេយ្យសិក្សាបាននាំមកនូវការកែលម្អ និងការពង្រឹងគុណភាពការផ្តល់សេវាអប់រំកុមារតូច ដែលចូលរួមចំណែកដល់ការលើកកម្ពស់ការគាំពារ និងអភិវឌ្ឍកុមារតូចគ្រប់រូបភាព ប្រកបដោយសមធម៌ បរិយាបន្ន និងបណ្តុះកុមារតូចនូវបំណិនសង្គម និងបំណិនចំណេះដឹង ដើម្បីត្រៀមខ្លួនសម្រាប់ការចូលរៀននៅបឋមសិក្សា។ ម៉្យាងវិញទៀត ប្រជាជនកម្ពុជា និងអាជ្ញាធរថ្នាក់ក្រោមជាតិមានការយល់ដឹងពីសារសំខាន់សេវាអប់រំកុមារតូច ជាពិសេស បានចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍។

៨២. អត្រាចុះឈ្មោះចូលរៀនរបស់កុមារទទួលបានសេវាអប់រំគ្រប់រូបភាពមាន៖ កុមារអាយុ ៥ឆ្នាំ ៧៧,៩% កើន ៦,៥% ស្រី ៧៨,៣% កើន ៦,៣%។ កុមារអាយុ ៤ឆ្នាំ ៤២,៦% ថយ ០,៥% ស្រី ៤៣,៩% ថយ ០,៤%។ កុមារអាយុ ៣ឆ្នាំ ១៦,៥% ថយ ០,២% ស្រី ១៧,៣% ថយ ០,៣%។

៨៣. ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីការអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច (ទំពួន គ្រឹង ព្នង កួយ ក្រោល កាវ៉ែត ព្រៅ ចារ៉ាយ និងកាចក់) នៅ ២១ក្រុង ស្រុក ក្នុងខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ក្រចេះ និងព្រះវិហារ ដែលមានសាលាមត្តេយ្យសិក្សារដ្ឋ ៤កន្លែង មានកុមារ ១៤២នាក់ (ស្រី ៧៧នាក់) និងមត្តេយ្យសិក្សាសហគមន៍ ១៧៨ កន្លែង កើន ២៤ កន្លែង មានកុមារ ៣ ៤២៦ នាក់ (ស្រី ១ ៧៩៧ នាក់)។

៨៤. ក្រសួងបានអនុវត្តកម្មវិធីការអប់រំបរិយាបន្នសម្រាប់សាលាមត្តេយ្យសិក្សាសាធារណៈ ដោយមានកុមារមានពិការភាពចំនួន ៧២០ នាក់ ស្រីចំនួន ២៨៦ នាក់ និងមត្តេយ្យសិក្សាសហគមន៍ចំនួន ៣៨១កន្លែង កុមារមានពិការភាពចំនួន ២៣២នាក់ ស្រីចំនួន ៩១នាក់ នៅខេត្តសៀមរាប កំពង់ធំ រតនគិរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ឧត្តរមានជ័យ ព្រៃវែង ព្រះសីហនុ និងរាជធានីភ្នំពេញ។ ក្រសួងក៏បានបំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាស្តីពីការអប់រំបរិយាបន្ន និងផែនការជួយជាបុគ្គលសម្រាប់កុមារ ដែលមានតម្រូវការពិសេស ព្រមទាំងចុះពិនិត្យតាមដានការអនុវត្តគំរូល្បែងបរិយាបន្ន ដោយសហការជាមួយដៃគូអភិវឌ្ឍ។

៨៥. ក្រសួងបានគាំទ្រសាលាមត្តេយ្យសិក្សាឱ្យមានស្តង់ដាទឹកស្អាតកម្រិត៣ ចំនួន ៤៦សាលា និងបង្គន់អនាម័យ ៤១៣សាលា (ស្មើ ១០០%) ព្រមទាំងផ្តល់ប្រអប់សង្គ្រោះបឋម និងផ្តល់ថ្នាំទម្លាក់ដង្កូវព្រូនដល់កុមារ។ ទន្ទឹមនឹងនេះ ក្រសួងក៏បានអនុវត្តសាកល្បងកម្មវិធីផ្តល់អាហារតាមសាលារៀនដល់កុមារមត្តេយ្យសិក្សាចំនួន ១០៣សាលា (ស្មើ ២៤,៨%) ដែលមានកុមារចូលរួម ១៤ ១៦២ នាក់ ស្រី ៩ ៥១៣ នាក់។

៨៦. ការអនុវត្តកម្មវិធី និងសកម្មភាពនានាទទួលបានការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធ។ ប្រការនេះបានបង្ហាញនូវវឌ្ឍនភាព នៃការវិនិយោគលើការអប់រំកុមារតូចបែបពហុវិស័យ ប្រកបដោយភាពប្រទាក់ក្រឡាគ្រប់ទិដ្ឋភាព ដើម្បីធានាដល់ការអភិវឌ្ឍមូលធនមនុស្សតាំងពីវ័យកុមារ។

### គ. ការអប់រំបឋមសិក្សា

៨៧. សាលាបឋមសិក្សាសរុបមានចំនួន ៨ ២៤៨។ សាលាបឋមសិក្សារដ្ឋមានចំនួន ៧ ៣២១ ក្នុងនោះសាលាបឋមសិក្សាមិនគ្រប់កម្រិតមានចំនួន ២៤៧។ សាលារៀនឯកជនកម្រិតបឋមសិក្សាមានចំនួន ៩២៧ កើនចំនួន ៣៧។

៨៨. សិស្សបឋមសិក្សាសរុបមានចំនួន ២ ២៥៦ ១៦៣នាក់ ថយ ៥ ០៥៣នាក់ ស្រីចំនួន ១ ០៨៥ ៤០៣នាក់ ថយ ៤៧៧នាក់ ធៀបទៅនឹងឆ្នាំសិក្សាមុន។ សិស្សបឋមសិក្សាសាធារណៈចំនួន ២ ០៦២ ៦៩៨នាក់ ថយ ១៥ ៧០៣នាក់ ស្រីចំនួន ៩៩០ ៩១១នាក់ ថយ ៦ ០៩២នាក់។ សិស្សបឋមសិក្សាឯកជនចំនួន ១៩៣ ៤៦៥នាក់ កើន ១០ ៦៥០នាក់ ស្រីចំនួន ៩៤ ៤៩២នាក់ កើន ៥ ៦១៥នាក់។

៨៩. អត្រាពិតចូលរៀនថ្មីនៅបឋមសិក្សា ៩៦% ថយ ១,២% ប្រុស ៩៦,៥% ថយ ១,៤% និងស្រី ៩៥,៤% ថយ ១,១%។ អត្រាពិតនៃការសិក្សាបឋមសិក្សា ១០១,៦% (ថយ ០,៧%) ប្រុស ១០២,៣% (ថយ ០,៨%) ស្រី ១០១,០% (ថយ ០,៥%)។ អត្រារួមនៃការសិក្សា ១១៩,១% ថយ ៥,៥% ប្រុស ១២០,៩% ថយ ៥,៩% ស្រី ១១៧,១% ថយ ៥,៣%។ អត្រាបញ្ចប់ការសិក្សា ១០៤,៣% កើន ២,៨% ប្រុស ១០០,៧% កើន ១,៧% ស្រី ១០៧,៩% កើន ៣,៨%។ អត្រាគង់វង្សនៅបឋមសិក្សា ៨៣,៥% ថយ ១% ប្រុស ៧៩,១% ថយ ០,៥% ស្រី ៨៨,៤% ថយ ១,៤% ទោះបីជាមានការថយចុះធៀបនឹងឆ្នាំមុន ក៏នៅតែមានកម្រិតខ្ពស់លើសពីចំណុចដៅរំពឹងទុក។

៩០. អត្រាត្រួតថ្នាក់ ៥,១% ថយ ០,៣% ប្រុស ៦,៥% ថយ ០,៤% ស្រី ៣,៥% ថយ ០,៤%។ អត្រាបោះបង់ការសិក្សា ៤,៤% កើន ០,៣% ប្រុស ៥,៣% កើន ០,១% ស្រី ៣,៤% កើន ០,៥%។

៩១. ក្រសួងបានផ្តល់មូលនិធិគាំទ្រដំណើរការសាលារៀនសាធារណៈ ដោយផ្អែកលើទីតាំងតំបន់ និងចំនួនសិស្ស។ កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើកសិផលសហគមន៍បានអនុវត្តកើនដល់ចំនួន ១ ១១៤សាលា ក្នុងខេត្ត ១០ មានសិស្សទទួលផល ៣០៧ ៥៥៩នាក់ ស្រី ១៤៩ ៨៤៧នាក់។ កម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក បានអនុវត្តដល់សិស្សសរុបកើនដល់ ៤០៣ ១៦៩នាក់ ស្រី ២០០ ៩០១នាក់ នៅ ៧ ៣៩៨ សាលា គ្រប់រាជធានី ខេត្ត។

៩២. រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានយកចិត្តទុកដាក់ក្នុងការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដើម្បីបង្កើនការចូលរៀន និងការលើកកម្ពស់អាហារូបត្ថម្ភឈានទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ទន្ទឹមនេះ ក្រសួងក៏បានបង្កើនសាលារៀនជំនាន់ថ្មីបឋមសិក្សា តាមរយៈការផ្តល់នូវវិញ្ញាបនបត្រសាលារៀនជំនាន់ថ្មី ដែលបច្ចុប្បន្នមាន ៤សាលា មានសិស្ស ២ ៤៧២នាក់ (ស្រី ១ ១២៦នាក់)។ ក្នុងនោះក្រសួងក៏បានបង្កើនម៉ោងសិក្សា មុខវិជ្ជាសិក្សា និងជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យប្រកបដោយគុណភាព។ ពង្រឹងវិធីសាស្ត្របង្រៀននិងរៀន និងសម្ភារឧបទេសតាមរយៈការសិក្សាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង ដែលមានវិធីសាស្ត្រថ្មីៗ។

៩៣. ក្រសួងអប់រំ យុវជន និងកីឡា បានពង្រឹងកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារជនជាតិដើមភាគតិច និងកុមារមានពិការភាព។ សម្រាប់អប់រំបរិយាបន្ននៅសាលាបឋមសិក្សា មានកុមារមានពិការភាពចំនួន ១៩ ៦៦២នាក់ (ស្រី ៧ ៩៨៣នាក់) ត្រូវបានបញ្ចូលឱ្យរៀននៅសាលារៀនទូទៅ។ កម្មវិធីអប់រំពហុភាសាអនុវត្តនៅ ៩៦សាលា ១៨ស្រុក មានគ្រូ ២៣៥នាក់ (ស្រី ៩៤នាក់) និងសិស្ស ៤ ០៨៥នាក់ (ស្រី ១ ៩០៤នាក់ ថយចុះ ១៧៦នាក់) នៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង។ កម្មវិធីអប់រំកុមារមានពិការភាព និងការពន្លឿនការសិក្សា បានផ្តល់ឱកាសកាន់តែប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។

## ឃ. ការអប់រំមធ្យមសិក្សា

៩៤. គ្រឹះស្ថានមធ្យមសិក្សាសាធារណៈមាន ១ ៨៣១ កើន ៦ ក្នុងនោះអនុវិទ្យាល័យ ១ ២៤០ ថយ ៤ និងវិទ្យាល័យ ៥៩១ កើន ១០ (វិទ្យាល័យធនធាន ៦៧ និងវិទ្យាល័យអប់រំពិសេស ៦)។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី ៧ ដល់ថ្នាក់ទី១២ មាន ៥៥៧ កើន ១១ និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន ៣៤ ថយ ១។

៩៥. គ្រឹះស្ថានមធ្យមសិក្សាឯកជនមាន ៤៨៦ កើន ៤៤ ក្នុងនោះអនុវិទ្យាល័យ ១២០ កើន ៦ និងវិទ្យាល័យ ៣៦៦ កើន៣៨។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ថ្នាក់ទី១២ មាន ៣៥៩ កើន ៣៧ និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន៧ កើន ១។

៩៦. សិស្សមធ្យមសិក្សាបឋមភូមិមាន ៧២៨ ៥៣៣នាក់ កើន ១៦ ២៣៥នាក់ ស្រី ៣៧៩ ៥៦៩នាក់ កើន ៨ ៣៨១នាក់។ សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋ ៦៦៧ ០០៥នាក់ កើន ៥ ៤៩៧នាក់ ស្រី ៣៤៨ ៣៧៨នាក់ កើន ៣ ៤៧២នាក់។ សិស្សមធ្យមសិក្សាបឋមភូមិឯកជន ៦១ ៥២៨នាក់ កើន ១០ ៧៣៨នាក់ ស្រី ៣១ ១៩១នាក់ កើន ៤ ៩០៩នាក់។

**ស្ថិតិមធ្យមសិក្សាចំណោះទូទៅសាធារណៈ ឆ្នាំសិក្សា ២០២៤-២០២៥ និង២០២៥-២០២៦**

| បរិយាយ | ឆ្នាំសិក្សា | | កើន/ថយ (+/-) |
|---|---|---|---|
| | ២០២៤-២០២៥ | ២០២៥-២០២៦ | |
| សាលារៀន | ១ ៨២៥ | ១ ៨៣១ | +៦ |
| បន្ទប់រៀន | ២១ ៦២០ | ២១ ៨៦១ | +២៤១ |
| ថ្នាក់រៀន | ២៣ ០៦៣ | ២៣ ៦២៥ | +៥៦២ |
| បុគ្គលិកសរុប | ៥២ ៣០០ | ៥២ ៨៣៥ | +៥៣៥ |
| បុគ្គលិកស្រី | ២១ ៣៧០ | ២១ ៦៩៣ | +៣២៣ |
| បុគ្គលិកមិនបង្រៀនសរុប | ៨ ០០៧ | ៨ ១២៩ | +១២២ |
| បុគ្គលិកមិនបង្រៀនស្រី | ២ ២២២ | ២ ២៨០ | +៥៨ |
| បុគ្គលិកបង្រៀនសរុប | ៤៤ ២៩៣ | ៤៤ ៧០៦ | +៤១៣ |
| បុគ្គលិកបង្រៀនស្រី | ១៩ ១៤៨ | ១៩ ៤១៣ | +២៦៥ |
| សិស្សមធ្យមសិក្សាសរុប | ១ ០៧៤ ៨៦០ | ១ ០៧៨ ៧៩៣ | +៣ ៩៣៣ |
| សិស្សមធ្យមសិក្សាស្រី | ៥៧៦ ៤០៣ | ៥៧៩ ៨៥០ | +៣ ៤៤៧ |

ប្រភព៖ នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

៩៧. សិស្សមធ្យមសិក្សាទុតិយភូមិសរុប ៤៥៥ ៩២១នាក់ កើន ៨៨៣នាក់ ស្រី ២៥៤ ៥១៣នាក់ កើន ៦៤៩ នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋ ៤១១ ៧៨៨នាក់ ថយ ១ ៥៦៤នាក់ ស្រី ២៣១ ៤៧២នាក់ ថយ ២៥នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិឯកជន ៤៤ ១៣៣នាក់ កើន ៦៨១នាក់ ស្រី ២៣ ០៤១នាក់ កើន ៦៧៤នាក់។

៩៨. មធ្យមសិក្សាបឋមភូមិ៖ អត្រាឆ្លងភូមិសិក្សាពីបឋមមកមធ្យមសិក្សាបឋមភូមិសម្រេចបាន ៨៨,0% កើន ១,៤%។ អត្រាត្រួតថ្នាក់មានកម្រិត ២,៦% (ប្រុស ៣,៥% ស្រី ១,៦%) ។ អត្រាបញ្ចប់ការសិក្សាសម្រេចបាន ៦៣,៦% កើន ៣,៣% ។ ចំណែកអត្រាបោះបង់ការសិក្សាបានបន្តថយចុះមកនៅត្រឹម ១៤,១%។

៩៩. មធ្យមសិក្សាទុតិយភូមិ៖ អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិសម្រេចបាន ៧៩,១% កើន 0,៣%។ អត្រាត្រួតថ្នាក់មានកម្រិតទាបត្រឹម ១,៣% ។ អត្រាបញ្ចប់ការសិក្សាសម្រេចបាន ៤១,៧% កើន ៣,២%។ ចំណែកអត្រាបោះបង់ការសិក្សាបានបន្តថយចុះមកនៅត្រឹម ១១,២%។

អត្រាលំហូរសិស្សនៅមធ្យមសិក្សារវាងឆ្នាំសិក្សា ២០២៣-២០២៤ និង ២០២៤-២០២៥

| បរិយាយ | ឆ្នាំសិក្សា | | កើន-ថយ | ឆ្នាំសិក្សា | | កើន-ថយ |
|---|---|---|---|---|---|---|
| | ២០២៣-២៤ | ២០២៤-២៥ | (+/-) | ២០២៣-២៤ | ២០២៤-២៥ | (+/-) |
| | មធ្យមសិក្សាបឋមភូមិ | | | | | |
| | សរុប | | | ស្រី | | |
| អត្រាឡើងថ្នាក់ | ៨១,៧ | ៨២,៦ | +0,៩ | ៨៤,៨ | ៨៥,៦ | +0,៨ |
| អត្រាត្រួតថ្នាក់ | ២,៨ | ២,៦ | -0,២ | ១,៧ | ១,៦ | -0,១ |
| អត្រាបោះបង់ការសិក្សា | ១៥,៥ | ១៤,៨ | -0,៧ | ១៣,៥ | ១២,៨ | -0,៧ |
| បរិយាយ | មធ្យមសិក្សាទុតិយភូមិ | | | | | |
| | សរុប | | | ស្រី | | |
| អត្រាឡើងថ្នាក់ | ៨៤,៨ | ៨៦,៦ | +១,៨ | ៨៧,៣ | ៨៩,១ | +១,៨ |
| អត្រាត្រួតថ្នាក់ | ១,៥ | ១,៣ | - 0,២ | ១,១ | ១,0 | -0,១ |
| អត្រាបោះបង់ការសិក្សា | ១៣,៧ | ១២,១ | - ១,៦ | ១១.៦ | ៩,៩ | -១,៧ |

ប្រភព៖ នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

១០០. លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ៖ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានចំនួន ១៧១ ៧១៧នាក់ ស្មើ ៩៤,៣៤% ស្រី ៩៤ ៨៥១នាក់ ស្មើ ៩៦,៥៦% ដោយមានកំណត់និទ្ទេសល្អ ល្អបង្គួរ និងមធ្យម។ បើធៀបទៅនឹងឆ្នាំ២០២៣-២០២៤ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមាន ១៧៥ ៣៩៦នាក់ ស្មើ ៩៤,៦៩% ស្រី ៩៧ ៤៥៦នាក់ ស្មើ ៩៦,២១%។

១០១. លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ៖ បេក្ខជនមកប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួន ១៤៤ ៨៣៨នាក់ ស្រី ៨០ ៦៩៦នាក់។ បេក្ខជនប្រឡងជាប់ ១២២ ៤៧៣នាក់ ស្មើ ៨៤,៥៦% ស្រី ៧០ ៩៩១នាក់ ស្មើ ៨៧,៩៧% ក្នុងនោះបេក្ខជននិទ្ទេស A ៣ 00៣នាក់ ស្រី ១ ៦៩៤នាក់, និទ្ទេស B ៩ ៩0១នាក់ ស្រី ៦ ១៩៨នាក់, និទ្ទេស C ២៨ ៨0១នាក់ ស្រី ១៨ ៥៧៨នាក់, និទ្ទេស D ៤៥ ៨៥៩នាក់ ស្រី ២៧ ១៨៩នាក់, និងនិទ្ទេស E ៣៤ ៩0៩នាក់ ស្រី ១៧ ៣៣២នាក់។

ការប្រៀបធៀបលទ្ធផលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅនិងបំពេញវិជ្ជា រវាងឆ្នាំសិក្សា២០២៣-២០២៤ និង២០២៤-២០២៥

| ភូមិសិក្សា | ឆ្នាំសិក្សា ២០២៣-២៤ | | ឆ្នាំសិក្សា ២០២៤-២៥ | | កើន-ថយ,(+/-) | | | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ភាគរយ | ស្រី | ភាគរយ |
| ម.បឋមភូមិ | ១៧៥,៣៩៦ | ៩៧ ៤៥៦ | ១៧១ ៧១៧ | ៩៤ ៨៥១ | -៣ ៦៧៩ | -២.១០ | -២ ៦០៥ | -២.៦៧ |
| ម.ទុតិយភូមិ | ១០៦,៣៥១ | ៦១,៥៣០ | ១២២,៤៧៣ | ៧០ ៩៩១ | +១៦ ១២២ | +១៥,១៦ | +៩ ៤៦១ | +១៥,៣៨ |

១០២. លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ២០២៤-២០២៥ ធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ ថយ ០.៣៥% ស្រីកើន ០.៣៥%។ រីឯលទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២០២៤-២០២៥ ធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ កើន ១៥.១៦% ស្រីកើន ១៥.៣៨%។

១០៣. លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២០២៤-២០២៥ ធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ កើន ១៥.១៦% ស្រីកើន ១៥.៣៨% ក្នុងនោះថ្នាក់វិទ្យាសាស្ត្រកើន ៧.៥៨% ស្រីកើន ៧.៦៦% និងថ្នាក់វិទ្យាសាស្ត្រសង្គមកើន ១៧.៩៥% ស្រីកើន ១៨.៤២%។

១០៤. សាលាមធ្យមវិចិត្រសិល្បៈ មានការិយាល័យចំនួន៤ និងមានសាលាជំនាញចំនួន៥ គឺ (ទី១)-សាលាតូរ្យតន្ត្រី មាន ២៤ឯកទេស (ទី២)-សាលារបាំ មាន ៣ឯកទេស (ទី៣)-សាលាល្ខោន មាន ៣ឯកទេស (ទី៤)-សាលាសៀក មាន ៧ឯកទេស និង(ទី៥)-សាលាសិល្បៈសូនរូប មាន ១០ឯកទេស។ សាលាមធ្យមវិចិត្រសិល្បៈ មានគ្រូបង្រៀនពេញម៉ោងចំនួន ២១០នាក់ (ស្រីចំនួន៦៥នាក់) គ្រូបង្រៀនក្រៅម៉ោង ចំនួន១២៣នាក់ (ស្រីចំនួន៥៣នាក់) បុគ្គលិកសិក្សាចំនួន៣២នាក់ (ស្រី១០នាក់) និងមានសិស្សានុសិស្សសរុបចំនួន៩២៨នាក់ (សិស្សស្រីចំនួន៥២៦នាក់)។

១០៥. សាលាមធ្យមវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គឺជាគ្រឹះស្ថានសិក្សាចាប់ពីកម្រិតបឋមភូមិ (ថ្នាក់ថ្នាលទី១ ឬថ្នាក់ទី៤នៃសាលាចំណេះដឹងទូទៅ) រហូតដល់កម្រិតទុតិយភូមិ (ថ្នាក់ឆ្នាំទី៦ ឬថ្នាក់ទី១២ នៃសាលាចំណេះដឹងទូទៅ) របស់រដ្ឋតែមួយគត់ ដែលមានកម្មវិធីសិក្សាផ្តោតសំខាន់លើវិស័យសិល្បៈវប្បធម៌ ក្នុងគោលបំណងអភិរក្ស ថែរក្សា បណ្តុះបណ្តាល និងផ្ទេរចំណេះជំនាញ ក៏ដូចជាបទពិសោធន៍លើវិស័យសិល្បៈ ទស្សនីយភាព និងសិល្បៈសូនរូបទាំងទម្រង់បុរាណនិងសម័យ ប្រកបដោយគុណភាពដល់ក្មេងជំនាន់ក្រោយ។ សិស្សានុសិស្ស ដែលបានឆ្លងកាត់ប្រព័ន្ធសិក្សានៅសាលាមធ្យមវិចិត្រសិល្បៈនឹងក្លាយជាធនធានសិល្បករប្រកបដោយវិជ្ជាជីវៈពេញលេញ និងមានគុណសម្បត្តិសិល្បៈ ដែលអាចផ្ទេរចំណេះដឹង បម្រើ គាំពារ និងលើកស្ទួយសិល្បៈវប្បធម៌ខ្មែរឲ្យថ្កុំថ្កើនទៅអនាគត។ បន្ថែមពីលើជំនាញសិល្បៈ សាលាបានបញ្ចូលកម្មវិធីសិក្សាចំណេះដឹងទូទៅស្របតាមក្របខ័ណ្ឌរបស់ក្រសួងអប់រំ យុវជន និងកីឡា។

១០៦. ការសិក្សានៅសាលាមធ្យមវិចិត្រសិល្បៈ បែងចែកជា ៣ កម្រិតធំៗ គឺភូមិសិក្សាថ្នាល ភូមិសិក្សាទី១ និងភូមិសិក្សាទី២។ សញ្ញាបត្ររបស់សាលាមធ្យមវិចិត្រសិល្បៈមាន ២ កម្រិត គឺសិស្សដែលបញ្ចប់ភូមិសិក្សាទី១ ឬថ្នាក់ឆ្នាំទី៣ (មធ្យមសិក្សាបឋមភូមិឬឌីប្លូម) ទទួលបានសញ្ញាបត្រសិល្បៈ និងសិស្សដែលបញ្ចប់ភូមិសិក្សាទី២ ឬថ្នាក់ឆ្នាំទី៦ (មធ្យមសិក្សាទុតិយភូមិឬបាក់ឌុប) ទទួលបានស្នាតកបត្រសិល្បៈ។

## ៤.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ

១០៧. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបណ្តុះបណ្តាល សិក្ខាកាម សិស្ស និស្សិតចំនួន១៤៧ ៦៥០នាក់ ស្រី ៦១៧៩៧នាក់។ ក្រសួងបានបន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ (១,៥លាននាក់) កម្រិត C1 ដោយសិក្សាមិនបង់ថ្លៃ ព្រមទាំងទទួលបានប្រាក់ឧបត្ថម្ភចំនួន ២៨០ ០០០ រៀល ក្នុង១នាក់រយៈពេល៤ខែសម្រាប់សិស្សដែលមានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យ។គិតត្រឹមឆ្នាំ២០២៥ សិស្សបានបញ្ចប់ការសិក្សាចំនួន ៧៩ ២៨៥នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ៣៩ ១៩៩នាក់) ដោយមានសិស្សទទួលបានការងារធ្វើមានចំនួន ៥១ ៥៩១នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ២៦ ៨៦៦នាក់)។

១០៨. មជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតជាទីកន្លែងផ្តល់ចំណេះដឹង និងបំណិនជីវិត នៅកម្រិតសហគមន៍ដើម្បីចូលរួមអភិវឌ្ឍធនធានមនុស្ស និងសហគមន៍ដោយផ្តល់ឱកាសដើម្បីអភិវឌ្ឍសមត្ថភាពប្រកបដោយភាពធន់ ដែលជាផ្នែកមួយនៃការអនុវត្តគោលនយោបាយជាតិ ស្តីពីការសិក្សាពេញមួយជិវិត។ មជ្ឈមណ្ឌលសិក្សាសហគមន៍មាន ២៩២ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតមាន ២៩។

១០៩. កម្មវិធីបង្កើនប្រាក់ចំណូល ជាកម្មវិធីជួយអ្នករៀនឱ្យចេះរកប្រាក់ចំណូលតាមរយៈការបណ្តុះបណ្តាលជំនាញមុខរបរងាយៗដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីកែលម្អជីវភាពរស់នៅ ហើយជាកម្មវិធីមិនអាចខ្វះបានសម្រាប់ការងារអប់រំក្រៅប្រព័ន្ធ។ ជាលទ្ធផលក្នុងឆ្នាំសិក្សា២០២៤-២០២៥ យុវជន និងមនុស្សពេញវ័យបានទទួលអត្ថប្រយោជន៍ពីកម្មវិធីបង្កើនប្រាក់ចំណូល ៤ ០៨០នាក់ ស្មើ ៩៦,៧៧% បើធៀបនឹងចំណុចដៅ។

**ចំនួនយុវជន និងមនុស្សពេញវ័យបានទទួលអត្ថប្រយោជន៍ពីកម្មវិធីបង្កើនប្រាក់ចំណូល**



| | ចំនួនយុវជន និងមនុស្សពេញវ័យបានទទួលអត្ថប្រយោជន៍ពីកម្មវិធីបង្កើនប្រាក់ចំណូល |
|---|---|
| ជាក់ស្តែង២០២៤ | ៣៧៧២ |
| ចំណុចដៅ២០២៥ | ៤២១៦ |
| ជាក់ស្តែង២០២៥ | ៤០៨០ |

ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

# ៥. ការការពារកុមារ



៥.១. ការបង្ការ ទប់ស្កាត់

៥.២. ការអន្តរាគមន៍ និងឆ្លើយតប

៥.៣. ការផ្តល់ជំនួយ និងសេវាគាំទ្រ

## ៥. ការការពារកុមារ

### ៥.១.ការបង្ការ ទប់ស្កាត់

១១០. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) បានបន្តពង្រឹងយន្តការបរិយាបន្នក្នុងការធានាការពារ និងលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារកម្ពុជា។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៥ ក.ជ.ក. បានរៀបចំ "សន្និសីទថ្នាក់ជាតិស្តីពីការចូលរួមរបស់កុមារ និងយុវជន" នៅថ្ងៃទី២៨ ខែកុម្ភៈ និងបានសហការរៀបចំ "វេទិកាកុមារ និងអ្នកធ្វើគោលនយោបាយ" នៅថ្ងៃទី០៧ ខែឧសភា ដើម្បីផ្តល់ឱកាសឱ្យកុមារបានលើកឡើងនូវបញ្ហាប្រឈម និងដើម្បីកំណត់ទិសដៅរួមគ្នា។

១១១. សម្រាប់ការអបអរសាទរខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី២៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២៥ ត្រូវបានប្រារព្ធឡើងយ៉ាងទូលំទូលាយ ក្រោមប្រធានបទ "បញ្ឈប់អំពើហិង្សាលើកុមារគ្រប់ទម្រង់ គឺជាការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព" និង "លើកកម្ពស់ការងារសមរម្យសម្រាប់កម្មករនិយោជិតវ័យក្មេងនៅគ្រប់ខ្សែច្រវាក់ផលិតកម្ម ដើម្បីធានាកំណើនប្រកបដោយចីរភាព និងភាពធន់"។ ការអបអរសាទរទិវានេះ បានផ្តល់ឱកាសឱ្យតំណាងកុមារ កុមារមានពិការភាព កុមារជនជាតិដើមភាគតិច និងកុមាររងាយរងគ្រោះផ្សេងៗ បានបញ្ចេញមតិ និងសំណូមពររបស់ពួកគេទៅកាន់អ្នកពាក់ព័ន្ធ។

១១២. គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើវិស័យសិទ្ធិមនុស្ស បានយកចិត្តទុកដាក់បំពេញបេសកកម្មការងារតាមតួនាទីនិងភារកិច្ច និងផែនការការងារដែល គ.ស.ម.ក. បានដាក់ចេញ សំដៅធានារក្សាការពារ និងលើកកម្ពស់វិស័យសិទ្ធិមនុស្សនៅកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ គ.ស.ម.ក. បានខិតខំប្រមូលធាតុចូល និងរៀបចំរបាយការណ៍ជាតិស្តីពីការអនុវត្តអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិក ដើម្បីផ្ញើជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិឱ្យបានទាន់ពេលវេលា ដោយនៅក្នុងឆ្នាំ២០២៥នេះ គ.ស.ម.ក. បានដឹកនាំកិច្ចប្រជុំក្រុមសរសេររបាយការណ៍បានចំនួន ២លើក ជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ លើរបាយការណ៍ពិនិត្យជាសកលតាមកាលកំណត់ (UPR)។

១១៣. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ បានបន្តពិនិត្យតាមដានការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ (CRC) ហើយទន្ទឹមគ្នានេះ ក៏បានចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ និងតាមដានការអនុវត្តអនុសាសន៍ ដែលទទួលបានពីការពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទី៤ ដើម្បីបញ្ជ្រាបការយល់ដឹង និងជំរុញយន្តការការពារសិទ្ធិកុមារ និងសិទ្ធិមនុស្សជាសកលនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។

១១៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ.) បានបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍កុមារ ដោយបាននិង កំពុងរៀបចំឯកសារពាក់ព័ន្ធទាំងអស់នៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច មុននឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី។ សេចក្តីព្រាងច្បាប់នេះនឹងផ្តល់នូវគុណសម្បត្តិ និងអត្ថប្រយោជន៍ដូចតទៅ៖ (១).តម្កល់ឧត្តមប្រយោជន៍របស់កុមារក្នុងគ្រប់ទិដ្ឋភាព (២).កុមារទទួលបានការថែទាំ និងការការពារកាន់តែ

មានប្រសិទ្ធភាព (៣).ជំរុញការទទួលខុសត្រូវ និងករណីយកិច្ចរបស់ឪពុកម្តាយ អាណាព្យាបាល និងអាជ្ញាធរមានសមត្ថកិច្ចឲ្យបានត្រឹមត្រូវ (៤).លើកកម្ពស់សិទ្ធិ និងសមត្ថភាពរបស់កុមារក្នុងការចូលរួមក្នុងសង្គម និង (៥).ជំរុញការអនុវត្តតាមខ្លឹមសារនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

១១៥. ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ក្រសួង ស.អ.យ. បានរៀប ចំនិងផ្សព្វផ្សាយផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ បង្កើតយន្តការដឹកនាំការងារនិងបើកយុទ្ធនាការ "គ្រួសាររឹងមាំ" តាមរយៈការផ្សព្វផ្សាយសារអប់រំពាក់ព័ន្ធនឹងអំពើហិង្សានៅលើផេកហ្វេសប៊ុកនៃយុទ្ធនាការគ្រួសាររឹងមាំ (Strong Family Facebook Page) សរុបចំនួន ៥៦ដង ដល់អ្នកប្រើប្រាស់គណនេយ្យហ្វេសប៊ុកនៅទូទាំងប្រទេសសរុបចំនួន ១ ៣៦៤ ២៦០នាក់ មានអ្នកចូលទស្សនាសរុបចំនួន ១ ៦៧០ ១៣៦ដង ការមានប្រតិកម្មត្រឡប់សរុបចំនួន ២៣ ២៨៨ដង និងអ្នកចែករំលែកបន្តបានចំនួន ១ ១៨១ដង។ ក្រសួងបានបណ្តុះបណ្តាលឃុំ-សង្កាត់ អំពីការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់អំពើហិង្សា និងការរំលោភបំពានផ្សេងៗមកលើកុមារចំនួន ១១៦ឃុំ សង្កាត់ លើ ៥០ឃុំ សង្កាត់ នៃផែនការកំណត់។

១១៦. ក្រសួង ស.អ.យ. បានបណ្តុះបណ្តាលស្តីពីអង្គការសុវត្ថិភាពកុមារដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន ២៥ បើធៀបជាមួយ ចំណុចដៅនៃផែនការសកម្មភាពឆ្នាំ២០២៥ កើនឡើង ១០អង្គការ ស្មើនឹង ៦៧%។ បានផ្តល់វិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារចំនួន ៦៥មណ្ឌល ដែលមានសុពលភាពលើមណ្ឌលថែទាំកុមារសរុបចំនួន ១៣៦។

១១៧. ក្រសួង ស.អ.យ. បានរៀបចំបណ្តុះបណ្តាលអំពីការអនុវត្តនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត ទាំង២៥ និងសម្រាប់មន្ត្រីរដ្ឋបាលក្រុង ស្រុក នៃខេត្តបន្ទាយមានជ័យ ព្រមទាំងវគ្គរំលឹក ដល់មន្ត្រីមន្ទីរ ស.អ.យ រដ្ឋបាល ក្រុង ស្រុក ចំនួន ០៥ខេត្ត រួមមាន ខេត្តបន្ទាយមានជ័យ សៀមរាប ព្រះវិហា ប៉ៃលិន និងខេត្តកណ្តាល។ ក្រសួងក៏បានចុះប៉ាន់ប្រមាណស្តីពីផលប៉ះពាល់ទៅលើកុមារដោយសារការឈ្លានពានរបស់ថៃមកលើកម្ពុជា ក្នុងសីហា ឆ្នាំ២០២៥។ តាមរយៈរបកគំហើញនេះ ក្រសួងបានរៀបចំផែនការសកម្មភាពឆ្លើយតប និងរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការសង្គ្រោះបឋមផ្លូវចិត្តជូនដល់មន្ត្រីទទួលបន្ទុកបុគ្គលិកសង្គមថ្នាក់ក្រោមជាតិសម្រាប់ខេត្តព្រះវិហារ ឧត្តរមានជ័យ និងសៀមរាប សរុបចំនួន ៨៤នាក់ ស្រី ៤៧នាក់ ព្រមទាំងបានចុះផ្សព្វផ្សាយ និងប្រឹក្សាផ្លូ ដល់កុមារ និងគ្រួសារភៀសសឹក នៅតាមជំរុំនៃខេត្តទាំងបីនេះ សរុបក្រុមគោលដៅចំនួន ២ ៤៥៧នាក់ ក្នុង មានកុមារចំនួន ១ ០១៤នាក់។ ក្រសួងក៏បានធ្វើការកំណត់ហានីភ័យ និងគ្រប់គ្រងករណីកុមារដែលវិញត្រទ ប្រទេសថៃ ដើម្បីសេវាកិច្ចការពារកុមារ។

១១៨. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំគំនិតផ្តួចផ្តើម និងពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ (ដំណាក់កាលទី៣) ដើម្បីបន្តការប្តេជ្ញាចិត្ត និងរួមគ្នាអនុវត្តគោលដៅបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឱ្យមានប្រសិទ្ធភាព។

១១៩. ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា ក្រោមប្រធានបទ "លើកកម្ពស់ការងារសមរម្យសម្រាប់កម្មករ និយោជិតវ័យក្មេងនៅគ្រប់ខ្សែច្រវាក់ផលិតកម្ម ដើម្បីធានាកំណើនប្រកបដោយចីរភាព និងភាពធន់"

ដើម្បីឆ្លុះបញ្ចាំងពីការបង្កើនល្បឿនកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចប់ពលកម្មកុមារ ដោយផ្ដោតសំខាន់លើការពង្រឹងលក្ខខណ្ឌការងារ ការវិនិយោគលើយុវជនវ័យក្មេង និងធានាបាននូវកំណើន និងភាពធន់ប្រកបដោយនិរន្តរភាព ដែលមានអ្នកចូលរួមសរុបចំនួន ៤០០នាក់ ស្រី ១៥០នាក់។ ទន្ទឹមនឹងនេះ ការដាក់ចេញនូវចលនាប្រឡងប្រណាំង "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" ដែលជាចក្ខុវិស័យមួយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍវិស័យការងារ សំដៅប្រែក្លាយទៅជាចលនាជាតិមួយនៅកន្លែងធ្វើការងារ ដែលគ្រប់ភាគីពាក់ព័ន្ធ ជាពិសេស កម្មករនិយោជិត និងនិយោជកចូលរួមអនុវត្ត ដើម្បីបង្កើតបានវប្បធម៌អនុលោមភាពតាមច្បាប់ សុខដុមនីយកម្ម ទំនាក់ទំនងវិជ្ជាជីវៈ និងទំនួលខុសត្រូវផ្នែកសង្គមរបស់សហគ្រាស ដោយកំណត់លក្ខណៈវិនិច្ឆ័យ "មិនមានការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ" ជាវិញ្ញាបនបត្រអនុលោមភាពមួយសម្រាប់ជាលក្ខខណ្ឌកំណត់ថា សហគ្រាសមួយអាចទទួលបានពានសហគមន៍សុខសាន្តប្រចាំឆ្នាំ។

១២០. ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានបើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានផលិតផល ក្បឿង ដល់មន្ត្រីអធិការកិច្ចការងារផ្នែកពលកម្មកុមារ និងអាជ្ញាធរមូលដ្ឋានរាជធានី/ខេត្ត ក្រុង/ស្រុក ឃុំ/សង្កាត់ នៃរាជធានីខេត្តចំនួន ៨វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៤៨៩នាក់ ស្រី ១០៦នាក់ ដែលក្នុងនោះអធិការការងារចំនួន ៣០៤នាក់ ស្រី ៣៦នាក់ និងមន្ត្រីមូលដ្ឋានថ្នាក់ខេត្ត/ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ចំនួន ១៨៥នាក់ ស្រី ៧០នាក់ ក្នុងគោលបំណងពង្រឹងសមត្ថភាព និងបង្កើនប្រសិទ្ធភាពការងារបង្ការ និងទប់ស្កាត់ពលកម្មកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១២១. ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានបើកយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប និងការចុះយុទ្ធនាការផ្សព្វផ្សាយដល់ទីតាំងចំនួន ៤៤៣ទីតាំង ដើម្បីផ្លាស់ប្ដូរផ្នត់គំនិតពាក់ព័ន្ធនឹងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ការងារដោយបង្ខំ និងជំរុញចលនាសហគមន៍ឆ្ពោះទៅការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ សហព័ន្ធសហជីព អង្គការដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន កម្មករនិយោជិតជាអាណាព្យាបាល និងកុមារសរុបចំនួន ១២ ០៨២នាក់ ស្រី ៤ ៩២៩នាក់។ ក្រសួងក៏បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីផ្សព្វផ្សាយសារអំពាវនាវក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ តាមរយៈការដាក់បញ្ចូលក្នុងប្រព័ន្ធនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) សម្រាប់ដាក់បញ្ចូលទៅក្នុងសារទូរស័ព្ទទូទាំងប្រទេស ព្រមទាំងបានផលិតវីដេអូ និងចម្រៀងសម្រាប់ជំរុញការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយដល់សាធារណជន អំពីការចូលរួមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។

១២២. ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានចុះអធិការកិច្ចការងារលើវិស័យសិប្បកម្មផលិតផល ក្បឿង ចំនួន ២៩៩លើក ដើម្បីធានាថាកុមារងាយរងគ្រោះត្រូវបានការពារពីការកេងប្រវ័ញ្ច និងបានធ្វើលិខិតធានាអះអាងស្ដីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ជាមួយនិយោជកចំនួន ៩៦លិខិត និងកិច្ចសន្យារវាងអាណាព្យាបាល និងនិយោជក ស្ដីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារចំនួន ៤៦៩កិច្ចសន្យា។ ស្របគ្នានេះ ក្រសួងបានសហការជាមួយអាជ្ញាធរ មូលដ្ឋាន ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងសិប្បកម្មផលិតផល ក្បឿង និងឱកាសអប់រំសម្រាប់កុមារដែលងាយរងផលប៉ះពាល់។ ក្រសួងក៏បានចុះត្រួតពិនិត្យលក្ខខណ្ឌ និងប្រភេទការងារ ក្នុងករណីនិយោជកស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេង ក្នុងគោលបំណងធានាឱ្យការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងស្របតាមច្បាប់ការងារ និងមិនប៉ះពាល់ដល់សុខភាព សុវត្ថិភាព និងការអភិវឌ្ឍរបស់កុមារ។

តារាងសង្ខេប៖ ការពង្រឹងសមត្ថភាពមន្ត្រី និងការលើកកម្ពស់ការយល់ដឹងតាមរយៈការផ្សព្វផ្សាយ

| ល.រ | សកម្មភាពការងារ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ១ | ផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ | លើក/ទីតាំង | ៣១២ | ៤៤៧ | ៤៣% |
| | | សរុប (នាក់) | ៨,៤៤៥ | ១២,៩០០ | ៥៣% |
| | | ស្រី (នាក់) | ៣,៥៩០ | ៥,៣១៤ | ៤៨% |
| ២ | បណ្តុះបណ្តាលស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ | វគ្គ | ២៣ | ៦ | -៧៤% |
| | | សរុប (នាក់) | ៥៥៨ | ៥៧៣ | ៣% |
| | | ស្រី (នាក់) | ២១៦ | ១៣៥ | -៣៨% |

ប្រភព៖ នាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១២៣. ក្រសួងទេសចរណ៍បាននិងកំពុងយកចិត្តទុកដាក់លើការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ក្នុងការចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានមកលើវិស័យទេសចរណ៍ ជាពិសេសការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មមកលើកុមារ ដោយព្យាយាមលុបបំបាត់ "ទេសចរណ៍ផ្លូវភេទ-Child Sex Tourism" ដើម្បីថែរក្សាតម្លៃវប្បធម៌ប្រពៃណី ការលើកកម្ពស់សីលធម៌សង្គមនិងគ្រួសារខ្មែរ ការយល់ដឹងពីតម្លៃនិងសិទ្ធិរបស់កុមារ និងចូលរួមការពារលើកស្ទួយកុមារឱ្យរួចផុតពីការជួញដូរតាមគ្រប់រូបភាព។

១២៤. ក្រសួងទេសចរណ៍បានចេញប្រកាសលេខ ០៧៦ប្រក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ "គ.ស.ក.ទ."។ ក្រសួងក៏បានរៀបចំផ្សព្វផ្សាយកម្មវិធីខួបលើកទី៧៦ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៥ ដោយមានការចូលរួមពីកុមារ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការសរុបចំនួន ៥១២នាក់។

១២៥. ការងារសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ក្រសួងបានរៀបចំសិក្ខាសាលាស្តីពី "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ដោយមានការចូលរួមពីរដ្ឋបាលខេត្ត អាជ្ញាធរដែនដី មន្ទីរពាក់ព័ន្ធ យុវជន ស.ស.យ.ក. ម្ចាស់ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍នៅខេត្តកោះកុង និងខេត្តស្វាយរៀង សរុបចំនួន ១៥៦នាក់ និងបានសហការជាមួយមន្ទីរទេសចរណ៍ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង ប្រជុំផ្សព្វផ្សាយស្តីពី "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ដោយមានការចូលរួមសរុបចំនួន ២២៤នាក់។

១២៦. ក្រសួងទេសចរណ៍បានចុះធ្វើអធិការកិច្ចលើមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ចំនួន ១៥ខេត្ត រួមមាន៖ ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត ខេត្តកែប ខេត្តក្រចេះ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តសៀមរាប និងខេត្តបាត់ដំបង និងពិនិត្យលើមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍សរុបចំនួន ១៤៦ ទីតាំង។

១២៧. តាមរយៈក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប.) ដែលជាសេនាធិការរបស់ក្រសួង បានធ្វើការផ្សព្វផ្សាយការយល់ដឹងអំពីច្បាប់ស្តីអំពីសុវត្ថិភាពចំណីអាហារ និងការយល់ដឹងអំពីរបៀបនៃការជ្រើសរើសម្ហូបអាហារ ដែលមានសុវត្ថិភាព នៅតាមបណ្តាគ្រឹះ

ស្ថានសិក្សានានាក្នុងរាជធានី ខេត្ត បានចំនួន ២៧៧ លើក ដែលមានសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និង អាជីវករចូលរួមចំនួន ១២៧ ១២៤ នាក់។ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការហាមឃាត់ការទទួលទាន ការចែកចាយ ការដាក់តាំងលក់ និងការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលភេសជ្ជៈប៉ូវកម្លាំងនៅក្នុង និងខាងក្រៅសាលារៀនបានចំនួន ៥ លើកដែលមានអ្នកចូលរួមចំនួន ១ ១០៦ នាក់។

១២៨. ក្រសួងព័ត៌មានបានផលិត និងផ្សព្វផ្សាយមាតិកាវិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី និងព័ត៌មានបោះពុម្ពពាក់ព័ន្ធទៅនឹងការបង្ការ និងការទប់ស្កាត់អំពើហិង្សាលើកុមារ រួមមាន៖ មាតិកាទម្រង់ជាព័ត៌មាន មាតិកាទម្រង់ជាបទយកការណ៍ និងបទអត្ថាធិប្បាយ។ មាតិកាគ្រប់ទម្រង់ត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិរួមមានទូរទស្សន៍ វិទ្យុAM វិទ្យុFM ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ទូរទស្សន៍ថ្នាលឌីជីថល MoInfoTV និងបណ្ដាញសង្គមថ្នាក់ជាតិ និងរាជធានី ខេត្ត រួមមាន Facebook, Telegram គេហទំព័រ និងTik Tok Instagram ព្រមទាំងមធ្យោបាយផ្សព្វផ្សាយបោះពុម្ព រួមមាន៖ ព្រឹត្តិប័ត្រប្រចាំថ្ងៃ ទស្សនាវដ្ដីកម្ពុជាប្រចាំខែ និងកាសែតអេឡិចត្រូនិចប្រចាំថ្ងៃ។ ក្រសួងក៏បានបង្កើតក្រុមការងារដើម្បីត្រួតពិនិត្យព័ត៌ក្លែងក្លាយ ដោយធ្វើការទប់ស្កាត់ និងចាត់ការទៅតាមនីតិវិធីផ្លូវច្បាប់ផងដែរ។

១២៩. ដើម្បីចូលរួមចំណែកពង្រឹងការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារស្របតាមច្បាប់ជាតិ និងអន្តរជាតិ ក្រសួងព័ត៌មានបានបញ្ជ្រាបនូវការអប់រំស្ដីពីសិទ្ធកុមារជូនកុមារផ្ទាល់ មាតាបិតា អាណាព្យាបាល និងសាធារណជនតាមរយៈសកម្មភាពសំខាន់ៗចំនួន៣៖ (១).នាទីកុមារ (២).មហោស្រពតន្ត្រី និងចម្រៀងកុមារពានរង្វាន់ក្រសួងព័ត៌មាន និង (៣).ការផលិតមាតិកាចម្រុះ និងវេទិកាពិភាក្សា។ នាទីកុមារនេះត្រូវបានរៀបចំឡើងជាភាពយន្តគំនូរជីវចល ក្នុងគោលបំណងបង្កើនការចងចាំ និងបណ្ដុះទម្លាប់ល្អៗដល់កុមារ។ ការបញ្ជ្រាបចំណេះដឹងតាមរយៈរូបភាពចលនា និងពណ៌ចម្រុះ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ការអប់រំកុមារ។ មហោស្រពតន្ត្រី និងចម្រៀងកុមារពានរង្វាន់ក្រសួងព័ត៌មាន ត្រូវបានបង្កើតឡើងដើម្បីបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិកុមារតាមរយៈសិល្បៈកម្សាន្ត តាមរយៈការប្រើប្រាស់ភាសាសិល្បៈជាឧបករណ៍បញ្ជ្រាបការអប់រំ និងបំផុសស្មារតីមាតាបិតាអាណាព្យាបាល សារធារណជនអោយយកចិត្តទុកដាក់អនុវត្តន៍សិទ្ធិកុមារ និងផ្តល់ឱកាសឱ្យកុមារបានបញ្ចេញសមត្ថភាព ភាពក្លាហាន ចេះសាមគ្គីគ្នា និងការច្នៃប្រឌិត។ ទន្ទឹមនឹងនេះ មហោស្រពកុមារត្រូវបានរៀបចំឡើងដើម្បីអបអរសាទរទិវាកុមារអន្តរជាតិ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាផងដែរ។ ការផលិតមាតិកាចម្រុះ និងវេទិកាពិភាក្សា គឺជាការបង្កើនការយល់ដឹងជាសកលក្នុងសង្គម ដើម្បីជំរុញឱ្យបញ្ហាកុមារក្លាយជាកិច្ចការអាទិភាពរបស់សង្គមទាំងមូល។

១៣០. ក្រសួងព័ត៌មានបានពង្រីកវិសាលភាព នៃការផលិតមាតិកាព័ត៌មានឱ្យកាន់តែសម្បូរបែប និងមានលក្ខណៈវិទ្យាសាស្ត្រ។ ក្រសួងបានផលិតនូវបទយកការណ៍ស៊ីជម្រៅដែលឆ្លុះបញ្ចាំងពីជីវភាព និងតម្រូវការជាក់ស្ដែងរបស់កុមារ។ ជាមួយគ្នានេះ វេទិកាពិភាក្សាដែលមានការចូលរួមពីអ្នកជំនាញផ្នែកសិទ្ធិកុមារ និងតំណាងស្ថាប័នពាក់ព័ន្ធ បានជួយជម្រុញឱ្យសាធារណជនយល់ដឹងកាន់តែច្បាស់ អំពីកិច្ចការពារកុមារតាមផ្លូវច្បាប់ និងតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននានា។ ការងារនេះ បានធ្វើឱ្យកិច្ចការពារកុមារក្លាយជាចលនារួមមួយដែលគ្រប់គ្នាមិនអាចរំលងបាន។

១៣១. ក្រសួងព័ត៌មានបានសម្រេចលើបេសកកម្មសំខាន់ៗក្នុងការគាំពារកុមារ តាមរយៈការចុះបំពេញបេសកកម្មផ្ទាល់ដល់តំបន់ជួរមុខ ដើម្បីផលិតបទយកការណ៍ និងកិច្ចសម្ភាសន៍បានឆ្លុះបញ្ចាំងពីសុខទុក្ខ និងក្តីស្រមៃរបស់កុមាររៀសសឹកសំដៅជាស់តឿនស្មារតីសាធារណជន ឱ្យរួមគ្នាការពារនិងផ្តល់កិច្ចសង្គ្រោះដល់កុមាររងគ្រោះឱ្យបានទាន់ពេលវេលា។

១៣២. ក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក.) បានបន្តពង្រឹងការអនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ដោយបានរៀបចំសិក្ខាសាលាបង្កើតផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយនេះសម្រាប់ ឆ្នាំ២០២៤-២០២៨។ ការវាយតម្លៃកន្លងមកបានបង្ហាញថា កម្មវិធីវិន័យបែបវិជ្ជមានបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សាលារៀនតាមរយៈការលើកកម្ពស់អហិង្សា និងសុខុមាលភាពរបស់កុមារ។ លើសពីនេះ ក្រសួង អ.យ.ក. ក៏បានសហការផ្តល់វគ្គបណ្តុះបណ្តាលស្តីពី "ការដាក់វិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព" ដល់មន្ត្រីជំនាញ មន្ទីរអប់រំ និងគណៈកម្មការទ្រទ្រង់សាលា ព្រមទាំងបានចេញសេចក្តីសម្រេចលេខ៥៣ ស្តីពីការបង្កើតក្រុមការងារលើកកម្ពស់ និងទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ ក្នុងរចនាសម្ព័ន្ធរបស់ក្រសួងផងដែរ។

១៣៣. កិច្ចការពារកុមារ ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ គឺជាសកម្មភាពដ៏សំខាន់មួយរបស់ប្រទេសកម្ពុជាដែលជាសមាជិក ដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ និងអនុសញ្ញា ស៊ី-ដ ក្នុងការបន្តពង្រឹងការអនុវត្ត និងរក្សានិរន្តរភាព ព្រមទាំងភាពម្ចាស់ការក្នុងការដឹកនាំ និងគ្រប់គ្រងដ៏រឹងមាំក្នុងការទប់ស្កាត់គ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីឈានទៅសម្រេចឱ្យបាននូវការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបគតិបណ្ឌិតស្វាហាប់ និងចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី និងស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) នៅឆ្នាំ២០៣០។

១៣៤. ក្រសួងកិច្ចការនារី បាននិងកំពុងដំណើរការរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ ឆ្នាំ២០២៦-២០៣០ សេចក្តីព្រាងផែនការសកម្មភាពជាតិនេះ មានគោលបំណងកាត់បន្ថយ និងលប់បំបាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ ការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់។ ផែនការនេះ រំពឹងនឹងទទួលបានការអនុមតិពីថ្នាក់ដឹកនាំក្នុងពេលឆាប់ខាងមុខ។

១៣៥. ក្រសួងកិច្ចការនារី ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បាននិងកំពុងបន្តផ្សព្វផ្សាយ និងជំរុញការអនុវត្តច្បាប់ពាក់ព័ន្ធ ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដើម្បីជួយរកយុត្តិធម៌ជូនដល់ជនរងគ្រោះឱ្យបានទាន់ពេលវេលា ព្រមទាំងបណ្តុះបណ្តាលជាប្រចាំនូវជំនាញផ្នែកច្បាប់ដល់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ។

១៣៦. ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលបានបង្កើតកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើតនិងកំពុងដំណើរការនៅក្នុងមន្ទីរពេទ្យបង្អែក រាជធានី ខេត្ត ចំនួន១១។ នៅថ្នាក់

ក្រោមជាតិ ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើត និងកំពុងដំណើរការ នៅក្នុងរាជធានី ខេត្ត ចំនួន១១ និងក្រុង ស្រុក ចំនួន ៥៣ (និងគ្រោងពង្រីកទៅខេត្តថ្មីចំនួន ៥ និង ១៤ស្រុក បន្ថែមទៀត)។ បន្ទប់ប្រឹក្សាយោបល់សម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ ចំនួន ៥៥កន្លែង ត្រូវបានបង្កើត និងកំពុងដំណើរការនៅក្នុងខេត្តគោលដៅ ចំនួន៤។

១៣៧. តាមរយៈក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រសួងយុត្តិធម៌ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន និងក្រសួងកិច្ចការនារី បានចូលរួមគាំទ្រជំនួយផ្នែកច្បាប់ដល់ស្ត្រី និងក្មេងស្រីក្រីក្រ រងគ្រោះដោយអំពើហិង្សា សរុបចំនួន ៥ ២៩០ ករណី។

១៣៨. នៅថ្នាក់ក្រោមជាតិៈ គណៈកម្មការចម្រុះថ្នាក់ខេត្តរាជធានី បានដឹកនាំនិងសម្របសម្រួលការងារលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរនៅថ្នាក់មូលដ្ឋាន តាមរយៈកម្មវិធីអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ ការជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការចាត់វិធានការអប់រំណែនាំតាមសមត្ថកិច្ចរៀងៗខ្លួន។ នៅក្នុងនោះ មន្ទីរកិច្ចការនារីរាជធានី ខេត្ត បានចូលរួមផ្តល់សេវាផ្សព្វផ្សាយនិងអប់រំដល់ប្រជាពលរដ្ឋក្នុងសហគមន៍ និងតាមជំរុំជនភៀសសឹក ចំនួន ១៥ ៤១០នាក់ បានទទួលការយល់ដឹង អំពីការចិញ្ចឹមកូនបែបវិជ្ជមាន (កម្មវិធីពុកម៉ែល្អ កូនល្អ និងគ្រួសារល្អ) ការទំនាក់ទំនងអន្តរជំនាន់ សីលធម៌សង្គម សុខុមាលភាពផ្លូវចិត្ត និងការទប់ស្កាត់រាល់ទម្រង់អំពើហិង្សាលើស្ត្រីនិងកុមារ។

១៣៩. ចំពោះកម្មវិធីការចិញ្ចឹមកូនបែបវិជ្ជមាន ក្រសួងកិច្ចការនារីបានប្តេជ្ញា ដាក់បញ្ចូលបញ្ហាសំខាន់ៗចំនួន៨ ដែលត្រូវបានកំណត់ដោយកុមារផ្ទាល់ (រួមមានបញ្ហាអំពើហិង្សា ពលកម្មកុមារ ការប្រើប្រាស់គ្រឿងញៀន ការបោះបង់ការសិក្សា។ល។) ទៅក្នុងយុទ្ធសាស្ត្រការចិញ្ចឹមកូនបែបវិជ្ជមាន។ ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំផែនការគាំទ្រដល់ការការពារសិទ្ធិកុមារ ដែលមាននិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះ (SOGIESC) ដោយគ្រោងនឹងរួមបញ្ចូលមាតិកាពាក់ព័ន្ធនឹងក្រុមកុមារនេះទៅក្នុងកម្មវិធីការចិញ្ចឹមកូនបែបវិជ្ជមានបន្ថែមទៀត។

១៤០. ក្នុងការលើកកម្ពស់សិទ្ធិ និងសុខុមាលភាពកុមារី ក្រសួងកិច្ចការនារីបានចូលរួមយ៉ាងសកម្មក្នុងកិច្ចពិគ្រោះយោបល់អំពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ (UNCRC) និង UPR ដើម្បីស្វែងរកការការពារសិទ្ធិកុមារចម្រុះ។ បន្ថែមពីនេះ ក្នុងនាមជាកិច្ចការអាទិភាពសម្រាប់ឆ្នាំ២០២៦ ក្រសួងកិច្ចការនារីបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការរៀបចំវិធានការឆ្លើយតប និងតាមដានការវាយតម្លៃឥទ្ធិពលយេនឌ័រ ស្ថានភាព និងសុខុមាលភាពរបស់ស្ត្រី ក្មេងស្រី និងគ្រួសារ ទាំងមូល។

១៤១. ក្នុងឆ្នាំ២០២៥ ការបណ្តុះបណ្តាលស្តីពី "កិច្ចការពារកុមារ ការចិញ្ចឹមកូនបែបវិជ្ជមាន និងសុវត្ថិភាពលើប្រព័ន្ធអនឡាញ" ត្រូវបានបន្តអនុវត្តយ៉ាងសកម្ម។ ជាក់ស្តែង អង្គការដៃគូបានសហការជាមួយក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីបង្គោលចំនួន ៣៨ នាក់ (ស្រី ១៧នាក់) មកពីមន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច និងការិយាល័យពាក់ព័ន្ធ។ បន្ថែមពីនេះ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ-សង្កាត់ (គ.ក.ន.ក) ចំនួន ៧២នាក់ (ស្រី ៥១នាក់) ក៏ទទួលបានវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន អំពើហិង្សា និងការគាំពារសុវត្ថិភាពកុមារផងដែរ។

១៤២. ការត្រួតពិនិត្យគ្រឿងស្រវឹង៖ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចបង្កើតក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដើម្បីកំណត់អំពីបែបបទ នីតិវិធី និងវិធានក្នុងការគ្រប់គ្រងការផ្សាយ

ពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដើម្បីធានាសណ្តាប់ធ្នាប់សង្គម សុខុមាលភាពសាធារណៈ កាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីជាតិ។ ក្រុមការងារបានដាក់ចេញនូវប្រកាសស្តីពីការកំណត់អំពីបែបបទ នីតិវិធី និងវិធានក្នុងការគ្រប់គ្រងការផ្សាយពាណិជ្ជកម្ម ផលិតផលគ្រឿងស្រវឹង ដែលមានគោលការណ៍ចំនួន ១៧ចំណុច ក្នុងនោះមានកំណត់ទីតាំងដែលមិនអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង នៅចម្ងាយតិចជាង ២០០ម៉ែត្រ ជុំវិញបរិវេណគ្រឹះស្ថានសិក្សា គ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសាសនា រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ អាកាសយានដ្ឋានអន្តរជាតិ ជាដើម និងការដាក់សារអប់រំលើរាល់ការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង និងគ្រប់គ្រងលើខ្លឹមសារ សកម្មភាព និងមធ្យោបាយនៃការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង។

១៤៣. ក្រសួងសុខាភិបាលបានឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីការផ្តល់ប្រឹក្សាលះបង់ការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង និងបានផ្តល់ដល់មណ្ឌលសុខភាព ស្ថាប័នពាក់ព័ន្ធ សម្រាប់អប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាជន អំពីឥរិយាបថរស់នៅប្រកបដោយសុខុមាលភាពក្នុងការបង្ការជំងឺមិនឆ្លង ដែលបណ្តាលមកពីការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានពិនិត្យលិខិតអនុញ្ញាតផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដែលទទួលបានពីក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង (គ.ក.ផ.ស) បានចំនួន ៦៤លិខិត និងបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងបន្ថែមទៀតផងដែរ។

១៤៤. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) ដោយលមានការគាំទ្រពីអង្គការដៃនដីមនុស្ស-ហូឡង់ដ៍ (TdH) ធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា ឆ្នាំ២០២១-២០២៥។ ទន្ទឹមនឹងនេះ ចំពោះសកម្មភាពដែលនៅសេសសល់ ក.ជ.ក. បានបន្តដាក់បញ្ចូលទៅក្នុង "ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០" ដោយបានដាក់បញ្ចូលនូវការលើកកម្ពស់ការយល់ដឹងលើកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ (Online) និងក្រៅប្រព័ន្ធ (Offline) ឱ្យស្របតាមបរិបទបច្ចេកវិទ្យាសកលបច្ចុប្បន្ន។ ស្របពេលជាមួយគ្នានេះ

១៤៥. ក្នុងកិច្ចខិតខំជំរុញការកសាងមូលធនមនុស្សឌីជីថល ដើម្បីអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ២០២២-២០៣៥ ជាពិសេស គឺការចូលរួមអនុវត្តក្របខណ្ឌយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានកំណត់យកបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាឌីជីថលជាអាទិភាពគន្លឹះទី៥ និងគោលនយោបាយ សេដ្ឋកិច្ច សង្គម និងរដ្ឋាភិបាលឌីជីថលកម្ពុជា ឱ្យមានប្រសិទ្ធភាព ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (ក.ប.ទ.) បានបង្កើតគម្រោងការកសាងមជ្ឈមណ្ឌលបច្ចេកវិទ្យា សហគមន៍នៅតាមវិទ្យាល័យសាធារណៈ ដើម្បីបំពេញបេសកកម្មលើគំនិតផ្តួចផ្តើមបរិវត្តកម្មឌីជីថលបម្រើដល់ការអប់រំ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍមូលធនមនុស្សឌីជីថល និងអនាគតឌីជីថលកម្ពុជា។ បច្ចុប្បន្ន មជ្ឈមណ្ឌលបច្ចេកវិទ្យាសហគមន៍នៅតាមវិទ្យាល័យសាធារណៈ មានចំនួន ២១ នៅក្នុងខេត្តតាកែវ។

១៤៦. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានផលិតវីដេអូអប់រំ ៣ ភាគស្តីពី "ការកេងប្រវ័ញ្ចផ្លូវភេទដើម្បីជំរិតទារប្រាក់" (Sexual Extortion) អមដោយសៀវភៅណែនាំសម្រាប់អង្គការសង្គមស៊ីវិល ក្រោមកិច្ចសហការ

ជាមួយអង្គការដែនដីមនុស្ស-ហូឡង់ដ៍។ ក្រសួង និងនិយ័តករទូរគមនាគមន៍កម្ពុជាក៏បានបន្តបិទខ្ទប់នូវគេហទំព័រមិនសមរម្យ ជាពិសេសមានលក្ខណៈរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

១៤៧. ដោយមានការឯកភាពពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងមានកិច្ចគាំទ្រពីអង្គការឆាលហ្វាន កម្ពុជា អគ្គលេខាធិការដ្ឋាន ក.ជ.ក. និងវិទ្យាស្ថានជាតិសង្គមកិច្ច បានសហការរៀបចំសៀវភៅមេរៀនស្តីពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ" សម្រាប់បណ្តុះបណ្តាលនិស្សិតរបស់វិទ្យាស្ថាន។ ទន្ទឹមនេះ អគ្គលេខាធិការដ្ឋាន ក.ជ.ក. និងអង្គការឆាលហ្វាន កម្ពុជា បាននិងកំពុងបន្តអភិវឌ្ឍកម្មវិធីអេបស្វ័យសិក្សាតាមទូរសព្ទស្តីពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ (Swipe Safe app)" ដើម្បីដាក់ឱ្យប្រើប្រាស់ស្របការវិវត្តនៃបច្ចេកវិទ្យាឌីជីថល។

១៤៨. ក្នុងឆ្នាំ២០២៥ ក្រសួងមហាផ្ទៃបានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត រៀបចំការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីបញ្ហាគ្រឿងញៀនចំនួន ២១៧ ០៣៨លើក អ្នកចូលរួមការបណ្តុះបណ្តាល និងបានទទួលការអប់រំចំនួន ២៣ ៣០១ ៤៤២អង្គ/នាក់ ព្រមទាំងបានធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានស្តីពី បញ្ហាគ្រឿងញៀន ដល់មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន ៤ ៧៥៣រូប ។

១៤៩. កម្មវិធីទូរសព្ទដៃ NoDrug បានរួមចំណែកយ៉ាងសំខាន់ក្នុងដំណើរការប្រយុទ្ធប្រឆាំងបញ្ហាគ្រឿងញៀននៅមូលដ្ឋាន តាមរយៈការផ្តល់សារអប់រំ ចំណេះដឹងអំពីផលប៉ះពាល់ និងវិធានការបង្ការការប្រើប្រាស់គ្រឿងញៀន ព័ត៌មានពាក់ព័ន្ធនឹងការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងជាមធ្យោបាយរាយការណ៍បញ្ហាបទល្មើសគ្រឿងញៀនមកកាន់សមត្ថកិច្ច។ គិតមកដល់បច្ចុប្បន្នមានអ្នកទាញយកកម្មវិធីទូរសព្ទដៃ NoDrug ប្រមាណ ៦៧ ៣៨៩នាក់ និងសមត្ថកិច្ចទទួលបានការរាយការណ៍អំពីបញ្ហាគ្រឿងញៀនតាមរយៈកម្មវិធីនេះចំនួន ២ ៩២០ករណី ។

១៥០. ពាក់ព័ន្ធនឹងការងារចុះអង្កេតអំពី "ការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន" បច្ចុប្បន្ន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ រៀបចំឯកសារស្ទង់មតិរួចរាល់ហើយ (អាចអនុវត្តសកម្មភាពចុះអង្កេតនាដើមឆ្នាំ២០២៦នេះ) ។ ចំពោះការងាររៀបចំភូមិ ឃុំ សង្កាត់ "ស" គ្មានគ្រឿងញៀន ពុំទាន់បានដំណើរការនៅឡើយទេ ដោយសារគោលនយោបាយនេះ មិនទាន់បានអនុម័ត ។

១៥១. អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) បានសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពពាក់ព័ន្ធជាសមាជិកទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អនុវត្តផែនការសកម្មភាពនានានៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨។ គ.ជ.ប.ជ. បានឯកភាពជាមួយភាគីថៃលើផែនការសកម្មភាពរួមសម្រាប់អនុវត្តអនុស្សារណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ ដំណាក់កាលទី២ (២០២៥-២០២៨)។ គ.ជ.ប.ជ. បានបញ្ចប់ឯកសារក្របខ័ណ្ឌតាមដាន វាយតម្លៃ និងរៀនសូត្រ (MEL) សម្រាប់ធ្វើការតាមដាន វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨។

១៥២. គ.ជ.ប.ជ. បានប្រកាសដាក់ឱ្យប្រើប្រាស់ផែនការជាតិអនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (NIP/GCM)។ បានប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។ បានប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅគោលការណ៍ណែនាំស្តីពីបទដ្ឋានអប្បបរមា ដើម្បីផ្តល់សេវាសមាហរណកម្ម និងសេវាបញ្ជូនសម្រាប់មណ្ឌលទទួលពលករកំរៀង។ បានអនុស្សារណៈនៃការយោគយល់ជាមួយអង្គការការីតាស់ស្វីសប្រចាំកម្ពុជា ស្តីពីការរួមចំណែកលើការលើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ស្តីពីសកម្មភាពទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ក្នុងបរិបទទេសន្តរប្រវេសន៍ ២០២៥-២០២៨។ អនុស្សារណៈនៃការយោគយល់ជាមួយអង្គការម៉ារីស៊ី ស្តីពីការរួមចំណែកក្នុងសកម្មភាពមនុស្សធម៌សម្រាប់ការងារប្រឆាំងអំពើជួញដូរមនុស្ស។

១៥៣. ក្រុមការងារបង្ការ ទប់ស្កាត់នៃ គ.ជ.ប.ជ. បានជំរុញលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានជាតិសេសក្រុមងាយរងគ្រោះ តាមរយៈការចុះផ្សព្វផ្សាយដោយផ្ទាល់ ការធ្វើវេទិកាសាធារណៈ នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព" ការប្រារព្ធវេទិកាអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណេត ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទិវាអន្តរជាតិសម្រាប់ពលករទេសន្តរប្រវេសន៍ ពិព័ណការងារ និងផលិតផលជាតិ ការផ្សព្វផ្សាយអប់រំតាមសាលារៀន តាមសហគមន៍ និងកម្មវិធីផ្សេងៗសរុបចំនួន ២៣៤ ២៤៣លើក មានអ្នកចូលរួមចំនួន ១៣ ៨៨០ ៨៦៦ នាក់ ស្ត្រី ៧ ៥២៣ ៨០២នាក់ ។

## ៥.២. ការអន្តរាគមន៍ និងឆ្លើយតប

១៥៤. ក្រសួងកិច្ចការនារីបានបន្តពង្រឹងការផ្តល់សេវាឆ្លើយតបឱ្យកាន់តែប្រសើរ ដោយបានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវសៀវភៅគោលការណ៍ណែនាំស្តីពីការថែទាំសុខភាពផ្លូវភេទ និងបន្តពូជសម្រាប់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)។ ទន្ទឹមគ្នានេះ មន្ត្រី និងអ្នកផ្តល់សេវាពាក់ព័ន្ធសរុបចំនួន ៧៤៣នាក់ ទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញក្នុងការផ្តល់សេវាឆ្លើយតបជួយជនរងគ្រោះ ខណៈដែលជនរងគ្រោះ (រួមមានស្ត្រីបម្រើការតាមហាងម៉ាស្សា ស្ត្រីនិងក្មេងស្រីថ្លង់ និងស្ត្រីជនជាតិដើមភាគតិច) ចំនួន ៥៦៣ករណី បានទទួលបានការប្រឹក្សាផ្លូវច្បាប់ទាន់ពេលវេលាផងដែរ។

១៥៥. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ផ្អែកតាមព័ត៌មានជំនាញ និងការស្រាវជ្រាវ ស៊ើបអង្កេត សមត្ថកិច្ចបើកប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន ១០ ៧៤៣ករណី ឃាត់ខ្លួន ២៧ ៨៨៩នាក់ រឹបអូសបានគ្រឿងញៀនគ្រប់ប្រភេទប្រមាណជាង ៥តោន ៨៩៧គ.ក្រ និងសារធាតុគីមីផ្សំប្រមាណ ៤២តោន ។

១៥៦. ចំពោះប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ក្រុមការងារអនុវត្តច្បាប់នៃ គ.ជ.ប.ជ. (កម្លាំងនគរបាលជាតិ និងកងរាជអាវុធហត្ថ) បានបើកប្រតិបត្តិការស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន ២៧២ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ៤១០នាក់ (ស្ត្រី ៥៣នាក់ ជនបរទេស ៤៣នាក់) និងសង្គ្រោះជនរងគ្រោះបានចំនួន ៩៩៤នាក់ (ស្ត្រី ៦២៤នាក់ អនីតិជន ២៨២នាក់) បញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន ៣៣១ នាក់ អាណាព្យាបាលចំនួន ៦៣៣នាក់ និងអង្គភាពពាក់ព័ន្ធចំនួន ៣០នាក់។ សាលាដំបូងរាជធានី ខេត្ត បានដំណើរការជំនុំជម្រះសំណុំរឿងចំនួន ៣៧៥សំណុំរឿង (សំណុំរឿងចាស់ ៨២សំណុំរឿង និងសំណុំ

រឿងថ្មី ២៩៣សំណុំរឿង) មានជនរងគ្រោះចំនួន ៣៨៥នាក់ ស្រី ២៦៥នាក់ ជនជាប់ចោទចំនួន ៥៦៩នាក់ ស្រ្តី ៥០នាក់ ក្នុងនោះ បានចាត់ការរួចចំនួន ២៧០សំណុំរឿង និងកំពុងចាត់ការចំនួន ១០៥សំណុំរឿង។

១៥៧. ចំពោះកិច្ចការពារជនរងគ្រោះ ការផ្តល់សេវាគាំទ្រ និងស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងការធ្វើមាតុភូមិនិវត្តន៍ ក្រុមការងារការពារជនរងគ្រោះនៃ គ.ជ.ប.ជ. បានសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងនៅក្នុងប្រទេស និងក្រៅប្រទេសសរុបចំនួន ៣៥៥នាក់ (ស្រី ២៥២នាក់ អនីតិជន ៨៤នាក់) និងបានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះទៅទទួលសេវាគាំទ្រ និងស្តារនីតិសម្បទានៅមណ្ឌលរបស់រដ្ឋ និងអង្គការដៃគូ ព្រមទាំងបានសមាហរណកម្មជនរងគ្រោះទៅក្នុងសហគមន៍វិញចំនួន ២០០នាក់ (ស្រី ១៥៦នាក់ កុមារ ៣៥នាក់)។ គ.ជ.ប.ជ. ក៏បានសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ជនបរទេសទៅប្រទេសដើមវិញចំនួន ២៨នាក់ (ស្រី ២៤នាក់) និងការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរជាជនរងគ្រោះ និងបុគ្គលសង្ស័យថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងការរំលោភបំពានផ្លូវភេទពីប្រទេសថៃចំនួន ៣៨នាក់ (ស្រី ១៤នាក់ អនីតិជន ១១នាក់)។

១៥៨. ការបង្ក្រាបសកម្មភាពជនទំនើង ក្រសួងមហាផ្ទៃបានដាក់ចេញ និងជំរុញអនុវត្តម៉ឺងម៉ាត់នូវវិធានការបង្ការ ទប់ស្កាត់ក្រុមសង្គមងងឹត និងក្រុមក្មេងទំនើងដែលអាចបង្កឱ្យមានភាពអនាធិបតេយ្យក្នុងសង្គមជាតិ ក្នុងនោះ សមត្ថកិច្ចបង្ក្រាបសកម្មភាពជនទំនើងបានចំនួន ៩៩១លើក មនុស្សចំនួន ៣ ៦០៧នាក់ ។

| បរិយាយ | បង្ក្រាប | ឃាត់ខ្លួន | អនុវត្តវិធានការច្បាប់ | អនុវត្តវិធានការរដ្ឋបាល |
|---|---|---|---|---|
| ឆ្នាំ២០២៤ | ១ ៦១១ ករណី | ៥ ២៦៤ នាក់ | ២ ៨០២ នាក់ | ២ ៤៦២ នាក់ |
| ឆ្នាំ២០២៥ | ៩៩១ ករណី | ៣ ៦០៧ នាក់ | ២ ៣៥៥ នាក់ | ១ ២៣៨ នាក់ |

១៥៩. ក្រសួងមហាផ្ទៃ៖ ស្ថានភាពជនជាប់ឃុំមានការប្រែប្រួលជាអាទិ៍ ដូចជា ទទួលចូលថ្មីចំនួន ៣២ ៦៨៧នាក់ ស្រ្តី ២ ២៧៦នាក់ អនុវត្តដីកាដោះលែងចំនួន ២៣ ៩៨០នាក់ ស្រ្តី ១ ៥៣៣នាក់ ស្លាប់ចំនួន ៣០០នាក់ ស្រ្តី ៦នាក់ ផ្ទេរទៅមណ្ឌលយុវនីតិសម្បទាចំនួន ៤៨៨នាក់ ។ គិតត្រឹមថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ជនជាប់ឃុំមានចំនួនសរុប ៦១ ៧៨៣នាក់ ស្រ្តី ៣ ៩៨០នាក់ ។ បានអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនជនជាប់ឃុំទៅកាន់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់សរុបចំនួន ៧០ ៧១៣ដីកា ស្មើ ១២០ ៨៦៩នាក់ ស្រ្តី ៧ ៩០៧នាក់ ។

| បរិយាយ (នាក់) | ជនត្រូវចោទ | ជនជាប់ចោទ | ពិរុទ្ធជន | ទណ្ឌិត | បទល្មើសរួមមាន |
|---|---|---|---|---|---|
| សរុប | ១១ ៦២១ | ៦ ៥១០ | ២៣ ០៧២ | ២០ ៥៨០ | បទល្មើសគ្រឿងញៀន ៥០,៧១%<br>លួចមានស្ថានទម្ងន់ទោស ៨,១៤%<br>លួច ១១,៣៦%<br>រំលោភសេពសន្ថវៈ ៤,៥៥%<br>មនុស្សឃាត និងឃាតកម្ម ៣,៦៧%<br>និងបទល្មើសផ្សេងៗ ២១,៥៧% ។ |
| ស្រី | ៨៩២ | ៤៦៣ | ១ ៤២៥ | ១ ២០០ | |
| ជនបរទេស | ១ ៦៣០ | ៧៦០ | ១ ៦៥៤ | ៩២៥ | |
| អនីតិជន | ១ ០៩៦ | ៦៦១ | ១ ៣៨៧ | ៧៦៥ | |

១៦០. បច្ចុប្បន្ននេះ កម្ពុជាមានបណ្តាញទូរសព្ទចំនួន ២ខ្សែសំខាន់ៗដែលផ្តល់សេវាជួយកុមារ ក្នុងនោះមានបណ្តាញទូរសព្ទទាន់ហេតុការណ៍ ១២៨៨ របស់នគរបាលជាតិ និងបណ្តាញទូរសព្ទជំនួយកុមារ ១២៨០ របស់អង្គការបណ្តាញទូរសព្ទជំនួយកុមារកម្ពុជា។ ក្រៅពីបណ្តាញទូរសព្ទទាន់ហេតុការណ៍ទាំងពីរនេះ ក៏មានបណ្តាញទូរសព្ទទាន់ហេតុការណ៍មួយចំនួនផ្សេងទៀត ផ្តល់ដោយអង្គការដៃគូដែលធ្វើការពាក់ព័ន្ធនឹងកុមារផងដែរ។

១៦១. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញឆានែលតេលេក្រាម ដើម្បីឆ្លើយតបរាល់សំណួរពាក់ព័ន្ធនឹងវិស័យការងារ ដូចជា https://t.me/KhmerWorkerChat (សម្រាប់កម្មករនិយោជិត) និង https://t.me/EmployerChat (សម្រាប់និយោជក)។ រាល់ករណីសង្ស័យប្រើប្រាស់ពលកម្មកុមារ សាធារណជនអាចទំនាក់ទំនង ឬរាយការណ៍តាមរយៈខ្សែទូរស័ព្ទទាន់ហេតុការណ៍លេខ១២៨៦ ឬ១២៩៧ និងប្រអប់បណ្តឹងអនាមិករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់អន្តរាគមន៍ក្នុងរយៈពេល ២៤ ម៉ោង។

១៦២. បន្ថែមពីលើនេះ ក្នុងឆ្នាំ២០២៥ ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនបានពង្រីកយន្តការបណ្តាញទូរសព្ទទាន់ហេតុការណ៍ និងការរាយការណ៍តាមអនឡាញ (Online) បន្ថែមទៀត រួមមាន **ក្រសួងមហាផ្ទៃ** អគ្គស្នងការដ្ឋាននគរបាលជាតិបានបង្កើតប្រព័ន្ធទទួលបណ្តឹងតាមគេហទំព័រ "Hotline Scam Reporting 24/7" និងបន្តដំណើរការទូរសព្ទទាន់ហេតុការណ៍ Hotline ១១៧ ដែលបានទទួលព័ត៌មាន និងអន្តរាគមន៍ដោះស្រាយបានចំនួន ២ ១១៣លើក។ ទន្ទឹមនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មបានដាក់ឱ្យប្រើប្រាស់ Hotline ១២៧១ និងកម្មវិធីទូរសព្ទ GDI e-Service ខណៈដែលអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានបង្កើតប្រព័ន្ធ Hotline និងអ៊ីមែល (hotline@immigration.gov.kh) សម្រាប់រាយការណ៍ និងសុំអន្តរាគមន៍ដោះស្រាយបញ្ហានានា។ **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** បានដាក់ឱ្យប្រើប្រាស់លេខទូរសព្ទទាន់ហេតុការណ៍ Hotline ៦៧៨៩ សម្រាប់សាធារណជនសាកសួរព័ត៌មាន រាយការណ៍ពីសកម្មភាពគួរឱ្យសង្ស័យ ឬប្តឹងតវ៉ាពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍។[13] **ក្រសួងទេសចរណ៍** បានដាក់ឱ្យដំណើរការប្រព័ន្ធ Hotline ១២២១ សម្រាប់បម្រើដល់ការរាយការណ៍ និងសាកសួរព័ត៌មានទាក់ទងនឹងវិស័យទេសចរណ៍យ៉ាងឆាប់រហ័ស។[14]

## ៥.៣. ការផ្តល់ជំនួយ និងសេវាគាំទ្រ

១៦៣. **ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ៖** បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់គ្រួសាររងគ្រោះដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយ ដោយយថាហេតុនៅតាមសហគមន៍សរុបចំនួន ៥០ ១៧១គ្រួសារ មានការកើនឡើង១៥ ២៧៧គ្រួសារ ស្មើនឹង ៤៤% បើធៀបនឹងលទ្ធផលឆ្នាំ ២០២៤។

១៦៤. **ការងារជនអនាថា និងជនផ្ទុកមេរោគអេដស៍៖** បានផ្តល់សេវាពិគ្រោះយោបល់ ដោះស្រាយ ទប់ស្កាត់ និងការពារដល់ជនអនាថាសរុបចំនួន ១ ១៤៥នាក់ កើនឡើង ៨៧% ធៀបនឹងឆ្នាំ២០២៤ និងបានធ្វើសមាហរណកម្មឬបង្រួបបង្រួមទៅគ្រួសារ និងសហគមន៍វិញចំនួន ១ ១៤៥នាក់។ បានប្រឹក្សាយោបល់ ថែទាំ គាំទ្រជនរងគ្រោះ ដែលរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ចំនួន ២៥០នាក់។

---

[13] របាយការណ៍សង្ខេបលទ្ធផលការងាររយៈពេល ៥ឆ្នាំ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

[14] ក្រសួងទេសចរ របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារ_ឆ្នាំ២០២៥_និងលើកទិសដៅការងារ

១៦៥. មជ្ឈមណ្ឌលជនវិបល្លាសស្មារតីបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅសរុបចំនួន ១២៩នាក់ និងបានសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញចំនួន ៦៦នាក់។ បើគិតពីឆ្នាំ២០២១មក មានជនវិបល្លាសស្មារតីសរុបចំនួន ៣៥០នាក់ កំពុងស្នាក់នៅព្យាបាល។ បន្ថែមពីលើនេះ នៅក្នុងឆ្នាំ២០២៥ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) ក៏បានចុះពិនិត្យស្ថានភាពសិទ្ធិមនុស្សដោយផ្ទាល់ និងជាទៀងទាត់នៅតាមមណ្ឌលស្តារនីតិសម្បទានានា រួមទាំង "មជ្ឈមណ្ឌលថែទាំ និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី" ផងដែរ ដោយបានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអង្គការសង្គមស៊ីវិល ដើម្បីធានានូវការគោរពសិទ្ធិមនុស្ស ការថែទាំ និងការដោះស្រាយស្វែងរកយុត្តិធម៌ជូនជនរងគ្រោះឱ្យបានត្រឹមត្រូវ។[15]

១៦៦. លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ដោយបានធ្វើបច្ចុប្បន្នភាពទិន្នន័យអនីតិជនទំនាស់នឹងច្បាប់នៅតាមពន្ធនាគារ មណ្ឌលអប់រំកែប្រែរាជធានី ខេត្ត និងមណ្ឌលយុវនីតិសម្បទា មានអនីតិជនសរុបចំនួន ៤ ៤០៨នាក់ ស្រី ១៥៧នាក់ (ទណ្ឌិត ១ ១៩៥នាក់ ស្រី ២៨នាក់ ពិរុទ្ធជន ៣ ២១៣នាក់ ស្រី ២៩នាក់)។ បន្ថែមពីនេះ បានទទួលអនីតិជនទំនាស់នឹងច្បាប់ស្នាក់នៅដើម្បីស្តារនីតិសម្បទាសរុបចំនួន ៩២៣នាក់ និងបានធ្វើសមាហរណកម្មចំនួន ៣៣១នាក់។ ទន្ទឹមនេះ ក៏បានអនុវត្តកម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់ ដោយក្នុងនោះរួមមាន៖ (១).ដំណាក់កាលរៀបចំរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ ចំនួន ១៨៤ករណី។ (២).ដំណាក់កាលចូលរួមស្តាប់ចម្លើយក្នុងសវនាការចំនួន ៨៩៩ករណី។ (៣).ដំណាក់កាលបង្វែរចំនួន ៤៦ករណី និងវិធានការផ្សេងទៀតក្រៅពីឃុំខ្លួនអនីតិជនទំនាស់នឹងច្បាប់ចំនួន ៤៩ករណី។ (៤).សមាហរណកម្មអនីតិជនចំនួន ១ករណី។ (៥).បិទករណីអនីតិជនដោយជោគជ័យចំនួន ១៤ករណី (បង្វែរ ៣ករណី និងប្រព្រឹត្តបទល្មើសសាជាថ្មី ១ករណី)។ (៦).អនីតិជនជាទណ្ឌិតទទួលបានការបន្ធូរបន្ថយទោស និងលើកលែងទោសចំនួន ២០នាក់ ក្នុងឱកាសពិធីបុណ្យឯករាជ្យជាតិ និងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីត និងសំពះព្រះខែ អកអំបុក។ បន្ថែមពីលើសមិទ្ធផលទាំងនេះ យោងតាមវឌ្ឍនភាពឆ្នាំ២០២៥ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) បានបន្តយកចិត្តទុកដាក់ចុះពិនិត្យស្ថានភាពសិទ្ធិមនុស្សជាទៀងទាត់នៅតាមពន្ធនាគារ និង "មណ្ឌលយុវនីតិសម្បទា" ដើម្បីធានាការគោរពសិទ្ធិ និងជួយសម្របសម្រួលស្វែងរកយុត្តិធម៌ជូនពួកគេ។ ដោយឡែក នៅក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលក៏បានពិនិត្យ និងរៀបចំសំណើសុំបន្ធូរបន្ថយទោស និងលើកលែងទោសដល់ជនជាប់ឃុំទូទៅសរុបចំនួន ១ ៨០៥នាក់ ផងដែរ។

១៦៧. ក្នុងឆ្នាំ២០២៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានផ្តល់បណ្ណពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋានជូនជនមានពិការភាពចំនួន ១៣ ៨៩៣នាក់បន្ថែមទៀត។

១៦៨. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តគម្រោងកិច្ចអន្តរាគមន៍ស្នូល ដែលជាយុទ្ធសាស្ត្រទប់ស្កាត់មួយ ត្រូវបានបង្កើតឡើងដោយមានការផ្សាភ្ជាប់ទៅនឹងមូលហេតុដែលនាំឱ្យមានការប្រើប្រាស់ពលកម្មកុមារ និងផ្សាភ្ជាប់ទៅជាមួយវិធានការក្នុងការកាត់បន្ថយភាពក្រីក្រដែលអាចអនុវត្តបាន ដើម្បីទប់ស្កាត់ការពារកុមារងាយរងគ្រោះ និងបន្តគាំពារដល់កុមារ និងគ្រួសារងាយរងគ្រោះ តាមរយៈវិធានការចំនួន ២ រួមមាន៖ (១).ការជំរុញលើកទឹកចិត្ត និងផ្តល់ឱកាសអប់រំ លើកកម្ពស់បំណិនជីវិត បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ តាមរយៈការផ្តល់សម្ភារៈសិក្សា មធ្យោបាយធ្វើដំណើរវគ្គបំប៉ន និងអាហាររូបករណ៍ ព្រមទាំងលើកកម្ពស់

[15] របាយការណ៍សកម្មភាពការងាររបស់គ_ស_ម_ក_ប្រចាំឆ្នាំ២០២៥ ទំព័រទី ៣ និងទី ៤

សុខុមាលភាពកុមារ តាមរយៈការផ្តល់អាហាររូបត្ថម្ភដល់កុមារដែលចូលរៀនវគ្គបំប៉ន និង(២).ការលើកស្ទួយជីវភាពគ្រួសាររបស់កុមារ តាមរយៈការបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ។ ក្នុងឆ្នាំ២០២៥ កុមារសរុប ៤០០នាក់ ស្រី ១៨២នាក់ ដែលត្រូវបានទប់ស្កាត់ពីការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាសផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម ក្នុងខេត្តគោលដៅចំនួន៧ខេត្ត រួមមានខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ និងកុមារចំនួន ២០០នាក់ ត្រូវបានបន្តការគាំពារ តាមរយៈការផ្តល់ជាសម្ភារៈសិក្សា និងវគ្គបំប៉នមុនចូលរៀនបន្ថែម។ ទន្ទឹមនឹងនេះ កុមារដែលមានអាយុពី១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ និងក្រុមគ្រួសារកុមារ ត្រូវបានលើកកម្ពស់បំណិនជីវិត តាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងផ្តល់សម្ភារៈ ឬមធ្យោបាយក្នុងការផ្តល់ឱកាសបង្កើតមុខរបរ ព្រមទាំងការផ្តល់នូវពូជសត្វ ពូជបន្លែ និងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដើម្បីលើកស្ទួយជីវភាពគ្រួសារ។

១៦៩. តាមរយៈការអនុវត្តកម្មវិធីគាំពារសង្គម ជនមានពិការភាពចំនួន ៥៥ ៥៥៩នាក់ កំពុងទទួលផលពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ទន្ទឹមនឹងនេះ យុវជនដែលមានពិការភាពចំនួន ៨១៥នាក់ ក៏ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដោយឥតគិតថ្លៃ ព្រមទាំងទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋពីកម្មវិធីជាតិជំនួយសង្គមផងដែរ។ លើសពីនេះ ជនមានពិការភាពចំនួន ៣៨៤នាក់ កំពុងទទួលផលពីកម្មវិធីស្តារជីវភាពឡើងវិញសម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជន នៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង ខេត្តសៀមរាប។ ទោះជាយ៉ាងណា ជុំវិញការអនុវត្ត "កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ" នេះ យោងតាមវឌ្ឍនភាពឆ្នាំ២០២៤-២០២៥ រាជរដ្ឋាភិបាលតាមរយៈមូលនិធិជាតិជំនួយសង្គម បានពង្រីកការគ្របដណ្តប់កាន់តែធំ ដោយបានផ្តល់អាហារូបករណ៍ថ្នាក់បឋមសិក្សាដល់កូនចៅគ្រួសារក្រីក្រដែលមានប័ណ្ណសមធម៌សរុបចំនួន ៣៥៧ ៥៧៤នាក់ (ស្រី ១៧៨ ៧០១នាក់) បន្ថែមទៀត។

១៧០. ស្របពេលជាមួយគ្នានេះ សម្រាប់ការលើកកម្ពស់ការអប់រំ និងវិជ្ជាជីវៈដល់ជនមានពិការភាព ក្រសួងអប់រំ យុវជន និងកីឡាក៏បានយកចិត្តទុកដាក់ផ្តល់ការអប់រំពិសេសដល់សិស្សមានពិការភាពសរុបចំនួន ១ ២២៥នាក់ (ស្រី ៥៤៣នាក់) ព្រមទាំងបានជួយគាំទ្របណ្តុះបណ្តាលនិស្សិតមានពិការភាពចំនួន ៣៣៦នាក់ ឱ្យទទួលបានការងារធ្វើប្រកបដោយនិរន្តរភាពផងដែរ។[16]

១៧១. តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ សរុបចំនួន ៣៥៥នាក់។ ជាមួយគ្នានេះ ក្រសួងក៏បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេសចំនួន ២៦៤នាក់ បានជួយធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះទៅប្រទេសដើមវិញចំនួន ២៨នាក់ ព្រមទាំងបានទទួលជនរងគ្រោះដែលនិរទេសពីប្រទេសថៃចំនួន ៧ ៩៩០នាក់ និងទទួលជនរងគ្រោះ និងងាយរងគ្រោះស្នាក់នៅក្នុងមណ្ឌលសំចតសរុបចំនួន ២ ០៥៤នាក់។

១៧២. សម្រាប់ការស្តារនីតិសម្បទា ក្រសួងបានសហការបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ទៅទទួលសេវាស្នាក់នៅ និងស្តារនីតិសម្បទាតាមមណ្ឌលរបស់អង្គការដៃគូសរុបចំនួន ៣៥៥នាក់។ បន្ថែមពីនេះ ក្រសួងបានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះទៅ

[16] របាយការណ៍សន្និបាតក្រសួងអប់រំ ឆ្នាំ២០២៥

គ្រួសារ និងសហគមន៍វិញបានចំនួន ២០០នាក់ បានចុះតាមដានជនរងគ្រោះក្រោយធ្វើសមាហរណកម្ម ចំនួន ៤៣៦នាក់ និងបានបិទករណីចំនួន ១០៧នាក់។

១៧៣. ក្រសួងកិច្ចការនារី៖ ក្រុមការងារជំនាញនាយកដ្ឋានការពារផ្លូវច្បាប់ បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្ត និងអន្តរាគមន៍ដល់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ការគំរាមចែកចាយ រូបអាសអាភាសបានចំនួន ០៨ករណី មានជនល្មើស ០៩នាក់ ត្រូវតុលាការសាលាដំបូងសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពី ៥-៧ឆ្នាំ និងសងសំណងទៅដល់ជនរងគ្រោះសរុបចំនួន ១០៦ ០០០ ០០០រៀល។

១៧៤. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងលេខាធិការដ្ឋាន គ.រ.ប.ជ./គ.ខ.ប.ជ. សហការជាមួយអង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ ផ្តល់សេវាផ្នែកច្បាប់ កិច្ចការពារ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ធ្វើសមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុបចំនួន ២០០នាក់ (ស្ត្រី ១៥៦នាក់ និងកុមារ ៣៥នាក់)។ បានសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ជនបរទេសទៅប្រទេសដើមវិញមានចំនួន ២៨នាក់ (ស្ត្រី ២៤នាក់) និងការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរជាជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះពីប្រទេសថៃចំនួន ៣៨នាក់ (ស្ត្រី ១៤នាក់ អនីតិជន ១១នាក់)។ បានតាមដានករណីជនរងគ្រោះ និងងាយរងគ្រោះ ក្រោយពីធ្វើសមាហរណកម្មទៅសហគមន៍វិញចំនួន ៤៣៦នាក់។ បានបិទករណីនៃការផ្តល់សេវាដល់ជនរងគ្រោះ និងងាយរងគ្រោះសរុបចំនួន ១០៧នាក់។

១៧៥. អ្នកញៀនគ្រឿងញៀនសល់ក្នុងឆ្នាំ២០២៤ នៅតាមមជ្ឈមណ្ឌល និងមណ្ឌលនានា (រដ្ឋ ឯកជន និងអង្គការ សរុប ១៩កន្លែង) មានចំនួន ៨ ៦៨២នាក់ និងចូលថ្មីក្នុងឆ្នាំ២០២៥ មានចំនួន ១៩ ៤២៨នាក់ សរុបមានចំនួន ២៨ ១១០នាក់។ ក្នុងនោះ កំពុងបន្តសម្រាកព្យាបាល និងស្តារនីតិសម្បទានៅក្នុងមជ្ឈមណ្ឌល មណ្ឌលមានចំនួន ៨ ៧៨៨នាក់ និងបានធ្វើសមាហរណកម្មចូលក្នុងគ្រួសារ និងសហគមន៍វិញសរុបចំនួន ១៩ ៣២២នាក់ (ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះចំនួន ១ ៥២៥នាក់ ផងដែរ)។

១៧៦. ដោយឡែក អគ្គនាយកដ្ឋានពន្ធនាគារបានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសន្តិសុខ និងការគ្រប់គ្រងពន្ធនាគារនិងមណ្ឌលអប់រំកែប្រែឱ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ តាមរយៈការត្រួតពិនិត្យ ឆែកឆេរបន្ទប់ឃុំឃាំង និងខ្លួនប្រាណជនជាប់ឃុំជាប្រចាំ ដើម្បីទប់ស្កាត់ការលួចនាំចូលគ្រឿងញៀន និងសម្ភារៈហាមឃាត់ផ្សេងៗ។ ទន្ទឹមនេះ អង្គភាពកំពុងរៀបចំបំពាក់ឧបករណ៍ផ្តាច់ប្រព័ន្ធសេវាទូរសព្ទ (នៅមណ្ឌលអប់រំកែប្រែទី១) ដើម្បីកាត់ផ្តាច់ទំនាក់ទំនងបទល្មើសពីក្នុងពន្ធនាគារមកខាងក្រៅ។ បច្ចុប្បន្ន ជនជាប់ឃុំដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនមានអត្រារហូតដល់ ៥០,៧១% នៃជនជាប់ឃុំសរុប ហើយក្នុងឆ្នាំ២០២៥ នេះ ជនជាប់ឃុំចំនួន ៣៧៧នាក់ ត្រូវបានដាក់ឱ្យស្ថិតក្នុងការព្យាបាលផ្លូវចិត្ត និងព្យាបាលផលប៉ះពាល់ពីគ្រឿងញៀន/គ្រឿងស្រវឹង និងត្រូវបន្តពិចារណាលើវិធានការគ្រប់គ្រងជនល្មើសពាក់ព័ន្ធគ្រឿងញៀនដាច់ដោយឡែកពីទណ្ឌិត ឬពិរុទ្ធជនដទៃទៀត។

១៧៧. ក្រសួងសុខាភិបាល បានខិតខំលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈក្នុងការបន្សាបនិងព្យាបាល ព្រមទាំងពង្រីកសេវាបន្សាប ព្យាបាលដោយផ្អែកលើសហគមន៍ នៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ដើម្បីចូលរួមចំណែកកាត់បន្ថយការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀននៅតាមមូលដ្ឋាន។ ជាក់ស្តែងក្នុងឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលសាធារណៈដែលផ្តល់សេវាព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន បានកើន

ឡើងដល់ ៥៥៦កន្លែង (កើនពី ៤៥៨កន្លែង ក្នុងឆ្នាំ២០២៤) និងបានផ្តល់សេវាពិនិត្យពិគ្រោះ និងព្យាបាលអ្នកញៀនគ្រឿងញៀនសរុបចំនួន ៧ ៤២៨ករណី (ស្រី ៥៦៥ករណី)។ ទន្ទឹមនេះ ក្រសួងក៏បានបណ្តុះបណ្តាលបង្កើនសមត្ថភាពបច្ចេកទេសទាក់ទងការផ្តល់សេវាសុខភាពផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនដល់គ្រូពេទ្យ និងគិលានុបដ្ឋាកនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកបានចំនួន ១៧៤នាក់ និងការគ្រប់គ្រងវិបត្តិបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនលើសកម្រិតចំនួន ៤៩នាក់ ផងដែរ។

១៧៨. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននិងកំពុងពង្រឹងនិងពង្រីកសមត្ថភាពមជ្ឈមណ្ឌលជាតិ ព្រមទាំងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋបន្ថែមទៀត ដើម្បីត្រៀមទទួលជនរងគ្រោះ ដែលប្រមូលបានឬរកឃើញតាមរយៈការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់ ក្នុងយុទ្ធនាការនេះ និង/ឬតាមការស្នើសុំដោយស្ម័គ្រចិត្តពីសំណាក់ក្រុមគ្រួសារនិងជនរងគ្រោះ។ ក្នុងឆ្នាំ២០២៥ មជ្ឈមណ្ឌលរដ្ឋ មណ្ឌលឯកជន និងអង្គការសរុបចំនួន ១៩កន្លែង បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនឱ្យស្នាក់នៅ បន្សាប ព្យាបាល និងស្តារនីតិសម្បទាចំនួន ១៩ ៤២៨នាក់ (ស្រី ១ ១៦៧នាក់) ព្រមទាំងបានបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពួកគេចំនួន ១ ៥២៥នាក់ ផងដែរ។ បន្ថែមលើនេះ ក្រសួងក៏បានរៀបចំសេចក្តីព្រាងអនុក្រឹត្យបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមតំបន់ភូមិភាគថែមទៀតផង។

១៧៩. **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានជំរុញការអប់រំផ្សព្វផ្សាយស្តីពី ការបង្ការ និងទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងគ្រឿងញៀនដល់សិស្ស និស្សិត កម្មករនិយោជិតនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ ក្រោមឱវាទក្រសួង ដែលមានអ្នកចូលរួមសរុបចំនួន ៦៧ ៩៤៥នាក់ (ស្រី ៣៦ ៥០៦នាក់)។ ក្រសួងបានបណ្តុះបណ្តាលជនញៀនគ្រឿងញៀន នៅក្នុងមណ្ឌលបន្សាបគ្រឿងញៀនចំនួន ២១៤៨នាក់ (ស្រី១៤៦នាក់) អ្នកទោសក្នុងពន្ធនាគារចំនួន ២១២១នាក់ (ស្រី ១៣៤នាក់) និងជនមានពិការភាពចំនួន ៥៨៧នាក់ ស្រី ២៩៤នាក់។

១៨០. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមានយន្តការគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀន ដោយត្រូវប្រមូលទិន្នន័យឱ្យបានច្បាស់លាស់អំពីមុខសញ្ញាប្រើប្រាស់ និងងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន។ ទន្ទឹមគ្នានោះ ត្រូវជំរុញនិងលើកទឹកចិត្តអ្នកដែលមិនទាន់ទទួលបានការព្យាបាល ឱ្យទៅទទួលយកការព្យាបាល និងត្រូវចាត់វិធានការតាមដានគ្រប់គ្រងចំពោះបុគ្គលដែលបានធ្វើសមាហរណកម្មចូលក្នុងសហគមន៍ (ឆ្នាំ២០២៥ មានចំនួន ១៩ ៣២២នាក់) បន្ទាប់ពីចាកចេញពីមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យវិលត្រឡប់ទៅសេពគ្រឿងញៀនវិញ។

១៨១. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាព និងលើកសំណើដើម្បីបង្កើតនូវមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅមូលដ្ឋានរបស់ខ្លួន។

១៨២. លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន៖ មជ្ឈមណ្ឌលរដ្ឋ មណ្ឌលឯកជន និងអង្គការសរុបចំនួន ១៩កន្លែង បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចូលថ្មីក្នុងឆ្នាំ២០២៥ ចំនួន ១៩ ៤២៨នាក់ (ស្រី ១ ១៦៧នាក់) ឱ្យស្នាក់នៅបន្សាប ព្យាបាល និងស្តារនីតិសម្បទា និងបានបញ្ចេញ (ធ្វើ

សមាហរណកម្ម) ជនរងគ្រោះចំនួន ១៩ ៣២២នាក់ (ស្រី ១ ២៤៨នាក់) ដូចនេះនៅសល់ជាក់ស្តែងកំពុងសម្រាកព្យាបាលចំនួន ៨ ៧៨៨នាក់ (ស្រី ៤៥២នាក់)។

១៨៣. ការងារគាំពារកុមាររបស់កាកបាទក្រហមកម្ពុជា (កក្រក) ក្នុងឆ្នាំ២០២៥ និងបូកបន្ថែមការងារទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ និងការអប់រំផ្សព្វផ្សាយការលើកកម្ពស់សុវត្ថិភាពចរាចរណ៍ដល់កុមារតាមសាលារៀន ដូចខាងក្រោម៖

១៨៤. សិស្សានុសិស្សចំនួន ១.៣១០នាក់ (ស្រី៩២៩នាក់) ទទួលបានវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ ចំនួន ១៩វគ្គ ពីសាខាកាកបាទក្រហមកម្ពុជា ខេត្តក្រចេះ កំពត ពោធិ៍សាត់ រតនគិរី និងព្រះវិហារ បន្ទាប់ពីទទួលបានចំណេះដឹងនេះ សិស្សានុសិស្សទាំងអស់ ដែលជាកុមារវ័យជំទង់ បានបន្តផ្សព្វផ្សាយដល់មិត្តភ័ក្ត សាច់ញាតិ និងក្រុមគ្រួសាររបស់ខ្លួនឱ្យយល់ដឹងពីហានិភ័យនៃការកេងប្រវ័ញ្ច និងការរំលោភបំពានតាមអនឡាញ និតិវិធីដោះស្រាយ និងរបៀបរាយការណ៍ពេលមានករណីរំលោភបំពានកើតឡើង។

១៨៥. ក្នុងកំឡុងពេល និងក្រោយពេលមានជម្លោះព្រំដែនកម្ពុជា-ថៃ យុវជនកាកបាទក្រហមកម្ពុជា ដែលភាគច្រើនពួកគេក៏ជាកុមារវ័យជំទង់ ចំនួន ៣៤៦នាក់ (ស្រី១០៥នាក់) បានទទួលការបណ្តុះបណ្តាលបន្ថែមពីកាកបាទក្រហមកម្ពុជា ស្តីពីការបង្ការនិងចេះការពារខ្លួនពីការរំលោភបំពានផ្លូវភេទ ការពារផ្សែងពុល និងការបង្ការគ្រាប់មីន-យុទ្ធភណ្ឌមិនទាន់ផ្ទុះ បានចុះទៅអប់រំផ្សព្វផ្សាយបន្តជូនដល់កុមារា កុមារី និងក្រុមគ្រួសារជនភៀសសឹកឱ្យចេះថែរក្សាសុវត្ថិភាពក្មេងស្រី ក្មេងប្រុស ពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទគ្រប់ទម្រង់ដែលអាចកើតមានឡើងក្នុងពេលស្នាក់នៅជំរំជនភៀសសឹកប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ។

១៨៦. កុមារា កុមារីចំនួន៩.៧០៨នាក់ (ស្រី៥.៦១៧នាក់) បានទទួលចំណេះដឹង ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក និងកត្តាគួរអនុវត្តន៍ពេលប្រើប្រាស់ផ្លូវគោក ពីសាខាកាកបាទក្រហមកម្ពុជា ចំនួន១៥ រួមមាន សាខាខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ ព្រៃវែង រតនគិរី កំពត ក្រចេះ ព្រះវិហារ ស្វាយរៀង តាកែវ កណ្តាល ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និងរាជធានីភ្នំពេញ។

១៨៧. ដើម្បីលើកកម្ពស់សុខភាពកុមារ និងជួយសង្គ្រោះកុមារពីជំងឺធ្ងន់ និងមិនធ្ងន់នានា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ម៉ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា បានសម្រេចបន្តផ្តល់ថវិកាជូនមន្ទីរពេទ្យ ចំនួន៣ មណ្ឌលកុមារកំព្រាចំនួន២ និងគ្រួសារកុមារក្រីក្រជាច្រើនគ្រួសារទៀត ក្នុងនោះរួមមាន៖

- មន្ទីរពេទ្យហ្លួងម៉ែ (មន្ទីរពេទ្យជាតិឯកទេសព្យាបាលជំងឺមហារីក) ថវិកាចំនួន ៥លានដុល្លារអាម៉េរិក។
- មូលនិធិគន្ធបុប្ផាកម្ពុជា (លើកទី៨) និងមន្ទីរពេទ្យកុមារគន្ធបុប្ផា(លើកទី១៤) ថវិកា ១លានដុល្លារអាម៉េរិក។
- មន្ទីរពេទ្យកុមារអង្គរ (លើកទី៨) ថវិកា ៥ម៉ឺនដុល្លារអាម៉េរិក។ ព្រមទាំងបានរៀបចំទិវាសុខភាពមាតា ទារក កុមារ ដើម្បីផ្សព្វផ្សាយការថែទាំសុខភាពពេលមានផ្ទៃពោះ ក្រោយសម្រាល និងការរីករាលដាលនៃជំងឺអេសដ៍ជូនស្ត្រីទើបសម្រាលកូនរួច និងស្ត្រីមានផ្ទៃពោះ ៤០ ០៤០នាក់ ដើម្បីធានាថាទារក និងកុមារមានសុខភាព និងការថែទាំសុខភាពក្នុងសហគមន៍ផ្សេងទៀត ។

- ផ្តល់អំណោយជាស្បៀង សម្ភារៈ និងថវិកាជូនដល់កុមារដែលកំពុងស្នាក់នៅក្នុងមណ្ឌលកុមារកំព្រាមែកឈើ១៨៦នាក់ អង្គការផ្ទះបាយកុមារចំនួន២៥០នាក់ និងគ្រួសារកុមារក្រីក្រ ស្ត្រីមេម៉ាយមានកូនច្រើន គ្រួសារចាស់ជរា ចំនួន ៣៦.៣៩៥ គ្រួសារ។
- ផ្តល់អំណោយមនុស្សធម៌ជូនគ្រួសារកុមារភៀសសឹក ២៩.៤៩៦គ្រួសារ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ព្រមទាំងចុះអប់រំពីសុខភាព អនាម័យ បរិស្ថាន ការរស់នៅស្អាត ហូបស្អាត និងការពារជំងឺឆ្លង និងមិនឆ្លងនានា។

១៨៨. ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់៖ ក្នុងឆ្នាំ២០២៥ កម្មវិធីជាតិជំនួយសង្គម ផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ មានយុវជនដែលបានចូលមកសិក្សាជំនាញ និងទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីមានចំនួនសរុប ១៧ ៧៧៩នាក់ (ក្នុងនោះយុវជនមានពិការភាពចំនួន ៨១៥នាក់) ដោយចំណាយថវិកាសរុបចំនួន ៣៣ ២១០ ៤៣៨ ០០០រៀល (ស្មើនឹង ៨ ៣០២ ៦១០ដុល្លារអាម៉េរិក)។

១៨៩. ចំពោះកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ក្នុងឆ្នាំ២០២៥ គ្រួសារគោលដែលបានចុះឈ្មោះទទួលផលមានចំនួនសរុប ៧២៥ ៤៣៤គ្រួសារ ដែលក្នុងនោះរួមមាន ជនចាស់ជរាចំនួន ៤៣៩ ៩៩២នាក់ ជនមានពិការភាពចំនួន ៥៥ ៥៥៩នាក់ និងអ្នកផ្ទុកមេរោគ/កើតជំងឺអេដស៍ចំនួន ៦ ០៣១នាក់ សិស្សានុសិស្សចំនួន ៤៦៧ ១៧៤នាក់។ ស្ត្រីមានផ្ទៃពោះចំនួន ៤៤ ៤០៤នាក់ និងកុមារអាយុក្រោម២ឆ្នាំចំនួន ១៤ ៥០៧នាក់។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏បានផ្តល់ប្រាក់ឧបត្ថម្ភជូន ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះចំនួន ៦៥នាក់ និងកូនអាយុក្រោម២ឆ្នាំតាមម្តាយក្នុងពន្ធនាគារចំនួន ៨៨នាក់ ព្រមទាំងបានអនុវត្តកម្មវិធីស្តារជីវភាពជូនគ្រួសារផ្លាស់ប្តូរលំនៅឋាននៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែងចំនួន ៩ ៨៥៣គ្រួសារ (ក្នុងនោះមានកុមារអាយុក្រោម៥ឆ្នាំចំនួន ៤ ១៥៩នាក់) ផងដែរ។ ដើម្បីអនុវត្តកម្មវិធីឱ្យទទួលបានជោគជ័យ មូលនិធិជាតិជំនួយសង្គមបានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រមូលនិធិជាតិជំនួយសង្គម ២០២៤-២០២៨។

១៩០. កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលបានត្រៀមរៀបចំកាលពីឆ្នាំកន្លងទៅ ត្រូវបានដាក់ឱ្យអនុវត្តយ៉ាងពេញលេញ និងជោគជ័យក្នុងឆ្នាំ២០២៥ ដោយបានធ្វើសមាហរណកម្មអាហារូបករណ៍សិស្សចូលក្នុងកម្មវិធីនេះរួចរាល់។ ជាក់ស្តែង ក្នុងឆ្នាំ២០២៥ មានសិស្សានុសិស្សមកពីគ្រួសារមានបណ្ណសមធម៌សរុបចំនួន ៤៦៧ ១៧៤នាក់ បានទទួលប្រាក់ឧបត្ថម្ភពីកម្មវិធីនេះ ដោយបានចំណាយថវិកាសរុបចំនួន ៨៣ ៥៥៨ ៥៩០ ០០០រៀល (ស្មើនឹង ២០ ៨៨៩ ៦៤៨ដុល្លារអាម៉េរិក)។

១៩១. អនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានអនុវត្តជាផ្លូវការនូវការឧបត្ថម្ភសាច់ប្រាក់ជូន ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះចំនួន ៦៥នាក់ និងកូនអាយុក្រោម ២ឆ្នាំតាមម្តាយក្នុងពន្ធនាគារចំនួន ៨៨នាក់ ដោយចំណាយថវិកាសរុបចំនួន ៤១ ៦៤០ ០០០រៀល (ស្មើនឹង ១០ ៤១០ដុល្លារអាម៉េរិក)។

១៩២. ទន្ទឹមគ្នានេះ សម្រាប់កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ក្នុងឆ្នាំ២០២៥ មាន **ម្តាយចំនួន ១២២ ៨៦២ នាក់** និង **កុមារចំនួន ១៧០ ០៦៣នាក់** បានទទួលការឧបត្ថម្ភ ដោយចំណាយថវិកាអស់ប្រមាណ **១១៣ ៣៩៧,២៨ លានរៀល** និងគិត

ត្រឹមឆ្នាំ២០២៥ តាមរយៈកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ក្រសួងក៏បានផ្តល់ប្រាក់ឧបត្ថម្ភដល់កុមារអាយុក្រោម ២ឆ្នាំ (កូន) ចំនួន ៧៣២ ១២៣នាក់ និងស្ត្រីមានផ្ទៃពោះ (ម្តាយ) ចំនួន ៦៩៦ ៧៥១នាក់ ដោយចំណាយថវិកាអស់ប្រមាណ **៤០៩ ៩៦៤,១៦លានរៀល** ផងដែរ ខណៈដែលចំនួនសមាជិក ប.ស.ស. ផ្នែកថែទាំសុខភាពសរុបទូទាំងប្រទេសបានកើនឡើងដល់ **៣ ៥៣៦ ៥០៩នាក់** ( ដោយគិតត្រឹមឆ្នាំ២០២៤ សមាជិកមានត្រឹមតែ ២,៧២លាននាក់ប៉ុណ្ណោះ)។ លើសពីនេះ រាជរដ្ឋាភិបាល ក៏បានចេញប្រកាសពង្រីកវិសាលភាពការអនុវត្តកម្មវិធីផ្តល់សាច់ប្រាក់ឧបត្ថម្ភនេះ ទៅដល់ **មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ** ផងដែរ។

១៩៣. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជំរុញការអភិវឌ្ឍសមត្ថភាពកម្លាំងពលកម្មដែលនៅក្នុងទីផ្សារការងារ និងត្រៀមចូលទីផ្សារការងារ តាមរយៈការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ដោយមានសហគ្រាស ក្រុមហ៊ុន រោងចក្របានចុះបញ្ជិកាចំនួន ១ ២២៦ មានកូនជាងហ្វឹកហ្វឺនចំនួន ៤៣ ៩៨៩នាក់ (ស្រី ២៧ ៥៦០នាក់), កូនជាងកំពុងហ្វឹកហ្វឺនចំនួន ១១ ៧១៤នាក់ (ស្រី ៧ ២៥២នាក់) និងបានបញ្ចប់ការហ្វឹកហ្វឺនចំនួន ៣៦ ៩៥៦នាក់ (ស្រី ២៣ ៥៦៦នាក់)។

១៩៤. កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះដឹងទូទៅ នៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបានដាក់ឱ្យអនុវត្តជាក់ស្តែង និងពេញលេញ។ សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ នេះ មានសិស្សក្រីក្រមានបណ្ណសមធម៌សរុបចំនួន ៤៦២ ៣៥៨នាក់ បានទទួលអាហារូបករណ៍ពីមូលនិធិជាតិជំនួយសង្គម ក្នុងនោះកម្រិតបឋមសិក្សាមានចំនួន ៣៥៤ ៦៤៤នាក់ និងកម្រិតមធ្យមសិក្សាមានចំនួន ១០៧ ៧១៤នាក់ (មធ្យមសិក្សាបឋមភូមិ ៧៤ ០៩៧នាក់ និងទុតិយភូមិ ៣៣ ៦១៧នាក់) ដែលប្រើប្រាស់កញ្ចប់ថវិការហូតដល់ ១១៥ ប៊ីលានរៀល ក្នុងឆ្នាំ២០២៥។ ចំណែកឯសិស្សក្រីក្រគ្មានបណ្ណសមធម៌សរុបចំនួន ៨៨ ៧១៥នាក់ ផ្សេងទៀត (បឋម ៤៥ ៥៩៥នាក់ និងមធ្យម ៤៣ ១២០នាក់) ត្រូវបានផ្តល់អាហារូបករណ៍ដោយក្រសួងអប់រំ យុវជន និងកីឡា។

១៩៥. អនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥ ស្តីពីក្របខណ្ឌនៃការប្រើប្រាស់មូលនិធិសន្តិសុខសង្គមសម្រាប់ចំណាយប្រតិបត្តិការរបស់បេឡាជាតិសន្តិសុខសង្គម។ អនុក្រឹត្យនេះបង្កើតឡើង ដើម្បីធានាបាននូវប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុនៃមូលនិធិសន្តិសុខសង្គម។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសអន្តរក្រសួងលេខ ០៧៥/២៥ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ ស្តីពីការពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ (ពីរ) ឆ្នាំ ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ។ ប្រកាសនេះកំណត់អំពីការពង្រីកវិសាលភាពអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ (ពីរ)ឆ្នាំ ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ដើម្បីចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក រួមចំណែកដោះស្រាយកង្វះអាហារូបត្ថម្ភ ព្រមទាំងជំរុញ ការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។

១៩៦. អនុក្រឹត្យលេខ ៣០៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃបេឡាជាតិសន្តិសុខសង្គម។ អនុក្រឹត្យនេះកំណត់ អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម នៃបេឡាជាតិសន្តិសុខសង្គម ដែលសរសេរជាអក្សរ

កាត់ថា ក.ធ.ស. ដើម្បីគ្រប់គ្រងកិច្ចការវិនិយោគមូលនិធិរបស់ផ្នែកនីមួយៗ នៃរបបសន្តិសុខសង្គម សំដៅធានាឱ្យបាននូវនិរន្តរភាពមូលនិធិសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

១៩៧. បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកំណើនសមាជិកផ្នែកថែទាំសុខភាពប្រមាណ ៨២ម៉ឺននាក់ ដែលធ្វើឱ្យសមាជិក ប.ស.ស. សរុបបានកើនឡើងដល់ប្រមាណ ៣,៥លាននាក់ (ស្រីប្រមាណ ១,៩លាននាក់) ក្នុងនោះ សមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួនប្រមាណ ៨៦ម៉ឺននាក់ (ស្រីប្រមាណ ៥១,៦ម៉ឺននាក់)។ ក្នុងឆ្នាំ២០២៥ មានសមាជិក ប.ស.ស. បានប្រើប្រាស់សេវាផ្នែកថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាលសរុបចំនួនប្រមាណ ៨,១លានដង (ស្រីប្រមាណ ៥,៦លានដង) ក្នុងនោះ តាមរបបភាគទានជាកាតព្វកិច្ចចំនួនប្រមាណ ៦លានដង (ស្រីប្រមាណ ៤,២លានដង) និងតាមរបបភាគទានដោយស្ម័គ្រចិត្តប្រមាណ ២,១លានដង (ស្រីប្រមាណ ១,៤លានដង) ដោយបានចំណាយថវិកាសរុបប្រមាណ ៨០១,១ប៊ីលានរៀល។

១៩៨. ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះចំនួនប្រមាណ ១២,៣ម៉ឺននាក់ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួនប្រមាណ ១៧ម៉ឺននាក់ ដោយបានចំណាយថវិកាប្រមាណ ១១៣,៤ប៊ីលានរៀល។ បើគិតត្រឹមឆ្នាំ២០២៥នេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះចំនួនប្រមាណ ៦៩,៧ម៉ឺននាក់ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួនប្រមាណ ៧៣,២ម៉ឺននាក់ ដោយបានចំណាយថវិកាប្រមាណ ៤១០ប៊ីលានរៀល។

# ៦. ការចូលរួមរបស់កុមារ



៦.១. ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងក្រុមកាយរឹទ្ធិជាតិកម្ពុជា

៦.២. បណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ

# ៦. ការចូលរួមរបស់កុមារ[17]

## ៦.១. ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងកាយរឹទ្ធិជាតិកម្ពុជា[18]

១៩៩. ក្រុមប្រឹក្សាកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សាចំនួន ៩ ១៨៨ មានសមាជិក ១ ៦៣១ ៩០២នាក់ ស្រី ៨២១ ៦៤០នាក់ (កើនឡើង ៣៤ ៧៩៨នាក់) និងក្រុមប្រឹក្សាយុវជនកម្ពុជានៅតាមគ្រឹះស្ថានសិក្សា ៥៨១ មានសមាជិក ៤១៣ ៣៥២នាក់ ស្រី ២៣១ ៤៩៧នាក់ (កើន ២៧ ៥២៣នាក់) ធៀបទៅនឹងឆ្នាំសិក្សា២០២៣-២០២៤។

២០០. សមាជិកកាយរឹទ្ធិជាតិកម្ពុជា ១៩០ ៧១២នាក់ ស្រី ៩៣ ២៣៨នាក់ កើន ៥ ៣៥៦នាក់ ធៀបនឹងឆ្នាំសិក្សា ២០២៣-២០២៤។ ការអប់រំកាយរិទ្ធិកម្មផ្តោលើការសិក្សាជំនាញកាយរឹទ្ធិកម្មតាមរយៈវិធីសាស្ត្ររៀនបែបអនុវត្តគម្រោង និងរៀនបែបអនុវត្តជាក់ស្តែងនៅតាមទីវាល ផ្តោតជាសំខាន់លើការអភិវឌ្ឍបុគ្គលិកលក្ខណៈ បំណិនជីវិតភាពជាពលរដ្ឋសកល និងបុគ្គលមានការទទួលខុសត្រូវក្នុងសហគមន៍របស់ខ្លួន។ សមាជិកភាពនៃកាយរឹទ្ធិជាតិកម្ពុជា បានកើនឡើងដោយសារការយល់ច្បាស់អំពីគុណតម្លៃនៃគោលការណ៍គ្រឹះកាយរឹទ្ធិ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការពង្រឹងប្រព័ន្ធកងល្បាតនៅតាមគឹះស្ថានសិក្សាសាធារណៈ ឯកជន និងសហគមន៍។

២០១. ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ឱកាសដល់យុវជន និងកុមារក្នុងការអនុវត្តគម្រោងស្ម័គ្រចិត្ត និងធ្វើការប្រកួតប្រជែង បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលស្តីពីការងារស្ម័គ្រចិត្ត ដែលបង្ហាញពីការចូលរួមរបស់យុវជន និងកុមារ ដើម្បីបង្ហាញពីសមត្ថភាព ការរួមចំណែក និងទស្សនៈរបស់ពួកគេ។ កម្មវិធីនេះ ឆ្លើយតបនឹងអាទិភាពទី៥ នៃផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។ ក្រសួងបានរៀបចំទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត អបអរសាទរ និងលើកទឹកចិត្តដល់យុវជនស្ម័គ្រចិត្ត ដើម្បីបង្ហាញអំពីស្នាដៃការងារស្ម័គ្រចិត្តរបស់ខ្លួន។ កម្មវិធីយុវជន និងកុមារ បានជះឥទ្ធិពលដល់ការអភិវឌ្ឍយុវជន និងកុមារគួរឱ្យកត់សម្គាល់ដោយផ្ទាល់ និងប្រយោល។ យុវជន និងកុមារដែលបានចូលរួមផ្ទាល់ក្នុងកម្មវិធីនេះ ទទួលបានការបំប៉នចំណេះដឹង និងសមត្ថភាពបន្ថែមពីលើការសិក្សាក្នុងថ្នាក់រៀន តាមរយៈការអនុវត្តជាក់ស្តែងស្របតាមបរិបទកម្មវិធីបំណិនសតវត្សរ៍ទី២១។

## ៦.២. បណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ

២០២. ក្រៅពីក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា កាយរឹទ្ធិជាតិកម្ពុជា និងយុវជនកាកបាទក្រហមក៏មានអង្គការសង្គមស៊ីវិលជាច្រើនបានបង្កើតនូវបណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ ដែលមានគោលដៅលើកកម្ពស់ការចូលរួម សាមគ្គីភាព ការចែករំលែកបទពិសោធន៍ និងទស្សនៈ ជាពិសេសសំឡេងរបស់ពួកគេទាក់ទងនឹងបញ្ហាកុមារនៅកម្ពុជា ដែលក្នុងនោះមានដូចជា អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា និងសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ។ល។

---

[17] កុមារមានសិទ្ធិចូលរួមក្នុងការបញ្ចេញមតិយោបល់លើបញ្ហា ឬសកម្មភាពដែលមានឥទ្ធិពលដល់ដំណើរជីវិតរបស់ពួកគេ ចូលរួមសកម្មភាពក្នុងសហគមន៍ ការប្រជុំនានា ចូលរួមការទទួលនិងផ្សព្វផ្សាយព័ត៌មាន ការអានសៀវភៅ កាសែត ទស្សនាវដ្តី មើលទូរទស្សន៍ ដើម្បីពង្រីកការយល់ដឹង និងចេះប្រើវិចារណញាណ រិះគិតចំពោះព្រឹត្តិការណ៍ផ្សេងៗ។

[18] សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៤-២០២៥ និងទិសដៅឆ្នាំសិក្សា២០២៥-២០២៦

# ៧. កិច្ចសហប្រតិបត្តិការលើវិស័យកុមារ



## ៧.១. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

## ៧. កិច្ចសហប្រតិបត្តិការលើវិស័យកុមារ

### ៧.១. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

២០៣. ទន្ទឹមនឹងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ជាពិសេសក្រសួង ស្ថាប័ន ដែលបំពេញការងារផ្តោតលើកុមារ បានប្រឹងប្រែងក្នុងការលើកកម្ពស់សិទ្ធិកុមារពីថ្នាក់ក្រោមជាតិ និងថ្នាក់ក្រោមជាតិ ក្នុងនោះក៏មាន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិល ជាច្រើនបានចូលរួមសហការយ៉ាងសកម្មលើការការពារ និងលើកកម្ពស់ឧត្តមប្រយោជន៍កុមារ និងបានសហការយ៉ាងជិតស្និទជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារផងដែរ ដែលមានដូចជា អង្គការយូនីសេហ្វ អង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការឆាលហ្វាន កម្ពុជា អង្គការដែនដីមនុស្ស-ហូឡង់ដ៍ អង្គការសេរីភាពកម្ពុជាអូស្រ្តាលី អង្គការសង្គ្រោះកុមារ អង្គការទស្សនៈពិភពលោក អង្គភាពការពារកុមារ (CPU) អង្គការ Eriks អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ អង្គការមូលនិធិហាការអន្តរជាតិ អង្គការសម្ព័ន្ធចាប់ដៃ អង្គការសម្ពន្ធដើម្បីសិទ្ធិកុមារកម្ពុជា អង្គការបណ្តាញទូរសព្ទជំនួយកុមារកម្ពុជា អង្គការសកម្មភាពដើម្បីកុមារ និងសមាគមចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ។ល។ ខាងក្រោមនេះ គឺជាលទ្ធផលការងាររបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិលមួយចំនួន ដែលបានផ្តល់ជូនមក ក.ជ.ក.។

#### ក. អង្គការភ្លែនអន្តរជាតិកម្ពុជា

២០៤. ក្នុងឆ្នាំ២០២៥ អង្គការភ្លែនអន្តរជាតិកម្ពុជាបានបន្តជំរុញការអនុវត្តយុទ្ធសាស្រ្តប្រទេសឆ្នាំ ២០២១-២០២៧ របស់ខ្លួន ដោយទទួលបានជោគជ័យគួរឱ្យកត់សម្គាល់តាមរយៈកម្មវិធីស្នូលចំនួន ៤ គឺ៖ ការចាប់ផ្តើមនូវសុខភាពល្អ កិច្ចការពារជំនាន់ថ្មី ការរៀនសូត្រពេញមួយជីវិត និងក្មេងស្រីជាអ្នកដឹកនាំ។ សមិទ្ធផលសំខាន់ៗ រួមមានការគាំទ្រកុមារជិត ៥ លាននាក់ក្នុងកម្មវិធីសុខភាព ការសម្រេចបាននូវស្ថានភាពបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (ODF) ក្នុងខេត្តចំនួន ២១ និងការបង្កើតផែនការសកម្មភាពថ្នាក់ជាតិដើម្បីការពារសិទ្ធិកុមារ និងសមភាពយេនឌ័រ។ អង្គការបានពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានានិរន្តរភាព និងការផ្លាស់ប្តូរជាប្រព័ន្ធ។

២០៥. **កម្មវិធីចាប់ផ្តើមជាមួយសុខភាពល្អ** (Healthy Start) ផ្តោតលើសុខភាព អាហារូបត្ថម្ភ និងការអភិវឌ្ឍកុមារតូច ដែលបានគាំទ្រកុមារប្រហែល ៥ លាននាក់ ទាំងដោយផ្ទាល់និងប្រយោល។ តាមរយៈគម្រោងអនាម័យ និងទឹកស្អាត (WASH) បានសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីដាក់ចេញនូវស្តង់ដារបង្គន់ប្រកបដោយបរិយាបន្ននៅតាមឃុំ-សង្កាត់ទូទាំងប្រទេស។ លើសពីនេះ បានគាំទ្រក្រសួងអភិវឌ្ឍន៍ជនបទក្នុងការប្រកាសរាជធានី-ខេត្តចំនួន ២១ ជាតំបន់ ODF ត្រឹមដំណាច់ឆ្នាំ២០២៥។ គម្រោងអាហារូបត្ថម្ភ និងការអប់រំដំបូង កំពុងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងកង្វះអាហារូបត្ថម្ភស្រួចស្រាវ (IMAM) ជាមួយក្រសួងសុខាភិបាល។ សម្រាប់ផ្នែកអប់រំ សៀវភៅណែនាំ ៨ សប្តាហ៍មុនរដូវប្រាំង (8WPP) ត្រូវបានរៀបចំឡើងដើម្បីត្រៀមលក្ខណៈឱ្យកុមារអាយុ ៥ ដល់ ៧ ឆ្នាំ ចូលរៀនថ្នាក់ទី១។

២០៦. **កម្មវិធីកិច្ចការពារជំនាន់ថ្មី** (Protection Plus) ផ្តោតលើការការពារកុមារពីអំពើហិង្សា និងការកេងប្រវ័ញ្ច ដែលបានគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ដែលនឹងផ្

ល់អត្ថប្រយោជន៍ដល់កុមារប្រមាណ ៦.៣លាននាក់។ គម្រោងទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ បានសហការជាមួយក្រសួងកិច្ចការនារីលើផែនការសកម្មភាពជាតិ ២០២៥-២០៣០ ដើម្បីបង្ការអាពាហ៍ពិពាហ៍មុនវ័យ និងការមានផ្ទៃពោះវ័យជំទង់។ គម្រោងផ្តល់អំណាចដល់កុមារី បានជួយកុមារីងាយរងគ្រោះ ១៥០នាក់ បញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយភាគច្រើនទទួលបានការងារធ្វើ ឬបង្កើតអាជីវកម្មផ្ទាល់ខ្លួន។

២០៧. **កម្មវិធីរៀនសូត្រពេញមួយជីវិត** (Lifelong Learning) ផ្តោតលើការអប់រំបរិយាបន្ន និងសុវត្ថិភាពសាលារៀន ដែលក្នុងនោះមានគម្រោងសន្តិសុខស្បៀងក្នុងសាលារៀន ដែលផ្តល់អាហារដល់សាលារៀនចំនួន ១៣០ ក្នុងខេត្តសៀមរាប ត្រូវបានផ្ទេរទៅឱ្យក្រសួងអប់រំ យុវជន និងកីឡា គ្រប់គ្រង ដែលធានាអាហារសម្រាប់កុមារ ៣១,០០០ នាក់។ គម្រោងការអប់រំកុមារក្រៅសាលា តាមរយៈគម្រោង CCOSC ដំណាក់កាលទី២ បានគាំទ្រសាលារៀនចំនួន ២៥០ និងកុមារក្រៅសាលាជាង ៤,៧០០ នាក់ តាមរយៈការសាងសង់អគារសិក្សា និងផ្តល់សម្ភារៈសិក្សា។ គម្រោងបរិស្ថាន និងអាកាសធាតុ បានគាំទ្រចំពោះផែនការអនុវត្តសម្រាប់គ្រោះមហន្តរាយ និងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុក្របខណ្ឌអប់រំ ២០២៤-២០២៨ របស់ក្រសួងអប់រំ យុវជន និងកីឡា។

២០៨. **កម្មវិធីក្មេងស្រីជាអ្នកដឹកនាំ** (Girls Lead) ផ្តោតលើការពង្រឹងសមត្ថភាពដឹកនាំរបស់យុវនារី ដែលជាគំនិតផ្តួចផ្តើមថ្នាក់ជាតិបានបើកដំណើរការគម្រោង "ការដឹកនាំផ្លូវសម្រាប់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី" (LWGL) ២០២៤-២០២៨ ក្នុងភាពជាដៃគូជាមួយក្រសួងកិច្ចការនារី។ គម្រោងការតស៊ូមតិ និងការយល់ដឹង តាមរយៈយុទ្ធនាការទិវាអន្តរជាតិនារីបានទាក់ទាញអ្នកចូលរួមផ្ទាល់ជាង ២,៨០០នាក់ និងអ្នកទស្សនាតាមអនឡាញជាង ៥០០,០០០នាក់។ គម្រោងសំឡេងយុវជន បានតែងតាំងឯកអគ្គរដ្ឋទូតសមភាពយេនឌ័រ (GEAs) ចំនួន ៣ នាក់ ដើម្បីតំណាងឱ្យសំឡេងយុវជនក្នុងគោលនយោបាយជាតិ។ លើសពីនេះ យុវជនត្រូវបានបណ្តុះបណ្តាលលើផ្នែកសារព័ត៌មានពលរដ្ឋ ដើម្បីពង្រីកសំឡេងសហគមន៍។

២០៩. លទ្ធផលក្នុងឆ្នាំ២០២៥ បានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងខ្លាំងរបស់អង្គការផ្លែនអន្តរជាតិកម្ពុជា ក្នុងការលើកកម្ពស់សិទ្ធិកុមារ និងសមភាពសម្រាប់ក្មេងស្រី។ តាមរយៈការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងការផ្តល់អំណាចដល់យុវជននៅថ្នាក់មូលដ្ឋាន អង្គការមិនត្រឹមតែផ្តល់ជំនួយផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចូលរួមចំណែកក្នុងការកសាងប្រព័ន្ធការពារ និងអប់រំ ដែលមាននិរន្តរភាពសម្រាប់កម្ពុជាទៀតផង។

### ខ. អង្គការឆោលហ្វាន កម្ពុជា

២១០. ក្នុងឆ្នាំ២០២៥ អង្គការឆោលហ្វានកម្ពុជា បានសហការយ៉ាងជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងវិទ្យាស្ថានជាតិសង្គមកិច្ច ព្រមទាំងអង្គការដៃគូក្នុងខេត្តក្រចេះ ខេត្តបាត់ដំបង និងខេត្តព្រៃវែង។ តាមរយៈគម្រោង "**សហគមន៍មានសុវត្ថិភាពសម្រាប់កុមារ**" និង "**សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ**" កិច្ចអន្តរាគមន៍បានផ្តល់ការគាំទ្រដោយផ្ទាល់ដល់កុមាររងគ្រោះជាង ១៣០ករណី និងបានពង្រឹងសមត្ថភាពឪពុកម្តាយ អាជ្ញាធរ និងយុវជនរាប់ពាន់នាក់។ ចំណុចគន្លឹះនៃភាពជោគជ័យគឺការធ្វើសមាហរណកម្មផែនការការពារកុមារទៅក្នុងប្រព័ន្ធរដ្ឋបាលឃុំ និងការបង្កើនការយល់ដឹងអំពីហានិភ័យឌីជីថលដែលកំពុងកើនឡើង។

២១១. **ការពង្រឹងប្រព័ន្ធការពារកុមារក្នុងសហគមន៍** (Safe Community for Children) គម្រោងនេះផ្ដោតលើការឆ្លើយតបករណីរំលោភបំពាន និងការកសាងបណ្ដាញការពារកុមារនៅថ្នាក់មូលដ្ឋាន តាមរយៈការគ្រប់គ្រងករណី និងការអន្តរាគមន៍ នៅខេត្តបាត់ដំបង ករណីរំលោភបំពានចំនួន ១០៣ករណី (កុមារី ៥២នាក់) ទទួលបានការគាំទ្រផ្នែកប្រឹក្សាយោបល់ ស្បៀងអាហារ និងជំនួយផ្លូវច្បាប់ទាន់ពេលវេលា។ ចំណែកនៅព្រៃវែង អ្នកសង្គមកិច្ចបានចុះគាំទ្រករណីកុមាររងគ្រោះចំនួន ២៨នាក់ សរុបចំនួន ២៦០ដង។

២១២. **ការអប់រំឪពុកម្ដាយ និងអាណាព្យាបាល** ឪពុកម្ដាយចំនួន ៤០៨ នាក់នៅបាត់ដំបង បានបញ្ចប់វគ្គបណ្ដុះបណ្ដាល "ការចិញ្ចឹមកូនបែបវិជ្ជមាន" កម្រិតទី២ ខណៈដែលយុទ្ធនាការផ្សព្វផ្សាយបានទៅដល់ប្រជាពលរដ្ឋចំនួន ៨៥១នាក់ បន្ថែមទៀតក្នុងសហគមន៍។ **ការកសាងសមត្ថភាពអាជ្ញាធរ** មន្ត្រីអាជ្ញាធរ និងកម្លាំងសេវាសង្គមសរុប ៧៦នាក់ (៥១នាក់នៅបាត់ដំបង និង ២៥នាក់នៅព្រៃវែង) ទទួលបានការបណ្ដុះបណ្ដាលលើជំនាញទំនាក់ទំនង និងដំណើរការគ្រប់គ្រងករណី។

២១៣. **សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ** (Swipe Safe Cambodia) ដោយមើលឃើញនូវការកើនឡើង នៃហានិភ័យតាមឌីជីថល គម្រោងបានពង្រីកសកម្មភាពយ៉ាងសកម្ម តាមរយៈការបណ្ដុះបណ្ដាលកុមារ និងយុវជន ក្នុងដំណាក់កាលទី២ នៅខេត្តព្រៃវែង កុមារចំនួន ៨៨០នាក់ បានរៀនសូត្រពីរបៀបការពារខ្លួនពីការកេងប្រវ័ញ្ចតាមអនឡាញ។ នៅស្រុកសង្កែ ខេត្តបាត់ដំបង កុមារចំនួន ៨៩នាក់ ក៏ទទួលបានចំណេះដឹងស្រដៀងគ្នានេះដែរ។ បង្កើនការយល់ដឹងដល់ឪពុកម្ដាយ អាណាព្យាបាលសរុបជាង ៦៣០នាក់ (៥២៦នាក់នៅព្រៃវែង និង ៦៥នាក់នៅបាត់ដំបង) ដោយបានបណ្ដុះបណ្ដាលពីរបៀបតាមដាន និងគាំទ្រកូនៗក្នុងការប្រើប្រាស់អ៊ីនធឺណិត។ ការផ្ដល់បច្ចេកទេសកម្រិតជំនាញដល់កម្លាំងសេវាសង្គមចំនួន ៥៧នាក់នៅព្រៃវែង ដោយបានទទួលការបណ្ដុះបណ្ដាលបច្ចេកទេសស៊ីជម្រៅស្ដីពីសុវត្ថិភាពកុមារតាមអនឡាញសម្រាប់អ្នកជំនាញ។

២១៤. **ការធ្វើសមាហរណកម្មកម្មវិធីសិក្សា** ក្រុមការងារបច្ចេកទេសដែលសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងវិទ្យាស្ថានជាតិសង្គម បានបញ្ចូលឯកសារបណ្ដុះបណ្ដាលពាក់ព័ន្ធនឹងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញទៅក្នុងកម្មវិធីសិក្សាសម្រាប់និស្សិតនៃវិទ្យាស្ថានជាតិសង្គម ដើម្បីធានាបាននូវចំណេះដឹងយូរអង្វែង។

២១៥. កិច្ចសហការ និងនិរន្តរភាពគម្រោងរបស់អង្គការឆាលហ្វាន កម្ពុជា ត្រូវបានគាំទ្រចំពោះការដាក់បញ្ចូលក្នុងផែនការរដ្ឋ ដោយនៅព្រៃវែងមានការរៀបចំកិច្ចប្រជុំជាមួយឃុំគោលដៅ ដើម្បីដាក់បញ្ចូលផែនការការពារកុមារទៅក្នុងផែនការវិនិយោគឃុំ (CIP) ។ ទន្ទឹមនេះ ក៏មានការសហការអន្តរវិស័យ ដែលអង្គការឆាលហ្វានកម្ពុជាបានរៀបចំកិច្ចប្រជុំកម្រិតតំបន់ប្រចាំត្រីមាស ដោយមានការចូលរួមពីមន្ត្រីមកពីមន្ទីរសង្គមកិច្ច មន្ទីរអប់រំ នគរបាល និងតុលាការ ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម និងពង្រឹងប្រព័ន្ធរាយការណ៍។

២១៦. លទ្ធផលឆ្នាំ ២០២៥ បង្ហាញពីឥទ្ធិពលវិជ្ជមាននៃការរួមបញ្ចូលគ្នារវាងការការពារកុមារក្នុងសហគមន៍ផ្ទាល់ និងការការពារលើប្រព័ន្ធឌីជីថល។ សមត្ថភាពដែលបានកសាងដល់ឪពុកម្ដាយ និងអាជ្ញាធរមូលដ្ឋាន គឺជាគ្រឹះដ៏រឹងមាំសម្រាប់កាត់បន្ថយអំពើហិង្សា និងបង្កើតបរិយាកាសសុវត្ថិភាពសម្រាប់កុមារគ្រប់រូប។

## គ. អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា

២១៧. ក្នុងឆ្នាំ២០២៥ អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំនៅកម្ពុជាបានបង្ហាញពីសមិទ្ធផលចុងក្រោយនៃគម្រោង "សុវត្ថិភាពសម្រាប់កុមារ និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ" (Safety for Children and their Rights OnLine - SCROL) និងការសម្រេចចិត្តជាយុទ្ធសាស្ត្រក្នុងការបញ្ឈប់ប្រតិបត្តិការការិយាល័យតំណាងរបស់អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា (Tdh NL) នៅកម្ពុជាត្រឹមខែមិថុនា ឆ្នាំ២០២៦ បន្ទាប់ពីបានបំពេញបេសកកម្មអស់រយៈពេល ២០ឆ្នាំ។ ការសម្រេចចិត្តនេះធ្វើឡើងក្នុងគោលបំណងបន្ស៊ីខ្លួនទៅនឹងការផ្លាស់ប្តូរនៃចរន្តថវិកាជំនួយអន្តរជាតិ និងដើម្បីជំរុញតួនាទីរបស់អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជាឱ្យក្លាយជា "កាតាលីករសម្រាប់យន្តការផ្លាស់ប្តូរប្រព័ន្ធ" តាមរយៈការស្រាវជ្រាវ និងការតស៊ូមតិថ្នាក់តំបន់។ អង្គការកំពុងឆ្លងកាត់ការធ្វើបរិវត្តកម្មទៅរកគំរូប្រតិបត្តិការថ្មី ដែលផ្តោតលើការផ្តល់សិទ្ធិអំណាច និងការគាំទ្រដល់អង្គការសង្គមស៊ីវិលក្នុងស្រុកដែលមានស្វ័យភាព ដើម្បីធានានូវនិរន្តរភាពយូរអង្វែង។ អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើវិស័យយុទ្ធសាស្ត្រមួយចំនួន៖

២១៨. **ការថែទាំដែលផ្តោតលើការយល់ដឹងពីផលប៉ះពាល់នៃរបួសផ្លូវចិត្ត (Trauma-Informed Care)** ក្នុងខែឧសភា ឆ្នាំ២០២៥ វគ្គបណ្តុះបណ្តាលកម្រិតតំបន់ត្រូវបានរៀបចំឡើងនៅទីក្រុងបាងកក សម្រាប់អង្គការដៃគូមកពីកម្ពុជា ថៃ និងហ្វីលីពីន។ គោលបំណងគឺដើម្បីពង្រឹងគុណភាពនៃការផ្តល់សេវាដល់កុមាររងគ្រោះ កាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តជាថ្មី (re-traumatization) និងការពារសុខុមាលភាពផ្លូវចិត្តរបស់បុគ្គលិកជួរមុខ។

២១៩. **ទំនាក់ទំនងយុទ្ធសាស្ត្រ និងការស្រាវជ្រាវបែបនវានុវត្តន៍** សហការជាមួយកញ្ញា Catherine Harry និងនាយកដ្ឋានគោលនយោបាយ ICT នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផលិតវីដេអូអប់រំ ៣ ភាគស្តីពី "ការកេងប្រវ័ញ្ចផ្លូវភេទដើម្បីជំរិតទារប្រាក់" (Sexual Extortion) អមដោយសៀវភៅណែនាំសម្រាប់អង្គការសង្គមស៊ីវិលផ្សេងទៀត។ ជាមួយគ្នានេះ កម្មវិធី Vodcast ជាមួយព្រះតេជគុណ គូ សុភាព ទទួលបានការចូលទស្សនាជាង ១០០,០០០ដង។ លើសពីនេះ អង្គការបានបញ្ចេញលទ្ធផលស្រាវជ្រាវស្តីពី "បញ្ញាសិប្បនិម្មិត (AI) និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ" ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការរៀបចំគោលនយោបាយឌីជីថល។

២២០. **ការកែទម្រង់ស្ថាប័ន និងគោលនយោបាយ** សមិទ្ធផលដ៏ធំធេងមួយគឺការដែលសាលានគរបាលជាតិ បានអនុម័ត និងដាក់ឱ្យប្រើប្រាស់ "សៀវភៅណែនាំស្តីពីការស៊ើបអង្កេតដែលមេត្រីភាពចំពោះកុមារ" ដែលជាការបញ្ជ្រាបស្តង់ដារយល់ដឹងពីផលប៉ះពាល់ផ្លូវចិត្តទៅក្នុងប្រព័ន្ធយុត្តិធម៌។ អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជាក៏បានដើរតួនាទីជាដៃគូបច្ចេកទេសក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ និងបានសហការជាមួយនិយតករទូរគមនាគមន៍កម្ពុជាលើការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍កិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ (COP) នៅខេត្តសៀមរាប។

២២១. **ការចូលរួមរបស់កុមារ និងយុវជន** បានគាំទ្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) ក្នុងការរៀបចំវេទិកាកុមារ និងយុវជនថ្នាក់ជាតិ ដើម្បីធានាថា រាល់បញ្ហារបស់ពួកគេត្រូវបានដាក់បញ្ចូលក្នុងរបៀបវារៈ នៃគោលនយោបាយជាតិ។

២២២. តាមរយៈការអនុវត្តគម្រោង បានកត់ត្រានូវការកើនឡើងយ៉ាងខ្លាំងនៃការរាយការណ៍ករណីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) ដោយកើនឡើងពី ៣២៤ករណីក្នុងឆ្នាំ២០២៣ ដល់ ៥៨០ករណីក្នុងឆ្នាំ២០២៥ (កើនឡើងជិត ៨០%) ដែលឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃយន្តការរាយការណ៍ និងការយល់ដឹងជាសាធារណៈ។ វិសាលភាពនៃអ្នកទទួលផលសរុបមានចំនួន ១៣,៨៦១នាក់។

២២៣. **លទ្ធផលនៃការវាយតម្លៃបញ្ចប់គម្រោង** (Findings from the End Evaluation) ផ្អែកតាមស្តង់ដារ OECD-DAC គម្រោងទទួលបានពិន្ទុរួម ៣.១៥ លើ ៤ (កម្រិត "សមស្រប") ជាមួយនឹងការវិភាគដូចជា **ប្រសិទ្ធភាព** ចំណេះដឹងរបស់មាតាបិតាកើនពី ៥២% ដល់ ៩៤% និងកុមារកើនពី ៦២% ដល់ ៦៩%។ ការផ្លាស់ប្តូរឥរិយាបថសុវត្ថិភាពតាមអនឡាញកើនពី ៤៦% ដល់ ៨៦%។ បញ្ហា OCSE ត្រូវបានបញ្ជ្រាបទៅក្នុងគោលនយោបាយជាតិចំនួន ៤។ **ភាពពាក់ព័ន្ធ** គម្រោងមានភាពស៊ីចង្វាក់គ្នាខ្ពស់ទៅនឹងបរិវត្តកម្មឌីជីថល និងតម្រូវការបន្ទាន់របស់កម្ពុជា។ **និរន្តរភាព និងហានិភ័យ** និរន្តរភាពប្រឈមនឹងបញ្ហាមួយចំនួនដូចជា (១) កង្វះភាពដាច់ដោយឡែក នៃច្បាប់ស្តីពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (២) ការចំណាយខ្ពស់លើសេវាប្រឹក្សាផ្លូវចិត្តឯកទេស (៣៥០-៥០០ ក្នុងមួយករណី) និង (៣) ការចូលរួមនៅមានកម្រិតពីសំណាក់បុរស និងឪពុក ក្នុងកិច្ចការពារកុមារ។ **អនុសាសន៍យុទ្ធសាស្ត្រ** រុញច្រានឱ្យមានការច្បាប់ស្តីពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បញ្ចូលការអប់រំសុវត្ថិភាពតាមអនឡាញក្នុងកម្មវិធីសិក្សារដ្ឋ និងបង្កើតមូលនិធិរួម (Pooled Funding) រវាងរដ្ឋ និងម្ចាស់ជំនួយដើម្បីគាំទ្រសេវាឆ្លើយតប។

២២៤. ទោះបីជា អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជានឹងបញ្ចប់វត្តមានរូបវន្តនៃការិយាល័យតំណាងនៅកម្ពុជាត្រឹមខែមិថុនា ឆ្នាំ២០២៦ ក៏ដោយ ក៏កេរដំណែល និងនិរន្តរភាពនៃការងារការពារកុមារត្រូវបានផ្ទេរទៅឱ្យដៃគូយុទ្ធសាស្ត្រក្នុងស្រុកដែលមានសមត្ថភាពខ្ពស់ ដូចជា អង្គការសកម្មភាពដើម្បីកុមារ (APLE) និងអង្គការសេរីភាពកម្ពុជាអូស្ត្រាលី (AusCam Freedom Project)។ ភាពជាម្ចាស់ត្រូវបានពង្រឹងតាមរយៈការប្តេជ្ញាចិត្តរបស់ស្ថាប័នរដ្ឋ (គ.ជ.ក និង ក្រសួងប្រៃសណីយ៍) ក្នុងការបន្តអនុវត្តច្បាប់ និងស្តង់ដារដែលបានបង្កើតឡើង។ ទៅថ្ងៃអនាគត អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា នឹងបន្តគាំទ្រកម្ពុជាតាមរយៈគំរូប្រតិបត្តិការថ្មីដែលផ្តោតលើ "តំបន់ភាវូបនីយកម្ម" (Localization) ដោយផ្តល់ការគាំទ្រដល់អង្គការក្នុងស្រុកដែលមានស្វ័យភាព ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមថ្មីៗក្នុងយុគសម័យឌីជីថល។

### ឃ. អង្គការសកម្មភាពដើម្បីកុមារ (APLE)

២២៥. ក្នុងឆ្នាំ២០២៥ អង្គការសកម្មភាពដើម្បីកុមារ (APLE) សម្រេចបាននូវវឌ្ឍនភាពយុទ្ធសាស្ត្រក្នុងការតភ្ជាប់គម្លាតរវាងបច្ចេកវិទ្យា ការអនុវត្តច្បាប់ និងការគាំពារជនរងគ្រោះ ដើម្បីឆ្លើយតបនឹងការវិវត្តនៃឧក្រិដ្ឋកម្មកេងប្រវ័ញ្ចផ្លូវភេទកុមារ។ បេសកកម្មរបស់ APLE បានពង្រីកវិសាលភាពឥទ្ធិពលលើសពីក្របខណ្ឌជាតិ ដោយបានចូលរួមចំណែកយ៉ាងសកម្មក្នុងយន្តការសកលនៅតាមបណ្តាប្រទេសក្នុងទ្វីបអាស៊ី អាហ្វ្រិក និងអឺរ៉ុប តាមរយៈគម្រោង SCROL និងការចូលរួមក្នុងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មតាមអនឡាញ។

២២៦. សមិទ្ធផលគន្លឹះក្នុងឆ្នាំនេះ រួមមានការចុះហត្ថលេខាលើគម្រោង IMPACT (២០២៦-២០២៩) ការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់តាមរយៈការបណ្តុះបណ្តាល "ការស៊ើបអង្កេតផ្តោតលើជនរងគ្រោះ" និងការវិភាគមាតិការំលោភបំពានផ្លូវភេទកុមារ (CSAM) ជាង ៦០ម៉ឺនរូបភាព។ តាមរយៈកិច្ចសហការជិតស្និទ្ធជាមួយ

រាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមជាសមាជិកនៃបណ្តាញអន្តរជាតិ ECPAT និង INHOPE អង្គការ APLE បានបង្ហាញពីតួនាទីជាអ្នកសម្របសម្រួលយុត្តិធម៌ និងការផ្តល់សិទ្ធិអំណាចដល់កុមារ ដើម្បីធានាបាននូវបរិយាកាសឌីជីថលប្រកបដោយសុវត្ថិភាព និងបរិយាបន្ន។

២២៧. **ក្របខណ្ឌច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ** (Legal Framework & Policy) ក្នុងភាពជាដៃគូយុទ្ធសាស្ត្រថ្នាក់ជាតិ អង្គការបានបន្តភាពជាដៃគូជាមួយ គ.ជ.ប.ជ. និង ក.ជ.ក. ក្នុងការផ្តល់ធាតុចូលសម្រាប់ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ APLE បានចុះហត្ថលេខាលើគម្រោង IMPACT (២០២៦-២០២៩) រយៈពេល ៤ឆ្នាំ ជាមួយ Mission Alliance Cambodia ដែលឧបត្ថម្ភដោយប្រទេសន័រវេស ក្នុងចំណោមអង្គការសង្គមស៊ីវិលចំនួន ១២ ដើម្បីជំរុញសសរស្តម្ភសហគមន៍មានសុវត្ថិភាពសម្រាប់ស្ត្រី និងកុមារ។

២២៨. **ការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំបច្ចេកទេសសំខាន់ៗ** បានការកសាងសមត្ថភាពមន្ត្រីបច្ចេកទេសតាមរយៈកិច្ចប្រជុំជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅខេត្តសៀមរាប មានមន្ត្រីជំនាញបច្ចេកទេសចំនួន ៩០នាក់ បានចូលរួមពិភាក្សាលើគោលការណ៍ណែនាំសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យា។ វេទិកាសុវត្ថិភាពអនឡាញ និងរដ្ឋាភិបាលឌីជីថល៖ ចូលរួមក្នុងវេទិកាដែលមានអ្នកចូលរួមជាង ៦០០នាក់ ដើម្បីលើកកម្ពស់ទំនុកចិត្តក្នុងយុគសម័យបញ្ញាសិប្បនិម្មិត (AI) និងការបង្កើតក្រុមការងារអន្តរក្រសួងត្រួតពិនិត្យមាតិកាអនឡាញ។ សិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ជាតិ៖ សហការជាមួយ គ.ជ.ប.ជ. រៀបចំសិក្ខាសាលាដែលមានអ្នកចូលរួម ១៥០នាក់ ដើម្បីពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃយុទ្ធសាស្ត្របង្ការការជួញដូរមនុស្ស។

២២៩. **កិច្ចសហប្រតិបត្តិការអន្តរជាតិ និងតំបន់** បានចូលរួមពិធីចុះហត្ថលេខានៅវៀតណាម ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត (អនុសញ្ញាអង្គការសហប្រជាជាតិ)។ ក្នុងនាមជាសមាជិក ECPAT International អង្គការ APLE បានរំលេចពីសារៈសំខាន់នៃបណ្តាញសហប្រតិបត្តិការសកល ២៤/៧ ដើម្បីពន្លឿនការដកមាតិកាខុសច្បាប់ និងការស៊ើបអង្កេតឆ្លងដែន។ ក្នុងកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យា អង្គការបានចូលរួមកិច្ចប្រជុំ Tech Coalition (អ្នកជំនាញ ៨៥នាក់ មកពី ១៦ប្រទេស) និងកិច្ចប្រជុំ TikTok នៅទីក្រុងសេអ៊ូល ដើម្បីជម្រុញការទទួលខុសត្រូវរួមរបស់វិស័យឧស្សាហកម្ម។ ក្នុងតួនាទីនៃការដឹកនាំយុទ្ធសាស្ត្រសកល នាយកប្រតិបត្តិ APLE បានបញ្ចប់អាណត្តិ ២ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាភិបាល INHOPE នៅទីស្នាក់ការកណ្តាល Europol ក្នុងប្រទេសហូឡង់។ គម្រោង SCROL បានវាយតម្លៃដោយជោគជ័យលើគម្រោងរយៈពេល ៣ឆ្នាំ (២០២៣-២០២៥) ដែលបានអនុវត្តក្នុងប្រទេសកម្ពុជា កេនយ៉ា នេប៉ាល់ និងហ្វីលីពីន។

២៣០. **ការអភិវឌ្ឍផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ** (Criminal Justice Development) តាមរយការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ អង្គការបានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល នៃបណ្ឌិត្យសភានគរបាលកម្ពុជាចំនួន ២២នាក់ (ស្រី ០៤នាក់) លើប្រធានបទ "ការស៊ើបអង្កេតផ្តោតលើជនរងគ្រោះ"។ បណ្តុះបណ្តាលមន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេសចំនួន ៦០រូប (ស្រី ៣៣រូប) ដោយលទ្ធផលវាយតម្លៃចំណេះដឹងមានការកើនឡើងគួរឱ្យកត់សម្គាល់។

២៣១. **ប្រតិបត្តិការបណ្តាញទាន់ហេតុការណ៍** (Hotline) **និងការវិភាគមាតិកា** (Arachnid) អង្គការទទួលបានករណីសង្ស័យសរុប ៣០៣ករណី (២២៥ករណី ពាក់ព័ន្ធនឹងអនឡាញ)។ បានបញ្ជូនព័ត៌មាន និងភស្តុតាងចំនួន

២៤ករណី ទៅកាន់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីចាត់វិធានការច្បាប់។ បានការវិភាគរូបភាព CSAM និងចាត់ថ្នាក់រូបភាពចំនួន ៦២៧,៩៤៨ រូបភាព (៨៤% ជា CSAM ពិតប្រាកដ, ១១% ជាសម្ភារៈបង្កគ្រោះថ្នាក់ និង ៥% ជាមាតិកាមនុស្សពេញវ័យ/AI)។ ក្នុងកិច្ចសហការជាមួយអង្គភាពជំនាញ អង្គការ APLE បានចុះជួបពិភាក្សា និងចែករំលែកបទពិសោធន៍បែបកុមារមេត្រីជាមួយមន្ត្រីនគរបាលជំនាញនៅតាមបណ្តា រាជធានីភ្នំពេញ កណ្តាល បាត់ដំបង សៀមរាប ក្រចេះ និងព្រះសីហនុ។

២៣២. **កម្មវិធីផ្តល់ជំនួយសម្រាប់កុមាររងគ្រោះ** (Victim Support Services) អង្គការបានផ្តល់សេវាគាំទ្រដល់កុមាររងគ្រោះថ្មី ៣១នាក់ និងគ្រួសារ ៣០នាក់ រួមទាំងការផ្តល់ជំនួយសម្ភារៈដល់ ៤៥កុមារ/គ្រួសារ (រួមមាន៖ អង្ករ ត្រីខ មី សម្ភារៈអនាម័យ ឯកសណ្ឋានសិស្ស និងសម្ភារៈសិក្សា)។ អង្គការបានរៀបចំកម្មវិធីពិភាក្សាលើកកម្ពស់សិទ្ធិអំណាចកុមារ និងបណ្តុះបណ្តាលអាណាព្យាបាល ១០៦នាក់ ដើម្បីបង្កើតបរិយាកាសសុវត្ថិភាព និងការរាយការណ៍ដោយទំនុកចិត្ត។

២៣៣. **សេវាគាំទ្រផ្នែកច្បាប់ និងការផ្តន្ទាទោស** អង្គការបានផ្តល់សេវាគាំទ្រផ្នែកសង្គមកិច្ចដល់កុមាររងគ្រោះចំនួន ១១១នាក់ (ស្រី៩៧នាក់ ប្រុក ១២នាក់ និង LGBTQ+ ២នាក់) កុមារងាយរងគ្រោះចំនួន ៣នាក់ (ស្រី ៣នាក់) និងគ្រួសាររបស់ពួកគេ ១០៦ (ស្រី ៨៤នាក់ ប្រុស ២២នាក់) សរុបចំនួន ២២០នាក់។ ផ្តល់សេវាគាំទ្រផ្លូវច្បាប់ដល់កុមាររងគ្រោះ១១១នាក់ (ស្រី៩៧នាក់ ប្រុក ១២នាក់ និង LGBTQ+ ២នាក់) និងគ្រួសាររបស់ពួកគេ ៧៨ (ស្រី ៥៨នាក់ ប្រុស ២០នាក់) សរុបចំនួន ១៨៩នាក់។ លទ្ធផលតុលាការ និងការផ្តន្ទាទោស ករណីក្នុងស្រុកមានជនល្មើសជាតិខ្មែរត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ២ដល់៨ឆ្នាំ តាមប្រភេទបទល្មើស (រួមមាន៖ ការនាំយកអនីតិជនចេញដោយមិនស្របច្បាប់ រំលោភសេពសន្ថៈ និងសញ្ចារកម្ម)។ តុលាការកំពូលបានតម្កល់ទោសជនល្មើស ៣នាក់ ឱ្យជាប់ពន្ធនាគារចន្លោះពី ៣.៥ឆ្នាំ ដល់ ៧ឆ្នាំ។ ករណីអន្តរជាតិ ជនជាតិអាមេរិកម្នាក់ត្រូវបានតុលាការរដ្ឋ Florida ផ្តន្ទាទោស ៩ឆ្នាំ ពីបទរំលោភបំពានលើកុមារីកម្ពុជា ០៤នាក់។ ចំពោះសំណងជម្ងឺចិត្ត កុមារីរងគ្រោះ ៩នាក់ ទទួលបានសំណងសរុប ២២ ៤៨០ដុល្លារអាមេរិក។

២៣៤. **ការចូលរួមរបស់សហគមន៍ ឧស្សាហកម្ម និងប្រព័ន្ធផ្សព្វផ្សាយ** (Community & Media Engagement) បានធ្វើការលើកកម្ពស់ការយល់ដឹង ដែលមានអ្នកចូលរួមសរុប ៣ ៧៤១នាក់ (ស្រី ២ ០៥៤នាក់) តាមរយៈកម្មវិធីអប់រំចំនួន ១១ដង និងវគ្គបណ្តុះបណ្តាលចំនួន ២៩វគ្គ នៅ ៨ រាជធានី ខេត្ត។ បានគាំទ្រការរៀបចំយុទ្ធនាការទិវាសុវត្ថិភាពអ៊ីនធឺណិត (SID 2025) ដែលមានការចូលរួមដោយផ្ទាល់ចំនួន ១ ៥៧៨នាក់ នៅតាមសាលារៀនប៊ែលធី វ៉េសឡាញ និងវិទ្យាស្ថានជាតិអប់រំ ព្រមទាំងមានអ្នកចូលមើលតាមអនឡាញ និងទូរទស្សន៍ចំនួន ១៣៩ ៨២៧នាក់ ជាមួយអត្រាពេញចិត្ត ៩៩%។ អង្គការក៏បានផលិតផល និងសម្ភារៈអប់រំដូចជា សៀវភៅគោលស្តីពីការឆ្លើយតបនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារលើអនឡាញ ឯកសារស្រាវជ្រាវវិភាគគម្លាតច្បាប់ការពារកុមារ Pisey Chatbot: មានអ្នកប្រើប្រាស់ ១៩៧,៨៧០នាក់ និងផលិតផ្ទាំងរូបភាពព័ត៌មានចំនួន ០៥ផ្ទាំង។ កញ្ចប់ព័ត៌មានកុមារមេត្រីសម្រាប់មន្ត្រីអនុវត្តច្បាប់ និងក្រុមគ្រួសារកុមាររងគ្រោះ។

២៣៥. អង្គការ APLE ប្តេជ្ញាចិត្តខ្ពស់ក្នុងការបន្តកិច្ចសហការជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល និងដៃគូអន្តរជាតិ ដើម្បីពង្រឹងយន្តការការពារកុមារឱ្យកាន់តែមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងការវិវត្តនៃឧក្រិដ្ឋកម្មបច្ចេកវិទ្យាដែលកំពុងជះឥទ្ធិពលដល់សុវត្ថិភាពកុមារ។

### ង. អង្គការសេរីភាពកម្ពុជាអូស្ត្រាលី (AusCam Freedom Project)

២៣៦. ក្នុងកំឡុងឆ្នាំ ២០២៥ អង្គការ AusCam Freedom Project បានសម្រេចនូវសមិទ្ធិផលគួរឱ្យកត់សម្គាល់ក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសតាមប្រព័ន្ធអនឡាញ (OCSE)។ អង្គការបានផ្តល់ការគាំទ្រដល់កុមារី និងយុវតីសរុបចំនួន ១៥ ១៦៧នាក់ តាមរយៈកម្មវិធីអប់រំការការពារ និងការផ្តល់អំណាចក្នុងសហគមន៍។ ចំណុចសំខាន់ៗរួមមានការផ្តល់អាហារូបករណ៍ដល់សិស្ស ១០២នាក់ ការផ្តល់សេវាប្រឹក្សាផ្លូវចិត្តដល់អតិថិជន ៨៤នាក់ និងការជួយយុវតី ៤៦នាក់ឱ្យទទួលបានការងារដែលមានសុវត្ថិភាព។

២៣៧. អង្គការបានបែងចែកលទ្ធផលការងារជាបួនផ្នែកធំៗ រួមមាន **ការគាំទ្រផ្នែកអប់រំ** មានយុវតីងាយរងគ្រោះចំនួន ១២០នាក់ទទួលបានអាហារូបករណ៍ (ក្នុងនោះ ១០២នាក់កំពុងសិក្សាកម្រិតវិទ្យាល័យ និងសាកលវិទ្យាល័យ)។ **ការបណ្តុះបណ្តាល និងយុទ្ធនាការ** មានមនុស្សចំនួន ៣ ២៦៨នាក់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និង ១១ ៧១៥នាក់ទៀតបានចូលរួមក្នុងយុទ្ធនាការដឹកនាំដោយយុវតី។ **សេវាការពារ** មានកុមារី និងយុវតីចំនួន ៦៤នាក់ទទួលបានសេវាការពារ និងគាំទ្រដោយផ្ទាល់។ **បណ្តាញទូរសព្ទទាន់ហេតុការណ៍** ទទួលបានការហៅចូលចំនួន ៤៩៩នាក់ ដែលក្នុងនោះមាន ២៥ករណីពាក់ព័ន្ធនឹងការជួញដូរ ឬការកេងប្រវ័ញ្ច។

២៣៨. **ការអន្តរាគមន៍ និងការគាំទ្រ** (Interventions and Support) អង្គការបានអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងករណីដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែង ដោយបានផ្តល់ការគាំទ្រផ្លូវចិត្ត និងសង្គម តាមរយៈការវាយតម្លៃលើសិស្សងាយរងគ្រោះ ៦៧នាក់ និងផ្តល់សេវាប្រឹក្សាផ្លូវចិត្តចំនួន ៣៦០ដងដល់យុវតី និងគ្រួសារ។ ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ដើម្បីកាត់បន្ថយហានិភ័យ នៃការបោះបង់ការសិក្សា អង្គការបានផ្តល់កញ្ចប់អង្ករ ២៨៦កញ្ចប់ (តម្លៃ ៤ ២៩០ដុល្លារ) និងកញ្ចប់សង្គ្រោះបន្ទាន់ ៧៤កញ្ចប់ ដល់គ្រួសារដែលមានតម្រូវការ។ ផ្តល់សេវាផ្លូវច្បាប់ និងសុវត្ថិភាពដល់អតិថិជន ៤៧នាក់ ដោយទទួលបានអន្តរាគមន៍វិបត្តិ រួមមានសេវាការពារសុវត្ថិភាព ជំនួយផ្លូវច្បាប់ និងការព្យាបាលសុខភាព។

២៣៩. **ការការកសាងសមត្ថភាព និងការត្រៀមខ្លួនសម្រាប់អាជីព** តាមរយៈក្លឹបយុវតី (GLOW Club) ដែលផ្តោតលើជំនាញអភិវឌ្ឍន៍ខ្លួនឯង មានសិស្ស ៥៣នាក់ បានបញ្ចប់ការសិក្សាដោយជោគជ័យក្នុងឆ្នាំ២០២៥។ គម្រោងបំណិនឌីជីថល មានយុវតី ៤៧នាក់បានបញ្ចប់វគ្គបណ្តុះបណ្តាលកុំព្យូទ័រ និងគម្រោងតម្រង់ទិសអាជីពបានរៀបចំសិក្ខាសាលាចំនួន ១០លើក ដែលមានអ្នកចូលរួម ៥៤៨នាក់ និងផ្តល់ការប្រឹក្សាអាជីពដល់យុវតី ៤៨នាក់ ដើម្បីត្រៀមខ្លួនចូលទីផ្សារការងារ។ ជាលទ្ធផល យុវតី ៤៦នាក់ទទួលបានការងារដែលមានសុវត្ថិភាព។

២៤០. **យុទ្ធនាការ និងការផ្សព្វផ្សាយក្នុងសហគមន៍** កម្មវិធីភ្នាក់ងារផ្លាស់ប្តូរ (Change Agents) មានក្រុមយុវតីចំនួន ១៧ក្រុម បានអនុវត្តគម្រោងសហគមន៍ដើម្បីការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSE)។ កម្មវិធីការយល់ដឹងជាសាធារណៈ អង្គការបានរៀបចំយុទ្ធនាការអន

ឡាញក្នុងឱកាសទិវានារីអន្តរជាតិបានទៅដល់មនុស្សជាង ៤ ៦០០នាក់។ លើសពីនេះ អង្គការបានបណ្តុះបណ្តាលឪពុកម្តាយ ២២៤នាក់អំពីការអប់រំកូនបែបវិជ្ជមាន។

### ច. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO)

២៤១. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៤ ដើម្បីការពារកុមារ និងយុវជនដែលប្រឈមនឹងហានិភ័យនៅកម្ពុជា។ អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះកំពុងអនុវត្តគម្រោង EVAC ដែលផ្តោតលើការ "បញ្ចប់ការដាក់ទណ្ឌកម្មកុមារ និងលើកកម្ពស់ការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាន" ក្នុងខេត្តកំពង់ឆ្នាំង ដោយគ្របដណ្តប់លើភូមិចំនួន ៦០ ក្នុងឃុំចំនួន ៦ និងស្រុកចំនួន ២ ។

២៤២. ក្នុងឆ្នាំ ២០២៥ អង្គការសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ រួមមាន ទាក់ទងនឹងការការអប់រំ និងការយល់ដឹង មានគ្រូបង្រៀនចំនួន ៦៩២នាក់ ទទួលបានការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ និងវិន័យវិជ្ជមាន។ អាណាព្យាបាលក្នុងសហគមន៍ចំនួន ៥ ៩០២នាក់ បានចូលរួមក្នុងវគ្គផ្សព្វផ្សាយអំពីការអប់រំកូនបែបវិជ្ជមាន។ កុមារ និងយុវជនចំនួន ២ ៤៨៣នាក់ យល់ដឹងកាន់តែច្បាស់អំពីការដោះស្រាយជម្លោះដោយអហិង្សា និងរបៀបរាយការណ៍ករណីហិង្សា។ តាមរយៈគម្រោងបានបង្ហាញពីការផ្លាស់ប្តូរឥរិយាបថ ដោយគ្រូបង្រៀនប្រមាណ ៩០% បានអនុវត្តវិន័យបែបវិជ្ជមាន ជំនួសឱ្យការប្រើអំពើហិង្សា។ ការអនុវត្តការចិញ្ចឹមកូនបែបវិជ្ជមានក្នុងសហគមន៍បានកើនឡើងពី ៦០% ក្នុងឆ្នាំ ២០២៤ ដល់ ៧៧% ក្នុងឆ្នាំ ២០២៥។

២៤៣. អង្គការក៏បានការគាំទ្រជាសម្ភារៈ ដោយផ្តល់សម្ភារៈសិក្សាដល់កុមារ ៩០នាក់ និងកង់ចំនួន ២៧គ្រឿង ដល់កុមារមកពីគ្រួសារក្រីក្រ ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ។ ទោះបីមានវឌ្ឍនភាពក៏ដោយ ក៏អង្គការនៅមានបញ្ហាមួយចំនួន ដូចជា ការចូលរួមរបស់បុរសក្នុងវគ្គផ្សព្វផ្សាយនៅមានកម្រិតទាប ដោយសារការចំណាកស្រុក។ ការយល់ដឹងអំពីយន្តការរាយការណ៍ ករណីបំពានកុមារនៅមានកម្រិតនៅឡើយ។ របាំងសេដ្ឋកិច្ចសង្គម ដូចជាភាពក្រីក្រ និងអំពើហិង្សាក្នុងគ្រួសារ នៅតែជាឧបសគ្គដល់ការអនុវត្តសិទ្ធិកុមារ។ ការផ្លាស់ប្តូរសាលារបស់សមាជិកក្រុមកុមារមិត្តអប់រំមិត្ត ប៉ះពាល់ដល់និរន្តរភាពនៃសកម្មភាពគម្រោង។

២៤៤. ដើម្បីបន្តពង្រឹងកិច្ចការពារកុមារ អង្គការ VCAO បានកំណត់ទិសដៅពង្រឹងកិច្ចសហការ ដោយបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡា និងអាជ្ញាធរមូលដ្ឋាន ដើម្បីតាមដានការអនុវត្តវិន័យវិជ្ជមាន។ ពង្រីកវិសាលភាព ដោយបង្កើនការបណ្តុះបណ្តាលដល់គ្រូបង្រៀន ឪពុកម្តាយ និងអាជ្ញាធរឱ្យកាន់តែទូលំទូលាយ។ ការផ្លាស់ប្តូរឥរិយាបថប្រកបដោយនិរន្តរភាព ដោយបង្កើនការចុះទស្សនកិច្ចតាមផ្ទះ និងសកម្មភាពអប់រំក្នុងសហគមន៍ ដើម្បីធានាថាការចិញ្ចឹមកូនបែបវិជ្ជមានត្រូវបានអនុវត្តជាប្រចាំ។ ពង្រឹងយន្តការតាមដានប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ករណីហិង្សាលើកុមារឱ្យមានប្រសិទ្ធភាពជាងមុន ។

### ឆ. អង្គការមូលនិធិហាការអន្តរជាតិ (Hagar International Foundation)

២៤៥. អង្គការហាការបន្តបេសកកម្មសំខាន់ក្នុងការគាំទ្រដល់ជនរងគ្រោះ ជាពិសេសកុមារ ដែលរងគ្រោះពីការរំលោភបំពាននានា ដើម្បីស្តារជីវិតរបស់ពួកគេឡើងវិញ និងផ្តល់សិទ្ធិអំណាច។ អង្គការបានប្រើប្រាស់វិធីសាស្ត្រផ្តល់សេវាសង្គមគ្រប់ជ្រុងជ្រោយ ដែលហៅថា "The Whole Journey" (TWJ) ដែលរួមមាន៖

- ការផ្តល់ស្បៀងអាហារ និងការកែលម្អលំនៅឋាន។
- សេវាព្យាបាលការប៉ះទង្គិចផ្លូវចិត្ត និងសេវាសុខភាព។

- សេវាផ្លូវច្បាប់ និងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ។
- ការអប់រំ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច។

២៤៦. លទ្ធផលសំខាន់ៗនៃការផ្តល់សេវា ឆ្នាំ២០២៥ រួមមាន ការគាំទ្រជនរងគ្រោះ ដោយបានផ្តល់សេវាគាំទ្រដល់ជនរងគ្រោះជាកុមារសរុបចំនួន ១៥០នាក់ (ស្រី ១២៣នាក់)។ ការបិទករណី ជនរងគ្រោះជាកុមារចំនួន ៤៧ នាក់ (ស្រី ៤២នាក់) ត្រូវបានបិទករណីដោយជោគជ័យ និងបានផ្លាស់ប្តូរជីវិតទៅរកភាពប្រសើរឡើងក្នុងគ្រួសារ និងសហគមន៍។

២៤៧. ការពង្រឹងសមត្ថភាពកុមារ និងយុវជនក្នុងសហគមន៍ អង្គការបានបង្កើត និងគាំទ្រក្រុមយុវជន និងក្រុមប្រឹក្សាកុមារ ដើម្បីដើរតួនាទីជាអ្នកការពារកុមារក្នុងសហគមន៍ ដោយបានបង្កើតក្រុមយុវជនសហគមន៍ មានចំនួន ២៣ក្រុម (សមាជិក ២៣០នាក់) ក្នុងខេត្តគោលដៅចំនួន ៨ (បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ប៉ៃលិន សៀមរាប និងស្វាយរៀង)។ ក្រុមប្រឹក្សាកុមារតាមសាលារៀន គាំទ្រចំនួន ៣ សាលា ក្នុងខេត្តសៀមរាប (សមាជិក ៩០នាក់)។ ផ្តល់ការបណ្តុះបណ្តាល ផ្តោតលើសិទ្ធិកុមារ កិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ការអប់រំកូនតាមបែបវិជ្ជមាន និងបរិស្ថាន។

២៤៨. ការគាំទ្រប្រព័ន្ធ និងយន្តការការពារកុមារ អង្គការហាការបានចូលរួមចំណែកយ៉ាងសកម្មជាមួយយន្តការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបានគាំទ្រថវិកាសម្រាប់សកម្មភាពនានា និងផ្តល់ធាតុចូលក្នុងការរៀបចំគោលនយោបាយ និងគោលការណ៍ណែនាំ។ ថ្នាក់ក្រោមជាតិ បានគាំទ្រការងាររបស់គណៈកម្មការពិគ្រោះយោបល់ស្ត្រី និងកុមារ (ថ្នាក់ខេត្ត) និងគណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារ (ថ្នាក់ឃុំ) ក្នុងខេត្តគោលដៅចំនួន ៩ រួមមាន កំពង់ស្ពឺ កំពត កំពង់ឆ្នាំង ស្វាយរៀង បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន សៀមរាប និងកំពង់ធំ។

### ជ. អង្គការសម្ព័ន្ធចាប់ដៃ

២៤៩. ឆ្នាំ២០២៥ នេះ បង្ហាញពីវឌ្ឍនភាពប្រកបដោយបរិយាបន្ន និងប្រសិទ្ធភាពខ្ពស់របស់អង្គការសម្ព័ន្ធចាប់ដៃក្នុងបេសកកម្មយុទ្ធសាស្ត្រដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងទាសភាពសម័យទំនើប។ តាមរយៈការអនុវត្តអន្តរាគមន៍ចម្រុះក្នុងគម្រោងការពារ គម្រោងសម្ព័ន្ធ និងគម្រោងបង្ការ អង្គការបានសម្រេចនូវលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការស្តារសិទ្ធិសេរីភាព និងពង្រឹងភាពធន់របស់ជនរងគ្រោះ នៅក្នុងសហគមន៍គោលដៅ។

២៥០. អង្គការបានគ្រប់គ្រងករណីរំលោភបំពានសរុបចំនួន ៤៥ករណី ផ្តល់សេវាប្រឹក្សាសុខភាពផ្លូវចិត្តដល់ជនរងគ្រោះចំនួន ៣២ករណី និងពង្រឹងបណ្តាញសហការជាមួយស្ថាប័នដៃគូចំនួន ៤៣អង្គការ។ ជាចំណុចយុទ្ធសាស្ត្រ អង្គការបានរក្សានូវចីរភាពហិរញ្ញវត្ថុយ៉ាងរឹងមាំ ដោយមានថវិកាបម្រុងប្រមាណ ២៣% (ស្មើនឹង ១២០,៥៨៣.៥២ ដុល្លារ) សម្រាប់បន្តសកម្មភាពក្នុងឆ្នាំ ២០២៦។ ផ្អែកលើការវាយតម្លៃជារួម ការអនុវត្តគម្រោងក្នុងឆ្នាំនេះ ត្រូវបានចាត់ថ្នាក់ក្នុងកម្រិត **"ល្អណាស់" (Very Good)** ដែលបង្ហាញពីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដើម្បីឧត្តមប្រយោជន៍របស់អ្នកទទួលផល។ សូចនាករសំខាន់ៗប្រចាំឆ្នាំ រួមមាន ធនធានមនុស្សសរុប ៣០នាក់ (បុគ្គលិកខ្មែរ ២៨នាក់ បរទេស ១នាក់ និងជនមានពិការភាព ១នាក់)។ ចំនួនអ្នកទទួលផល (Unique Beneficiaries) សរុប ៩៤២នាក់ (ស្រី ៦៨២នាក់ និងប្រុស ២៦១នាក់)។ ជោគជ័យ

នៃសមាហរណកម្ម ដោយបានជួយជនរងគ្រោះចំនួន ១៦នាក់ និងបានធ្វើសមាហរណកម្មចូលទៅក្នុងគ្រួសារ និងសហគមន៍វិញដោយជោគជ័យ និងសុវត្ថិភាព។

២៥១. អង្គការបានពង្រីកសកម្មភាពគ្របដណ្តប់លើរាជធានី ខេត្តចំនួន ១៩ នៅទូទាំងប្រទេសកម្ពុជា។ ក្នុងនោះ ខេត្តត្បូងឃ្មុំ និងព្រះវិហារ គឺជាតំបន់ប្រតិបត្តិការស្នូល (Primary Hubs) ដែលទទួលបានកិច្ចអន្តរាគមន៍លើគ្រប់សមាសភាគគម្រោង។ បណ្តាខេត្តដទៃទៀត រួមមាន ភ្នំពេញ ស្វាយរៀង កំពង់ចាម ក្រចេះ ព្រៃវែង កំពង់ធំ កំពង់ឆ្នាំង បន្ទាយមានជ័យ កណ្តាល សៀមរាប កំពង់ស្ពឺ ពោធិ៍សាត់ ឧត្តរមានជ័យ តាកែវ បាត់ដំបង កំពត និងស្ទឹងត្រែង។

២៥២. អង្គការអនុវត្តលើគម្រោងសំខាន់ៗមួយចំនួន រួមមាន **គម្រោងការពារ** (Protection Project) ដែលផ្តោតលើការស្តារអំណាច (Empowerment) និងការផ្តល់សេវាគាំពារសង្គមគ្រប់ជ្រុងជ្រោយដល់ជនរួចពីរងគ្រោះ។ តាមរយៈ **ការគ្រប់គ្រងករណី និងជំនួយច្បាប់** ដោយបានគ្រប់គ្រងករណីជួញដូរមនុស្ស និងរំលោភបំពានសរុប ៤៥ករណី ក្នុងខេត្តចំនួន ១២។ ផ្តល់ជំនួយផ្នែកច្បាប់ចំនួន ២៣ ករណី ដោយបែងចែកតាមដំណាក់កាលនីតិវិធី៖ ដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរ (១៧ករណី), ដំណាក់កាលជំនុំជម្រះ/សវនាការ (៤ករណី) និងការផ្តល់ប្រឹក្សាផ្នែកច្បាប់ (២ករណី)។ **សុខភាពផ្លូវចិត្ត និងសម្ភារឧបត្ថម្ភ** ដោយផ្តល់សេវាប្រឹក្សាផ្លូវចិត្តបាន ៣២ករណី ក្នុងខេត្តចំនួន ១៦។ ផ្តល់កញ្ចប់គ្រឿងឧបភោគបរិភោគ (តម្លៃ ៣០/ម្នាក់) និងសម្ភារអនាម័យ (តម្លៃ ២០/ម្នាក់) ដល់អតិថិជន ព្រមទាំងការគាំទ្រជីវភាព និងមុខរបរខ្នាតតូច ៦ ករណី។

២៥៣. **គម្រោងសម្ព័ន្ធ** (Coalition Project) គម្រោងនេះ ដើរតួនាទីជាអ្នកសម្របសម្រួលបណ្តាញអង្គការសង្គមស៊ីវិល ដើម្បីពង្រឹងប្រសិទ្ធភាពឆ្លើយតបជាប្រព័ន្ធ។ **ភាពជាដៃគូ** រៀបសិក្ខាសាលាជាមួយអង្គការជាសមាជិកចំនួន ៤៣ស្ថាប័ន (អ្នកចូលរួម ៩២នាក់)។ **ការកសាងសមត្ថភាព** បណ្តុះបណ្តាលលើប្រធានបទយុទ្ធសាស្ត្រ រួមមាន ការសង្គ្រោះបឋម ការគ្រប់គ្រងករណី ការការពារកុមារតាមប្រព័ន្ធអនឡាញ និងការងារមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

២៥៤. **គម្រោងបង្ការទប់ស្កាត់** (Prevention Project) ដោយបង្កើតយុទ្ធនាការសហគមន៍ តាមរយៈវេទិកាផ្សព្វផ្សាយ "ការបង្ការក៏ជាកិច្ចការសំខាន់" ត្រូវបានរៀបចំនៅវិទ្យាល័យ ជា ស៊ីម កណ្តោលជ្រុំ និងវិទ្យាល័យ ហ៊ុន សែន ក្តុល ដោយមានអ្នកចូលរួម ៣១៧នាក់។ អង្គការក៏បានស្ទង់មតិលើប្រជាពលរដ្ឋ ១៥៥នាក់ បានរកឃើញនូវតម្រូវការចាំបាច់ក្នុងការបង្កើនចំណេះដឹងលើ "ការចំណាកស្រុកដោយសុវត្ថិភាព" និង "ប្រព័ន្ធរាយការណ៍ក្នុងមូលដ្ឋាន" ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំយុទ្ធសាស្ត្របង្ការឱ្យចំគោលដៅ។

២៥៥. ការអនុវត្តការងារក្នុងឆ្នាំ២០២៥ បានសម្រេចនូវសូចនាករគន្លឹះលើសពីការរំពឹងទុក ជាពិសេសលើការងារគ្រប់គ្រងករណី និងការគាំទ្រផ្នែកច្បាប់។ ទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយអាជ្ញាធរមូលដ្ឋាន និងការប្រើប្រាស់ថវិកាប្រកបដោយតម្លាភាព បានធ្វើឱ្យអង្គការទទួលបានការវាយតម្លៃកម្រិត "ល្អណាស់" ពីគ្រប់ភាគីពាក់ព័ន្ធ។ ផ្អែកលើទិន្នន័យឆ្លុះបញ្ចាំងពីឆ្នាំ២០២៥ អង្គការបានបញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រ និងទិសដៅការងារបន្តសម្រាប់ឆ្នាំ២០២៦ ដោយផ្តោតលើចំណុចសំខាន់ៗចំនួនពីរ ១. ពង្រឹងយន្តការបង្ការកម្រិតសហគមន៍តាមរយៈការបង្កើនចំណេះដឹងអំពីការចំណាកស្រុកដោយសុវត្ថិភាព។ ២. ពង្រីកវិសាលភាពនៃសេវាជំនួយច្បាប់ និងការស្តារនីតិសម្បទាជនរងគ្រោះឱ្យកាន់តែស៊ីជម្រៅនៅបណ្តាខេត្តជាប់ព្រំដែន។

## ឈ. អង្គការសង្គ្រោះកុមារ (Save the Children)

២៥៦. ឆ្នាំ២០២៥ អង្គការសង្គ្រោះកុមារ (Save the Children) សម្រេចបាននូវវឌ្ឍនភាពជាយុទ្ធសាស្ត្រក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកិច្ចការពារកុមារ និងការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។ របាយការណ៍នេះ បង្ហាញពីលទ្ធផលនៃការងារតស៊ូមតិ និងការរៀបចំគោលនយោបាយដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ សមិទ្ធផលគន្លឹះទាំងនេះ រួមមាន **ការធ្វើស្ថាប័ននីយកម្មនៃការចូលរួមរបស់កុមារ (Institutionalizing Child Participation)** ការបញ្ចូលកុមារជាសមាជិកផ្លូវការក្នុងយន្តការសម្រេចចិត្តថ្នាក់ក្រោមជាតិ និងការទទួលបានវិភាជថវិកាជាក់លាក់ពីកញ្ចប់ថវិកាឃុំ។ **ការជំរុញបរិយាបន្ន SOGIESC ក្នុងគោលនយោបាយជាតិ** ការបញ្ចូលប្រធានបទសិទ្ធិកុមារដែលមានអត្តសញ្ញាណយេនឌ័រចម្រុះទៅក្នុងកម្មវិធី "ការចិញ្ចឹមកូនបែបវិជ្ជមាន" របស់ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល។ **នវានុវត្តន៍ឌីជីថលដើម្បីគណនេយ្យភាព** ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាដូចជា Kobo Toolbox និង Social Accountability App ដើម្បីពង្រឹងការធ្វើផែនការវិនិយោគឃុំដែលផ្អែកលើភស្តុតាង។ **ការពង្រឹងសុវត្ថិភាពក្នុងសាលារៀន** ការកាត់បន្ថយអំពើហិង្សាលើកុមារតាមរយៈការបង្កើតយន្តការរាយការណ៍ និងការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្លូវចិត្តក្នុងសាលារៀនគោលដៅ។

២៥៧. ការអនុវត្តការងារ ត្រូវបានរៀបចំឡើងតាមរយៈគម្រោងយុទ្ធសាស្ត្រចំនួន ៣ ៖ (១) ពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិល ជំរុញគណនេយ្យភាពសង្គម និងការចូលរួមរបស់កុមារក្នុងអភិបាលកិច្ច (២)ការលើកកម្ពស់បរិយាបន្ន និងកិច្ចការពារកុមារដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ (៣)លុបបំបាត់អំពើហិង្សាលើកុមារក្នុងសាលារៀន (Ending Violence Against Children in Schools) ដែលមានការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីម្ចាស់ជំនួយអន្តរជាតិ និងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូក្នុងស្រុក ដូចជា LLC, CCYMCR, WOMEN, GADC, CRC-Cambodia, CCC ។

២៥៨. **ការពង្រឹងសមត្ថភាព និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល (Capacity Building and Digital Innovation)** អង្គការបានបញ្ចូលនវានុវត្តន៍ឌីជីថលទៅក្នុងអភិបាលកិច្ចមូលដ្ឋាន ដើម្បីធានានូវតម្លាភាព និងប្រសិទ្ធភាព។ ការប្រើប្រាស់ Kobo Toolbox បានអនុញ្ញាតឱ្យមន្ត្រីឃុំ និងតំណាងកុមារធ្វើផែនទីសេវាសង្គមតាមប្រព័ន្ធឌីជីថល ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការធ្វើផែនការវិនិយោគឃុំ (CIP)។ ទន្ទឹមនឹងនេះ កម្មវិធី Social Accountability App ត្រូវបានប្រើប្រាស់ដើម្បីឱ្យកុមារអាចចូលមើល និងវិភាគទិន្នន័យថវិកាឃុំ មណ្ឌលសុខភាព និងសាលារៀន។ ចំពោះការតស៊ូមតិ កុមារត្រូវបានបណ្តុះបណ្តាលលើឧបករណ៍ SHIFT 360 ដើម្បីដឹកនាំយុទ្ធនាការស្វែងរកការគាំទ្រប្រកបដោយវិជ្ជាជីវៈ។ សមិទ្ធផលបច្ចេកទេសមួយទៀតគឺ Online Learning Hub ដែលសម្រេចបាននូវការចូលមើលរហូតដល់ ១៤៧ ០៩៦ដង ដោយផ្តល់នូវធនធានសិក្សាសុវត្ថិភាពអំពីសិទ្ធិកុមារ។ លទ្ធផលនៃការបណ្តុះបណ្តាលលើការចូលរួមរបស់កុមារក្នុង CIP និងកិច្ចការពារកុមារសម្រាប់អាជ្ញាធរមូលដ្ឋាន និងគ្រូបង្រៀន បានបង្ហាញពីការកើនឡើងនៃចំណេះដឹងពី ៤៨.៥៥% ដល់ ៨២.៨៤% ។

២៥៩. **ការបញ្ចូលកុមារក្នុងអភិបាលកិច្ច និងការរៀបចំថវិកាថ្នាក់ក្រោមជាតិ (Inclusion in Local Governance and Budgeting)** វឌ្ឍនភាពដ៏សំខាន់ក្នុងឆ្នាំ២០២៥ គឺការធ្វើឱ្យការចូលរួមរបស់កុមារក្លាយជាផ្នែកមួយនៃប្រព័ន្ធអភិបាលកិច្ចជាផ្លូវការ។ កុមារចំនួន ១១នាក់ ត្រូវបានទទួលស្គាល់ជាសមាជិកផ្លូវការនៃគណៈកម្មាធិ

ការទទួលបន្ទុកកិច្ចការនារីនិងកុមារ (គ.ក.ន.ក) នៅតាមឃុំគោលដៅ។ នេះគឺជាជំហានដ៏មានសារៈសំខាន់សម្រាប់ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការកុមារ (Child-Responsive Budgeting)។ លទ្ធផលជាក់ស្តែងនៃការបែងចែកកញ្ចប់ថវិកាក្នុងផែនការវិនិយោគឃុំ (CIP) រួមមាន៖ ឃុំត្រាំសសរបានវិភាជថវិកាចំនួន ១ ០០០ ០០០រៀល សម្រាប់កិច្ចប្រជុំត្រីមាស និងយុទ្ធនាការរបស់ក្លឹបកុមារ សង្កាត់បឹងខ្នាបានបែងចែកថវិកាចំនួន ១ ០៨០ ០០០រៀល សម្រាប់ទ្រទ្រង់សកម្មភាព និងសម្ភារៈរបស់ក្លឹបកុមារ ឃុំស្លាបានផ្តល់ថវិកាចំនួន ៦០០ ០០០រៀល ដើម្បីឧបត្ថម្ភដល់យុទ្ធនាការដឹកនាំដោយកុមារ។

២៦០. **ការលើកកម្ពស់បរិយាបន្ន និងសិទ្ធិកុមារដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ** (Inclusivity and SOGIESC Rights) ការងារលើបរិយាបន្ន SOGIESC បានសម្រេចនូវលទ្ធផលគួរឱ្យកត់សម្គាល់តាមរយៈយុទ្ធនាការ "បញ្ចប់ការរើសអើងលើកុមារដែលមាន SOGIESC ចម្រុះ" ។ យុទ្ធនាការឌីជីថលក្នុងទិវា IDAHOBIT បានជះឥទ្ធិពលដល់មនុស្សចំនួន ៥៤៣ ៣៨៧នាក់។ លើសពីនេះ ការបណ្តុះបណ្តាលដល់អាជ្ញាធរមូលដ្ឋានបានបង្ហាញពីការកើនឡើងចំណេះដឹងចំនួន ៤១.២៥% នៅសៀមរាប និង៤២.៨៦% នៅខេត្តកណ្តាល។ **ករណីសិក្សា** តំណាង គ.ក.ន.ក ម្នាក់បានចែករំលែកថា ក្រោយពីទទួលបានការបណ្តុះបណ្តាលពីអង្គការ CCYMCR គាត់បានផ្លាស់ប្តូរឥរិយាបថពីការបដិសេធ មកជាការទទួលយក និងផ្តល់តម្លៃដល់អត្តសញ្ញាណយេនឌ័រពិតប្រាកដរបស់កូនស្រីគាត់ ដែលនាំមកនូវសុខដុមរមនាក្នុងគ្រួសារ។ ជាយុទ្ធសាស្ត្រ ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលបានប្តេជ្ញាបញ្ចូលប្រធានបទ SOGIESC ទៅក្នុងកម្មវិធីជាតិស្តីពី "ការចិញ្ចឹមកូនបែបវិជ្ជមាន" ដើម្បីលុបបំបាត់ការរើសអើង និងអំពើហិង្សា។

២៦១. **កិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល** (National Policy Dialogue and Government Commitments) ក្នុងសិក្ខាសាលាថ្នាក់ជាតិឆ្នាំ២០២៥ កុមារបានបង្ហាញនូវ **បញ្ហាសំខាន់ៗ ចំនួន ៨** ដែលជាអាទិភាពសម្រាប់ការដោះស្រាយ៖ ១. អំពើហិង្សាផ្លូវកាយនៅផ្ទះ និងសាលារៀន។ ២. ការរំលោភបំពានផ្លូវភេទតាមអនឡាញ។ ៣. ការរើសអើងចំពោះកុមារដែលមាន SOGIESC ចម្រុះ។ ៤. ការបង្ខំឱ្យរៀបការនៅវ័យក្មេង។ ៥. ការប្រើប្រាស់គ្រឿងញៀន។ ៦. ពលកម្មកុមារ។ ៧. ការបោះបង់ការសិក្សា។ ៨. ការចូលរួមមិនបានពេញលេញក្នុងដំណើរការសម្រេចចិត្ត។

២៦២. **ការឆ្លើយតបជាយុទ្ធសាស្ត្រពីរាជរដ្ឋាភិបាល** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរាយការណ៍ពីការផ្សព្វផ្សាយ "ផែនការអាស៊ានក្នុងការបញ្ចប់អំពើហិង្សាលើកុមារ ឆ្នាំ២០៣០" និង "យុទ្ធនាការគ្រួសាររឹងមាំ ដំណាក់កាលទី២ (២០២៥-២០៣០)" ព្រមទាំងការជំរុញអនុម័តច្បាប់ស្តីពីកិច្ចការពារកុមារនៅឆ្នាំ២០២៦។ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាធានាឱ្យមានសាលាបឋមសិក្សាមួយក្នុងមួយឃុំ និងវិទ្យាល័យមួយក្នុងមួយស្រុក។ក្រសួងកិច្ចការនារី កំពុងបញ្ចប់ "ផែនការជាតិទប់ស្កាត់ការរៀបការវ័យក្មេង" ដែលគ្រោងនឹងចេញផ្សាយនៅចុងឆ្នាំ២០២៥។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ កំពុងអភិវឌ្ឍប្រព័ន្ធជាតិសម្រាប់រាយការណ៍អំពីអំពើរំលោភបំពាន និងអនុវត្តគោលការណ៍ណែនាំកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ។

២៦៣. **បរិស្ថានសុវត្ថិភាពក្នុងសាលារៀន និងយន្តការការពារកុមារ** (Safe School Environment and Protection Mechanisms) គម្រោង EVACiS បានសម្រេចនូវលទ្ធផលសំខាន់ៗក្នុងសាលាបឋមសិក្សាគោលដៅចំនួន ៤៣ ដោយមានអ្នកចូលរួមសរុប ៥ ០៤៩នាក់។ ពិធីប្រគល់ហេដ្ឋារចនាសម្ព័ន្ធត្រូវបានដឹកនាំដោយ អភិបាល

ស្រុក ឬអភិបាលរងស្រុក ដែលបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់របស់អាជ្ញាធរ។ សមិទ្ធផលសំខាន់ៗរួមមាន **ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ** ដូចជា ការសាងសង់ និងប្រគល់បន្ទប់ប្រឹក្សាយោបល់ចំនួន ៥ នៅក្នុងសាលា៖ ពូសាលា រការអា កោះតាង៉ោល កន្លែងរុន និងថ្លុកជ្រៅ។ **ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ** ដោយសាលារៀនបានផលិតវីដេអូអប់រំអំពីកិច្ចការពារកុមារ ដែលវីដេអូជ័យលាភីទទួលបានការចូលមើលរហូតដល់ ៣ ៨០០ដងលើ Facebook។ **យន្តការរាយការណ៍** បានពង្រឹងសមត្ថភាពអ្នកទទួលបន្ទុកកិច្ចការពារកុមារ (CPFP) ក្នុងការកំណត់អត្តសញ្ញាណ និងបញ្ជូនករណីអំពើហិង្សា។

២៦៤. ឆ្នាំ២០២៥ គឺជាឆ្នាំនៃការផ្លាស់ប្តូរជាវិជ្ជមានតាមរយៈការបញ្ចូលសម្លេងកុមារទៅក្នុងប្រព័ន្ធគោលនយោបាយជាតិ និងការវិភាជថវិកាថ្នាក់ក្រោមជាតិ។ កិច្ចសហការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបានបង្កើតនូវយន្តការប្រកបដោយនិរន្តរភាពសម្រាប់ការត្រួតពិនិត្យ និងរាយការណ៍អំពីសិទ្ធិកុមារ។ ដើម្បីបន្តវឌ្ឍនភាពនេះ ចាំបាច់ត្រូវមានការតាមដានយ៉ាងហ្មត់ចត់លើការអនុវត្តអនុសាសន៍របស់ UNCRC និង UPR ព្រមទាំងការបន្តវិនិយោគលើសមត្ថភាពឪពុកម្តាយ និងកិច្ចការពារកុមារតាមគ្រប់រូបភាព។

## ញ. អង្គការបណ្តាញទូរសព្ទជំនួយកុមារកម្ពុជា (១២៨០)

២៦៥. អង្គការបណ្តាញទូរសព្ទជំនួយកុមារកម្ពុជា (CHC១២៨០) បានអនុវត្តគោលដៅយុទ្ធសាស្ត្រចំនួន ០៤ រួមមាន (១)ការការពារ ដែលមានកម្មវិធីដូចជា ការផ្តល់សេវាពិគ្រោះយោបល់តាមទូរសព្ទ ដោយឥតគិតថ្លៃ ២៤/៧ ការផ្តល់ការពិគ្រោះយោបល់ដល់គ្រួសារ សេវាសុខភាពបឋម និងមនុស្សធម៌ ការផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ការបញ្ជូនបន្តនិងតាមដាន និងថ្នាលប្រព័ន្ធផ្សព្វផ្សាយសង្គម។ (២)ការបង្ការ-ទប់ស្កាត់ ដែលមានកម្មវិធីដូចជា យន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ (CRRM) យុវជនប្រេសិតរបស់បណ្តាញទូរសព្ទជំនួយកុមារ កម្មវិធីស្វ័យសិក្សា Chatbot/Autobot កម្មវិធីអេបសុខភាពយុវវ័យ (Youth Health Mobile App) កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" (My Journey Mobile App) កម្មវិធីអេប "សុវត្ថិភាពយើង" (Safe App) បន្ទប់សុខភាពសាលារៀន និងការបន្តការសិក្សា។ (៣)ការតស៊ូមតិ ដែលមានកម្មវិធីដូចជា ការទំនាក់ទំនង និងបោះពុម្ពផ្សាយ សិក្ខាសាលា/សន្និសីទអន្តរជាតិក្នុងតំបន់ និងថ្នាក់ជាតិ។ (៤)ការអភិវឌ្ឍស្ថាប័ន ដែលមានកម្មវិធីដូចជា ការគ្រប់គ្រងកម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុនិងរដ្ឋបាល ការអភិវឌ្ឍធនធានមនុស្ស។

២៦៦. កម្មវិធីការការពារមានគោលបំណង ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការការពារកុមារ និងយុវជនតាមរយៈរចនាសម្ព័ន្ធបណ្តាញជំនួយកុមារ ដោយសម្របសម្រួលសេវាដែលមានស្រាប់ និងការព្យាបាលផ្លូវចិត្ត-សង្គម។ ការផ្តល់សេវាពិគ្រោះយោបល់តាមទូរសព្ទដោយឥតគិតថ្លៃ ២៤/៧ ៖ ក្រុមអ្នកពិគ្រោះយោបល់របស់ CHC បានឆ្លើយការហៅចូលទូរសព្ទចំនួន ១៧ ៨៣១ដង ក្នុងនោះអតិថិជនចំនួន ៤ ០៣៨នាក់ បានទទួលការពិគ្រោះយោបល់តាមទូរសព្ទ និងអនឡាញ, អតិថិជនចំនួន ៥៩ នាក់ បានរាយការណ៍អំពីបញ្ហាទាក់ទងនឹងការការពារកុមារ អតិថិជនចំនួន ៥ ៤៦៨នាក់ បានទទួលសេវាកម្មអប់រំ និងព័ត៌មានផ្នែកលើបញ្ហា និងអតិថជនចំនួន ៨ ២៦៦នាក់ បានសាកល្បងក្នុងការជជែក។ ក្នុងចំណោមអតិថិជន ១៧ ៨៣១នាក់ (ស្ត្រី ៦ ៣០៨នាក់ បុរស ៣ ៤០៣នាក់ LGBTIQ ៧៧នាក់ មិនអាចកំណត់អត្តសញ្ញាណយេនឌ័របាន ៨ ៤០៣នាក់)។ ក្នុងចំណោមអតិថិជន ១៧ ៨៣១នាក់ មាន(កុមារ ៨៥៧នាក់ យុវជន ១ ៧៣៥នាក់ មនុស្សពេញវ័យ ៣ ៩០១នាក់ មិនអាចកំណត់អាយុបាន ៤ ៨៩២នាក់)។

២៦៧. ផ្តល់ការពិគ្រោះយោបល់ដល់គ្រួសារ សេវាសុខភាពបឋម និងមនុស្សធម៌៖ សេវាប្រឹក្សាគ្រួសារ សេវាសុខភាពបឋម និងសេវាមនុស្សធម៌ គឺជាកម្មវិធីយុទ្ធសាស្រ្តរបស់ CHC ដែលបង្កើតឡើង ដើម្បីបំបែកវប្បធម៌នៃភាពស្ងៀមស្ងាត់ និងការបិទបាំងការរំលោភបំពាននៅក្នុងសហគមន៍ ដែលក្មេងស្រី និងក្មេងជំទង់ភាគច្រើននៅស្ងៀម និងរក្សាការសម្ងាត់ចំពោះអំពើហិង្សា និងការរំលោភបំពានដែលសមាជិកគ្រួសារ ឬដៃគូជិតស្និទ្ធបានប្រព្រឹត្តមកលើពួកគេ។ ជួយគាំទ្រដល់កុមារក្មេងជំទង់ ក្មេងស្រី និងស្ត្រីដែលរងផលប៉ះពាល់ដោយអំពើហិង្សា និងការរំលោភបំពាន។ CHC ផ្តល់សេវាប្រឹក្សាគ្រួសារ សេវាសុខភាពបឋម និងសេវាមនុស្សធម៌ដល់ស្ត្រី និងកុមារីចំនួន៤៨៥នាក់ ដែលជាជនរងគ្រោះ/អ្នករួចផុតពីការរំលោភបំពាន និងអំពើហិង្សា ដើម្បីកាត់បន្ថយបន្ទុកសេដ្ឋកិច្ចគ្រួសារ និងភាពក្រីក្រ។ ការផ្តល់សេវាពិគ្រោះយោបល់តាមគ្រួសារ រួមមានព័ត៌មានអប់រំអំពីសុខភាពផ្លូវភេទ និងសិទ្ធិបន្តពូជ ផែនការគ្រួសារ ការពន្យារកំណើត/គម្លាតពីកំណើត ភាពជាឪពុកម្តាយវិជ្ជមាន ផលវិបាកអវិជ្ជមាននៃកុមារ/ការរៀបអាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ អំពើហិង្សា និងការរំលោភបំពាន និងរបៀបរាយការណ៍ទៅអាជ្ញាធរដែលនៅជិតបំផុត ឬទូរសព្ទជំនួយឥតគិតថ្លៃ 1280 សម្រាប់ជួយគាំទ្រ។ សេវាសុខភាពបឋម និងមនុស្សធម៌ រួមមានការផ្តល់អាហារូបត្ថម្ភ និងសម្ភារៈអនាម័យ ដូចជា ត្រីខកំប៉ុង សាប៊ូ ត្រីងៀត ពងទា អង្ករ ប្រេងឆា ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកដោះគោ អំបិល សម្ភារៈសង្គ្រោះបឋម បង់បិតដំបៅ ប្រេងកូឡា និងប្រេងខ្យល់។

២៦៨. ផ្តល់ជំនួយផ្នែកច្បាប់ ដោយឥតគិតថ្លៃ៖ ស្ត្រីនិងកុមារី ដែលជាជនរងគ្រោះនៃអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ បន្តប្រាប់អ្នកពិគ្រោះយោបល់ជួរមុខរបស់ CHC ថា ពួកគេមិនអាចដាក់ពាក្យបណ្តឹងនៅតុលាការប្រឆាំងជនល្មើសបានទេ ដោយសារការលំបាក/បញ្ហាប្រឈមហិរញ្ញវត្ថុ។ CHC ផ្តល់កញ្ចប់ជំនួយផ្នែកច្បាប់ពេញលេញ ដែលរួមមាន តំណាងផ្លូវច្បាប់ ថ្លៃតុលាការ និងថ្លៃធ្វើដំណើរ ដើម្បីឱ្យស្ត្រី និងកុមារី អាចប្តឹងតវ៉ានៅតុលាការប្រឆាំងនឹងអ្នករំលោភបំពាន/ជនល្មើសផ្លូវភេទ និងអ្នកដែលប្រព្រឹត្តអំពើហិង្សា ហើយធានាថាស្ត្រី និងកុមារីអាចទទួលបានដំណោះស្រាយផ្លូវច្បាប់ និងការផ្សះផ្សា តាមរយៈជំនួយផ្នែកច្បាប់។ នៅឆ្នាំ ២០២៥ CHC បានបញ្ជូនអតិថិជនចំនួន ៧២ នាក់ (ស្រី ៦២ នាក់ ប្រុស ១០ នាក់) ទៅសេវាកម្មជំនួយផ្នែកច្បាប់។ យោងតាមរបាយការណ៍របស់អ្នកផ្តល់សេវាផ្លូវច្បាប់ មានមួយករណីត្រូវបានបញ្ចប់និតិវិធីតុលាការ ហើយជាលទ្ធផលនៃសាលក្រម សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ១ឆ្នាំ និងសងជំងឺចិត្ត ៥លានរៀល។ លើសពីនេះ ជនប្រព្រឹត្ត២នាក់ត្រូវបានចាប់ខ្លួន និងកំពុងបន្តនិតិវិធីផ្លូវច្បាប់ក្នុងដំណើរការតុលា។

២៦៩. ការបញ្ជូនបន្ត និងតាមដាន៖ CHCមានគោលការណ៍ដើម្បីការពារការសម្ងាត់របស់អតិថិជន និងគោរពការសម្រេចចិត្តរបស់អតិថិជនក្នុងការបញ្ជូនបន្ត។ អតិថិជនចំនួន ១៥៤នាក់ (ស្ត្រី១១៧នាក់ និង បុរស៣៧នាក់) ត្រូវបានបញ្ជូនបន្ត ដោយផ្អែកលើការយល់ព្រមរបស់ពួកគេសម្រាប់សេវាផ្ទាល់ និងអន្តរាគមន៍ភ្លាមៗជាមួយដៃគូអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងចំណោមអតិថិជន ដែលបានបញ្ជូនបន្តចំនួន ១៥៤នាក់ អតិថិជន ៦នាក់ទទួលបានជំនួយសុខភាពផ្លូវកាយ ៣១នាក់ទទួលបានជំនួយសុខភាពផ្លូវចិត្ត ៧២នាក់បានទទួលជំនួយផ្នែកច្បាប់ ៧នាក់បានទទួលជំនួយតម្រូវការមូលដ្ឋាន ២៤នាក់ទទួលសេវាអន្តរាគមន៍ ៨នាក់ទទួលជំនួយលើការស្វែងរកការងារ និង ៦នាក់បានទទួលសេវាកម្មផ្សេងៗ។ អតិថិជនចំនួន ២ ៤២០នាក់ត្រូវបានតាមដានដើម្បីធានាថាពួកគេមានសុវត្ថិភាព និងរស់នៅក្នុងបរិយាកាសការពារ។

២៧០. ថ្នាលកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ទំព័រ Facebook របស់ Child Helpline Cambodia មាន អ្នកតាមដានចំនួន ១ ១០៥ ៩១១ នាក់ (ស្ត្រី៥២.១០% និងបុរស៤៧.៩០%)។

ភាគច្រើននៃអ្នកតាមដានមានអាយុចន្លោះពី២៥ ទៅ៣៤ឆ្នាំ។ នៅឆ្នាំ២០២៥ ក្រុមអ្នកពិគ្រោះយោបល់ CHC បានផ្តល់សេវាប្រឹក្សាតាមអនឡាញដល់យុវជនចំនួន ៨៦៨នាក់ និងព័ត៌មានផ្នែកលើបញ្ហាដល់យុវជនចំនួន ៣ ២២៤នាក់ ទទួលការពិគ្រោះយោបល់តាមរយៈកម្មវិធីផ្ញើសារសន្ទនា Facebook និង តេឡេក្រាម។

២៧១. ការបង្ការ-ទប់ស្កាត់ មានគោលបំណង ដើម្បីទប់ស្កាត់អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច តាមរយៈ ការចូលរួមពីសហគមន៍ ភ្នាក់ងារផ្លាស់ប្តូរសង្គម និងអាជ្ញាធរមូលដ្ឋានក្នុងការបង្កើតបរិយាកាស សុវត្ថិភាព ការចូលរួម និងគាំទ្រដល់កុមារ និងយុវជន ដើម្បីឱ្យពួកគេយល់ដឹងពីសិទ្ធិ និងឈានដល់សក្តានុពលពេញលេញ។ យន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ (CRRM)៖ CHC បានបណ្តុះបណ្តាលមន្ត្រីរាជការនៅមូលដ្ឋានចំនួន ២៦៤នាក់ (ស្រី១០៧នាក់) រួមមាន សមាជិក គ.ក.ន.ក. អភិបាលរងស្រុក មន្ត្រីមកពីមន្ទីរសង្គមកិច្ច នគរបាល មេភូមិ ប្រធានមណ្ឌលសុខភាព និងនាយកសាលា នៅខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តរតនគិរី ក្នុងឆ្នាំ២០២៥ ដោយផ្តោតលើយន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ មូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់ ការសង្គ្រោះផ្លូវចិត្តបឋម អំពើហិង្សាទាក់ទងនឹងយេនឌ័រ ផលវិបាកនៃអាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ការសង្គ្រោះបឋម ការបញ្ជូនបន្ត និងការគ្រប់គ្រងករណី។

២៧២. យុវជនប្រេសិតរបស់បណ្តាញទូរសព្ទជំនួយកុមារ៖ CHC បានបណ្តុះបណ្តាលយុវជនចំនួន ១ ០០៣នាក់ (ស្រី ៦០១នាក់) ទៅលើមូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់ ការអប់រំផ្លូវភេទទូលំទូលាយ (CSE) សុខភាពផ្លូវភេទ ការបន្តពូជ (SRH) អំពើហិង្សាទាក់ទងនឹងយេនឌ័រ ផលវិបាកនៃអាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ការសង្គ្រោះបឋម និងជំនាញសម្របសម្រួលក្នុងការបញ្ជូនបន្តនៅខេត្តកំពង់ចាម ត្បូងឃ្មុំ មណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ក្រុមយុវជនដែលចូលរួមបានបង្ហាញពីការប្តេជ្ញាចិត្ត និងការចូលរួមយ៉ាងសកម្មតាមរយៈការពិភាក្សាជាក្រុម និងអនុវត្តជំនាញរបស់ពួកគេជាមួយនឹងភាពជឿជាក់កម្រិតខ្ពស់។ ក្រុមយុវជនដែលបានទទួលការបណ្តុះបណ្តាលបានរៀនពីមូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់ ការអប់រំផ្លូវភេទ (CSE) សុខភាពផ្លូវភេទទូលំទូលាយ ការបន្តពូជ (SRH) អំពើហិង្សាទាក់ទងនឹងយេនឌ័រ ផលវិបាកនៃអាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ការសង្គ្រោះបឋម និងដំណើរការបន្ទប់សុខភាពសាលារៀន ការបញ្ជូនទៅកាន់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។

២៧៣. ស្វ័យសិក្សា Chatbot/Autobot៖ នៅខែមិថុនា ឆ្នាំ២០២២ CHC ដោយមានជំនួយផ្នែកហិរញ្ញវត្ថុពីភ្នាក់ងារអន្តរជាតិ បានរៀបចំបណ្តាញទំនាក់ទំនងសង្គម (Social Media)។ សៀវភៅណែនាំការស្វ័យសិក្សាប្រព័ន្ធ chatbot ដែលលក្ខណៈមេត្រីសម្រាប់កុមារ អំពីសិទ្ធិកុមារ បច្ចេកទេសស្វ័យការពារ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សមភាពយេនឌ័រ អំពើហិង្សាលើកុមារ សិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានចំនួន ១ ៣៣៨នាក់ អ្នកប្រើប្រាស់ (កុមារី ២៨៣នាក់ ស្ត្រី ១៨៣នាក់ អាយុចន្លោះ១៨ឆ្នាំ ដល់២៤ឆ្នាំ កុមារា ៥៣៤នាក់ បុរស ៣២២នាក់ អាយុចន្លោះ១៨ឆ្នាំ ដល់២៤ឆ្នាំ និងអត្តសញ្ញាណយេនឌ័រផ្សេងៗទៀតចំនួន ១៦នាក់)។ បានចូលប្រើថ្នាលសន្ទនា Chatbot សម្រាប់ស្វ័យសិក្សា ដែលក្នុងនោះ រួមមាន មេរៀនទី១ "តម្លៃ និងសិទ្ធិ" មេរៀនទី២ "ចំណេះដឹងរបស់ខ្ញុំ និងសុវត្ថិភាពរបស់ខ្ញុំ" មេរៀនទី៣ "ខ្ញុំឆ្លាតក្នុងការប្រើប្រាស់វេទិកាអនឡាញ" មេរៀនទី៤ "ខ្ញុំមានសក្តានុពល

សម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន" មេរៀនទី៥ "គ្មាននរណាម្នាក់អាចប្រព្រឹត្តអំពើហិង្សា និងការកេងប្រវ័ញ្ចលើខ្ញុំបានទេ" និងមេរៀនទី៦ "ខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីក្លាយជាមនុស្សពេញវ័យ"។ Chatbot សម្រាប់ស្វ័យសិក្សាអាចចូលមើលបាននៅទីនេះ https://web.facebook.com/chc1280chatbot ។

២៧៤. កម្មវិធីអេបសុខភាពយុវជន (Youth Health Mobile App)៖ "សុខភាពយុវជន" គឺជាកម្មវិធីទូរសព្ទដែលងាយស្រួលសម្រាប់យុវវ័យប្រើដោយឥតគិតថ្លៃ ជាភាសាខ្មែរ ដែលផ្តល់ឱ្យកុមារវ័យជំទង់ និងយុវជនកម្ពុជានូវព័ត៌មាន និងសេវាកម្មសំខាន់ៗ ដែលអាចទុកចិត្តបាន និងជាក់ស្តែងលើព័ត៌មាន និងសេវាសុខភាពបន្តពូជផ្លូវភេទ (SRHR) ការអប់រំផ្លូវភេទទូលំទូលាយ (CSE) យេនឌ័រ និងសុខភាពផ្លូវចិត្ត និងជំនួយផ្លូវចិត្ត (MHPSS) និងវីដេអូកម្សាន្តអប់រំ។ សុខភាពយុវជនត្រូវបានបង្កើតឡើងដើម្បីឱ្យកុមារ ក្មេងជំទង់ និងយុវជនអាចធ្វើការជ្រើសរើសបានកាន់តែប្រសើរ និងអនុវត្តសិទ្ធិរបស់ពួកគេ។ វាក៏មានតំណភ្ជាប់ទៅកាន់គ្លីនិក ឬអ្នកផ្តល់សេវា និងបណ្តាញជំនួយឥតគិតថ្លៃដោយផ្ទាល់ពីកម្មវិធីទូរសព្ទ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ កុមារជំទង់ និងយុវជនចំនួន ៣៥៤ ៩៧៧នាក់បានចូលប្រើប្រាស់កម្មវិធីសុខភាពយុវជន ដែលក្នុងនោះមានអ្នកប្រើប្រាស់សកម្មចំនួន ១០០ ០០០ នាក់ ។ Youth Health Mobile App អាចទាញយកបាននៅទីនេះ https://bit.ly/ 3Ek744T (Android) or https://apple.co/3Cagf6G (iOS)។

២៧៥. កម្មវិធីអេប "ដំណើរឆ្លងដែនរបស់ខ្ញុំ" (My Journey Mobile App) កម្មវិធីអេប "ដំណើរឆ្លងដែនរបស់ខ្ញុំ" ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់សិទ្ធិអំណាច ដល់ស្ត្រីចំណាកស្រុកឱ្យទទួលបានព័ត៌មាន ដែលអាចឱ្យពួកគេជ្រើសរើសដោយខ្លួនឯងសម្រាប់ការធ្វើការងារចំណាកស្រុក។ កម្មវិធីអេប "ដំណើរឆ្លងដែនរបស់ខ្ញុំ" មានផ្នែកសំខាន់ៗចំនួន៤ រួមមាន៖ ការធ្វើដំណើររបស់អ្នក សុវត្ថិភាពរបស់អ្នក ការស្វែងរកជំនួយ និងរឿងរ៉ាវរបស់អ្នក ដែលផ្តល់ព័ត៌ មានសំខាន់ៗសម្រាប់អ្នកប្រើប្រាស់ និងស្ត្រីចំណាកស្រុក។ ផ្នែកនីមួយៗមានអនុផ្នែក ដែលមានសារ និងព័ត៌មានជាក់លាក់សម្រាប់ពលករ ចំណាកស្រុកជាស្ត្រី និងសមាជិកគ្រួសាររបស់ពួកគេ ដើម្បីពិចារណា នៅពេលដែលពួកគេចង់ធ្វើចំណាកស្រុក។ មុខងារកម្មវិធី ក៏អនុញ្ញាតឱ្យអ្នកប្រើប្រាស់ចូលប្រើព័ត៌មានសំខាន់ៗទាក់ទងនឹងសុខភាពបន្តពូជ ការធ្វើផែនការគ្រួសារ ស្វ័យភាពលើរាងកាយរបស់ស្ត្រី តាមរយៈតំណភ្ជាប់។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានការទាញយកច្រើនជាង ២,៨០២។ កម្មវិធីអេបដំណើរ ឆ្លងដែនរបស់ខ្ញុំ My Journey Mobile App អាចទាញយកបាននៅទីនេះ http://bit.ly/myjourney mobileapp។

២៧៦. កម្មវិធីអេប "សុវត្ថិភាពយើង" (GVB Safe App)៖ កម្មវិធីអេប "សុវត្ថិភាពយើង" ត្រូវបានផ្តួចផ្តើមដោយក្រសួងកិច្ចការនារី ដែលផ្តល់មូលនិធិដោយ UNFPA និងអនុវត្តដោយ CHC ។ កម្មវិធីអេបសុវត្ថិភាពយើងគឺជាឌីជីថលវេទិកាដែលគាំទ្រ និងការពារជនរងគ្រោះពី អំពើហិង្សាផ្អែកលើយេនឌ័រ។ មុខងារនៅក្នុង កម្មវិធីសុវត្ថិភាពយើង រួមមាន ជំនួយបន្ទាន់ ការយល់ដឹងអំពីអំពើហិង្សាផ្អែកលើយេនឌ័រ អន្តរាគមន៍ ជំនួយផ្នែកច្បាប់ សេវាគាំទ្រ គន្លឹះសម្រាប់ការថែទាំខ្លួនឯង និងទំនាក់ទំនង ផែនទី និងតំណភ្ជាប់ទៅកាន់សេវាកម្ម។ គិតត្រឹមខែធ្នូ ឆ្នាំ ២០២៥ កម្មវិធីអេបសុវត្ថិភាពយើង មានអ្នកប្រើប្រាស់ច្រើនជាង ៨ ២១៩នាក់ រួមទាំងស្ត្រីដែលធ្វើការក្នុងឧស្សាហកម្មកាត់ដេរ និងនិស្សិតដែលកំពុងធ្វើការ និងរស់នៅក្នុងរាជធានីភ្នំពេញ។ កម្មវិធីអេប សុវត្ថិភាពយើង ត្រូវបានផ្តួចផ្តើមដោយក្រសួងកិច្ចការនារី។ គាំទ្រដោយមូលនិធិ Wesley តាមរយៈ UNFPA ក្នុងការសហការជាមួយបណ្តាញទូរសព្ទជំនួយកុមារកម្ពុជា។

២៧៧. បន្ទប់សុខភាព៖ បន្ទប់សុខភាព គឺជាយន្តការមួយដែលបានផ្តួចផ្តើម និងបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ឧបត្ថម្ភដោយ UNFPA តាមរយៈការងារនៅក្នុងភាពជាដៃគូក្នុងប្រទេសកម្ពុជា ដែលមានគោលបំណងផ្តល់លទ្ធភាពទទួលបានបញ្ហាសុខភាពនៅក្នុងសាលារៀន និងលើកកម្ពស់សមភាពយេនឌ័រ។ បន្ទប់សុខភាពសាលារៀនត្រូវបានដំណើរការនៅក្នុងសាលាគោលដៅចំនួន ៨ខេត្តនៃប្រទេសកម្ពុជា។ ឧបករណ៍បណ្តុះបណ្តាលបន្ទប់សុខភាពសាលា និងនីតិវិធីត្រូវបានបង្កើតឡើង ដើម្បីណែនាំដល់គណៈកម្មការបន្ទប់សុខភាពសាលា និងក្រុមមិត្តអប់រំមិត្ត។ ក្រុមមិត្តអប់រំមិត្តចំនួន ២១០នាក់ (ស្រី ១២៨នាក់) នៃបន្ទប់សុខភាពសាលាទទួលបានចំណេះដឹង និងជំនាញលើ សុខភាពផ្លូវភេទ ការបន្តពូជ, ការអប់រំផ្លូវភេទទូលំទូលាយ ជំនួយសង្គ្រោះបឋម មូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់ និងការសម្របសម្រួលដល់សិស្សានុសិស្ស និងយុវជននៅសហគមន៍។ នៅឆ្នាំ ២០២៥ សិស្សចំនួន ១ ៤១៧នាក់ (ស្រី ១ ០៨២នាក់) ទទួលបានសេវាពិគ្រោះទាក់ទងនឹងសុខភាព។ សិស្សចំនួន ៣២៣នាក់ (ស្ត្រី ២៣៥នាក់) ទទួលបានសេវាពិគ្រោះយោបល់ទាក់ទងនឹងសុខភាព សិស្សចំនួន ៧៣នាក់ (ស្ត្រី ២៨នាក់) ទទួលបានសេវាពិគ្រោះយោបល់គាំទ្រផ្លូវចិត្ត សិស្សចំនួន ១០០០នាក់ (ស្ត្រី ៨០៣នាក់) ទទួលបានសេវាសង្គ្រោះបឋម និងសិស្សចំនួន ២១នាក់ (ស្ត្រី ១៦នាក់) ត្រូវបានបញ្ជូនបន្តទៅមណ្ឌលសុខភាព។

២៧៨. ការបន្តការសិក្សា៖ តាមរយៈលទ្ធផលស្រាវជ្រាវស្តីពីអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងរបស់ក្រសួងកិច្ចការនារី ការបោះបង់ការសិក្សាជាមូលហេតុចំបងក្នុងការរៀបអាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់។ ដូច្នោះ CHC បានកំពុងអនុវត្តន៍គម្រោង "**ការផ្តល់សិទ្ធិអំណាចដល់ក្មេងជំទង់ និងក្មេងស្រីជនជាតិដើមភាគតិចដើម្បីបញ្ចប់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់**" លើខេត្តគោលដៅចំនួនពីរគឺ ខេត្តរតនគិរី និងខេត្តស្ទឹងត្រែងគាំទ្រដោយមូលនិធិសប្បុរសធម៌ KADOORIE របស់ទីក្រុង ហុងកុង ដើម្បីជំរុញសិស្សានុសិស្ស បន្តការសិក្សាចំណេះដឹងទូទៅ និងជំនាញ។ ជាលទ្ធផល សិស្សចំនួន ១៦នាក់ (ស្រី ១៥នាក់ ប្រុស ១នាក់) ដែលស្ថិតក្នុងអាយុ ១៥ឆ្នាំ ដល់ ១៧ឆ្នាំ បានកំពុងបន្តការសិក្សាថ្នាក់ទី១០ ហើយ សិស្សម្នាក់ទទួលបានការឧបត្ថម្ភតាមតំរូវការជាក់ស្តែងលើ អាហារ ការស្នាក់នៅ ថ្លៃទឹកភ្លើង ឯកសណ្ឋានសិស្ស សំភារៈសិក្សា និងថ្លៃធ្វើដំណើរមកជួបជុំគ្រួសារនៅពេលសំរាកពីការសិក្សា។ បន្ថែមពីនេះសិស្ស ដែលបានបោះបង់ចោលការសិក្សាចំណះដឹងទូទៅ ពួកគាត់បានបន្តការសិក្សាជំនាញវិជ្ជាជីវៈតាមរយៈគម្រោងរបស់យើង ដោយសិស្សម្នាក់ទទួលបានការឧបត្ថម្ភថវិការប្រចាំខែចំនួន ១០០ដុល្លា ជារៀងរាល់ខែសំរាប់៤ខែ និងទទួលបានការឧបត្ថម្ភ ៧០ដុល្លាក្នុងមួយខែសំរាប់ ២ខែក្នុងការស្វែងរកការងារធ្វើ។ បច្ចុប្បន្ន សិស្សសរុបចំនួន ៣០នាក់ ដែលក្នុងនោះ សិស្ស ២០នាក់ (ស្រី ៣នាក់ និងប្រុស ១៧នាក់) នៅខេត្តរតនគីរី និង សិស្ស ១០នាក់ (ស្រី៥នាក់ និងប្រុស ៥នាក់)នៅខេត្តស្ទឹងត្រែង គាំទ្រដោយមូលនិធីសប្បុរសធម៌ KADOORIE នេះ។

២៧៩. ការអភិវឌ្ឍអង្គការ៖ ការគ្រប់គ្រងកម្មវិធី ដើម្បីធានាបាននូវការអនុវត្តកម្មវិធី និងប្រតិបត្តិការសេវាកម្មប្រកបដោយប្រសិទ្ធភាព តាមរយៈចក្ខុវិស័យ ការធ្វើផែនការ ការរៃអង្គាសប្រាក់ ការត្រួតពិនិត្យ និងការវាយ តម្លៃ។ ក្រុមការងារគ្រប់គ្រង រួមមាន នាយកប្រតិបត្តិ អ្នកគ្រប់គ្រងកម្មវិធី អ្នកសម្របសម្រួលគម្រោង អ្នកគ្រប់គ្រងប្រឹក្សា មន្ត្រីគម្រោង ហិរញ្ញវត្ថុ និងមន្ត្រីរដ្ឋបាល។ នាយកប្រតិបត្តិ មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលគម្រោងទាំងអស់ និងធានាថា CHC ប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់បំផុតនៃតម្លាភាព គណនេយ្យភាព និងសេវាកម្មប្រកបដោយគុណភាពដល់កុមារ យុវជន ស្ត្រី និងគ្រួសាររបស់ពួកគេ។ ការគ្រប់គ្រងហិរញ្ញវត្ថុ

និងរដ្ឋបាល បង្កើត និងអនុវត្តគោលនយោបាយដែលធានាតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់មូលនិធិរបស់ CHC។ ការងារនេះមានសារៈសំខាន់ក្នុងការរក្សាការជឿទុកចិត្តក្នុងចំណោមគណៈគ្រប់គ្រង បុគ្គលិកគម្រោង និងម្ចាស់ជំនួយ។ ដើម្បីធានាបាននូវការសម្របសម្រួល និងដំណើរការដោយរលូននៃសកម្មភាពប្រចាំថ្ងៃរបស់អង្គការ ការគាំទ្រផ្នែកដឹកជញ្ជូន និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អង្គការ។ ការអភិវឌ្ឍធនធានមនុស្ស បុគ្គលិក CHC បានចូលរួមក្នុងសិក្ខាសាលាពង្រឹងសមត្ថភាពដោយផ្អែកលើតម្រូវការរបស់ពួកគេ ហើយថែមទាំងចូលរួមវគ្គរំលឹក ពីក្រមប្រតិបត្តិកិច្ចការពារពីអំពើកេងប្រវ័ញ្ចផ្លូវភេទ និងរំលោភបំពានរបស់អង្គការបណ្តាញទូរសព្ទជំនួយកុមារកម្ពុជា។ នៅឆ្នាំ ២០២៥ នាយកប្រតិបត្តិ អ្នកគ្រប់គ្រងកម្មវិធី ប្រធានផ្នែកពិគ្រោះយោបល់ អ្នកសម្របសម្រួលគម្រោង និងក្រុមអ្នកពិគ្រោះយោបល់ជួរមុខ បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ ឆ្លុះបញ្ចាំងការងារប្រចាំឆ្នាំ និងការថែទាំខ្លួន ដើម្បីធ្វើផែនការកាងារសំរាប់ឆ្នាំ២០២៦ ពង្រឹងសមត្ថភាពតាមរយៈការបណ្តុះបណ្តាលនានា និងរបៀបថែទាំខ្លួនដើម្បីផ្តល់សេវាអោយកាន់តែប្រសើរសំរាប់អតិថជន។ សកម្មភាពនេះ ត្រូវបានគាំទ្រដោយមូលនិធីសប្បុរសធម៌ KADOORIE របស់ទីក្រុង ហុងកុង។

### ដ. អង្គការសម្ពន្ធដើម្បីសិទ្ធិកុមារកម្ពុជា - ស.ស.ក. (CRC Cambodia)

២៨០. ក្នុងឆ្នាំ២០២៥ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (ស.ស.ក) បានសម្រេចនូវវឌ្ឍនភាពជាយុទ្ធសាស្ត្រក្នុងការជំរុញរបៀបវារៈសិទ្ធិកុមារនៅកម្ពុជា តាមរយៈការធ្វើស្ថាប័នូបនីយកម្មលើការចូលរួមរបស់កុមារក្នុងកម្រិតគោលនយោបាយជាតិ។ ក្នុងនាមជាអ្នកសម្របសម្រួលបណ្តាញសង្គមស៊ីវិលដ៏មានឥទ្ធិពល ស.ស.ក បានប្រើប្រាស់ការតស៊ូមតិផ្អែកលើភស្តុតាង ដើម្បីធានាថាការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ (UNCRC) ត្រូវបានឆ្លើយតបយ៉ាងពេញលេញ និងមានគណនេយ្យភាព។ បេសកកម្មឆ្នាំនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តលើការពង្រឹងប្រព័ន្ធកិច្ចការពារកុមារ និងការលើកកម្ពស់សំឡេងរបស់កុមារក្នុងវេទិកាសម្រេចចិត្តគ្រប់កម្រិត។

២៨១. សមិទ្ធផលគន្លឹះដែលត្រូវបានកត់សម្គាល់ រួមមាន ការបង្កើនឥទ្ធិពលលើគោលនយោបាយតាមរយៈការផ្តល់នូវអនុសាសន៍ផ្លូវការចំនួន ១៩ ទៅកាន់ក្រសួងអាទិភាពចំនួន ៦ និងការចូលរួមចំណែកបច្ចេកទេសក្នុងផែនការសកម្មភាពជាតិសំខាន់ៗ។ ស.ស.ក បានជោគជ័យក្នុងការផ្លាស់ប្តូរតួនាទីកុមារពី "អ្នកទទួលផលអកម្ម" មកជា "ភ្នាក់ងារនៃការផ្លាស់ប្តូរ" យ៉ាងសកម្ម តាមរយៈវេទិកាតស៊ូមតិទាំងក្នុងកម្រិតថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ។ សកម្មភាពទាំងអស់នេះត្រូវបានអនុវត្តក្រោមក្របខ័ណ្ឌនៃអភិបាលកិច្ចល្អ និរន្តរភាពហិរញ្ញវត្ថុ និងការពង្រឹងសមត្ថភាពបណ្តាញសមាជិកឱ្យកាន់តែមានភាពរឹងមាំ និងបរិយាបន្ន។

២៨២. **ការពង្រឹងភស្តុតាង និងការតាមដានស្ថានភាពសិទ្ធិកុមារ** ស.ស.ក បានពង្រឹងមូលដ្ឋានភស្តុតាងសម្រាប់ការតស៊ូមតិដោយផ្សារភ្ជាប់នឹង "សិទ្ធិក្នុងការត្រូវបានស្តាប់ឮ" ស្របតាមមាត្រា ១២ នៃអនុសញ្ញា UNCRC តាមរយៈការចូលរួមក្នុងទិវាកុមារអន្តរជាតិ នៅថ្ងៃទី ២៩ ឧសភា ២០២៥ ស.ស.ក បានគាំទ្រកុមារតំណាងឱ្យចូលរួមក្នុងទិវាកុមារអន្តរជាតិលើកទី ៧៦ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារលើកទី ២៤ ដោយបានដាក់តាំងបង្ហាញសមិទ្ធផលដឹកនាំដោយកុមារ ដើម្បីដោះស្រាយបទដ្ឋានយេនឌ័រ និងវិសមភាព។ សន្និបាតប្រចាំឆ្នាំ២០២៥ រៀបចំឡើងនៅខេត្តសៀមរាប (២៤-២៦ មិថុនា) ក្រោមប្រធានបទ "ការពង្រឹងការតស៊ូមតិ និងគណនេយ្យភាពលើវិស័យសិទ្ធិកុមារ"។ ព្រឹត្តិការណ៍នេះប្រមូលផ្តុំតំណាងអង្គការសមាជិកជាង ៤០ និង

អ្នកចូលរួម ៧០នាក់ ដើម្បីរៀបចំផែនការរួមលើបញ្ហា SOGIESC ការត្រួតពិនិត្យរបាយការណ៍ UPR និង UNCRC និងការជំរុញយុទ្ធនាការដែលដឹកនាំដោយយុវជន។

២៨៣. **ការជំរុញគោលនយោបាយជាតិ និងការវិនិយោគសាធារណៈ** តាមរយៈការសម្របសម្រួលធាតុចូលពីម្ចាស់សិទ្ធិផ្ទាល់ដល់អ្នកធ្វើគោលនយោបាយ ដោយការស្នើជាអនុសាសន៍តាមក្រសួង ផ្អែកលើសិក្ខាសាលាពិគ្រោះយោបល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៥ អនុសាសន៍ចំនួន ១៩ ត្រូវបានដាក់ជូនក្រសួងចំនួន ៦ រួមមានៈ ក្រសួងអប់រំ (៤អនុសាសន៍) ក្រសួងមហាផ្ទៃ (៥អនុសាសន៍) ក្រសួងសង្គមកិច្ច (៥អនុសាសន៍) ក្រសួងយុត្តិធម៌ (២អនុសាសន៍) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (២អនុសាសន៍) និងក្រសួងសុខាភិបាល (១អនុសាសន៍)។ ដែលមានបញ្ហាអាទិភាពចំនួន ៦ រួមមាន (១)ការធ្វេសប្រហែស (២)អំពើហិង្សា (៣)ការរំលោភបំពានផ្លូវភេទ (៤)ការប្រែប្រួលអាកាសធាតុ (៥)អាពាហ៍ពិពាហ៍កុមារភាព និង(៦)ខ្លឹមសារឌីជីថលបង្កគ្រោះថ្នាក់។ ឥទ្ធិពលគោលនយោបាយ ស.ស.ក បានដើរតួនាទីបច្ចេកទេសក្នុង "ផែនការសកម្មភាពជាតិស្តីពីការបង្ការ និងទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់" ជាមួយក្រសួងកិច្ចការនារី (១៦ ឧសភា ២០២៥)។

២៨៤. **ការលើកកម្ពស់ឥទ្ធិពលបណ្តាញកុមារ និងយុវជន** កុមារត្រូវបានលើកកម្ពស់ជា "ម្ចាស់សិទ្ធិ" តាមរយៈវេទិកាជាតិ និងអន្តរជាតិ។ វេទិកាតំបន់ តំណាងកុមារបានចូលរួមវេទិកាស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន (CRVS) នៅមជ្ឈមណ្ឌលសន្និសីទអង្គការសហប្រជាជាតិ ក្រុងបាងកក (៤-៦ មីនា ២០២៥) ដើម្បីត្រៀមសម្រាប់សន្និសីទថ្នាក់រដ្ឋមន្ត្រីនៅខែមិថុនា។ កិច្ចសន្ទនាជីវៈចម្រុះ នៅខេត្តរតនគិរី (១៥ សីហា ២០២៥) ស.ស.ក សហការជាមួយ Save Vulnerable Cambodians, WWF និង CRC Asia ដើម្បីជំរុញការឆ្លើយតបគោលនយោបាយតាមមូលដ្ឋាន ដែលមានបរិយាបន្ន និងផ្អែកលើសិទ្ធិកុមារ។

២៨៥. **ការអភិវឌ្ឍន៍ស្ថាប័ន និងនិរន្តរភាព** ស.ស.ក បានកសាងសមត្ថភាពផ្ទៃក្នុង និងអភិបាលកិច្ចជាឆ្អឹងខ្នងនៃនិរន្តរភាព តាមរយៈការបណ្តុះបណ្តាលបច្ចេកទេស រួមមានវិធីសាស្ត្រផ្អែកលើសិទ្ធិ (RBA) នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ និងការយល់ដឹងពី SOGIESC នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ ដើម្បីដោះស្រាយការរើសអើងក្នុងគ្រួសារ និងសាលារៀន ដែលបណ្តាលមកពីកង្វះកិច្ចការពារផ្លូវច្បាប់ច្បាស់លាស់។ ចំពោះបរិយាបន្ន និងអភិបាលកិច្ច ស.ស.ក. វគ្គបណ្តុះបណ្តាលស្តីពីការបញ្ចូលជនមានពិការភាពក្នុងផែនការវិនិយោគឃុំ (DI in CIP) នាថ្ងៃទី ១២ កញ្ញា បានពង្រឹងសមត្ថភាពដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន ២៨។ ទន្ទឹមនឹងនេះ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ២ (១៤ សីហា) បានផ្តោតលើនិរន្តរភាពហិរញ្ញវត្ថុ និងការកសាងសម្ព័ន្ធភាពយុទ្ធសាស្ត្រ។

២៨៦. ជារួមឆ្នាំ២០២៥ គឺជាឆ្នាំដែលអង្គការ ស.ស.ក បានពង្រឹងជំហររបស់ខ្លួនជាស្ថាប័នឈានមុខក្នុងការតស៊ូមតិដើម្បីសិទ្ធិកុមារនៅកម្ពុជា។ តាមរយៈការរួមបញ្ចូលគ្នារវាងការកសាងភស្តុតាង ការជំរុញគោលនយោបាយ និងការផ្តល់អំណាចដល់កុមារឱ្យក្លាយជាម្ចាស់សិទ្ធិពិតប្រាកដ អង្គការបានបង្កើតនូវផលជះជាវិជ្ជមានដល់ប្រព័ន្ធកិច្ចការពារកុមារជាតិ។ ទិសដៅទៅមុខអង្គការ ស.ស.ក នឹងបន្តធ្វើឱ្យកាន់តែស៊ីជម្រៅនូវការអនុវត្តអនុសាសន៍តាមក្រសួងស្ថាប័ន និងពង្រីកវិសាលភាពនៃការតស៊ូមតិលើបញ្ហានៅសេសសល់ ដូចជាសុវត្ថិភាពឌីជីថល និងសិទ្ធិកុមារក្នុងបរិបទប្រែប្រួលអាកាសធាតុ។ ការរក្សានូវអភិបាលកិច្ចរឹងមាំ និងការពង្រឹងបណ្តាញ

សមាជិកទាំង ៦១ ឱ្យមានភាពរស់រវើក នឹងនៅតែជាអាទិភាពចម្បង ដើម្បីធានាថាកុមារកម្ពុជាគ្រប់រូបអាចរស់នៅដោយសេចក្តីថ្លៃថ្នូរ និងឈានដល់សក្តានុពលពេញលេញរបស់ពួកគេ។

**៥. អង្គការម្លប់ឫស្សី**

២៨៧. ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះអង្គការម្លប់ឫស្សី បានធ្វើឱ្យមានការវិវត្តន៍គួរឱ្យកត់សម្គាល់នៅក្នុងទំនាក់ទំនង និងសហការជាមួយរដ្ឋាភិបាល ការចូលរួមរបស់សហគមន៍ និងកម្មវិធីថែទាំជំនួសចំពោះកុមារ។ តាមរយៈទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ការកសាងសមត្ថភាព និងការគាំទ្រដោយផ្ទាល់យើងបានពង្រឹងប្រព័ន្ធកែលម្អការថែទាំកុមារ ដែលងាយរងគ្រោះ និងលើកកម្ពស់ការថែទាំតាមគ្រួសារដើម្បី ទប់ស្កាត់ ការបំបែក កុមារចេញពីគ្រួសារដោយមិនចាំបាច់។ ដើម្បីបង្ហាញការងាររបស់យើងឲ្យបានច្បាស់ខណៈពេលដែលមានបញ្ហា ប្រឈម យើងចាប់យកភាពប្រទាក់ក្រឡា ជាវិធីសាស្ត្ររួម ចំពោះការការពារកុមារក្នុងការថែទាំជំនួស យើងបាន ចាត់ថ្នាក់ភាពជាដៃគូរបស់យើងជាបីក្រុម៖ អ្នកមានសិទ្ធិទទួលកាតព្វកិច្ចស្របច្បាប់ អ្នកទទួលកាតព្វកិច្ច សីលធម៌ និងអ្នកម្ចាស់សិទ្ធិជាអ្នកទទួលផល ។ របាយការណ៍នេះនឹងផ្តោតលើប្រភេទទាំងនេះ ដោយសង្កត់ធ្ងន់ ទាំងលទ្ធផល និងសមិទ្ធិផល។

២៨៨. ការចូលរួមក្នុងគោលនយោបាយ និងបទប្បញ្ញត្តិ (ថ្នាក់ជាតិ) អង្គការម្លប់ឫស្សីបានចូលរួមជាមួយក្រុមបច្ចេកទេសថ្នាក់ជាតិនៅក្រសួងសង្គមកិច្ច ដោយបានចូលរួមបង្កើតផែនការសកម្មភាពជាតិលើកទី២ (២០២៥-២០៣០) ស្តីពីការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ។ ផែនការនេះនឹងធានាថាក្រុមពាក់ព័ន្ធសម្របសម្រួលវិធានការការពារកុមារឲ្យបានសមស្រប និងទាន់ពេលវេលា ដើម្បីអនុវត្តសិទ្ធិមូលដ្ឋានរបស់កុមារ។ លើសពីនេះ ទិវាសិទ្ធិកុមារ នឹងចងក្រងប្រតិបត្តិការណ៍ជាប្រចាំ នៅថ្ងៃទី០១ ខែមិថុនា ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសិទ្ធិកុមារ។

២៨៩. គាំទ្រការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិសម្រាប់ មណ្ឌលថែទាំជំនួសជាដៃគូ កិច្ចចូលរួមរបស់ភាគីពាក់ព័ន្ធត្រូវបានអនុវត្ត ដើម្បីឲ្យមណ្ឌលថែទាំ អាចឆ្លើយតបតាមស្តង់ដានៃការថែទាំកុមារ។ លើកកម្ពស់គុណភាពសេវាកម្មថែទាំកុមារ។ គ្រប់គ្រងករណីទាំងអស់ប្រកបដោយវិជ្ជាជីវៈ។ បង្កើតនីតិវិធីស្តង់ដារសម្រាប់ការធ្វើសមាហរណកម្មកុមារ និងផែនការសមាហរណកម្មសម្រាប់គ្រួសារ។ បង្កើតក្រុមការងារបច្ចេកទេសកម្រិតខេត្ត ដើម្បីគ្រប់គ្រងការបិទមណ្ឌលថែទាំ និងការបំប្លែងពីការថែទាំក្នុងមណ្ឌលទៅជាការថែទាំក្នុងសហគមន៍។ អនុវត្តនីតិវិធីស្តង់ដាសម្រាប់ការធ្វើសមាហរណកម្ម និងបិទមណ្ឌល ដើម្បីធានាសុវត្ថិភាព និងសិទ្ធិរបស់កុមារ។

២៩០. ការចូលរួមក្នុងការរៀបចំកិច្ចអន្តរាគមន៍ការការពារកុមារ (OVC Service Intervention)។ ចូលរួមក្នុងសន្និសិទករណី ដើម្បីអន្តរាគមន៍លើបញ្ហាកុមារ (ការរំលោភបំពាន អ្នកជួញដូរកុមារ ជំងឺជាសាធារណៈ និងបញ្ហាសុខភាព)។ ផ្តល់សេវាកម្មសំខាន់ៗដល់កុមារ និងគ្រួសារ (បញ្ហារចនាសម្ពន្ធ គ្រឿងសម្ភារៈសិក្សា សុវត្ថិភាព អាហារ និងលំនៅឋាន)។ ពង្រឹងសិទ្ធិកុមារ ដោយផ្តល់ឯកសារពាក់ព័ន្ធ (វិញ្ញាបនប័ត្រចំណាកស្រុក សៀវភៅគ្រួសារ និងការគាំទ្រផ្លូវច្បាប់)។ អនុវត្តការការពារកុមារដោយផ្អែកលើអនុសញ្ញាសិទ្ធិកុមារ (CRC) ក្រមរដ្ឋប្បវេណីជាតិស្តីពីការការពារកុមារ និងការណែនាំរបស់ក្រសួងសង្គមកិច្ច និងក្រសួងមហាផ្ទៃ។ គាំទ្រការធ្វើសមាហរណកម្ម (Reintegration Service)។ រៀបចំផែនការសមាហរណកម្មកុមារ។ សហការជាមួយ

អាជ្ញាធរមូលដ្ឋានក្នុងការស្វែងរកគ្រួសារ និងវាយតម្លៃលទ្ធភាពសមាហរណកម្ម។ រៀបចំកិច្ចប្រជុំករណី ដើម្បីធានាការដាក់កុមារទៅក្នុងគ្រួសារ។ អភិវឌ្ឍសេវាសង្គមក្នុងសហគមន៍ ដើម្បីបំពេញតម្រូវការរបស់កុមារ។

### ឋ. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (ច.ក.យ.ក.ស.ក./CCYMCR)

២៩១. ក្នុងឆ្នាំ២០២៥ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (ច.ក.យ.ក.ស.ក) សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់សិទ្ធិកុមារ និងការពង្រឹងអភិបាលកិច្ចតាមរយៈគម្រោង SIDA CSOs Strengthening និងគម្រោង SOGIESC ដំណាក់កាលទី២។ ក្រោមការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការសង្គ្រោះកុមារ (Save the Children) និងទីភ្នាក់ងារ SIDA សមាគមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាពបច្ចេកទេសដល់កុមារ និងយុវជន ព្រមទាំងការបង្កើតឥទ្ធិពលលើការផ្លាស់ប្តូរគោលនយោបាយជាតិ។

២៩២. ច.ក.យ.ក.ស.ក. សម្រេចបាននូវភាពជោគជ័យចំនួន ៥ធំៗ ដែលក្នុងនោះរួមមាន ការបង្កើនប្រសិទ្ធភាពយន្តការគណនេយ្យភាព ដោយបណ្តុះបណ្តាលសមាជិកបណ្តាញ និងអាជ្ញាធរចំនួន ៧៥នាក់ លើប្រធានបទសិទ្ធិកុមារ និងការតស៊ូមតិ ដោយលទ្ធផលតេស្តក្រោយវគ្គបានកើនឡើងរហូតដល់ ៨២.៨៤%។ ការចល័តកម្លាំងសហគមន៍ដើម្បីការផ្លាស់ប្តូរឥរិយាបថ ដោយសម្រេចបាននូវការធ្វើយុទ្ធនាការផ្ទាល់ចំនួន ១២លើក និងឌីជីថល ២លើក ដែលមានការចូលរួមពីសហគមន៍ និងអ្នកពាក់ព័ន្ធសរុប ១ ២៨១នាក់ (ស្រី ៧៨៧នាក់) ដើម្បីដោះស្រាយបញ្ហាបោះបង់ការសិក្សា និងអំពើហិង្សា។ ការពង្រឹងតំណាងកុមារក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដោយជោគជ័យក្នុងការបញ្ចូលសមាជិកក្លឹបកុមារទៅក្នុងសមាសភាពផ្លូវការនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) ក្នុងឃុំគោលដៅចំនួន ៧។ ឥទ្ធិពលលើគោលនយោបាយជាតិ ការផ្តល់ "ធាតុចូល" យ៉ាងសំខាន់សម្រាប់ការរៀបចំសេចក្តីថ្លែងការណ៍កុមារ និងការដាក់ឱ្យប្រើប្រាស់ "ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០"។ និរន្តរភាពស្ថាប័ន និងអភិបាលកិច្ច បានវាយតម្លៃសមត្ថភាពស្ថាប័នតាមរយៈកិច្ចប្រជុំឆ្លុះបញ្ចាំងលទ្ធផលនៅខេត្តសៀមរាប ដែលឈានទៅដល់ការកែលម្អផែនការអភិវឌ្ឍន៍បុគ្គលិកលើវិជ្ជាជីវៈតស៊ូមតិ។

២៩៣. វឌ្ឍនភាពក្នុងឆ្នាំ២០២៥ បានបញ្ជាក់យ៉ាងច្បាស់ពីសមត្ថភាពរបស់ ច.ក.យ.ក.ស.ក ក្នុងការបំប្លែងការគាំទ្រពីដៃគូយុទ្ធសាស្ត្រ (SCI និង SIDA) ឱ្យទៅជាលទ្ធផលជាក់ស្តែងសម្រាប់កុមារ។ ការផ្សារភ្ជាប់គ្នារវាងការបណ្តុះបណ្តាលបច្ចេកទេស និងការចូលរួមក្នុងយន្តការសម្រេចចិត្តទាំងថ្នាក់ជាតិ និងក្រោមជាតិ បានបង្កើតនូវគ្រឹះដ៏រឹងមាំសម្រាប់អភិបាលកិច្ចសិទ្ធិកុមារ។ ទិសដៅបន្តគឺការធានាថា "ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០" ត្រូវបានអនុវត្តប្រកបដោយបរិយាបន្ន និងការបន្តពង្រឹងសំឡេងកុមារក្នុងគ្រប់វេទិកាសម្រេចចិត្ត ដើម្បីកសាងសង្គមកម្ពុជាមួយដែលសិទ្ធិកុមារត្រូវបានការពារ និងផ្តល់តម្លៃជាអាទិភាព។

### ឌ. អង្គការទស្សនៈពិភពលោក

២៩៤. អង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា បានអនុវត្តកម្មវិធីនៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧០ ហើយមានទិសដៅជួយដល់កុមារងាយរងគ្រោះអោយរួចផុតពីភាពក្រីក្រ ហើយមានជីវិតពេញបរិបូរ។ អង្គការកំពុងអនុវត្តកម្មវិធីផ្ទាល់នៅក្នុងរាជធានី ខេត្តចំនួន១១ និងអនុវត្តកម្មវិធីជាមួយអង្គការដៃគូតាមរយៈការ

ផ្តល់ថវិការ និងបច្ចេកទេសចំនួន ១០ខេត្តបន្ថែមទៀត ។ បច្ចុប្បន្នអង្គការកំពុងអនុវត្តកម្មវិធីស្នូលចំនួន៣គឺ៖ ១.កម្មវិធីកិច្ចការពារកុមារ និងការចូលរួម ២.កម្មវិធីអប់រំ ៣.កម្មវិធីអាហាររូបត្ថម្ភ អនាម័យទឹកស្អាត និងរបរចិញ្ចឹមជីវិត ។

២៩៥. កម្មវិធីកិច្ចការពារកុមារជាកម្មវិធីស្នូលក្នុងចំណោមកម្មវិធីទាំង៣ ហើយកម្មវិធីនេះមានគោលដៅសំខាន់ក្នុងការធ្វើអោយប្រសើរឡើងនូវស្ថានភាពរបស់កុមារ និងមនុស្សវ័យជំទង់អោយទទួលបាននូវការការពារឱ្យរួចផុតពីការរំលោភបំពានផ្សេងៗ និងមានការសម្រេចចិត្តពេញលេញ ។ ដើម្បីចូលរួមសម្រេចគោលដៅនេះ អង្គការបានផ្តោតលើការអនុវត្តកម្មវិធីការចិញ្ចឹមបីបាច់កូនតាមបែបវិជ្ជាមានឬកម្មវិធីគ្រួសាររីករាយ ការពង្រឹងជំនាញបំណិនជីវិតរបស់កុមារ និងមនុស្សវ័យជំទង់ និងធ្វើការជាមួយស្រុក ឃុំ ភូមិដើម្បីពង្រឹងប្រពន្ធ័កិច្ចការពារកុមារ។ លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៥៖

២៩៦. ការចូលរួមនិង ការសម្រេចចិត្តរបស់កុមារ និងកុមារវ័យជំទង់៖ បានបង្កើតក្លឹបកុមារ និងក្មេងវ័យជំទង់ដែលមានចំនួន ២ ១៥៧ក្លឹប មានសមាជិកចំនួន ៥៦ ១០៣នាក់។ ក្លឹបកុមារ និងក្មេងវ័យជំទង់ជាកន្លែងកុមារមេត្រីដែលមានភាពងាយស្រួលសម្រាប់កុមារ មកជួបជុំគ្នាជាប្រចាំ ដើម្បីទទួលបានការបណ្តុះបណ្តាលកញ្ចប់មេរៀនស្តីពីរក្សាសុវត្ថភាព កុមារ កញ្ចប់មេរៀនវិថីសន្តិភាព និងមេរៀនបន្ថែមផ្សេងៗទៀត ។ ជាលទ្ធផលមានកុមារ និងកុមារវ័យជំទង់ចំនួន ៥៦ ១០៣នាក់ បានទទួលបាននូវជំនាញបំណិនជីវិតដើម្បីការពារទប់ស្កាត់ ការកំណត់អត្តសញ្ញាណ ការរាយការណ៍ករណីអំពីអំពើហិង្សា និងមានការយល់ដឹងពីសិទ្ធិ និងចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ។

២៩៧. ទន្ទឹមនោះក៏មាន ១ ២៥០ គម្រោងសហគមន៍ដែលដឹកនាំដោយយុវជន។ គម្រោងនេះជួយកុមារ និងយុវជនមានឱកាសធ្វើការងារសហគមន៍ បង្កើនសមត្ថភាព នៃការគៀគរធនធាន ការទំនាក់ទំនងជាមួយអាជ្ញាធរប្រជាពលរដ្ឋ និងដកយកបទពិសោធន៍ពីការងារ សង្គម បង្កើនសមត្ថភាពក្នុងការចូលរួមជាមួយប្រជាជនក្នុងសហគមន៍ អាជ្ញាធរមូលដ្ឋាន ធនធាន ការសិក្សា និងការទទួលបានបទពិសោធន៍។

២៩៨. ចងក្រងក្រុមប្រឹក្សាកុមារមានសមាជិកជាតំណាងចំនួន ១៨នាក់។ ក្រុមនេះជាក្រុមតំណាងអោយក្រុមកុមារ និងក្មេងវ័យជំទង់ក្នុងការចូលរួមប្រជុំជួបជាមួយក្រុមអ្នកដឹកនាំរបស់អង្គការទស្សនៈពិភពលោក ធ្វើការជាមួយក្លឹបកុមារ និងយុវជនដើម្បីទទួលបានពត៌មានផ្សេងៗពីកង្វល់ និងបញ្ហា ដែលពួកគេកំពង់ជួបប្រទះ ទំនាក់ទំនង និងផ្តល់ពត៌មានត្រឡប់ដល់អ្នកគ្រប់គ្រងតំបន់ ក្រុមអ្នកដឹកនាំរបស់អង្គការ ទស្សនៈពិភពលោក និងចូលរួមប្រជុំជាទៀងទាត់នៅថ្នាក់តំបន់ និងថ្នាក់ជាតិ។

២៩៩. បានសហការ និងគាំទ្រអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងការរៀបចំកិច្ចសន្ទនាកុមារថ្នាក់ជាតិជាមួយអ្នកធ្វើគោលនយោបាយមកពីក្រសួងសំខាន់ៗ រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ...។ អ្នកចូលរួមសរុបចំនួន ២១០នាក់ (កុមារ និងមនុស្សពេញវ័យ) បានចូលរួមក្នុងព្រឹត្តិការណ៍នេះ រួមទាំងថ្នាក់ដឹកនាំក្លឹបកុមារ និងយុវជន (CYC) ចំនួន ២៧រូប និងថ្នាក់ដឹកនាំក្លឹបយុវជន (ស្ត្រី ១៥នាក់) ដែលតំណាងឱ្យអង្គការ WVI-C។ ព្រឹត្តិការណ៍នេះត្រូវបានដឹកនាំដោយកុមារ និងកុមារវ័យជំទង់ ដោយមានតំណាងយុវជនពីរនាក់ធ្វើជាពិធីករ (MCs)។ កិច្ចសន្ទនានេះបានបម្រើជាវេទិកាថ្នាក់ជាតិដ៏សំខាន់មួយសម្រាប់ការចូលរួមរវាងកុមារ និងតំណាងរដ្ឋាភិបាល។

៣០០. បន្តសម្របសម្រួលអោយមានការចូលរួមរបស់កុមារ និងយុវវ័យក្នុងព្រឹត្តិការណ៍ផ្សេងៗនៅថ្នាក់ក្រោមជាតិ។ ព្រឹត្តិការណ៍ទាំងនេះរួមមានដំណើរការអភិវឌ្ឍន៍ផែនការវិនិយោគឃុំ និងកិច្ចប្រជុំប្រចាំត្រីមាសឃុំ។ កុមារ និងយុវជនបានចូលរួមក្នុងសកម្មភាពផ្សេងៗគ្នាចំនួន ១៣២ លើក។

៣០១. ការធ្វើអោយប្រសើរឡើងលើការផ្លាស់ប្តូរឥរិយាបទរបស់ឪពុកម្តាយ និងអ្នកថែទាំ តាមរយៈការពង្រឹងធនធានមនុស្សនៅក្នុងសហគមន៍កម្មវិធីបានពង្រឹងសមត្ថភាពអ្នកស្ម័គ្រចិត្តសហគមន៍ចំនួន ៣៥៩នាក់ ឱ្យមានជំនាញនិងសមត្ថភាពក្នុងការសម្របសម្រួលកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន នៅក្នុងសហគមន៍របស់ពួកគេ ។ ការលើកកម្ពស់ការចិញ្ចឹមកូនបែបវិជ្ជមាន ជាកម្មវិធីធ្វើការជាមួយក្រុមឪពុកម្តាយ និងអ្នកថែទាំឱ្យប្រើប្រាស់ការអប់រំកូនបែបវិជ្ជមាន និងអហិង្សា ដើម្បីអោយគ្រួសារមានបរិយាកាសសុវត្ថិភាព និងបង្ហាញពីការយកចិត្តទុកដាក់ចំពោះកុមារឬកូន។ ជាលទ្ធផលមានឪពុកម្តាយចំនួន ៣៧ ៥៤០នាក់ ដែលជាសមាជិកក្រុមបានទទួលការបណ្តុះបណ្តាល និងការជួបជុំមកជួបជុំគ្នាជាប្រចាំ ដើម្បីរៀនសូត្រអំពីការចិញ្ចឹមកូនបែបវិជ្ជមាន ការចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍។

៣០២. ការពង្រឹងប្រពន្ធ័កិច្ចការពារកុមារ កម្មវិធីបានធ្វើការសហការជាមួយរាជរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់ និងកាត់បន្ថយអំពើហិង្សាលើកុមារ។ សម្រាប់ថ្នាក់ជាតិកម្មវិធីបានសហការជាមួយក្រសួងសង្គមកិច្ច និងក្រសួងមហាផ្ទៃ ក្នុងការអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ការរៀបចំផែនការជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ។

៣០៣. នៅថ្នាក់ក្រោមជាតិ កម្មវិធីធ្វើការយ៉ាងជិតស្និទ្ធិជាមួយអាជ្ញាធរឃុំ ស្រុក ក្នុងការពង្រឹងនៅយន្តការការពារឆ្លើយតប និងរាយការណ៍ករណីកិច្ចការពារកុមារ ។ សម្របសម្រួលបង្កើតក្រុមការពារកិច្ចការពារកុមារនិងពង្រឹងនូវយន្តការដែលមានស្រាប់នៅថ្នាក់ឃុំបានចំនួន ១០៥ឃុំ សរុបសមជិគមានចំនួន ៣ ១៥០នាក់ ។ ក្រុមកិច្ចការពារកុមារនៅថ្នាក់ឃុំនេះដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលដឹកនាំកំណត់ឬសគល់អាទិភាពនៃបញ្ហា និងរៀបចំផែនការ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការវិនិយោគរបស់ឃុំ សង្កាត់។ លើសពីនេះ ក្រុមការពារកិច្ចការពារកុមារដើរតួនាទីយ៉ាងសកម្មក្នុងការសម្របសម្រួល ប្រព័ន្ធរាយការណ៍ និងបញ្ជូនករណី/កង្វល់ការពារកុមារ ដើម្បីធានាថាសហគមន៍មានការយល់ដឹង និងដឹងពីរបៀបរាយការណ៍។

៣០៤. សហការគាំទ្រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតសម្បទា និងក្រសួងមហាផ្ទៃក្នុងការអនុវត្ត នីតិវិធីប្រតិបត្តិកិច្ចការពារកុមា សម្រាប់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ។ មានគ្រូបង្គោលថ្នាក់ខេត្តបានចំនួន ២២ រាជធានីខេត្ត សរុបមានមន្ត្រីរដ្ឋាភិបាល ដែលទទួលការបណ្តាលមានចំនួន ១៥៩នាក់ ដែលជាអភិបាលរងខេត្ត ប្រធានគ.ក.ស.ក និងតំណាងមកពីមន្ទីរសង្គមកិច្ច ។

### ណ. អង្គភាពការពារកុមារ (CPU)

៣០៥. ក្នុងឆ្នាំ២០២៥ កន្លងទៅនេះ អង្គភាពការពារកុមារ (CPU) បានបន្តនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងកិច្ចការការពារសុវត្ថិភាពកុមារដែលរងគ្រោះដោយអំពើហិង្សា ការមិនអើពើយកចិត្តទុកដាក់ ការរំលោភបំពាន និងអំពើកេងប្រវ័ញ្ច។ តាមរយៈការគ្រប់គ្រងសំណុំរឿង ការចូលរួមពីបណ្តាសហគមន៍នានា និងភាពជាដៃគូការងារដ៏រឹងមាំជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គភាពការពារកុមារ (CPU) បានឆ្លើយតបទៅនឹងហានិភ័យ

ទាំងឡាយដែលកំពុងកើតមានឡើងលើកុមារ ខណៈកំពុងពង្រឹងការងារបង្ការទប់ស្កាត់និងប្រព័ន្ធរាយការណ៍ចាំបាច់។

៣០៦. ឆ្នាំនេះ ជាឆ្នាំបង្ហាញពីសក្ខីភាពចំពោះការប្តេជ្ញាចិត្តដ៏តឹងដាក់របស់អង្គភាពយើងក្នុងកិច្ចការពារសុវត្ថិភាពសម្រាប់កុមារកម្ពុជា ដែលងាយរងគ្រោះបំផុត ហើយយើងតែងតែប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវមាគ៌ា បេសកកម្មរបស់អង្គភាពយើងជានិច្ច គឺការផ្តល់ការការពារ ការផ្តល់ការគាំទ្រ និងការតស៊ូមតិសម្រាប់កុមារីគ្រប់រូបដើម្បីសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូររបស់ពួកគេ។ អង្គភាពការពារកុមារ (CPU) បានពង្រីកសកម្មភាពការងារនិងពង្រឹងនូវកម្មវិធីរបស់ខ្លួន បន្ថែមដើម្បីធ្វើឲ្យសហគមន៍កាន់តែច្រើនថែមទៀតទទួលបាននូវសេវាកម្មចាំបាច់ផ្សេងៗពីអង្គភាពយើង។ គិតចាប់ពីការផ្តល់ជំនួយសង្គ្រោះបន្ទាន់ និងជំនួយផ្លូវច្បាប់រហូតដល់ការគាំទ្រផ្នែកស៊ើបអង្កេតកោសល្យវិច័យ វេជ្ជសាស្ត្រ និងចិត្តសាស្ត្រ ក្រុមការងាររបស់អង្គភាពយើងបានខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់ ដើម្បីផ្តល់នូវសេវាថែទាំគ្រប់ជ្រុងជ្រោយ ដល់ជនរងគ្រោះទាំងឡាយ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានបង្កើនប្រសិទ្ធភាព តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន និងបណ្តាដៃគូការងារអន្តរជាតិនានា ដើម្បីពង្រឹងនូវគោលដៅរួមរបស់យើងគឺធានាធ្វើយ៉ាងណា មិនឲ្យកុមាររងគ្រោះណាម្នាក់ត្រូវបានគេទុកចោល ឬមើលរំលងឡើយ។

៣០៧. ទោះបីមានបញ្ហាប្រឈមដោយសារសំពាធផ្នែកសេដ្ឋកិច្ចសង្គម និងហានិភ័យផ្សេងៗ ដែលកំពុងមានការប្រែប្រួលយ៉ាងណាក៏ដោយ ក៏ការតាំងចិត្តដ៏មោះមុតរបស់អង្គភាពយើងមិនប្រែប្រួលឡើយ។ រាល់ភាពជោគជ័យដែលយើងសម្រេចបាន គឺជាការឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់ក្រុមការងារអ្នកស្ម័គ្រចិត្តម្ចាស់ជំនួយ និងដៃគូរសហការទាំងឡាយរបស់អង្គភាពយើង ការផ្តល់ទំនុកចិត្ត និងការជួយគាំទ្ររបស់អ្នកពាក់ព័ន្ធទាំងឡាយបានជួយជម្រុញឲ្យយើងអាចបង្កើតការផ្លាស់ប្តូរដ៏ស៊ីជម្រៅមួយ សម្រាប់ជីវិតរស់នៅកាន់តែប្រសើរឡើងសម្រាប់កុមារ និងក្រុមគ្រួសារកុមាររងគ្រោះជាច្រើននាក់នៅទូទាំងប្រទេសកម្ពុជា។

៣០៨. លទ្ធផលការងារអង្គភាពការពារកុមាឆ្នាំ២០២៥ រួមមាន៖

- បានដំណើរការស៊ើបអង្កេតចំនួន ៣៣៥ករណី លើបទល្មើសកម្រិតធ្ងន់ដែលមានប្រព្រឹត្តលើកុមារពាក់ព័ន្ធករណីឃាតកម្ម រំលោភសេពសន្ថវៈ ការវាយប្រហារធ្ងន់ធ្ងរ និងបទល្មើសកម្រិតធ្ងន់ផ្សេងៗទៀតលើកុមារ។
- ការចាប់ខ្លួនជនល្មើសពាក់ព័ន្ធបទល្មើសប្រព្រឹត្តលើកុមារចំនួន ២៩១នាក់
- ស៊ើបអង្កេតករណីឃាតកម្ម ចំនួន ២៨ករណី
- ចាប់ជនល្មើសបានប្រមាណ ៨៧%
- ការស៊ើបអង្កេតបទល្មើសប្រព្រឹត្តលើកុមារតាមបណ្តាញអ៊ីនធឺណិតចំនួន ៣១ករណី
- ការផ្តល់សេវាស៊ើបអង្កេតបន្ថែមផ្នែកកោសល្យវិច័យដល់នគរបាលជាតិកម្ពុជាចំនួន ៨លើក
- ការផ្តន្ទាទោសដាក់ពន្ធធានាគារគិតជាឆ្នាំលើជនល្មើស ៤៩០
- ជនរងគ្រោះទទួលបានសេវាផ្លូវច្បាប់ដោយឥតគិតថ្លៃដោយអង្គភាពការពារកុមារចំនួន ២១៣នាក់
- ការចុះទស្សនកិច្ចពង្រឹងការងារតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី ខេត្តទូទាំង ២៥
- ករណីជម្រះចប់ជាស្ថាពរចំនួន ៦៩ករណី
- ក្រុមការងារចម្រុះស៊ើបអង្កេតបទល្មើសកម្រិតធ្ងន់ចំនួន ១០។

# ៨. បញ្ហាប្រឈម



## ៨. បញ្ហាប្រឈម

៣០៩. ការប្រឈមមុខផ្នែកសន្តិសុខជាតិ និងបូរណភាពទឹកដី ដែលរំលោភឈ្លានពានដោយប្រដាប់អាវុធពីសំណាក់កងទ័ពថៃមកលើបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់ប្រាសាទព្រះវិហារ និងតំបន់ជុំវិញ។ បទល្មើសឆ្លងដែន និងបច្ចេកវិទ្យា ការកើនឡើងនូវបទល្មើសគ្រឿងញៀន ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) មានការកើនឡើង។ សកម្មភាពក្មេងទំនើងនៅតែជាបញ្ហាដែលប៉ះពាល់ដល់សុវត្ថិភាពសហគមន៍។

៣១០. នៅថ្នាក់ក្រោមជាតិ ធនធានមនុស្សនៅតែជាបញ្ហា ដោយសារការខ្វះខាតមន្ត្រី ទាំងចំនួន និងសមត្ថភាពជំនាញ នៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដើម្បីគាំទ្រមុខងារដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិនៅមានកម្រិត និងទាមទារឱ្យមានការពង្រឹងបន្ថែម។ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យានៅមានកម្រិត ដែលធ្វើឱ្យការរៀបចំប្រព័ន្ធឌីជីថលសម្រាប់ការផ្តល់សេវាសាធារណៈ មានភាពយឺតយ៉ាវ។ កំហុសឆ្គងក្នុងបញ្ជីអត្រានុកូលដ្ឋាននៅតែបន្តកើតមាន។

៣១១. ចំពោះវិស័យអប់រំ មានការខ្វះខាតមន្ត្រីជំនាញលើផ្នែកផែនការ ស្ថិតិអប់រំ ព័ត៌មានវិទ្យា និងការវិភាគបញ្ហានៅកម្រិតសាលារៀន។ ថវិកាចំណាយចរន្ត និងចំណាយក្រៅបន្ទុកបុគ្គលិក មិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅ ២០% នៃចំណាយចរន្តថ្នាក់ជាតិ និងតម្រូវការអភិវឌ្ឍសមត្ថភាពស្ថាប័ន។ ប្រសិទ្ធភាព នៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងសមត្ថភាពគ្រប់គ្រងវិវាទបុគ្គលិកអប់រំនៅមានកម្រិត។

៣១២. ការបើកថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា និងការពង្រីកមត្តេយ្យសហគមន៍នៅតាមតំបន់រោងចក្រមិនទាន់ឆ្លើយតបតាមតម្រូវការជាក់ស្តែង។ គុណវុឌ្ឍិគ្រូបង្រៀនបឋមសិក្សា មិនទាន់ឆ្លើយតបពេញលេញនឹងកំណែទម្រង់ថ្មី ហើយការអនុវត្តកញ្ចប់អំណាន និងគណិតវិទ្យាថ្នាក់ដំបូងមិនទាន់បានគ្រប់សាលារៀន។ ការអប់រំមធ្យមសិក្សា និងបច្ចេកទេស នៅមានកង្វះហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដូចជា បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ និងមន្ត្រីជំនាញផ្នែកបញ្ញាសិប្បនិម្មិត (AI)។ ដោយឡែកការអប់រំឧត្តមសិក្សាអត្រានិស្សិតចុះឈ្មោះចូលរៀននៅមានកម្រិតទាប ហើយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងប្រព័ន្ធធានាគុណភាពផ្ទៃក្នុងនៅមានភាពខ្វះខាត។ ចំពោះការងារយុវជន និងកីឡា កម្មវិធីអភិវឌ្ឍន៍យុវជនមិនទាន់ឆ្លើយតបពេញលេញនឹងតម្រូវការសតវត្សទី២១ ហើយហេដ្ឋារចនាសម្ព័ន្ធកីឡា និងមន្ត្រីជំនាញផ្នែកកីឡានៅមានកម្រិត។ ការអប់រំក្រៅប្រព័ន្ធនៅខ្វះគ្រូបង្រៀនជំនាញអប់រំពិសេសសម្រាប់កុមារពិការភ្នែក និងគ-ថ្លង់ ក៏ដូចជាកង្វះថវិកាគាំទ្រនៅថ្នាក់ក្រោមជាតិ។

៣១៣. ទោះបីការផ្តល់សេវាសុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ ទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្តី ក៏បញ្ហាប្រឈមចម្បងៗមួយចំនួន នៅតែទាមទារការបន្តដោះស្រាយប្រកបដោយប្រសិទ្ធភាព នៅក្នុងឆ្នាំ២០២៥ និងឆ្នាំបន្តបន្ទាប់ ដែលក្នុងនោះ រួមមាន អត្រាមរណភាពមាតានៅមានកម្រិតខ្ពស់នៅឡើយ (១៥៤ស្លាប់ ក្នុង ១០០ ០០០កំណើតរស់) ដែលតួលេខនេះនៅឆ្ងាយពីគោលដៅដែលបានកំណត់សម្រាប់ឆ្នាំ២០៣០ (៧០ស្លាប់ ក្នុង ១០០ ០០០កំណើតរស់)។ ទន្ទឹមនឹងនេះ អត្រាសម្រាលដោយបុគ្គលិកសុខាភិបាលនៅមានកម្រិតទាប ខណៈការពិនិត្យស្រាវជ្រាវមរណភាពមាតា និងទារកជុំវិញកំណើត ក៏នៅមានកម្រិត។ មូលហេតុដែលបណ្តាលឱ្យមាតាស្លាប់រហូតដល់ ៥៩% គឺបណ្តាលមកពីការធ្លាក់ឈាមក្រោយសម្រាល ដែលបញ្ហានេះពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងកម្រិតគុណភាពនៃការសង្គ្រោះបន្ទាន់ផ្នែកសម្ភព ការ

ថៃទាំទារកទើបកើត ព្រមទាំងគុណភាពនៃការពិនិត្យរកហានិភ័យប្រឈមនៅពេលមានផ្ទៃពោះ និងពេលសម្រាល។ ការចម្លងរោគពីម្ដាយទៅកូន៖ អត្រាចម្លងមេរោគអេដស៍ពីម្ដាយទៅកូននៅតែមានកម្រិតខ្ពស់ រហូតដល់ ៨,១៨% (ទិន្នន័យឆ្នាំ២០២៣) ដែលជាតួលេខមិនទាន់ឆ្លើយតបទៅនឹងគោលដៅលុបបំបាត់នៅឆ្នាំ២០២៥ (ត្រូវទម្លាក់ឱ្យនៅតិចជាង ៥%)។ ស្របគ្នានេះ ករណីឆ្លងថ្មីនៃមេរោគស្វាយពីកំណើតមានការកើនឡើង (១០៥ករណី ក្នុង ១០០ ០០០កំណើតទារកកើតរស់) ធៀបនឹងគោលដៅលុបបំបាត់នៅឆ្នាំ ២០២៥ ដែលត្រូវទម្លាក់ឱ្យនៅតិចជាង ៥០ករណី ក្នុង ១០០ ០០០កំណើតរស់។ បញ្ហាអាហារូបត្ថម្ភ និងការថៃទាំកុមារ៖ អត្រាកុមារស្គមស្គាំងមិនមានការប្រែប្រួលជាវិជ្ជមាននោះទេ ពោលគឺនៅទ្រឹងត្រឹមអត្រា ១០% ចាប់តាំងពីឆ្នាំ២០១៤មក (យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា)។ បន្ថែមពីនេះ ការពិនិត្យសុខភាពកុមារអាយុក្រោម ៥ឆ្នាំ តាមរយៈការអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មគ្រប់គ្រងជំងឺកុមារ នៅមានកម្រិតនៅឡើយ ដែលទាមទារការពង្រឹង និងពង្រីកបន្ថែមដើម្បីធានាសុខុមាលភាពកុមារ។

៣១៤. ក្រសួងអភិវឌ្ឍន៍ជនបទ៖ អត្រាគ្របដណ្ដប់សេវាទឹកស្អាត និងអនាម័យជនបទ នៅតំបន់ដាច់ស្រយ៉ាល និងតំបន់ដែលមានបរិស្ថានប្រឈមនៅមានកម្រិត។ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ បានប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ ទឹកស្អាត និងអនាម័យជនបទ។ វិសមភាពនៃការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ។ ធនធានសម្រាប់គាំទ្រសកម្មភាពផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទមិនទាន់ឆ្លើយ ទៅនឹងតម្រូវការជាក់ស្ដែង។ កិច្ចសហការរបស់អង្គការ និងដៃគូអភិវឌ្ឍន៍លើការងារផ្គត់ផ្គង់ទឹកជនបទនៅមានកម្រិត។ ការចាត់អាទិភាពការងារផ្គត់ផ្គង់ទឹក និងអនាម័យរបស់រដ្ឋបាលឃុំ សង្កាត់នៅមានកម្រិត។ សម្ភារៈផ្សព្វផ្សាយលើកកម្ពស់អនាម័យ និងទឹកស្អាតមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង។ ការផ្សព្វផ្សាយអំពីការផឹកទឹកសុវត្ថិភាព និងអនាម័យល្អសម្រាប់តំបន់ដាច់ស្រយាល និងតំបន់បរិស្ថានប្រឈមនៅមិនទាន់បានទូលំទូលាយនៅឡើយ។

៣១៥. ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖ ក្នុងឆ្នាំ២០២៥-២០២៦ ការវិវត្តនៃសេដ្ឋកិច្ច សង្គម និងបរិស្ថានសាកល នៅមានភាពស្រពិចស្រពិល និងមានបញ្ហាប្រឈមជាច្រើន ដូចជា កំណើនសេដ្ឋកិច្ចតូចចង្អៀត ការបន្តអូសបន្លាយនៃវិបត្តិសង្គ្រាម ការប្រកួតប្រជែងដ៏តានតឹងនៃពាណិជ្ជកម្មអន្តរជាតិ វិបត្តិសង្គមដោយសារបញ្ហាជនភៀសសឹក និងបម្រែបម្រួលអាកាសធាតុបានជះឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចក្នុងតំបន់ ការអភិវឌ្ឍសង្គម និងខ្សែច្រវាក់ផលិតកម្មសម្រាប់បម្រើការនាំចេញ។ ផលប៉ះពាល់ជាសាកលខាងលើនេះបានបង្កជាក្ដីបារម្ភ និងបង្កភាពរអាក់រអួលដល់ការរីកចម្រើនសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាពនៃប្រទេសកម្ពុជា។ បញ្ហាប្រឈមខាងលើ បានដាក់បន្ទុកលើធនធាន និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ការអភិវឌ្ឍសង្គម រួមទាំងកម្មវិធីជំនួយសង្គមនានា។ ជាក់ស្ដែង សម្ពាធនៃបំណុល កំណើនទាបនៃវិស័យសេវាកម្ម ការប្រើប្រាស់បច្ចេកវិទ្យាទំនើបរបស់ជនទុច្ចរិតដើម្បីកេងប្រវ័ញ្ចមកលើកុមារ បម្លាស់ទីនៃជនភៀសសឹកក្នុងការស្វែងរកការងារធ្វើនៅទីក្រុងធំៗ និងអត្រានៃភាពក្រីក្ររបស់ក្រុមគ្រួសារមួយចំនួន បានបង្កជាបញ្ហាប្រឈមក្នុងកិច្ចខិតខំប្រឹងប្រែងលុបបំបាត់ពលកម្មកុមារនៅកម្ពុជា ដូចមានចែងក្នុងគោលដៅអភិវឌ្ឍន៍សាកលប្រកបដោយចីរភាព ឆ្នាំ២០១៥-២០៣០ ដែលកំណត់ការបញ្ចប់គ្រប់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្មមកលើកុមារត្រឹមឆ្នាំ២០៣០។

៣១៦. ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានបញ្ហាប្រឈមមួយចំនួនក្នុងកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមកិច្ចឌីជីថល និងទីផ្សារ

ការងារសកម្ម ជាពិសេសនៅក្នុងក្របខណ្ឌសេដ្ឋកិច្ចបៃតង (១). ការចុះឈ្មោះចូលរៀនកម្មវិធីTVET និងការផ្សព្វផ្សាយអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ក្រុមគោលដៅក្នុងកម្មវិធី ១,៥ លាន នៅមានកម្រិត (២). គ្រឹះស្ថានTVET ធំៗ ប្រមូលផ្តុំនៅរាជធានីភ្នំពេញ និងស្ថិតនៅទីរួមខេត្ត ខណៈក្រុមគោលដៅស្ថិតនៅឆ្ងាយនិងកំពុងធ្វើការនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ (៣). កញ្ចប់ស្តង់ដាបណ្តុះបណ្តាល នៅមិនទាន់មានគ្រប់ជំនាញ ឬមុខរបរ ដែលចាំបាច់ត្រូវអភិវឌ្ឍបន្ថែមតាមការវិវត្តរបស់តម្រូវការជំនាញក្នុងទីផ្សារការងារ និង(៤). ការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ពុំទាន់បានទូលំទូលាយ ហើយការបង្រៀន និងរៀននៅតាមគ្រឹះស្ថាន អ.ប.វ. មួយចំនួនមិនបានអនុវត្តទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាពេញលេញ ហើយមិនបានអនុវត្តតាមការបង្រៀនផ្អែកទៅលើសមត្ថភាព (CBT)។

៣១៧. ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ៖ ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈមមួយចំនួនដូចជា៖ ការទាមទារយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុសម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់នាំឱ្យផុតល្វែង។ ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា។ ជនល្មើសមានកលល្បិចជ្រៀតចូលមកធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះ ជាបន្តបន្ទាប់ ជាពិសេសអនីតិជន ដែលតួលេខនៃការសង្គ្រោះកន្លងមកបង្ហាញថាមានកុមាររងគ្រោះច្រើនដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។ បន្ថែមពីនេះ ការគ្រប់គ្រងមណ្ឌលថែទាំកុមាររដ្ឋ សេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅសហគមន៍ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មកុមារ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែជួបប្រទះបញ្ហាប្រឈម និងទាមទារឱ្យមានការគាំទ្របច្ចេកទេស និងតាមដានជាប្រចាំ។ ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់រូបភាព។

៣១៨. ទោះបីជាប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់ទទួលបានលទ្ធផលជាវិជ្ជមានក្តី តែយើងបានពិនិត្យឃើញបញ្ហាប្រឈមថ្មីមួយចំនួនដែលបានកើតឡើង ដូចជា ការប្រើប្រាស់ល្បិចកលនាំចូលនូវសារធាតុគីមីបម្រើឱ្យវិស័យកសិកម្ម ឧស្សាហកម្ម បន្លំយកមកកែច្នៃផលិតជាសារធាតុញៀន សំយោគ ការផ្លាស់ប្តូរច្រក និងផ្លូវចរាចរ រួមទាំងរូបភាពនៃការនាំចូលឆ្លងកាត់ ការកែច្នៃផលិតជាដើម។ ក្តីបារម្ភ ដែលជាបញ្ហាប្រឈមកុំរ៉ៃ និងកំពុងបង្កហានិភ័យដល់សង្គមជាតិនោះគឺការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ នៅតែបន្តកើតមាននៅឡើយ ជាពិសេសការរីករាលដាលបញ្ហាគ្រឿងញៀនក្នុងស្រទាប់យុវវ័យ ដែលជាកត្តាមួយរួមចំណែកធ្វើឱ្យកើនឡើងនូវសកម្មភាពក្មេងទំនើង និងការប្រព្រឹត្តបទល្មើសដោយអនីតិជន និងកំពុងតែទាមទារឱ្យចាត់វិធានការជាអាទិភាព ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពបានទាន់ពេលវេលា រួមទាំងការពង្រឹងការចូលរួមរបស់សហគមន៍ និងកិច្ចគាំពារគ្រួសារ ជាវិធានការបង្ការការប្រព្រឹត្តបទល្មើសដោយអនីតិជន។

៣១៩. ដោយពិនិត្យឃើញថា មហន្តរាយដែលបណ្តាលមកពីឧក្រិដ្ឋកម្មគ្រឿងញៀន និងសកម្មភាពក្មេងទំនើង នៅតែបន្តរីករាលដាលទាំងនៅក្នុងតំបន់ និងលើពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ រាជរដ្ឋា

ភិបាលកម្ពុជាសម្រេចបន្តដាក់ចេញនូវ ផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី ១០ ឆ្នាំ២០២៥ ក្នុងគោលដៅ ដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃគ្រឿងញៀនព្រមទាំងកសាងសង្គម ដែលមានសុខុមាលភាពនិងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ពិសេសធានាបាននូវបរិស្ថានរស់នៅប្រកបដោយសុវត្ថិភាព សម្រាប់ការលូតលាស់របស់កុមារ និងយុវជន ដែលជាទំពាំងស្នងឫស្សីរបស់ជាតិ ព្រមទាំងការពារកិត្តិយស។

៣២០. ការអនុវត្តច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធស្តីពីការការពារកុមារ ការកាត់បន្ថយ និងការលុបបំបាត់ពលកម្មកុមារ កុមារប្រើប្រាស់សារធាតុញៀន អំពើជួញដូរកុមារ អំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់រូបភាព ការសុំកូនអន្តរប្រទេស ។ល។ និងការធានាការពារកុមារឱ្យរីកលូតលាស់មានសុខុមាលភាព មិនទាន់បានផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងជ្រួតជ្រាបដល់សហគមន៍មូលដ្ឋាននៅឡើយ។ ពិសេសការអនុវត្តរាល់លិខិតបទដ្ឋានទាំងនេះនៅមានកម្រិតនៅឡើយ អាស្រ័យដោយបញ្ហាប្រឈមនៃកង្វះខាតធនធានមនុស្ស ជំនាញបច្ចេកទេស និងកញ្ចប់ថវិកាសម្រាប់ការងារសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធានាអនុវត្តមុខងារ ដែលបានផ្ទេរឱ្យ ដូចជាការគ្រប់គ្រងមណ្ឌលថែទាំកុមាររដ្ឋ និងសេវាថែទាំកុមារងាយរងគ្រោះនៅសហគមន៍។ ម្យ៉ាងវិញទៀត ហានិភ័យសង្គមថ្មីៗដូចជា បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល (ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអនឡាញ) ឥទ្ធិពលនៃគ្រឿងញៀន កំណើននៃសកម្មភាពក្មេងទំនើង ក៏ដូចជាកំណើនអនីតិជនក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ បានធ្វើឱ្យយន្តការអនុវត្តច្បាប់ ការស្តារនីតិសម្បទា និងការផ្តល់សេវាការពារកុមារជួបប្រទះភាពស្មុគស្មាញ ដែលទាមទារការពង្រឹងកិច្ចសហការគាំទ្រយ៉ាងជិតស្និទ្ធពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងការពង្រឹងកិច្ចគាំពារពីគ្រួសារ។

៣២១. បញ្ហាប្រឈមក្នុងវិស័យសង្គមកិច្ច៖ បញ្ហាអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារអហ្វឡាញ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញបានចាប់ផ្តើមកើតឡើង និងរីករាលដាលយ៉ាងឆាប់រហ័ស ស្របតាមការវិវត្តនៃបច្ចេកវិទ្យាឌីជីថល ដែលទាមទារឱ្យអ្នកផ្តល់សេវាកិច្ចការពារកុមារ ត្រូវពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីឱ្យស្របតាមបរិបទថ្មីនេះ ជាពិសេសក្នុងពេលដែលកម្ពុជាកំពុងវាយតម្លៃ និងអនុវត្តផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ ២០២១-២០២៥។ ដំណើរការកសាងប្រព័ន្ធកិច្ចការពារ និងថែទាំកុមារមិនទាន់បានសម្រេចតាមគោលដៅទាំងស្រុងនៅឡើយទេ។ កំណែទម្រង់ច្បាប់ និងគោលនយោបាយមិនទាន់មានលក្ខណៈសុខដុមនីយកម្ម និងនៅមានភាពភាន់ច្រឡំនៅជុំវិញនីតិវិធី តួនាទី និងការទទួលខុសត្រូវនានា ទោះបីជាសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារកំពុងត្រូវបានពន្លឿនរៀបចំដើម្បីដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រីក៏ដោយ។ បន្ថែមពីនេះ យន្តការសម្របសម្រួលនៅមានភាពខ្វះចន្លោះពាក់ព័ន្ធនឹងបែងចែកមុខងារ និងការទទួលខុសត្រូវផ្នែកកិច្ចការពារកុមារ។ ការផ្ទេរមុខងារ និងថវិកាពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការនៅមានបញ្ហាប្រឈម គួបផ្សំនឹងការរងសម្ពាធពីវិបត្តិថ្មីៗ (ដូចជាការឆ្លើយតបសង្គ្រោះបន្ទាន់ដល់កុមារក្នុងគ្រួសារពលករមាតុភូមិនិវត្តន៍ និងគ្រួសារភៀសសឹកនៅតាមព្រំដែនកម្ពុជា-ថៃ) ដែលធ្វើឱ្យការឆ្លើយតបទៅនឹងការងារកិច្ចការពារកុមារ នៅមិនទាន់ល្អប្រសើរ។ មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមិនមានលិខិតអនុញ្ញាត និងវិញ្ញាបនបត្រទទួលស្គាល់នៅមានចំនួនច្រើន (ជាក់ស្តែងក្នុងឆ្នាំ២០២៥

ក្រសួងទើបតែបានផ្តល់វិញ្ញាបនបត្រទទួលស្គាល់ដល់មណ្ឌលថែទាំកុមារចំនួន ៦៥ ប៉ុណ្ណោះ ក្នុងចំណោមមណ្ឌលរបស់អង្គការដៃគូសរុប ១៣៦)។

៣២២. ភាពមិនប្រាកដប្រជានៃប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិជាក់លាក់ ស្តីពីកុមាររងគ្រោះ និងងាយរងគ្រោះ បានបង្កឱ្យភាពរាំងស្ទះក្នុងការប្រើប្រាស់សម្រាប់ធ្វើការវិភាគ និងកំណត់អាទិភាពកិច្ចការពារកុមារ ខណៈពេលដែលប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS) ត្រូវបានបង្កើតរួចរាល់ និងកំពុងស្ថិតក្នុងដំណាក់កាលពង្រឹងសមត្ថភាពជនបង្គោល និងបញ្ចូលទិន្នន័យជាប្រចាំនៅឡើយ។ ជាមួយគ្នានេះ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីតាមបច្ចេកទេស Primero នៅមិនទាន់ដំណើរការដោយរលូន ដោយសារកត្តាខ្វះធនធានមនុស្សក្នុងគ្រប់គ្រង និងការប្រើប្រាស់ចំណេះដឹងផ្នែកបច្ចេកវិទ្យា ហើយប្រព័ន្ធនេះនៅមិនទាន់បានបន្ស៊ីគ្នាជាមួយប្រព័ន្ធផ្សេងទៀត ដូចជាប្រព័ន្ធ OSCaR ជាដើម។

៣២៣. ទោះបីជាក្នុងឆ្នាំ២០២៥ ការអនុវត្តការងារធ្វើសមាហរណកម្មកុមារចេញពីមណ្ឌលថែទាំទទួលបានលទ្ធផលខ្ពស់ (មានចំនួន ៧៦៦នាក់ កើនឡើងរហូតដល់ ១៤១% ធៀបនឹងឆ្នាំមុន) ក៏ពិតមែន ប៉ុន្តែ ការកំណត់គោលដៅសមាហរណកម្មប្រកបដោយមហិច្ឆិតា មិនទាន់សម្រេចបាននៅក្នុងរយៈពេលដំបូងដែលមានកំណត់នៅក្នុងផែនការសកម្មភាព ដោយសារកង្វះនីតិវិធីសម្រាប់សមាហរណកម្ម និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការធ្វើសមាហរណកម្ម និងយន្តការតាមដានត្រួតពិនិត្យលើកុមារ ដែលបានសមាហរណកម្ម (ដែលឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃការគ្រប់គ្រងករណីកិច្ចការពារកុមារជារួមរហូតដល់ ៥២%)។ ជាលទ្ធផលការអនុវត្តផែនការនេះ បានបង្ហាញនូវភាពខុសគ្នាទាក់ទងនឹងគុណភាព នៃដំណើរការសមាហរណកម្ម និងក្តីបារម្ភទាក់ទងនឹងភាពសមស្រប និងភាពគ្រប់គ្រាន់ នៃសេវាគាំទ្រដែលផ្តល់ដល់កុមារ និងគ្រួសារ។

៣២៤. ការផ្លាស់ប្តូរឥរិយាបទសាធារណជនទូទៅ ជាពិសេសឪពុកម្តាយ ដែលគិតថា ការទុកដាក់កុមារថែទាំក្នុងមណ្ឌលជាជម្រើសល្អ ដែលជាហេតុធ្វើឱ្យការជំរុញ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍ និងការទប់ស្កាត់ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ នៅមានបញ្ហាប្រឈម ថ្វីត្បិតតែក្រសួងបានខិតខំបើកយុទ្ធនាការ "គ្រួសាររឹងមាំ" យ៉ាងទូលំទូលាយតាមបណ្តាញសង្គម (ដែលមានអ្នកចូលទស្សនាជាង ១,៦លានដង) និងចុះបណ្តុះបណ្តាលផ្ទាល់នៅតាមមូលដ្ឋានជាង ១០០ឃុំ-សង្កាត់ក៏ដោយ។ ទន្ទឹមនឹងនេះ សមត្ថភាព បទពិសោធន៍ និងគុណភាពនៃការផ្តល់សេវាសង្គមនៅថ្នាក់មូលដ្ឋាន នៅតែជាឧបសគ្គចំពោះការពង្រឹងប្រព័ន្ធកិច្ចការពារ និងការថែទាំកុមារ ទោះបីជាមានការដាក់ឱ្យប្រើប្រាស់សៀវភៅក្របខណ្ឌស្តង់ដារគុណភាពជាតិសម្រាប់ការផ្តល់សេវាសង្គមកិច្ចហើយក្តី។ ការគ្របដណ្តប់ នៃសេវាសុខុមាលភាពកុមារ និងកិច្ចគាំពារសង្គមនៅមានកម្រិត រួមជាមួយនឹងសេវារបស់អង្គការមិនមែនរដ្ឋាភិបាលមានទំហំតូចៗ និងផ្តោតលើតំបន់គោលដៅរៀងៗខ្លួន បង្កឱ្យមានការគាំទ្រ និងលទ្ធផលខុសគ្នាស្រឡះសម្រាប់កុមារ។ ហានិភ័យនេះមានលក្ខណៈគួរឱ្យកត់សម្គាល់ចំពោះកុមារមានពិការភាព កុមារមានតម្រូវការពិសេស និងកុមារមកពីសហគមន៍ដាច់ស្រយាល ដែលតម្រូវការរបស់ពួកគេមិនត្រូវបានចាត់ជាអាទិភាព និងមិនសមស្របតាមគោលការណ៍សមធម៌។

៣២៥. ក្រសួងកិច្ចការនារី បញ្ហាប្រឈមនឹងបញ្ហាមួយចំនួន រួមមាន៖ អស្ថិរភាពសេដ្ឋកិច្ច និងនយោបាយសកលមានភាពតានតឹង និងភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកល ព្រមទាំងវិបត្តិសង្គ្រាមនៅមជ្ឈិមបូព៌ា ដែលជះឥទ្ធិពលអវិជ្ជមានដល់ការផ្គត់ផ្គង់ថាមពល និងសេដ្ឋកិច្ចពិភពលោក។ បញ្ហាព្រំដែន និងការធ្វើចំណាកស្រុក

ភាពមិនទាន់ច្បាស់លាស់ពាក់ព័ន្ធនឹងព្រំដែនកម្ពុជា (ជាពិសេសជាមួយប្រទេសថៃ) ដែលតម្រូវឱ្យមានការជួយដល់ពលករចំណាកស្រុក គ្រួសារយុទ្ធជនពលី និងការជំរុញសក្ដានុពលសេដ្ឋកិច្ច និងផលិតផលក្នុងស្រុក។ ការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យា ការប្រឈមនឹងការប្រែប្រួលអាកាសធាតុ និងការវិវត្តយ៉ាងរហ័សនៃបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត (AI) រួមទាំងតម្រូវការក្នុងការទប់ស្កាត់បទល្មើស និងការបៀតបៀនតាមប្រព័ន្ធអនឡាញ។ និន្នាការសង្គម និងប្រជាសាស្ត្រ៖ មានការប្រែប្រួលនៃរបត់ប្រជាសាស្ត្រក្នុងស្រុកមួយចំនួនដែលជាក្តីបារម្ភ ដូចជា កំណើនប្រជាជនមានការថយចុះ អត្រានៃការរៀបការក្នុងចំណោមយុវជនមានការថយចុះ ចំណែកអត្រានៃការលែងលះមានការកើនឡើង និងនិន្នាការថយចុះនៃការចូលរៀនរបស់ក្មេងប្រុស។

# ៩. ទិសដៅអនុវត្តបន្ត



## ៩. ទិសដៅអនុវត្តបន្ត

៣២៦. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) បន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងក្រោមជាតិ ដោយប្រើប្រាស់យន្តការដែលមានស្រាប់ ធ្វើការបណ្តុះបណ្តាល ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធិសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ។ ជាពិសេសជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០។

៣២៧. វិស័យសុខាភិបាលបានផ្តោតលើអាទិភាពជាយុទ្ធសាស្ត្រ រួមមាន៖ ការបង្កើនការទទួលបាន និងការគ្របដណ្តប់នៃសេវាថែទាំសុខភាព ការលើកកម្ពស់គុណភាព និងសុវត្ថិភាពនៃការថែទាំសុខភាព ការគាំពារហិរញ្ញវត្ថុ ការពង្រឹងសន្តិសុខសុខភាព និងការពង្រឹងសមត្ថភាព និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាលដែលគ្របដណ្តប់លើ ការអភិវឌ្ឍស្ថាប័ន និងអភិបាលកិច្ចសុខាភិបាល ការអភិវឌ្ឍធនធានមនុស្សសុខាភិបាល ការគ្រប់គ្រងហិរញ្ញវត្ថុ ផលិតផលសុខាភិបាល បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍទិន្នន័យ ការគ្រប់គ្រងព័ត៌មានសុខាភិបាល និងសុខាភិបាលឌីជីថល។

៣២៨. ក្រសួងអភិវឌ្ឍជនបទ៖ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវបន្តថែទាំ និងពង្រីកការសាងសង់ផ្លូវជនបទឱ្យមានគុណភាព ព្រមទាំងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវតាមបច្ចេកវិទ្យាព័ត៌មាន និងសិក្សាពីបច្ចេកទេសសាងសង់ដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ការកែលម្អបរិស្ថានរស់នៅជនបទ និងស្រាវជ្រាវបច្ចេកវិទ្យាទឹកស្អាត និងអនាម័យដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ច ដែលជំរុញការអភិវឌ្ឍសហគមន៍ជនបទ បង្កើត និងពង្រឹងអាជីវកម្មសហគមន៍ បណ្តុះបណ្តាលជំនាញបច្ចេកទេសដល់ប្រជាពលរដ្ឋ និងបន្តការងារអភិវឌ្ឍន៍សហគមន៍ជនជាតិដើមភាគតិច។ ការពង្រឹងស្ថាប័ន និងធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញវិជ្ជាជីវៈ ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តថវិកា។ អភិបាលកិច្ច និងបច្ចេកវិទ្យា ដោយជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងទំនាក់ទំនង ព្រមទាំងពង្រឹងអភិបាលកិច្ច និងការផ្តល់សេវាសាធារណៈឱ្យកាន់តែខិតជិតប្រជាពលរដ្ឋនៅមូលដ្ឋាន។

៣២៩. ក្រសួងអប់រំ យុវជន និងកីឡា លើកជាទិសដៅយុទ្ធសាស្ត្រសំខាន់ៗ រួមមាន៖ ការពង្រឹងអភិបាលកិច្ច និងស្តង់ដាសាលារៀនគំរូ (Model Schools) ពង្រីកវិសាលភាពសាលារៀនគំរូ ចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ដើម្បីធានាបាននូវការសិក្សាដែលមានគុណភាព វិន័យ សីលធម៌ និងការចូលរួមពីសហគមន៍។ បន្តការវាយតម្លៃ និងជួយគាំទ្រសាលារៀនឱ្យសម្រេចបាននូវស្តង់ដាសាលារៀនគំរូទាំង ៥ ដែលផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងការគ្រប់គ្រងសាលាប្រកបដោយប្រសិទ្ធភាព។ ការកែលម្អគុណវុឌ្ឍិ និងសមត្ថភាពគ្រូបង្រៀន៖អនុវត្តកំណែទម្រង់គ្រូបង្រៀន តាមរយៈការដំឡើងកម្រិតបណ្តុះបណ្តាលទៅជាប្រព័ន្ធ ១២+៤ (បរិញ្ញាបត្រអប់រំ) និង បរិញ្ញាបត្រ+១។ ជំរុញការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) សម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា ដើម្បីឱ្យទាន់សម័យកាលបច្ចេកវិទ្យា និងវិធីសាស្ត្របង្រៀនថ្មីៗ។ បំប្លែងការអប់រំឌីជីថល និងបញ្ញាសិប្បនិម្មិត (AI) ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងបញ្ញា

សិប្បនិម្មិត (AI) ក្នុងការរៀន និងបង្រៀន តាមរយៈការអភិវឌ្ឍមាតិកាឌីជីថល និងការបង្កើតថ្នាក់រៀនឆ្លាតវៃ (Smart Classroom)។ បន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS) និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HRMIS) ឱ្យមានភាពទំនើប និងតភ្ជាប់គ្នា។ ការអភិវឌ្ឍជំនាញសតវត្សទី២១ និងការអប់រំបច្ចេកទេស ពង្រឹងការអប់រំ STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) នៅគ្រប់កម្រិតសិក្សា ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។ អនុវត្តគន្លងអប់រំថ្មី ដែលតភ្ជាប់រវាងការអប់រំចំណេះទូទៅ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)។ បណ្តុះបណ្តាលយុវជនឱ្យមានជំនាញទន់ និងជំនាញបច្ចេកទេស ព្រមទាំងស្មារតីសហគ្រិនភាព និងភាពជាពលរដ្ឋល្អ។ លើកកម្ពស់សុខភាពសិក្សា និងការងារកីឡាតាមរយៈការរៀបចំការប្រកួតកីឡាសិស្ស-និស្សិត និងការហ្វឹកហ្វឺនកីឡាករជម្រើសជាតិឱ្យបានខ្លាំងក្លា។

៣៣០. វិស័យសង្គមកិច្ច លើកកម្ពស់ការពារកុមារ និងសិទ្ធិកុមារ៖ ក្រសួង ស.អ.យ. បានបន្តពង្រឹងការលើកកម្ពស់សេវាកិច្ចការពារកុមារ ទាំងអហ្វឡាញ និងអនឡាញ ដើម្បីឆ្លើយតបនឹងហានិភ័យថ្មីៗ និងធានាសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចគ្រប់រូបភាព ដោយពន្លឿនការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ប្រកបដោយបរិយាបន្ន ការគោរពសិទ្ធិជាមូលដ្ឋាន និងតម្កល់ឧត្តមប្រយោជន៍របស់កុមារជាចម្បង។ ពង្រឹងសមត្ថភាព និងគុណភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ពង្រឹងការអនុវត្តប្រព័ន្ធទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារ និងប្រព័ន្ធទិន្នន័យគ្រប់គ្រងករណីកុមារ Primero សំដៅធានាការរក្សាការសម្ងាត់ និងការឆ្លើយតបករណីរំលោភបំពានបានទាន់ពេលវេលា។ លើកកម្ពស់ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ ដែលផ្តល់បរិយាកាសកក់ក្តៅ និងគាំទ្រដល់ការលូតលាស់ផ្លូវកាយនិងផ្លូវចិត្តរបស់កុមារ ព្រមទាំងពង្រឹង និងពង្រីកកម្មវិធីទុកដាក់កុមារជាអចិន្ត្រៃយ៍តាមរយៈសុំកូនក្នុងប្រទេស ប្រកបដោយតម្លាភាព សុវត្ថិភាព និងអនុលោមតាមគោលការណ៍សិទ្ធិកុមារជាតិនិងអន្តរជាតិ។

៣៣១. លើកកម្ពស់ការអប់រំ ផ្សព្វផ្សាយ និងធ្វើការជាមួយអ្នកពាក់ព័ន្ធ ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ រាល់ទម្រង់ ការកេងប្រវ័ញ្ច និងការរំលោភបំពានសិទ្ធិកុមារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និងសម្របសម្រួលផ្តល់សេវាដល់កុមារតាមម្តាយក្នុងពន្ធនាគារ ដើម្បីធានាសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការថែទាំ និងការអភិវឌ្ឍសមស្របតាមវ័យ ដោយមិនមានការរើសអើង។ បន្តជំរុញឱ្យអង្គការដៃគូដាក់ពាក្យស្នើសុំវិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំជំនួសចំពោះកុមារ និងពង្រឹងនិងពង្រីកកម្មវិធីបណ្តុះបណ្តាលផ្តល់ការទទួលស្គាល់គុណវុឌ្ឍិន៍ នៃអង្គការសុវត្ថិភាពកុមារ ដើម្បីពង្រឹងប្រព័ន្ធការពារ និងទប់ស្កាត់រាល់ហានិភ័យនៃការកេងប្រវ័ញ្ចលើកុមារនៅតាមមណ្ឌលថែទាំ។ បន្តគាំទ្របច្ចេកទេសពាក់ព័ន្ធនឹងកិច្ចការពារកុមារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តមុខងារ និងសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីអនុវត្តនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការជួយសង្គ្រោះកុមាររងគ្រោះទាន់ពេលវេលា។ លើកកម្ពស់កិច្ចការគ្រួសារ និងសេវាគាំពារជនរងគ្រោះ ដោយបន្តសហការជាមួយ ក្រសួង ស្ថាប័ន អង្គការ និងសមាគមពាក់ព័ន្ធនានា ដើម្បីសម្របសម្រួល និងផ្តល់សេវាដល់មុខសញ្ញា ដែលជាជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស ជាពិសេសកុមាររងគ្រោះ ដោយធានាការផ្តល់សេវាគាំពារផ្លូវចិត្ត ស្តារនីតិសម្បទា និងសមាហរណកម្មប្រកបដោយមេត្រីភាពចំពោះកុមារ។

៣៣២. បន្តលើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ស្របតាមគោលការណ៍យុត្តិធម៌អនីតិជន និងសិទ្ធិកុមារ ដោយពង្រឹងការគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា ដើម្បីផ្តល់ឱកាសអប់រំកែប្រែខ្លួនក្នុងបរិយាកាសសុវត្ថិភាព ការ

គ្រប់គ្រងករណីអនីតិជនក្រោយពេលធ្វើសមាហរណកម្ម និងពង្រីកកម្មវិធីបង្វែរកុមារចេញពីប្រព័ន្ធតុលាការ ដែលផ្តោតលើការស្តារនីតិសម្បទាជាជាងការផ្តន្ទាទោស ការពារកុមារកុំឱ្យធ្លាក់ចូលក្នុងអំពើល្មើសជាថ្មី។ លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ជាពិសេសយកចិត្តទុកដាក់ជួយសង្គ្រោះកុមារ និងយុវជនងាយរងគ្រោះ ដោយផ្តោតលើការលើកកម្ពស់ការគ្រប់គ្រងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការគ្រប់គ្រងករណីអ្នកញៀនគ្រឿងញៀនក្រោយពេលធ្វើសមាហរណកម្ម និងការតាមដានគុណភាពស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយធានាការធ្វើសមាហរណកម្មសង្គម ដោយគ្មានការរើសអើង និងគាំទ្រដល់សិទ្ធិអភិវឌ្ឍន៍អនាគតដ៏ប្រសើររបស់កុមារនិងយុវជនឡើងវិញ។

៣៣៣. លើកកម្ពស់សុខុមាលភាពជនមានពិការភាព រួមទាំងកុមារមានពិការភាព ឱ្យទទួលបានសិទ្ធិស្មើភាពគ្នា គ្មានការរើសអើង និងការអន្តរាគមន៍ថែទាំតាំងពីវ័យកុមារ (Early Intervention) ដោយប្រមូលផ្តុំលើការលើកកម្ពស់សិទ្ធិការងារ និងសេវាយុត្តិធម៌ជនមានពិការភាព ការគាំទ្រសកម្មភាពកីឡា សិល្បៈនិងវប្បធម៌ជនពិការ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតមុខរបរជូនជនមានពិការភាព ព្រមទាំងផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព ដូចជា ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា និងសេវាស្តារវេជ្ជសាស្ត្រជូនជនមានពិការភាព ធានាថាកុមារមានពិការភាពទទួលបានការស្តារសម្បទា និងសម្ភារៈគាំទ្រសម្រាប់ការអប់រំបរិយាបន្នពេញលេញ ការផលិតឧបករណ៍សិប្បនិម្មិតរណប ដាក់ហិបសប្បុរសធម៌ ការផ្តល់របបគោលនយោបាយជួយឧបត្ថម្ភជនពិការ ជាពិសេសគ្រួសារដែលមានកុមារមានពិការភាព និងការលើកកម្ពស់ការគ្រប់គ្រងមជ្ឈមណ្ឌលជាតិជនពិការកម្ពុជា។

៣៣៤. ជំរុញការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គម ដើម្បីជាសំណាញ់សុវត្ថិភាពសង្គមការពារគ្រួសារងាយរងគ្រោះ ធានាថាកុមារទទួលបានសិទ្ធិរស់រានមានជីវិត អាហារូបត្ថម្ភគ្រប់គ្រាន់ និងមិនបង្ខំឱ្យកុមារបោះបង់ការសិក្សាដើម្បីរកប្រាក់ចំណូល ឬធ្លាក់ចូលក្នុងពលកម្មកុមារ។ រៀបចំកម្មវិធីស្ពានចម្លងសេវាសង្គមដល់គ្រួសារក្រីក្រ តាមរយៈការអនុវត្តកម្មវិធីស្ពានចម្លងសេវាសង្គមដល់គ្រួសារក្រីក្រ ជាពិសេសគ្រួសារដែលមានកុមារកំព្រា កុមារដែលគេបោះបង់ចោល កុមារងាយរងគ្រោះដោយកត្តាផ្សេងៗ និងកុមាររងគ្រោះដោយអំពើហិង្សា មនុស្សវ័យចាស់គ្មានទីពឹង ជនមានពិការភាព ជនអនាថា និងអ្នកញៀនគ្រឿងញៀន សំដៅការពារកុមារពីហានិភ័យនៃការកេងប្រវ័ញ្ច ការរំលោភបំពាន និងផ្តល់ការថែទាំប្រកបដោយសុវត្ថិភាពសម្រាប់ការលូតលាស់ប្រកបដោយសក្តានុពល។

៣៣៥. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) និងបូកសរុបរបាយការណ៍សម្រាប់ឆ្នាំ២០២៥ ដើម្បីកំណត់បញ្ហាប្រឈម និងទិសដៅសម្រាប់ការរៀបចំផែនការនេះរយៈពេល១០ឆ្នាំខាងមុខទៀត។ ក្រសួងនឹងបន្តពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ និងអាជ្ញាធរដែនដី ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងពង្រឹងវិធានការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារឱ្យមានប្រសិទ្ធភាព ទន្ទឹមនឹងការយកចិត្តទុកដាក់លើយន្តការអន្តរាគមន៍រហ័ស និងសេវាឆ្លើយតបតាមរយៈកិច្ចអន្តរាគមន៍ស្ទូល សំដៅផ្តល់ឱកាសអប់រំ បណ្តុះបណ្តាលជំនាញ និងបង្កើតមុខរបរដល់កុមារ និងក្រុមគ្រួសារងាយរងគ្រោះ។ ក្រសួងត្រូវលើកទិសដៅប្រកបដោយនវានុវត្តន៍ និងបុរេសកម្មទៅលើវិស័យការងារដែលងាយរងហានិភ័យខ្ពស់នៃពលកម្មកុមារ ពន្លាតសេវាបណ្តុះបណ្តាលជំនាញ បេឡាជាតិសន្តិសុខសង្គម សុខភាពសុវត្ថិភាពការងារ

ទារកដ្ឋាន និងកន្លែងទុកដាក់ក្មេង ដល់យុវជនវ័យក្មេង និងក្រុមគ្រួសារកុមារនៅសហគមន៍ និងកន្លែងការងារ។ ជាក់ស្តែង ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបណ្តុះបណ្តាលដើម្បីផលិតភាពការងារ តាមរយៈការបណ្តុះបណ្តាលចល័ត ការបង្វិតការបណ្តុះបណ្តាលឱ្យកៀកទៅនឹងយុវជនដែលមានតម្រូវការនៅតាមមូលដ្ឋានជនបទ និងការកសាងស្ពានចម្លង ឬគន្លងអប់រំវិជ្ជាជីវៈថ្មីដល់សិស្សានុសិស្សដែលបញ្ចប់ការអប់រំមូលដ្ឋាន៩ឆ្នាំ ឬនៅកម្រិតវិទ្យាល័យ ដើម្បីឆ្លើយតបទៅនឹងលំហូរទីផ្សារការងារក្នុងបរិវត្តន៍ឧស្សាហកម្ម ៤.0 សេដ្ឋកិច្ចសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង។

៣៣៦. ក្រសួងកិច្ចការនារី បានដាក់ចេញជារួមនូវចំណុចសំខាន់ៗមួយចំនួនដូចជា៖ ការបញ្ជ្រាបយេនឌ័រតាមវិស័យ បន្តជំរុញការធ្វើស្ថាប័នូបនីយកម្មយេនឌ័រ និងពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃឱ្យបានហ្មត់ចត់តាមវិស័យនីមួយៗ។ ការអភិវឌ្ឍសហគ្រិនភាព និងសេដ្ឋកិច្ច ពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនារី និងផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រីនៅតាមសហគមន៍។ សេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព (Care Economy) ចាប់ផ្តើមអនុវត្តក្របខណ្ឌការងារ និងផែនការសកម្មភាពដែលផ្តោតលើការងារថែទាំ និងសុខុមាលភាពគ្រួសារ។ ការទប់ស្កាត់អំពើហិង្សា ពង្រីកវិសាលភាពសេវាឆ្លើយតបពហុវិស័យ និងអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឱ្យកាន់តែមានប្រសិទ្ធភាព។ ការលើកកម្ពស់សីលធម៌សង្គម និងតម្លៃគ្រួសារ បន្តអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈកម្មវិធីអប់រំផ្សេងៗដូចជា «ពុកម៉ែល្អ កូនល្អ» និង «ស្វាមីញញឹម» ដើម្បីជំរុញវប្បធម៌អហិង្សា និងការចិញ្ចឹមកូនបែបវិជ្ជមាន។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ពង្រឹងទំនាក់ទំនងអន្តរជាតិដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងរបៀបវារៈ «ស្ត្រី សន្តិភាព និងសន្តិសុខ»។ ការកែទម្រង់ស្ថាប័ន បន្តអភិវឌ្ឍធនធានមនុស្ស ឌីជីថលូបនីយកម្មក្នុងប្រព័ន្ធព័ត៌មាន និងការគ្រប់គ្រងស្ថិតិ ដើម្បីគាំទ្រដល់កម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល។

៣៣៧. របស់ក្រសួងមហាផ្ទៃ បានដាក់ចេញនូវទិសដៅអនុវត្តបន្ត រួមមាន៖ ការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបន្តជំរុញការផ្ទេរមុខងារ សិទ្ធិអំណាច និងធនធានថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព និងតម្លាភាព។ កែលម្អរចនាសម្ព័ន្ធរដ្ឋបាលឱ្យស្របតាមការវិវត្តនៃស្ថានភាពភូមិសាស្ត្រ និងសេដ្ឋកិច្ចសង្គម ដោយបែងចែករដ្ឋបាលទីក្រុងធំ រដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋាន។ ធ្វើទំនើបកម្មសេវាសាធារណៈ តាមរយៈយន្តការច្រកចេញចូលតែមួយ ដោយប្រើប្រាស់ប្រព័ន្ធឌីជីថល ដើម្បីបង្កើនភាពងាយស្រួល និងឆាប់រហ័សជូនប្រជាពលរដ្ឋ។ ការរក្សាសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ពង្រឹងកិច្ចសហការការពារបូរណភាពទឹកដី និងជំរុញការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែសកម្ម ដើម្បីកាត់បន្ថយបទល្មើសគ្រឿងញៀន ការជួញដូរមនុស្ស និងល្បែងស៊ីសងខុសច្បាប់។ បង្កើនការបង្ក្រាបបទល្មើសបច្ចេកវិទ្យា (Online Scams) និងសកម្មភាពក្មេងទំនើងដែលបង្កអសន្តិសុខក្នុងសង្គម។ ជំរុញភាពស្អាតស្អំទិន្នន័យ ក្នុងប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជន (IPIS) និងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធអនឡាញពីថ្នាក់មូលដ្ឋាន។

៣៣៨. ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលសាធារណៈ ដោយបន្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការប្រើប្រាស់ប្រព័ន្ធ EFMS និង FMIS ដើម្បីធានាបាននូវតម្លាភាព និងគណនេយ្យភាព។

ពង្រឹងការងារវិមជ្ឈការ និងវិសហមជ្ឈការ ដោយផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា។

៣៣៩. លើសពីនេះទៀត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) នឹងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដោយជំរុញការរៀបចំបង្កើតប្រព័ន្ធទិន្នន័យ នៃការអនុវត្តសិទ្ធិកុមារ ព្រមទាំងត្រូវបំពេញតួនាទីជាសេនាធិការ ជូនរាជរដ្ឋាភិបាល ជាច្រកចេញចូលតែមួយក្នុងការពិនិត្យ និងរាយការណ៍ពាក់ព័ន្ធនឹងវិស័យការងារកុមារ។ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្ត និងដាក់បញ្ចូលអនុសាសន៍ នៃសេចក្តីសង្កេតចុងក្រោយទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងស្ថាប័នសាមី។ កាត់បន្ថយ និងលុបបំបាត់អំពើជួញដូរ អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ។ បន្តពង្រឹង និងពង្រីក ក.ជ.ក. នៅគ្រប់លំដាប់ថ្នាក់ ដើម្បីជាយន្តការសម្របសម្រួលជួយដល់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការអនុវត្តភារកិច្ចលើវិស័យការងារកុមារ ឱ្យមានប្រសិទ្ធភាព។ ពង្រីកការចូលរួមរបស់កុមារ តាមរយៈព្រឹត្តិការណ៍ជាតិ ក្រោមជាតិ តំបន់ និងថ្នាក់អន្តរជាតិនានា។ រាល់មតិយោបល់របស់កុមារ ត្រូវយកមកពិចារណា និងដាក់បញ្ចូលទៅក្នុង ផែនការសកម្មភាពនានាសម្រាប់ការអភិវឌ្ឍសិទ្ធិរបស់ពួកគេ។

៣៤០. បន្តពង្រីកកិច្ចសហការជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ ដើម្បីពង្រីកការអនុវត្តច្បាប់អន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងបរទេស សហគមន៍ ប្រជាពលរដ្ឋ មាតាបិតា អាណាព្យាបាល សំដៅជំរុញលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ។

# ១០. សេចក្តីសន្និដ្ឋាន



## ១០. សេចក្តីសន្និដ្ឋាន

៣៤១. តាមរយៈការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយកំណត់យកនូវអាទិភាពគន្លឹះចំនួន ៥ រួមមាន៖ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិ ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ តាមរយៈការអនុវត្តកន្លងមក បានបង្ហាញនូវវឌ្ឍនភាពគួរជាទីមោទនៈ ដែលជាការបង្ហាញនូវជំហរ និងជំហានយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំនិងអភិវឌ្ឍប្រទេសប្រកបដោយសុខដុម។

៣៤២. ការពង្រឹងវិស័យសុខាភិបាល មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយបានអនុវត្តកម្មវិធីលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងការកែលម្អកង្វះអាហារូបត្ថម្ភ ដែលធ្វើឱ្យអត្រាមរណភាពរបស់មាតា ទារក កុមារ មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។ គួរកត់សម្គាល់ថា មរណភាពទារក និងកុមារអាយុក្រោម ៥ ឆ្នាំ សម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ មុនកាលកំណត់ ៨ឆ្នាំ។ អន្តរាគមន៍នៃសេវាបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លងចម្បងៗត្រូវបានពង្រឹង និងពង្រីកការគ្របដណ្តប់បានកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ ដូចជាមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ គ្រុនឈាម និងជំងឺរបេងជាដើម។ រីឯគុណភាពសេវា ក៏ត្រូវបានកែលម្អជាប្រចាំ តាមរយៈការវាយតម្លៃគុណភាពនៃការងារគ្រប់គ្រង និងគុណភាពនៃសេវាថែទាំ។

៣៤៣. ក្រសួងអប់រំ យុវជន និងកីឡា បានការបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់ភូមិសិក្សា ជាពិសេសការអប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ តាមរយៈការបង្កលក្ខណៈសម្បត្តិអនុគ្រោះឱ្យកូនចៅប្រជាជន ដែលជួបការលំបាកមានលទ្ធភាពចូលរៀន រៀនបន្ត។ ពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សា និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និងនិស្សិតមកពីគ្រួសារក្រីក្រ។ល។ គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំក៏ត្រូវបានពង្រឹង តាមរយៈការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន និងការលើកទឹកចិត្ត ព្រមទាំងបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំគ្រប់លំដាប់ថ្នាក់។ល។

៣៤៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តការយកចិត្តទុកដាក់ការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាព រួមទាំងការជួញដូរកុមារ ការប្រើប្រាស់អំពើហិង្សាលើកុមារ។ កុមារគ្រប់រូបមានសិទ្ធិក្នុងការធំលូតលាស់នៅក្នុងបរិយាកាសដោយសុវត្ថិភាព និងការចិញ្ចឹមបីបាច់គ្មាន អំពើហិង្សា និងការកេងប្រវ័ញ្ច។ ដោយសារការគាំទ្រ និងការវិនិយោគមានការកើនឡើងសម្រាប់វិស័យ កិច្ចការពារកុមារ កុមារនៅកម្ពុជាទទួលបាននូវកិច្ចការពារកាន់តែប្រសើរឡើងជាងមុន តាមរយៈ ការពង្រឹងការអនុវត្តច្បាប់ បទដ្ឋានគតិយុត្ត និងសេវាឆ្លើយតបសមស្រប និងទាន់ពេលវេលា។ ជាមួយគ្នា នេះដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការបង្កើតកម្មវិធីជំនួយសង្គម យន្តការជាមូលដ្ឋានសម្រាប់កិច្ចការពារកុមារ ការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌលថែទាំជំនួស ការប្រយុទ្ធប្រឆាំងដើម្បីបញ្ឈប់អំពើហិង្សាលើកុមារ រួមទាំងក្លាយជាប្រទេសជាសមាជិកនៃប្រទេសដៃគូដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។

៣៤៥. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបន្តអនុវត្តផែនការសកម្មភាពជាតិស្តីពី ការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ ដែលជាត្រីវិស័យតម្រង់ទិសដើម្បីលើកកម្ពស់ ការយល់ដឹងឱ្យកាន់តែប្រសើរឡើងចំពោះបញ្ហាពលកម្មកុមារ និងផ្តល់ជាកម្លាំងចលករជំរុញដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការការពារឧត្តមប្រយោជន៍សម្រាប់កុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ ទន្ទឹមនឹងនេះ ក្រសួងក៏បន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ សំដៅធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពទីផ្សារការងារ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ សុខុដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ និងរបបសន្តិសុខសង្គម។ ការអនុវត្តនេះ ផ្តោតលើ (១). យន្តការសម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ជាតិ និងក្រោមជាតិ (២). ការលើកកម្ពស់ការយល់ដឹង តាមរយៈ ការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយ (៣). ការពង្រឹងការអនុវត្តច្បាប់តាមរយៈយន្តការអធិការកិច្ចការងារ និង(៤). ការអនុវត្តគម្រោងកិច្ចអន្តរាគមន៍ស្នូល ដើម្បីបង្ការ ទប់ស្កាត់ និងគាំពារកុមារ។

៣៤៦. សមិទ្ធផលទាំងនេះ គឺជាការឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី ប្រកបដោយទំនួលខុសត្រូវខ្ពស់ របស់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមានមនសិការមុតមាំក្នុងការពុះពារគ្រប់បញ្ហាប្រឈម ដើម្បីលើកកម្ពស់សុខុមាលភាព និងឧត្តមប្រយោជន៍របស់កុមារ តាមរយៈការពង្រឹងការអនុវត្តសិទ្ធិកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងបន្តសម្របសម្រួលក្រសួង ស្ថាប័ន ដើម្បីបង្ការ ទប់ស្កាត់ និងអន្តរាគមន៍ចំពោះអំពើហិង្សាលើកុមារ ព្រមទាំងដាក់ចេញនូវយន្តការឆ្លើយតបចាំបាច់នានា ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ ២០៣០។

៣៤៧. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារសូមសម្តែងនូវអំណរគុណដល់គ្រប់ក្រសួង ស្ថាប័នជាតិ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ អង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍនានា ប្រជាជន សហគមន៍ ព្រះសង្ឃ គ្រូបាចារ្យ មាតាបិតា អ្នកអាណាព្យាបាល និងកុមារខ្លួនឯងផ្ទាល់ ដែលបានចូលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមារនៅកម្ពុជាឲ្យមានការរីកចម្រើនស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ៕

# សកម្មភាពលើកកម្ពស់សិទ្ធិកុមារ
# របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
# និងក្រសួង ស្ថាប័នពាក់ព័ន្ធ

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ



១- កិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ លើកទី១ អាណត្តិ៧ នៃរាជរដ្ឋាភិបាល នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥











២- វេទិកាកុមារនឹងអ្នកធ្វើគោលនយោបាយ ក្រោមប្រធានបទ “បញ្ឈប់អំពើហិង្សាលើកុមារគ្រប់ទម្រង់ គឺជាការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព” នៅថ្ងៃទី០៧ ខែខ្វសភា ឆ្នាំ២០២៥ នាទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា












៣- មិទ្ទីងអបអរសាទរខួបលើកទី៧៦ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៤ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៥








៨- គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងសម្រេចលើផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០











៥- ពិធីប្រកាសដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥












៦- កិច្ចប្រជុំឆ្លុះបញ្ចាំងស្តីពីការអនុវត្តគម្រោងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ (Swipe Safe Project)
នៅសណ្ឋាគារសាន់វេ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥













៧- ការសាកល្បងដាក់ឱ្យប្រើប្រាស់កម្មវិធីស្វ័យសិក្សាតាមឧបករណ៍បច្ចេកវិទ្យាស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ដល់កុមារ និងយុវជន នៃសហគមន៍គោលដៅក្នុងខេត្តក្រចេះ បាត់ដំបង និងព្រៃវែង













៨- ការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ អង្គការដៃគូ និងកម្លាំងសេវាសង្គម
នៅរាជធានីភ្នំពេញ ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តព្រៃវែង និងខេត្តពោធិ៍សាត់













៩- កិច្ចសហការជាមួយវិទ្យាស្ថានជាតិសង្គមកិច្ចចងក្រងមេរៀនស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ
ដើម្បីបញ្ចូលក្នុងកម្មវិធីសិក្សាសម្រាប់និស្សិតរបស់វិទ្យាស្ថាន









# កាកបាទក្រហមកម្ពុជា



ការលើកកម្ពស់សុខភាពមាតា ទារក និងកុមារ








កាកបាទក្រហមកម្ពុជាផ្តល់អំណោយមនុស្សធម៌លើកទី១៣ និងរៀបចំអាហារសម្រន់ជូនយុវនារី-កុមារី នៅអង្គការអាហ្វេស៊ីបកម្ពុជា













១- ការចុះសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹកក្នុងជំរំសុវត្ថិភាពវត្តច័ន្ទសុី និងបន្តចុះពិនិត្យទិដ្ឋភាពនៃការអនុវត្តកម្មវិធីអន្តរាគមន៍សម្រាប់គ្រួសារភៀសសឹកដែលរងផលប៉ះពាល់ក្នុងតួមិសាស្ត្រជម្លោះព្រំដែន។












២- អបអរសាទរទិវាជនមានពិការភាពអូទីស្សឹម និងដោនស៊ីនដ្រូមកម្ពុជាលើកទី១៣ និងការរៀបចំអាហារសាមគ្គីផ្តល់នាពកក់ក្តៅ និងចែករំលែកក្តីស្រឡាញ់ជាមួយកុមារកំព្រា នៅមណ្ឌលកុមារកំព្រាភ្នំពេញថ្មី











៣- ការសំណេះសំណាល សួរសុខទុក្ខ និងជូនអំណោយប្រជាពលរដ្ឋជាជនមានពិការភាព និងរៀបចំអាហារជូនកុមារកំព្រា មកពី មណ្ឌលកុមារកំព្រាខេត្តព្រៃវែង មណ្ឌលកុមារកំព្រាអង្គការ Hope និងភូមិកុមារ SOS









# គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា



១. ឯកឧត្តមទេសរដ្ឋមន្ត្រី **កែវ រ៉េមី** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នាំយកថវិកា៤០លានរៀល ជូនមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីរួមចំណែកជួយសង្គ្រោះកុមារកម្ពុជា នៅថ្ងៃទី ១៥ មករា ២០២៥។



២. ឯកឧត្តមទេសរដ្ឋមន្ត្រី **កែវ រ៉េមី** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកថវិកា ព្រមទាំងគ្រឿងឧបភោគបរិភោគជាលើកទី១៦ ប្រគល់ជូនអង្គការកុមារកំព្រា នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥





៣. ឯកឧត្តមទេសរដ្ឋមន្ត្រី **កែវ រ៉េមី** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អញ្ជើញចុះសួរសុខទុក្ខ ជនជាប់ឃុំ នៅមន្ទីរអប់រំកែប្រែទី២ (ម២) នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២៥



៨. ឯកឧត្តមទេសរដ្ឋមន្ត្រី **កែវ រ៉េមី** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានចុះសួរសុខទុក្ខ និងនាំយកថវិកា និងគ្រឿងឧបភោគបរិភោគ ជូនដល់សមាគមស្ពានញញឹមថ្មីនៃក្ដីសង្ឃឹមរបស់កុមារ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤



៩. ក្រុមការងារគណៈកម្មការធិការសិទ្ធិមនុស្សកម្ពុជានាំយកអំណោយប្រចាំខែដ៏ថ្លៃថ្លារបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **កែវ រ៉េមី** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជូនសមាគមស្ពានញញឹមថ្មីនៃក្ដីសង្ឃឹមរបស់កុមារ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤



៦. ក្រុមការងារគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដឹកនាំដោយ ឯកឧត្តម **ជូ ហោខ** សមាជិក និងជាអគ្គនាយករង ចុះធ្វើការសម្រប សម្រួលនាំយកកុមារីពីររូបពីអង្គការការអតិវឌ្ឍកុមារកម្ពុជា មកជួបនិងស្នាក់នៅជាមួយម្ដាយ នៅមណ្ឌលអប់រំកែប្រែទី២ (ម២) ចំនួន៤យប់ ៥ថ្ងៃ ដើម្បីឲ្យកូនទទួលបាននូវភាពកក់ក្ដៅពីម្ដាយដូចកុមារដទៃទៀត ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ។



៧. លោកជំទាវ **ឆាំ ម៉ារី** អនុប្រធាន គ.ស.ម.ក. និងជាអគ្គនាយិកានៃអគ្គនាយកដ្ឋានស៊ើបអង្កេតនិងអប់រំសិទ្ធិមនុស្ស ដឹកនាំក្រុម ការងារគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចុះអប់រំផ្សព្វផ្សាយស្ដីពី "សិទ្ធិមនុស្សនិងច្បាប់" ដល់សិស្សានុសិស្ស នៅវិទ្យាល័យទឹកល្អក់ រាជធានីភ្នំពេញ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥។



៨. ឯកឧត្តម **ញ៉ៅម ចន្ទធឿន** សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដឹកនាំក្រុមការងារចុះអង្កេតស្រាវជ្រាវករណីបណ្តឹងករណីទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋ នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ នាថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥។



# ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



១- ការផ្តល់ផ្ទះ និងដីលំនៅឋានសម្បទានដីសង្គមកិច្ច ដើម្បីគ្រួសារមានភាពកក់ក្តៅ និងអភិវឌ្ឍន៍
នៅភូមិត្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់





២- ការកែលម្អបរិវេណសាលារៀនឆ្លើយតបនឹងបរិយាកាសបៃតង និងផាសុកភាព ដើម្បីអនាគតកុមារឆ្លាតវៃក្នុងសង្គម
នៅសាលារៀនស្នាច់ដែង ខេត្តព្រះសីហនុ





៣-លោកជំទាវ **ឱត នីតា សាយសំអាល់** បានអញ្ជើញចុះបណ្តុះស្មារតីបំណិនជីវិតដល់កុមារ នៅតាមសាលារៀន ស្ថិតនៅភូមិសុខសែនជ័យ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង អមដំណើរដោយឯកឧត្តម លោកជំទាវក្រុមការងារ





៤.លោកជំទាវ **ឱត នីតា សាយសំអាល់** អញ្ជើញដឹកនាំមន្ត្រីជំនាញរបស់ក្រសួង ចុះស្វែងយល់ពីស្ថានភាពសាលា និងសំណេះសំណាលជាមួយកុមារក្នុងថ្ងៃ១មិថុនា នៅសាលារៀនមតេយ្យសិក្សាវត្តកោះ





៥.លោកជំទាវ **ឱត នីតា សាយសំអាល់** អញ្ជើញដឹកនាំមន្ត្រីរបស់ក្រសួងចុះសំណេះសំណាលជាមួយកុមារ និងសម្ពោធដាក់ឱ្យប្រើប្រាស់ទីកម្សាន្តរបស់កុមារ ដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សាយ សំអាល់** និងលោកជំទាវ បានយកចិត្តទុកដាក់ឱ្យមន្ត្រីក្រោមឱវាទធ្វើការកែលម្អ និងបំពាក់នូវឧបករណ៍លេងកម្សាន្តក្នុងថ្ងៃទិវាមាតាពិភពលោក នៅសាលាមតេយ្យសិក្សាកំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ





៦. លោកជំទាវ **សេខ សុមេត្តា** រដ្ឋលេខាធិការ អញ្ជើញចូលរួមពិនិត្យស្ថានភាពសាលាមតេយ្យធនធានក្រុង នៅសង្កាត់លេខ២ ក្រុងព្រះសីហនុ ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដែលបច្ចុប្បន្នបាន ក្លាយជាសាលាមតេយ្យគំរូទូទាំងប្រទេស ក្រោយពីបានកែលម្អ និងបំពាក់បរិក្ខាសំខាន់ៗដែលជាតម្រូវការរបស់កុមារ និងការបង្រៀន




៧. លោកជំទាវ **ទេព បូរ៉ាមីន** រដ្ឋលេខាធិការ អញ្ជើញដឹកនាំក្រុមការងារចុះពិនិត្យទីតាំងដីសម្បទានសង្គមកិច្ចនៅទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ សម្រាប់គម្រោងផ្តល់ជូនគ្រួសារ ដែលកំពុងរស់នៅក្នុងតំបន់សំណង់មិនរៀបរយនៅទំនប់រលក




៨. លោកជំទាវ **សេរី សូរិយា** អនុរដ្ឋលេខាធិការ បានដឹកនាំមន្ត្រីជំនាញចុះពិនិត្យ សិក្សាវាយតម្លៃស្ថានភាពជាក់ស្តែង និងរក ដំណោះស្រាយករណីសំណង់អគារចាស់ទ្រុឌទ្រោម មានសភាពគ្រោះថ្នាក់ ដែលស្ថិតនៅទីតាំងភូមិសាស្ត្រក្នុងរាជធានីភ្នំពេញ ដើម្បី បង្ការ និងបញ្ចៀសគ្រោះថ្នាក់ប្រាក់រលំប៉ះពាល់អាយុជីវិតអ្នករស់នៅក្នុងអគារសំណង់ និងសាធារណជន មានទាំងកុមារនិងមនុស្សចាស់











៩. អនុវត្តតាមការចង្អុលបង្ហាញរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការលើកកម្ពស់នូវស្មារតីរបស់កុមារ និងយុវវ័យបន្តវេនឱ្យមានទម្លាប់រស់នៅស្អាត មានអនាម័យ និងយល់ដឹងពីគុណតម្លៃនៃបរិស្ថានបៃតង ដែលជាឧបករណ៍តែមួយគត់ក្នុងការឆ្លើយតបនឹងតាពធន់នៃការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់សុខភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់វ័យ




# ក្រសួងបរិស្ថាន

១. សកម្មភាពនៅថ្ងៃលបណ្តុះកូនឈើអូរសំចត ក្នុងឧទ្យានជាតិព្រះសុរាម្រិតកុសុមៈគីរីរម្យ ដោយមានការធ្វើបទបង្ហាញពីលោកប្រធានមន្ទីរបរិស្ថានអំពីរបៀបនៃការបណ្តុះកូនឈើ









២. សកម្មភាពទស្សនះកិច្ចសិក្សា ការធ្វើសមាធិ និងដាំកូនឈើនៅមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនា












៣. សកម្មភាពដាំកូនឈើរបស់អាណាព្យាបាល បុត្រា បុត្រី និងក្រុមការងារក្រសួងបរិស្ថាន រួមជាមួយសិស្សានុសិស្ស នៃបឋមសិក្សាដូង និងការធ្វើការសម្អាតអនាម័យបរិស្ថាននៅបរិវេណទីធ្លាខាងមុខសាលា







# ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១. ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចុះសួរសុខទុក្ខនិងផ្តល់ "អំណោយកាបូបនៃស្នាមញញឹម" ដល់កុមារភៀសសឹកចំនួន ៨០០០នាក់ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប។







២. ឯកឧត្តម **ជុន វ៉ាត** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាបច្ចេកទេសផ្សព្វផ្សាយ និងជំរុញការអនុវត្ត "គោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា" នៅខេត្តសៀមរាប ដោយមានអ្នកចូលរួមប្រមាណ ៩០នាក់។









៣.ប្រធានបទ"សុវត្ថិភាពលើប្រព័ន្ធអនឡាញសម្រាប់កុមារចូលរួមការពារជនងាយរងគ្រោះបំផុត" ត្រូវបានយកមកពិភាក្សាក្នុងវេទិកាសុវត្ថិភាពលើប្រព័ន្ធអនឡាញលើកទី២ ឆ្នាំ២០២៤ ក្រោមមូលបទ៖ "**កសាងទំនុកចិត្តក្នុងយុគសម័យបញ្ញាសិប្បនិម្មិត**" ដោយមានអ្នកចូលរួមផ្ទាល់ និងតាមអនឡាញប្រមាណ ៦០០នាក់ នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-កូរ៉េ។






៤. វេទិការអភិបាលកិច្ចអ៊ីនធឺណិតកម្ពុជា ២០២៤ ក្រោមមូលបទ៖ "**ការកសាងសង្គមឌីជីថលប្រកបដោយបរិយាបន្នសម្រាប់កម្ពុជា**" ដែលក្នុងនោះមានកិច្ចពិភាក្សាមួយពាក់ព័ន្ធនឹងកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ បានរៀបចំធ្វើនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។






# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## រួមគ្នាទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ដើម្បីលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់កុមារ




១. កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងាររបស់គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ





២. វគ្គបណ្តុះបណ្តាលស្តីពី "ការបង្ការនិងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថានផលិតឥដ្ឋ-ក្បឿង








៣. ពិធីបើកយុទ្ធនាការផ្សព្វផ្សាយស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារឆ្នាំ២០២៥"






៤. ការចុះយុទ្ធនាការផ្សព្វផ្សាយដល់ទីតាំងសិប្បកម្មផលិតឥដ្ឋ-ក្បឿង និងកសិ-ឧស្សាហកម្មទូទាំងប្រទេស








៥. ការចុះធ្វើអធិការកិច្ចការងារ ធ្វើលិខិតធានាអះអាងជាមួយនិយោជក និងកិច្ចសន្យារវាងអាណាព្យាបាលនិងនិយោជក ស្តីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ-ក្បឿង









៦. ដំណើរការសម្ភាស និងកំណត់អត្តសញ្ញាណកុមារងាយរងគ្រោះ៖

កុមារអាយុក្រោម១៥ឆ្នាំ បានសិក្សាវគ្គបំប៉ន អាហាររូបត្ថម្ភ សម្ភារសិក្សា និងមធ្យោបាយធ្វើដំណើរ








៧ ដំណើរការផ្តល់បំណិនជីវិត និងលើកកម្ពស់ជីវភាពគ្រួសារៈ

កុមារអាយុពី១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ និងក្រុមគ្រួសារកុមារ បានសិក្សាវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លី






៨. ដំណើរការផ្តល់បំណិនជីវិត និងលើកកម្ពស់ជីវភាពក្រុមគ្រួសាររបស់កុមារៈ

ការផ្តល់នូវពូជសត្វ ពូជបន្លែ និងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដើម្បីផ្តល់ឱកាសបង្កើតមុខរបរ








៩. ដំណើរការផ្តល់បំណិនជីវិត និងលើកកម្ពស់ជីវភាពក្រុមគ្រួសាររបស់កុមារ៖
ការផ្តល់នូវពូជសត្វ ពូជបន្លែ និងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដើម្បីផ្តល់ឱកាសបង្កើតមុខរបរ









# ក្រសួងរ៉ែ និងថាមពល

សកម្មភាពចុះជួបសំណេះសំណាល សួរសុខទុក្ខពីការសិក្សារបស់កុមារនៅតាមខ្នងផ្ទះ ស្ថិតក្នុងភូមិដើមរការ និងភូមិដំណាក់ធ្នង់ ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ និងជួបសំណេះសំណាល ព្រមទាំងចែកសម្ភារកីឡាជូនកុមារ ក្រោមប្រធានបទ **"រួមគ្នាលេងកីឡា ចៀសឆ្ងាយពីគ្រឿងញៀន"** នៅសាលាបឋមសិក្សាខ្នារទទឹង ស្ថិតនៅក្នុងឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់។









ចូលរួមសកម្មភាពចែកសម្ភារសិក្សា និងអាវស ដល់កុមារនៅសាលាមត្តេយ្យសិក្សា ភូមិប្អាក់មែក និងសាលាបឋមសិក្សាខ្នារទទឹង ស្ថិតក្នុងឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់។








ចូលរួមសកម្មភាពរើសសំរាមសម្អាតទីធ្លាសាលា និងតាមដងផ្លូវដើម្បីការពារបរិស្ថាន ស្ថិតក្នុងឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់។




បានចុះជួបសំណេះសំណាល សួរសុខទុក្ខ ការសិក្សារបស់កុមារ និងចែកអាវរងាជូនដល់កុមារ ស្ថិតក្នុងឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់។






ក្រុមហ៊ុនស៊ីណូហាយដ្រូកំចាយ ហាយដ្រូ អេឡិកទ្រិក ប្រជេក ការចែករំលែកសេចក្តីស្រលាញ់ ចំពោះសិស្សានុសិស្ស នៅចុងខែខ្វសតា ឆ្នាំ២០២៤ នៅសាលាបឋមសិក្សាព្រៃទុប ស្ថិតនៅភូមិមាត់ពាម ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត ដើម្បីជួយលើកកម្ពស់ និងគាំទ្រក្នុងការវិស័យអប់រំរបស់កុមារ នៅក្នុងតំបន់ប្រតិបត្តិការនៃគម្រោងវារីអគ្គិសនីកំចាយ។ រូបភាពសកម្មភាពមួយចំនួន ក្នុងអំឡុងចុះចែករំលែកសេចក្តីស្រលាញ់។





ក្រុមហ៊ុនហាយដ្រូផៅវ័រ ឡូវើសេសានក្រោមពីរ បានផ្តល់អាហារូបករណ៍ជូនដល់សិស្សក្រីក្រ សម្រាប់ឆ្នាំ២០២៤ ដល់សិស្ស ចំនួន ៣០នាក់ នៅសាលាបឋមសិក្សាភូមិស្រែគរ សាលាបឋមសិក្សាភូមិក្បាលរមាស និងសាលាបឋមសិក្សាភូមិស្រែស្រណុក ដើម្បី លើកទឹកចិត្តឱ្យពួកគាត់ខិតខំប្រឹងប្រែងរៀនសូត្របន្ថែមទៀត។










ក្រុមហ៊ុនស៊ីតិច អិនធីនេសិនណាល ហាយដ្រូផៅវ័រ ឌីអ៊ីឡុកមែន ខូអិលធីឌី និងថ្នាក់ដឹកនាំខេត្តចែកអំណោយដល់កុមារ ប្រជាពលរដ្ឋ និងឧបត្ថម្ភសប្បុរសធម៌ជាថវិកាដល់សាលាបឋមសិក្សាថ្មស នៅខេត្តកោះកុង ដើម្បីជួយសម្រួលដល់ការសិក្សារបស់សិស្ស និងលើកកម្ពស់គុណភាពអប់រំដល់កុមារ។









# ក្រសួងព័ត៌មាន



១. នាទីកុមារ ត្រូវបានរៀបចំឡើងជា ភាពយន្តគំនូរជីវចល ក្នុងគោលបំណងបង្កើនការចងចាំ និងបណ្តុះទម្លាប់ល្អៗដល់កុមារ











## ២. មហោស្រពតន្ត្រី និងចម្រៀងកុមារពានរង្វាន់ក្រសួងព័ត៌មាន៖ បញ្ជ្រាបការយល់ដឹងអំពីសិទ្ធិកុមារតាមរយៈសិល្បៈកម្សាន្ត






## ៣. ការផលិតមាតិកាចម្រុះ និងវេទិកាពិភាក្សា៖

បង្កើនការយល់ដឹងជាសកលក្នុងសង្គម ដើម្បីជំរុញឱ្យបញ្ហាកុមារក្លាយជាកិច្ចការអាទិភាពរបស់សង្គមទាំងមូល











## ៤. ការនាំយកសំឡេងកុមារភៀសសឹកមកកាន់មហាជន





# ក្រសួងកិច្ចការនារី



តួនាទីសារព័ត៌មានក្នុងការលើកកម្ពស់សមភាពយេនឌ័រ
និងទប់ស្កាត់អំពើហិង្សាលើស្ត្រី





បន្ទប់ប្រឹក្សាយោបល់សម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ






# ក្រសួងអប់រំ យុវជន និងកីឡា



១. កម្មវិធីផ្តល់អាហារតាមសាលារៀនក្នុងខេត្តកំពង់ឆ្នាំង
ក្រោមអធិបតីភាពលោកជំទាវបណ្ឌិត **ពេជ ច័ន្ទមុន្នី** នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦









## ២. ដំណើរទស្សនកិច្ចពិនិត្យមើលស្ថានភាពនៃការអប់រំនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ នៅជំរឹសុវត្ថិភាពវត្តពោធិ៍៥០០០ដើមខេត្តព្រះវិហារនាថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ និងដំណើរទស្សនកិច្ចទៅកាន់សាលារៀនចំនួន២ ដែលកំពុងអនុវត្តកម្មវិធី ផ្ដល់អាហារតាមសាលារៀន ក្នុងខេត្តសៀមរាប












# ក្រសួងពាណិជ្ជកម្ម




១. ពិធីសម្ពោធ "កុមារដ្ឋាននៃក្រសួងពាណិជ្ជកម្ម - Ministry of Commerce´s Day Care Center" ក្រោមអធិបតីភាព លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី









២. ការផ្សព្វផ្សាយការយល់ដឹងអំពីច្បាប់ស្តីអំពីសុវត្ថិភាពចំណីអាហារ និងការយល់ដឹងអំពីរបៀបនៃការជ្រើសរើសម្ហូបអាហារ ដែលមាន  សុវត្ថិភាព នៅតាមបណ្តាគ្រឹះស្ថានសិក្សានានាក្នុងរាជធានី ខេត្ត













www.cncc.gov.kh

**សហការរៀបចំដោយ៖**

**ឧបត្ថម្ភដោយ៖**